# គណិតវិទ្យា

អាន. គិត. យល់

# លំហាត់ល្អៗ និងចម្លើយ

ថ្មី

## ៤០០ លំហាត់-ចម្លើយ

តើមានលំហាត់ណាខ្លះ

ដែលអ្នកមិនធ្លាប់បានជួប?

បោះពុម្ពលើកទី២ ៖ ១២/១២/១២

រៀបរៀងដោយយុវនិស្សិតថ្នាក់បន្តបរិញ្ញាបត្រ : ប្រើស ដារ៉ា
គ្រូបង្រៀនឯកទេស គណិតវិទ្យា នៃវិទ្យាល័យ ហ៊ុន សែន ក្រោលគោ , ខេត្ត ស្វាយរៀង
Tel: 011 50 70 65 / 0977 65 70 50. E-mail : dara_st04@yahoo.com

# គណិតវិទ្យា

# លំហាត់ល្អៗ និងចម្លើយ

## ៤00 លំហាត់-ចម្លើយ

សៀវភៅលំហាត់ល្អៗ និងចម្លើយ នេះជាកម្មសិទ្ធិរបស់ :

-ឈ្មោះ .............................................. ភេទ ............

-សព្វថ្ងៃជា .............................. នៅ.................................

-បានថតចម្លងនៅថ្ងៃទី ...... ខែ ............ ឆ្នាំ 201.... តម្លៃ ............

-អាសយដ្ឋាន ...............................................................

-លេខទូរស័ព្ទទំនាក់ទំនង ..............................................

ផ្តល់សិទ្ធិថតចម្លងសម្រាប់តែការសិក្សាប៉ុណ្ណោះ



www.facebook.com/7khmer
fb : Entertainment  And Knowledge

www.facebook.com/7khmer
fb : Entertainment  And Knowledge

# អារម្ភកថា

***សូមស្វាគមន៍ :***

សួស្តី! លោកគ្រូ-អ្នកគ្រូ និងប្អូនៗសិស្សានុសិស្ស ជាទីស្រឡាញ់ និងជាទីរាប់អាន។ សៀវភៅដែលអ្នកកំពុងតែកាន់ អាននេះ គឺជាការប្រមូលផ្តុំ និងការបង្កើតថ្មី នូវលំហាត់ល្អៗជាច្រើនរហូតដល់ ៤០០ លំហាត់។ លំហាត់នីមួយៗសុទ្ធតែមាន លក្ខណៈពិសេសផ្សេងៗពីគ្នាទៅតាមសមត្ថភាពពីថ្នាក់ទី ៧ ដល់ថ្នាក់ទី ១២។ វាមានបង្ហាញពីកម្រិតសមត្ថភាព និង ដំណោះស្រាយប្រកបទៅដោយ ល្បិច វិធីសាស្ត្រ បច្ចេកទេស ...។

***គោលបំណងដើម្បី :***

-ប្រមូលផ្តុំលំហាត់ល្អៗដាក់ក្នុងសៀវភៅតែមួយទុកជាឯកសារ និងជាការកម្សាន្តលេង ពេលអផ្សុក ។

-សិស្សានុសិស្សត្រៀមប្រលងប្រជែងនានា អាហារូបករណ៍ ជាពិសេសប្រលងសិស្សពូកែ។

-សម្រួលដល់លោកគ្រូ-អ្នកគ្រូ ដែលមានការស្រាវជ្រាវ ចង់ពង្រឹង និងពង្រីកសមត្ថភាពផ្ទាល់ខ្លួនបន្ថែមទៀត។

-បង្ហាញឡើងវិញនូវលំហាត់ល្អៗ ក្នុងសម័យអតីតកាល ដែលស្ទើរតែបាត់បង់។

-អភិវឌ្ឍន៍ចំណេះដឹង និងសមត្ថភាពផ្ទាល់ខ្លួន ដើម្បីក្លាយជាបុគ្គលមានសមត្ថភាព។

***សំណូមពរ :***

ជាសំណូមពររបស់ខ្ញុំ ដែលជាអ្នករៀបរៀង សូមអ្នកអាន ឬអ្នកស្រាវជ្រាវ ដោះស្រាយលំហាត់ណា ដែលអ្នកចង់ដោះស្រាយ មិនចាំបាច់ធ្វើតាមលំដាប់លេខរៀងទេ។ បើពុំដឹងពីកម្រិតសមត្ថភាពទេ សូមមើលការបង្ហាញពីកម្រិតសមត្ថភាព នៅបន្ទាប់ពីលំហាត់ទាំងអស់។ ជាពិសេសសូមធ្វើលំហាត់ទាំងនេះនៅពេលដែលអ្នកមានអារម្មណ៍ល្អ ព្រោះវាត្រូវការការគិតច្រើន។ សូមបញ្ចេញឱ្យអស់ពីលទ្ធភាព និងសមត្ថភាពខ្លួនឯងជាមុនសិន មុននឹងផ្ទៀងផ្ទាត់មើលចម្លើយ ដែលមាននៅក្នុងសៀវភៅនេះ។ បើមានចម្ងល់មិនយល់ ឬមានបញ្ហា សូមទាក់ទងទៅកាន់មិត្តភក្តិរបស់អ្នកដែលមានសមត្ថភាព ឬអ្នករៀបរៀង នៅពេលវេលាសមរម្យ។

***ការរិះគន់ :***

ទោះបីជាខ្ញុំខិតខំ ប្រឹងប្រែង ប្រិតប្រៀង យ៉ាងណាក៏ដោយ ក៏កំហុសត្រូវតែកើតមានជាក់ជាមិនខានឡើយ។ នេះគឺដោយសារចំណេះដឹងនៅមានកម្រិត ទាំងផ្នែកបច្ចេកទេសគរុកោសល្យ អក្ខរាវិរុទ្ធ រចនាបថ និងបច្ចេកទេសកុំព្យូទ័រ ឬរឿងរាវបច្ចេកទេសផ្សេងៗទៀត។ ទោះបីជាមានកំហុសឆ្គងយ៉ាងដូចម្តេចក៏ដោយ សូមមិត្តអ្នកអានមេត្តាអធ្យាស្រ័យ អភ័យទោសដល់ខ្ញុំផង ហើយខ្ញុំសូមរងចាំ ការរិះគន់យ៉ាងរីករាយ ពីសំណាក់មិត្តអ្នកអានគ្រប់មជ្ឈដ្ឋានទាំងអស់ ដើម្បីឱ្យការបោះពុម្ពសៀវភៅនេះលើកក្រោយ កាន់តែប្រសើរជាងមុន។

***ជូនពរ :***

សូមមិត្តអ្នកអាន មានសុខភាពល្អបរិបូណ៌ រៀនសូត្របានពូកែ និងស្រាវជ្រាវទទួលបានជោគជ័យ ។

ស្វាយរៀង. ថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១២

យុវនិស្សិត ឯកទេស គណិតវិទ្យា : *ប្រើស ដារ៉ា*

*សូមអរគុណ !*



www.facebook.com/7khmer
fb : Entertainment And Knowledge

www.facebook.com/7khmer
fb : Entertainment  And Knowledge

# <u>បទពិសោធន៍ នៃការសិក្សា គណិតវិទ្យា</u>

ជាការពិតការសិក្សាគណិតវិទ្យា វាពុំមែនជាការងាយស្រួលនោះទេ ជាពិសេសគឺការសិក្សាដើម្បីឱ្យក្លាយខ្លួនជាសិស្សពូកែតែម្តង។ វាទាមទាឱ្យយើងមានការតស៊ូ ព្យាយាម អំណត់ អត់ធ្មត់ ជាច្រើនទាំងកាយ និងចិត្ត តែពុំមែនមានន័យថា យើងមិនអាចធ្វើបាននោះទេ។ ពេលសិក្សាយើងត្រូវចែកឱ្យដាច់ថា "***តើយើងរៀនយកចេះ ឬរៀនយកជាប់ ?***" ។ កាលណាយើងចង់ក្លាយខ្លួនទៅជាសិស្សពូកែគណិតវិទ្យា យើងត្រូវរៀនយកចេះ គឺមានន័យថាយើងត្រូវយល់ឱ្យច្បាស់ អំពីមេរៀន រូបមន្ត ឬលំហាត់ដែលយើងបានរៀនរួច មិនមែនរៀនបន្លំបង្ហូរខ្លួនឯងនោះទេ។ ការរៀនបន្លំខ្លួនឯង នឹងធ្វើឱ្យយើង ក្លាយទៅជាមនុស្សស្ទាក់ស្ទើរ រហូតដល់មានពេលខ្លះ មិនហ៊ានថាខ្លួនឯងខុស ឬត្រូវ ក៏មាន។ សកម្មភាពបែបនេះ នឹងធ្វើឱ្យយើងទទួលបានបរាជ័យក្នុងការសិក្សា នាំឱ្យយើងមានអនាគតមិនល្អ។

ក្នុងនាមជាអ្នកធ្លាប់ឆ្លងកាត់ការសិក្សា ហើយក៏ធ្លាប់ទទួលបានទាំងបរាជ័យ និងជោគជ័យ ក្នុងការសិក្សាផ្នែក គណិតវិទ្យា ខ្ញុំសូមបង្ហាញអំពីបទពិសោធន៍បរាជ័យរបស់ខ្ញុំដូចតទៅ :

-មិនយល់ពីរបៀបនៃការប្រឡង ឬរបៀបនៃការសរសេរវិញ្ញាសា។

-មិនបានពង្រឹងសមត្ថភាពខ្លួនឯង លើលំហាត់នីមួយៗឱ្យបានច្បាស់លាស់ ( មើលងាយលំហាត់ ) ។

-ចាំតែទទួលការបង្ហាត់បង្រៀនពីគ្រូ មិនបានស្វ័យសិក្សា មិនបានធ្វើការស្រាវជ្រាវលើលំហាត់ផ្សេងៗ។

-មានមោទនភាពជ្រុលលើខ្លួនឯង ...។

សកម្មភាពទាំងអស់ខាងលើនេះហើយ ដែលធ្វើឱ្យខ្ញុំទទួលបានបរាជ័យក្នុងការសិក្សាគណិតវិទ្យា ។

សូមកុំបោះបង់ចោលការតាំងចិត្ត នៅពេលដែលយើងចាប់ផ្តើមដំបូង ហើយយើងជួបលំហាត់សិស្សពូកែសុទ្ធតែលំបាក នោះវាជារឿងធម្មតាទេ ព្រោះយើងមិនទាន់មានបទពិសោធន៍គ្រប់គ្រាន់ដើម្បីដោះស្រាយវា។ យើងត្រូវគិតក្នុងចិត្តថា "***លំហាត់ដែលធ្វើចេញ គឺជាលំហាត់ដែលធ្លាប់ជួប***" ។ ឃ្លានេះគឺចង់មានន័យថា សិស្សពូកែគណិតវិទ្យាស្ទើរតែទាំងអស់សុទ្ធតែជាអ្នកមានបទពិសោធន៍ធ្លាប់ជួបលំហាត់ច្រើន ដូចនេះធ្វើឱ្យគេអាចដឹងអំពីវិធី ល្បិច ឬបច្ចេកទេសដើម្បីដោះស្រាយលំហាត់ទាំងនោះ ។ កាលណាយើងដោះស្រាយលំហាត់សិស្សពូកែបានកាន់តែច្រើន នោះធ្វើឱ្យយើងដឹងពីវិធីដោះស្រាយកាន់តែច្រើនដែរ។ ដើម្បីក្លាយខ្លួនទៅជាសិស្សពូកែគណិតវិទ្យា អ្នកមិនត្រូវមានគំនិតដូចខាងក្រោម :

-គេរៀនចេះមកពីគេជាកូនអ្នកមាន មានលុយរៀនគួ ឬជួលគ្រូបង្រៀន ។

-លំហាត់គេជួបល្អៗ ទាញចេញពីអ៊ីនធឺណេត រីឯយើងគ្មានលទ្ធភាពដូចគេ ។

-គេជាមនុស្សមានដុងតាំងពីកំណើត សុខភាពគេល្អ ...។

សូមកុំមានគំនិតបែបនេះ វាគ្មានប្រយោជន៍អ្វីសម្រាប់យើងទេ ក្រៅពីធ្វើឱ្យយើងតូចចិត្តលើខ្លួនឯង។

ចាប់ពីពេលនេះតទៅយើងត្រូវខំរៀនសូត្របន្ថែមទៀត ត្រូវស្រាវជ្រាវ ដោះស្រាយលំហាត់ឱ្យបានច្រើន ចៀសវាងការខ្ជិល។ ***បិសាចខ្ជិលខ្លាចការធ្វើការងារជាទំលាប់ណាស់*** ដូចនេះសូមកុំឱ្យបិសាចខ្ជិលចូលខ្លួនរបស់យើង គឺយើងត្រូវមានផែនការរៀនសូត្រឱ្យបានច្បាស់លាស់ ហើយអនុវត្តការរៀនសូត្រទាំងនោះឱ្យក្លាយទៅជាទម្លាប់។

ជាចុងក្រោយសូមជូនពរដល់មិត្តអ្នកអានទាំងអស់ មានសុខភាពល្អ ដើម្បីរៀនសូត្រក្លាយទៅជាមនុស្សមានសមត្ថភាព និងទទួលបានជោគជ័យ ដើម្បីអភិវឌ្ឍប្រទេសជាតិយើងឱ្យមានភាពរីកចម្រើន។



www.facebook.com/7khmer
fb : Entertainment And Knowledge

www.facebook.com/7khmer
fb : Entertainment  And Knowledge

# សេចក្ដីថ្លែងអំណរគុណ

សូមអរគុណជូនដល់លោកកឪពុក ជា ចំរើន និងអ្នកម្ដាយ ពេជ្រ សោភ័ណ្ឌ ដែលលោកទាំងពីរបានផ្ដល់កំណើតដល់កូន ហើយបីបាច់ថែរក្សាចិញ្ចឹមកូន ជួយឱ្យកូនបានសិក្សារហូតបានក្លាយជាគ្រូបង្រៀនម្នាក់។ សូមជូនពរលោកទាំងពីរមានព្រះជន្មយឺនយូរ ប្រកបដោយសុខភាពល្អ ដើម្បីជួយផ្ដល់ភាពកក់ក្ដៅដល់កូនចៅជំនាន់ក្រោយ។ អរគុណដល់បងប្អូនប្រុសស្រីទាំង ០៤ នាក់ ដែលបានជួយផ្គត់ផ្គង់ និងជ្រោមជ្រែងការរៀនសូត្ររបស់ខ្ញុំ ទាំងថវិការ និងសម្ភារៈ ជាពិសេសគឺកុំព្យូទ័រ ធ្វើឱ្យខ្ញុំអាចពង្រឹង និងពង្រីកចំណេះដឹងផ្នែកវិទ្យាសាស្ត្របានប្រសើរជាងមុន។ ជូនពរដល់ដល់បងប្អូនទាំង ៤ មានសុខភាពល្អ និងប្រកបរបរកាក់កបកើនចំណូល។

សូមអរព្រះគុណដល់ព្រះតេជគុណ ភីម សុភណ្ឌ ជាគ្រូចៅអធិការវត្តព្រៃរំដួល ដែលព្រះអង្គបានអនុញ្ញាតិឱ្យខ្ញុំព្រះករុណា ស្នាក់អាស្រ័យនៅក្នុងវត្ត និងប្រើប្រាស់អគ្គិសនី ក្នុងការរៀបចំមេរៀន ព្រមទាំងបានជួយផ្គត់ផ្គង់ខាងភស្តុភាឬសម្ភារៈផ្សេងៗ។ សូមប្រគេនពរដល់ព្រះតេជគុណមានព្រះជន្មយឺនយូរ។

សូមអរគុណដល់អ្នកគ្រូ Niko ជាអ្នកស្ម័គ្រចិត្តជនជាតិជប៉ុន ដែលអ្នកគ្រូបានផ្ដល់កម្លាំងចិត្ត និងលើកទឹកចិត្តដល់រូបខ្ញុំក្នុងការប្រកបរបរជាគ្រូបង្រៀន និងជួយឧបត្ថមដល់រូបខ្ញុំនូវថវិកាមួយចំនួនធំ។ សូមជូនពរអ្នកគ្រូមានសុខភាពល្អជាពិសេសនេះពេលអ្នកគ្រូធ្វើដំណើរមាតុភូមិនិវត្តន៏ទៅកាន់ប្រទេសជប៉ុនវិញ សូមមានសុវត្ថិភាពខ្ពស់បំផុត។

សូមអរគុណ ដល់មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ ក៏ដូចជាអនុវិទ្យាល័យអនុវត្ត ដែលបានផ្ដល់ជា ទីកន្លែង និងអគ្គិសនី ដើម្បីរៀបចំមេរៀន។ សូមអរគុណដល់អ្នកគ្រូ វណ្ណី ផល្លា ជាគ្រូឧទេសគណិតវិទ្យា , អ្នកគ្រូ ជា សុគន្ធារី ជាគ្រូគំរូគណិតវិទ្យា ។ អរគុណដល់ គរុសិស្សថ្នាក់ឯកទេស គណិតវិទ្យា-រូបវិទ្យា រួមជំនាន់ទី២១ មាន :

| | | |
|---|---|---|
| ១. លោក អាន សុខគន្ធា | ២. កញ្ញា ផល ស្រីធា | ៣. កញ្ញា ឆាយ សុគន្ធាមុំ |
| ៤. កញ្ញា ផាត់ សុវណ្ណារី | ៥. កញ្ញា ស៊ិន សុគន្ធា | ៦. លោក សុខា កុសល្យ |
| ៧. លោក ឯម សុខសុវណ្ណ | ៨. កញ្ញា គង់ រ័ត្នធី | ៩. លោក កុន អិត |
| ១០ លោក យន់ ម៉ារ៉ូ | ១១ លោក អុល អេន | ១២ លោក គីម ផាន់ណា |
| ១៣ កញ្ញា វ៉ាន់ ចន្ថា | ១៤ កញ្ញា ស្លឹក យ៉ាត | ១៥. កញ្ញា ស៊ឹម ស៊ីណាត |
| ១៦ លោក ពូក សុខសាន្ត | ១៧. លោក តេង សារី | ១៨ លោក ជឹម សារ៉ាត់ |
| ១៩ លោក រាជ វុត្ថា | ២០. លោក វន លីណា | ២១ លោក មាស ភារម្យ |
| ២២ កញ្ញា យ៉ោក បុប្ផ | ២៣ លោក ហួន ស៊ិញ | ២៤ គរុសិស្ស ប្រើស ដារ៉ា ។ |



www.facebook.com/7khmer
fb : Entertainment And Knowledge

www.facebook.com/7khmer
fb : Entertainment  And Knowledge

# គណិតវិទ្យា អាន. គិត. យល់

## សូមស្វាគមន៍ការមកដល់

## លំហាត់ល្អៗ





យោបល់ខ្ញុំ

សូមធ្វើលំហាត់ណាដែលអ្នកចង់ធ្វើ!

សូមធ្វើលំហាត់ទាំងនេះនៅពេលអ្នកមានអារម្មណ៍ល្អ!

បើធ្វើមិនចេញពេលនេះ សូមទុកធ្វើពេលក្រោយ!

សូមប្រឹងប្រែង ដើម្បីអនាគតដ៏ល្អរបស់អ្នក!



www.facebook.com/7khmer
fb : Entertainment  And Knowledge

www.facebook.com/7khmer
fb : Entertainment  And Knowledge

## តារាងបង្ហាញពីកម្រិតសមត្ថភាពដោះស្រាយលំហាត់ ៖

| លេខរៀងលំហាត់ | សមត្ថភាពថ្នាក់ទី | លេខរៀងលំហាត់ | សមត្ថភាពថ្នាក់ទី | លេខរៀងលំហាត់ | សមត្ថភាពថ្នាក់ទី | លេខរៀងលំហាត់ | សមត្ថភាពថ្នាក់ទី | លេខរៀងលំហាត់ | សមត្ថភាពថ្នាក់ទី |
|---|---|---|---|---|---|---|---|---|---|
| ១ | ៩ | ៣៦ | ១១ | ៧១ | ១២ | ១០៦ | ៩ | ១៤១ | ៩ |
| ២ | ៩ | ៣៧ | ១១ | ៧២ | ៩ | ១០៧ | ១២ | ១៤២ | ៩ |
| ៣ | ៩ | ៣៨ | ១០ | ៧៣ | ១២ | ១០៨ | ១២ | ១៤៣ | ១០ |
| ៤ | ៩ | ៣៩ | ១១ | ៧៤ | ៩ | ១០៩ | ១០ | ១៤៤ | ១០ |
| ៥ | ៩ | ៤០ | ៩ | ៧៥ | ៩ | ១១០ | ១០ | ១៤៥ | ១០ |
| ៦ | ៩ | ៤១ | ១០ | ៧៦ | ៩ | ១១១ | ៨ | ១៤៦ | ៩ |
| ៧ | ១០ | ៤២ | ១០ | ៧៧ | ៩ | ១១២ | ៩ | ១៤៧ | ៩ |
| ៨ | ១០ | ៤៣ | ១១ | ៧៨ | ៩ | ១១៣ | ៩ | ១៤៨ | ៩ |
| ៩ | ១១ | ៤៤ | ៩ | ៧៩ | ៩ | ១១៤ | ៩ | ១៤៩ | ៩ |
| ១០ | ៩ | ៤៥ | ៩ | ៨០ | ៩ | ១១៥ | ៩ | ១៥០ | ៩ |
| ១១ | ៩ | ៤៦ | ៩ | ៨១ | ១០ | ១១៦ | ៩ | ១៥១ | ៩ |
| ១២ | ៩ | ៤៧ | ៩ | ៨២ | ៩ | ១១៧ | ៩ | ១៥២ | ៩ |
| ១៣ | ៩ | ៤៨ | ១០ | ៨៣ | ៩ | ១១៨ | ៩ | ១៥៣ | ៩ |
| ១៤ | ៩ | ៤៩ | ១០ | ៨៤ | ៩ | ១១៩ | ១២ | ១៥៤ | ៩ |
| ១៥ | ៩ | ៥០ | ១២ | ៨៥ | ៩ | ១២០ | ៩ | ១៥៥ | ៩ |
| ១៦ | ៩ | ៥១ | ៩ | ៨៦ | ១២ | ១២១ | ៩ | ១៥៦ | ៩ |
| ១៧ | ៩ | ៥២ | ១០ | ៨៧ | ៩ | ១២២ | ៩ | ១៥៧ | ១០ |
| ១៨ | ៩ | ៥៣ | ៩ | ៨៨ | ៩ | ១២៣ | ១០ | ១៥៨ | ១០ |
| ១៩ | ១០ | ៥៤ | ១២ | ៨៩ | ៩ | ១២៤ | ៩ | ១៥៩ | ៩ |
| ២០ | ៩ | ៥៥ | ១២ | ៩០ | ៩ | ១២៥ | ៩ | ១៦០ | ៧ |
| ២១ | ៩ | ៥៦ | ១០ | ៩១ | ៩ | ១២៦ | ៩ | ១៦១ | ៧ |
| ២២ | ៩ | ៥៧ | ១២ | ៩២ | ១២ | ១២៧ | ១១ | ១៦២ | ៧ |
| ២៣ | ១០ | ៥៨ | ១២ | ៩៣ | ៩ | ១២៨ | ១២ | ១៦៣ | ៩ |
| ២៤ | ១០ | ៥៩ | ១០ | ៩៤ | ៩ | ១២៩ | ១២ | ១៦៤ | ៩ |
| ២៥ | ១២ | ៦០ | ១០ | ៩៥ | ៩ | ១៣០ | ១០ | ១៦៥ | ៩ |
| ២៦ | ៩ | ៦១ | ៩ | ៩៦ | ៩ | ១៣១ | ៩ | ១៦៦ | ១០ |
| ២៧ | ៩ | ៦២ | ៩ | ៩៧ | ៩ | ១៣២ | ៩ | ១៦៧ | ៩ |
| ២៨ | ៩ | ៦៣ | ៩ | ៩៨ | ៩ | ១៣៣ | ៩ | ១៦៨ | ៩ |
| ២៩ | ១០ | ៦៤ | ១២ | ៩៩ | ៩ | ១៣៤ | ៩ | ១៦៩ | ៩ |
| ៣០ | ៩ | ៦៥ | ១២ | ១០០ | ៨ | ១៣៥ | ១០ | ១៧០ | ៩ |
| ៣១ | ៩ | ៦៦ | ៩ | ១០១ | ៩ | ១៣៦ | ៩ | ១៧១ | ៩ |
| ៣២ | ៩ | ៦៧ | ៩ | ១០២ | ៩ | ១៣៧ | ៩ | ១៧២ | ៩ |
| ៣៣ | ៩ | ៦៨ | ៩ | ១០៣ | ៩ | ១៣៨ | ១០ | ១៧៣ | ៩ |
| ៣៤ | ១១ | ៦៩ | ១០ | ១០៤ | ៩ | ១៣៩ | ៩ | ១៧៤ | ៩ |
| ៣៥ | ១១ | ៧០ | ១២ | ១០៥ | ៩ | ១៤០ | ៩ | ១៧៥ | ៩ |



www.facebook.com/7khmer
fb : Entertainment And Knowledge

| លេខរៀង លំហាត់ | សមត្ថភាព ថ្នាក់ទី | លេខរៀង លំហាត់ | សមត្ថភាព ថ្នាក់ទី | លេខរៀង លំហាត់ | សមត្ថភាព ថ្នាក់ទី | លេខរៀង លំហាត់ | សមត្ថភាព ថ្នាក់ទី | លេខរៀង លំហាត់ | សមត្ថភាព ថ្នាក់ទី |
|---|---|---|---|---|---|---|---|---|---|
| ១៧៦ | ៩ | ២១១ | ៩ | ២៤៦ | ៧ | ២៨១ | ៩ | ៣១៦ | ៩ |
| ១៧៧ | ៩ | ២១២ | ៩ | ២៤៧ | ៩ | ២៨២ | ៩ | ៣១៧ | ៩ |
| ១៧៨ | ៩ | ២១៣ | ៩ | ២៤៨ | ៧ | ២៨៣ | ៩ | ៣១៨ | ៩ |
| ១៧៩ | ៩ | ២១៤ | ៩ | ២៤៩ | ៧ | ២៨៤ | ៩ | ៣១៩ | ៩ |
| ១៨០ | ៩ | ២១៥ | ៩ | ២៥០ | ១០ | ២៨៥ | ៩ | ៣២០ | ៩ |
| ១៨១ | ៩ | ២១៦ | ៩ | ២៥១ | ១០ | ២៨៦ | ៩ | ៣២១ | ១០ |
| ១៨២ | ១០ | ២១៧ | ៩ | ២៥២ | ៩ | ២៨៧ | ៩ | ៣២២ | ៩ |
| ១៨៣ | ១០ | ២១៨ | ៩ | ២៥៣ | ១២ | ២៨៨ | ៩ | ៣២៣ | ៩ |
| ១៨៤ | ៩ | ២១៩ | ៩ | ២៥៤ | ១២ | ២៨៩ | ៩ | ៣២៤ | ៩ |
| ១៨៥ | ៩ | ២២០ | ៩ | ២៥៥ | ៩ | ២៩០ | ៩ | ៣២៥ | ៩ |
| ១៨៦ | ៩ | ២២១ | ៧ | ២៥៦ | ៩ | ២៩១ | ១០ | ៣២៦ | ៩ |
| ១៨៧ | ៩ | ២២២ | ៩ | ២៥៧ | ៩ | ២៩២ | ៩ | ៣២៧ | ៩ |
| ១៨៨ | ១០ | ២២៣ | ៩ | ២៥៨ | ១២ | ២៩៣ | ៩ | ៣២៨ | ៩ |
| ១៨៩ | ១០ | ២២៤ | ៩ | ២៥៩ | ១០ | ២៩៤ | ៩ | ៣២៩ | ៩ |
| ១៩០ | ១០ | ២២៥ | ៩ | ២៦០ | ១០ | ២៩៥ | ៨ | ៣៣០ | ៩ |
| ១៩១ | ៩ | ២២៦ | ៩ | ២៦១ | ៩ | ២៩៦ | ៩ | ៣៣១ | ១០ |
| ១៩២ | ៩ | ២២៧ | ៩ | ២៦២ | ៩ | ២៩៧ | ៩ | ៣៣២ | ៩ |
| ១៩៣ | ៩ | ២២៨ | ១១ | ២៦៣ | ៩ | ២៩៨ | ៩ | ៣៣៣ | ១២ |
| ១៩៤ | ៩ | ២២៩ | ១០ | ២៦៤ | ៩ | ២៩៩ | ៩ | ៣៣៤ | ៩ |
| ១៩៥ | ៩ | ២៣០ | ៧ | ២៦៥ | ៩ | ៣០០ | ៩ | ៣៣៥ | ៩ |
| ១៩៦ | ៩ | ២៣១ | ១០ | ២៦៦ | ៩ | ៣០១ | ៩ | ៣៣៦ | ៩ |
| ១៩៧ | ៩ | ២៣២ | ៩ | ២៦៧ | ៩ | ៣០២ | ១០ | ៣៣៧ | ៩ |
| ១៩៨ | ១១ | ២៣៣ | ១១ | ២៦៨ | ៧ | ៣០៣ | ៩ | ៣៣៨ | ៩ |
| ១៩៩ | ១១ | ២៣៤ | ១០ | ២៦៩ | ៩ | ៣០៤ | ៩ | ៣៣៩ | ៩ |
| ២០០ | ៩ | ២៣៥ | ៩ | ២៧០ | ៩ | ៣០៥ | ៩ | ៣៤០ | ៩ |
| ២០១ | ៩ | ២៣៦ | ៩ | ២៧១ | ១១ | ៣០៦ | ៩ | ៣៤១ | ៩ |
| ២០២ | ៩ | ២៣៧ | ៩ | ២៧២ | ៩ | ៣០៧ | ៩ | ៣៤២ | ៩ |
| ២០៣ | ៩ | ២៣៨ | ៩ | ២៧៣ | ៩ | ៣០៨ | ៩ | ៣៤៣ | ៩ |
| ២០៤ | ៩ | ២៣៩ | ៩ | ២៧៤ | ១០ | ៣០៩ | ៩ | ៣៤៤ | ៩ |
| ២០៥ | ៩ | ២៤០ | ៩ | ២៧៥ | ១០ | ៣១០ | ៩ | ៣៤៥ | ៩ |
| ២០៦ | ៩ | ២៤១ | ៩ | ២៧៦ | ១០ | ៣១១ | ៩ | ៣៤៦ | ៩ |
| ២០៧ | ៩ | ២៤២ | ៩ | ២៧៧ | ៩ | ៣១២ | ៩ | ៣៤៧ | ៩ |
| ២០៨ | ១០ | ២៤៣ | ៩ | ២៧៨ | ១០ | ៣១៣ | ៩ | ៣៤៨ | ៩ |
| ២០៩ | ៩ | ២៤៤ | ៩ | ២៧៩ | ៩ | ៣១៤ | ៩ | ៣៤៩ | ៩ |
| ២១០ | ១០ | ២៤៥ | ៩ | ២៨០ | ១០ | ៣១៥ | ៩ | ៣៥០ | ៩ |

លេខបន្តបន្ទាប់គឺកម្រិតថ្នាក់ទី ៩ ទាំងអស់



www.facebook.com/7khmer
fb : Entertainment And Knowledge

## លំហាត់ល្អៗ

**១.** រកគ្រប់គូនៃចំនួនគត់វិជ្ជមាននៃ $a$ , $b$ ដែលផ្ទៀងផ្ទាត់ ទំនាក់ទំនង : $a^2+b^2=a+b+8$ ។

**២.** ស្រាយបញ្ជាក់ថា E ជាការេប្រាកដ ដែល $E=(x+1000)(x+2000)(x+3000)(x+4000)+1000^4$ ។

**៣.** រកលេខនៅខ្ទង់រាយនៃចំនួន : $A=3^{2011}\cdot 7^{2012}+3^{2013}\cdot 7^{2014}$ ។

**៤.** គណនាកន្សោម : $P=\dfrac{\sqrt{3-2\sqrt{2}}}{\sqrt{17-12\sqrt{2}}}-\dfrac{\sqrt{3+2\sqrt{2}}}{\sqrt{17+12\sqrt{2}}}$ ។

**៥.** គណនាតម្លៃ $x$ ដើម្បីឱ្យ $F$ មានតម្លៃអប្បបរមា (តូចបំផុត) ដែល : $F=(x-1)(x+2)(x+3)(x+6)$ ។

**៦.** គណនា $x^2+y^2$ ដោយដឹងថា $x^3+y^3=8100$ និង $x+y=30$ ។

**៧.** ស្រាយបំភ្លឺថា : $\dfrac{1}{1\cdot 2}+\dfrac{1}{2\cdot 3}+\dfrac{1}{3\cdot 4}+...+\dfrac{1}{n\cdot(n+1)}<1$ ដែល $n$ ជាចំនួនគត់វិជ្ជមាន ហើយធំជាង 1 ។

**៨.** គេឱ្យ $n$ ជាចំនួនគត់វិជ្ជមាន ដែល $n$ ចែកនឹង 7 ឱ្យសំណល់ 5 ហើយ $n$ ចែកនឹង 8 ឱ្យសំណល់ 3 ។

ក. តើ $n$ ចែកនឹង 56 ឱ្យសំណល់ប៉ុន្មាន ? ខ. រកចំនួន $n$ នោះដោយដឹងថា $5616<n<5626$ ។

**៩.** គេឱ្យស្វ៊ីតចំនួនពិត $a_n=\sqrt{1+\left(1+\dfrac{1}{n}\right)^2}+\sqrt{1+\left(1-\dfrac{1}{n}\right)^2}$ ដែល $n\geq 1$

បង្ហាញថា $A=\dfrac{1}{a_1}+\dfrac{1}{a_2}+\dfrac{1}{a_3}+...+\dfrac{1}{a_{20}}$ ជាចំនួនគត់ ។

**១០.** គណនាតម្លៃលេខនៃកន្សោមលេខ $A=\sqrt[3]{182+\sqrt{33125}}+\sqrt[3]{182-\sqrt{33125}}$ ។

**១១.** គេឱ្យពីរចំនួនគត់វិជ្ជមាន $x$ , $y$ ដែលមាន $2xy-y=4x^2-2x-1$ ។ គណនា $A=\sqrt{x^{2011}}+\sqrt{y^{2011}}$ ។

**១២.** គេឱ្យ $f(x)=x^{2011}-13x^{2010}+13x^{2009}-13x^{2008}+...-13x^2+13x-1$ ។ គណនា $f(12)$ ។

**១៣.** បរិមាត្រនៃប្រលេឡូក្រាម $ABCD$ មានរង្វាស់ស្មើនឹង $48cm$ ។ រង្វាស់កម្ពស់នៃប្រលេឡូក្រាមនេះមាន សមាមាត្រ $5:7$ ។ គណនារង្វាស់ជ្រុងនៃប្រលេឡូក្រាម $ABCD$ នោះ ។

**១៤.** រកសមីការមេដ្យាទ័រនៃអង្កត់ $[AB]$ ដោយដឹងថា $A(2\,,3)$ និង $B(4\,,4)$ ។

**១៥.** ថង់មួយមានឃ្លីពណ៌ក្រហម 2 ឃ្លីពណ៌លឿង 4 និងឃ្លីពណ៌ខៀវ 6 ។ គេចាប់យកឃ្លី 2 ដោយចៃដន្យ ។ រកប្រូបាប ចាប់បានឃ្លី 2 មិនមែនពណ៌ខៀវ ។

**១៦.** គណនាកន្សោម $A=\dfrac{(6+12+18+...+96)^2}{(12+24+36+...+192)^2}+\dfrac{3}{4}$ ។

**១៧.** គេឱ្យ $x>y>0$ និង $2x^2+2y^2=5xy$ គណនា $E=\dfrac{x+y}{x-y}$ ។

**១៨.** សម្រួលកន្សោម $E=\sqrt{2x^2-y^2+2x\sqrt{x+y}\cdot\sqrt{x-y}}-\sqrt{(x+y)(x-y)}$ ដែល $x>y>0$ ។

**១៩.** ដោយដឹងថា $\sin a-\cos a=\sqrt{2}\sin(45^o-a)$ និង $\sqrt{3}\cos a+\sin a=2\cos(30^o-a)$ ។

ចូរគណនាផលគុណ : ក. $A=(1-\cot 1^o)(1-\cot 2^o)(1-\cot 3^o)\times\cdots\times(1-\cot 44^o)$

ខ. $B=(\sqrt{3}+\tan 1^o)(\sqrt{3}+\tan 2^o)(\sqrt{3}+\tan 3^o)\times\cdots\times(\sqrt{3}+\tan 29^o)$ ។


www.facebook.com/7khmer
fb : Entertainment And Knowledge

**២០.** បើគេឱ្យបីចំនួនពិតវិជ្ជមាន $a, b, c$ ។ ចូរបង្ហាញថា : $(a+b)(b+c)(c+a)\geq 8abc$ ។

**២១.** គេឱ្យបីចំនួនពិតវិជ្ជមាន $a, b, c$ ។ បង្ហាញថា : $a^2+b^2+c^2\geq ab+bc+ca$ ។

**២២.** រកឫសគត់វិជ្ជមាននៃសមីការ : $2(x+y)+16=3xy$ ។

**២៣.** ស្រាយបញ្ជាក់ថាសមីការ : $(x-a)(x-b)+(x-b)(x-c)+(x-c)(x-a)=0$ មានឫសជានិច្ច ដែលនៅក្នុងសមីការនេះមាន $x$ ជាអញ្ញាត និង $a, b, c$ ជាចំនួនពិត។

**២៤.** គេឱ្យទំនាក់ទំនង : $f(x)=\dfrac{4^x}{4^x+2}$ ។

ក. គណនា $f(x)+f(y)$ ដោយដឹងថា $x+y=1$ ។

ខ. ទាញរកផលបូក $S=f\left(\dfrac{1}{2011}\right)+f\left(\dfrac{2}{2011}\right)+f\left(\dfrac{3}{2011}\right)+\ldots+f\left(\dfrac{2010}{2011}\right)$ ។

**២៥.** គណនាលីមីត : $\lim\limits_{x\to 0} x^x$ ។

**២៦.** គណនា : $A=2010\left(2011^{2010}+2011^{2009}+2011^{2008}+\ldots+2011^2+2012\right)+1$ ។

**២៧.** គេឱ្យពីរចំនួន $a$ និង $b$ ដែលផ្ទៀងផ្ទាត់ $a-b=1$ ។ បង្ហាញថា $(a+b)(a^2+b^2)(a^4+b^4)-(a^8-b^8)=0$ ។

**២៨.** គណនា $A=\left(1-\dfrac{1}{2}\right)\times\left(1-\dfrac{1}{3}\right)\times\left(1-\dfrac{1}{4}\right)\times\ldots\times\left(1-\dfrac{1}{2011}\right)$ ។

**២៩.** ដោះស្រាយសមីការ : $4x^4-5x^2+1=0$ ។

**៣០.** បើ $abc=1$ សូមបង្ហាញឱ្យជឿថា $\dfrac{1}{ab+a+1}+\dfrac{1}{bc+b+1}+\dfrac{1}{ca+c+1}=1$ ។

**៣១.** គណនា $S=\dfrac{1}{2\sqrt{1}+1\sqrt{2}}+\dfrac{1}{3\sqrt{2}+2\sqrt{3}}+\dfrac{1}{4\sqrt{3}+3\sqrt{4}}+\ldots\dfrac{1}{100\sqrt{99}+99\sqrt{100}}$ ។

**៣២.** សូមបង្ហាញឱ្យគេជឿថា : $2002^{2003}-2002^{1979}$ ចែកដាច់នឹង 6 ។

**៣៣.** គ្រប់ចំនួនពិត $a, b, c$ ដែលផ្ទៀងផ្ទាត់ $a+b+c=1$ ។ បង្ហាញឱ្យគេជឿថា $a^2+b^2+c^2\geq\dfrac{1}{3}$ ។

**៣៤.** គ្រប់ចំនួនពិត $a, b, c, \ldots, x, y$ វិជ្ជមាន និងខុសពី 1 ។ សូមបង្ហាញឱ្យគេជឿថា :

$\log_a b\times\log_b c\times\log_c d\times\ldots\times\log_x y\times\log_y a=1$ ។

**៣៥.** យើងមាន $f(x)=\log\left(\dfrac{1+x}{1-x}\right)$ ។ បង្ហាញថា $f(x)+f(y)=f\left(\dfrac{x+y}{1+xy}\right)$ ។

**៣៦.** ដោះស្រាយសមីការ $\left(\sqrt{7+\sqrt{48}}\right)^x+\left(\sqrt{7-\sqrt{48}}\right)^x=14$ ។

**៣៧.** គ្រប់ $a$ និង $b$ ជាចំនួនពិតវិជ្ជមាន និងខុសពី 1 ។ សូមបង្ហាញថា :

$(\log_a b+\log_b a+2)(\log_a b-\log_{ab} b)\cdot\log_b a-1=\log_a b$ ។

**៣៨.** សូមបង្ហាញថា : $\dfrac{1+\cos a}{1-\cos a}-\dfrac{1-\cos a}{1+\cos a}=\dfrac{4\cot a}{\sin a}$ ។

**៣៩.** ដោះស្រាយសមីការ : $5^{\log x}=50-x^{\log 5}$ ។

**៤០.** គេបោះគ្រាប់ឡុកឡាក់មួយតែម្តងគត់ ។ គណនាប្រូបាបដែលបោះបានលេខសេស ឬ លេខធំជាង 5 ។

**៤១.** ដោះស្រាយសមីការ $\sqrt{x+\sqrt{4x+\sqrt{16x+\ldots+\sqrt{4^n x+3}}}}=\sqrt{x}+1$ ។

**៤២.** ចំពោះគ្រប់ចំនួនគត់វិជ្ជមាន $n$ គេឱ្យ $f(n)=\dfrac{1}{\sqrt[3]{n^2+2n+1}+\sqrt[3]{n^2-1}+\sqrt[3]{n^2-2n+1}}$ ។ គណនាផលបូក $f(1)+f(3)+f(5)+\ldots+f(999997)+f(999999)$ ។

**៤៣.** ដោះស្រាយប្រព័ន្ធសមីការ : $a/\ \begin{cases}5(\log_y x+\log_x y)=26\\ xy=64\end{cases}$ $b/\ \begin{cases}4^x\cdot 5^y=\dfrac{1}{400}\\ 5^x\cdot 6^y=\dfrac{1}{900}\end{cases}$ ។

**៤៤.** គេឱ្យ $a$ និង $n$ ជាចំនួនវិជ្ជមាន ហើយ $n$ គត់ ដែលផលគុណ $a_1\cdot a_2\cdot a_3\times\ldots\times a_n=1$ ។ សូមបង្ហាញថា $(1+a_1)(1+a_2)(1+a_3)\times\ldots\times(1+a_n)\geq 2^n$ ។

**៤៥.** ដោះស្រាយប្រព័ន្ធសមីការ $a/\ \begin{cases}7x^3-3x^2y-21xy^2+26y^3=342\\ 9x^3-21x^2y+33xy^2-28y^3=344\end{cases}$ $b/\ \begin{cases}4^x\cdot 3^{y+1}+27^y=171\\ 8^x+2^x\cdot 3^{1+2y}=172\end{cases}$ ។

**៤៦.** ចំនួនមួយមានលេខប្រាំខ្ទង់ដែលលេខខ្ទង់វារៀបតាមលំដាប់គឺ $x$ , $x+1$ , $x+2$ , $3x$ , $x+3$ ហើយគេដឹងថា ចំនួននោះជាការេប្រាកដ ។ ចូររកចំនួននោះ ។

**៤៧.** គណនាផលបូក $S=\dfrac{1}{1+\sqrt{2}}+\dfrac{1}{\sqrt{2}+\sqrt{3}}+\dfrac{1}{\sqrt{3}+\sqrt{4}}+\ldots+\dfrac{1}{\sqrt{2024}+\sqrt{2025}}$ ។

**៤៨.** ស្រាយបញ្ជាក់ថា : $f(n)=3^{2n}+7$ ចែកដាច់នឹង 8 ដែល $n$ ជាចំនួនគត់ ។

**៤៩.** មាន $f(x)=2x+1$ និង $g[f(x)]=x^2+3x+1$ ។ សូមគណនា $g(3)$ ។

**៥០.** គ្រប់ចំនួនគត់វិជ្ជមាន $n$ ស្រាយបំភ្លឺថា $\dfrac{n}{3}+\dfrac{n^2}{2}+\dfrac{n^3}{6}$ ក៏ជាចំនួនគត់វិជ្ជមានដែរ ។

**៥១.** គណនាផលបូក $S=\dfrac{1}{1\cdot 2}+\dfrac{1}{2\cdot 3}+\dfrac{1}{3\cdot 4}+\ldots+\dfrac{1}{2010\cdot 2011}$ ។

**៥២.** គេឧបមាថា $x^2+x+1=0$ ។ ចូរគណនា $x^{2011}+\dfrac{1}{x^{2011}}$ ។

**៥៣.** ចំនួនមួយជាការេប្រាកដមានរាង $\overline{abcd}$ ។ ដោយដឹងថា $\overline{ab}-\overline{cd}=1$ ចូររកចំនួន $\overline{abcd}$ នោះ ។

**៥៤.** សូមបង្ហាញថា $n!>3^n$ ចំពោះគ្រប់ចំនួនពិតវិជ្ជមាន $n\geq 7$ ។

**៥៥.** អនុគមន៍ $f$ កំណត់ដោយ $f(x+a)=\dfrac{1}{2}+\sqrt{f(x)-f(x)^2}$ ចំពោះគ្រប់ $x\geq 0$ និង $a>0$ ។ សូមបង្ហាញឱ្យឃើញថា $f$ ជាអនុគមន៍ខួបលើចន្លោះ $[0,+\infty)$ ។

**៥៦.** ចំពោះ $n!=n\times(n-1)\times(n-2)\times\ldots\times 3\times 2\times 1$ ( $n!$ អានថា $n$ ហ្វាក់តូរ្យែល) ។ បង្ហាញថា $0!=1$ ។

**៥៧.** បង្ហាញថា $F=\dfrac{21n+4}{14n+3}$ ជាប្រភាគសម្រួលមិនបាន ចំពោះគ្រប់ចំនួនគត់ធម្មជាតិ $n$ ។

**៥៨.** រកចំនួនគត់ធម្មជាតិតូចបំផុត ដែលមាន 6 ជាលេខនៅខ្ទង់ឯកតា ( ខ្ទង់រាយ) ហើយបើប្តូរលេខ 6 ទៅខាងមុខគេបំផុតវិញ នោះគេនឹងបានចំនួនថ្មី ដែលស្មើនឹង 4 ដងនៃចំនួនដើម ។


www.facebook.com/7khmer
fb : Entertainment And Knowledge

**៥៩.** គេឱ្យលក្ខខណ្ឌបី ដែលបុរសបីនាក់ $A,B,C$ ទៅស្ដីដណ្ដឹងនារីបីនាក់ $1,2,3$ ជាគូអនាគត ដូចខាងក្រោម ៖

ក. បើបុរស $A$ ជាគូនឹងនារី $1$ នោះ បុរស $B$ ជាគូនឹងនារី $2$

ខ. បើបុរស $A$ ជាគូនឹងនារី $3$ នោះ បុរស $C$ ជាគូនឹងនារី $1$

គ. បើបុរស $B$ មិនជាគូនឹងនារី $3$ នោះ បុរស $C$ ជាគូនឹងនារី $1$ ។

សំណួរសួរថា តើបុរសណា ជាគូនឹងនារីណា ?

**៦០.** រក $11$ ចំនួនមិនអវិជ្ជមាន ដែលចំនួននីមួយៗ ស្មើនឹងការេនៃផលបូកនៃ $10$ ចំនួនផ្សេងទៀត ។

**៦១.** គេឱ្យ $a , b , c$ ជាចំនួនពិត ផ្ទៀងផ្ទាត់ $\begin{cases} a+b+c=0 \\ ab+bc+ca=0 \end{cases}$ ។ គណនា $A=(a-1)^{2010}+(b-1)^{2011}+(a-1)^{2012}$ ។

**៦២.** គណនាផលបូក $S=\sqrt{1+\frac{1}{1^2}+\frac{1}{2^2}}+\sqrt{1+\frac{1}{2^2}+\frac{1}{3^2}}+...+\sqrt{1+\frac{1}{2010^2}+\frac{1}{2011^2}}$ ។

**៦៣.** ដោះស្រាយសមីការមាន $x$ ជាចំនួនគត់៖ ក. $x^{2010}+x^{2011}+x^{2012}+x^{2013}=4$

ខ. $x^{2010}+x^{2011}+x^{2012}+x^{2013}=0$ ។

**៦៤.** ដោះស្រាយសមីការ ៖ $\overline{2x9y}=2^x\cdot 9^y$ ។ ( គេសរសេរ $\overline{2x9y}$ បញ្ជាក់ថាជាលេខ៤ខ្ទង់មានន័យថា $0\le x\le 9$ , $0\le y\le 9$ ) ។

**៦៥.** រកគ្រប់ចំនួនគត់ធម្មជាតិ $N=\overline{a_1a_2a_3...a_n}$ ដែលនាំឱ្យ $\frac{\overline{2a_1a_2a_3...a_n1}}{\overline{1a_1a_2a_3...a_n2}}=\frac{21}{12}$ ។

**៦៦.** គណនាផលបូក ៖ $S=\frac{1}{1\cdot 2\cdot 3}+\frac{1}{2\cdot 3\cdot 4}+\frac{1}{3\cdot 4\cdot 5}+...+\frac{1}{n(n+1)(n+2)}$ ។

**៦៧.** សម្រួលកន្សោម ៖ $(2+\sqrt{3})^{2011}\cdot(2-\sqrt{3})^{2012}+\sqrt{3}$ ។

**៦៨.** សូមបង្ហាញឱ្យឃើញថា $\frac{1}{x-1}-\frac{1}{x+1}-\frac{2}{x^2+1}-\frac{4}{x^4+1}=\frac{8}{x^8-1}$ ។

**៦៩.** ចំពោះ $n!=n\times(n-1)\times(n-2)\times...\times 3\times 2\times 1$ ។ គណនាផលបូក $S=\frac{1}{2!}+\frac{2}{3!}+\frac{3}{4!}+...+\frac{n}{(n+1)!}$ ។

**៧០.** កំណត់លេខខាងចុងនៃផលបូក ៖ $\Sigma=1^2+2^2+3^2+...+2010^2+2011^2$ ។

**៧១.** កំណត់លេខខាងចុងនៃផលបូក ៖ $\Sigma=1!+2!+3!+...+2010!+2011!$ ។

**៧២.** គេឱ្យ $\left(a+\sqrt{a^2+1}\right)\left(b+\sqrt{b^2+1}\right)=1$ ។ គណនាតម្លៃ $A=a^{2012}+ab^{2011}$ ។

**៧៣.** ដោះស្រាយសមីការ ៖ $2011^{\log_{2012}x}+x^{\log_{2012}2011}=4022$ ។

**៧៤.** គេឱ្យ $ab=1$ ។ ស្រាយបញ្ជាក់ឱ្យឃើញថា ៖ $a^5+b^5=(a^3+b^3)(a^2+b^2)-(a+b)$ ។

**៧៥.** គេឱ្យ $x$ , $y$ និង $z$ ដែលផ្ទៀងផ្ទាត់ $\begin{cases} x^2+2y+1=0 \\ y^2+2z+1=0 \\ z^2+2x+1=0 \end{cases}$ ។ គណនាកន្សោម ៖ $A=x^{2010}+y^{2011}+x^{2012}$ ។

**៧៦.** ពីសមាមាត្រ $\frac{a}{b}=\frac{c}{d}$ ។ បង្ហាញថា $\frac{ad+bc}{2ab}=\frac{2cd}{ad+bc}$ ។

**៧៧.** $a$ និង $b$ ជាពីរចំនួនគត់វិជ្ជមាន ។ ចូរសម្រួលកន្សោម ៖ $A=\left(\sqrt{\frac{a}{b}}+\sqrt{\frac{b}{a}}+\sqrt{2}\right)\left(\sqrt{\frac{a}{b}}+\sqrt{\frac{b}{a}}-\sqrt{2}\right)\left(\frac{a^2+b^2}{2011ab}\right)^{-1}$ ។


www.facebook.com/7khmer
fb : Entertainment And Knowledge

**៧៨.** គេឱ្យ $a+b+c=1$ , $a^2+b^2+c^2=1$ និង $\frac{x}{a}=\frac{y}{b}=\frac{z}{c}=m$ ។ ចូរគណនា $P=xy+yz+zx$ ។

**៧៩.** គេឱ្យត្រីកោណសមបាទមួយ ដែលមានមុំមួយមានរង្វាស់ស្មើ $\alpha$ និងជ្រុងពីរដែលអមនឹងមុំនេះ មានរង្វាស់ស្មើគ្នា ហើយស្មើ $a$ ។ គណនាក្រឡាផ្ទៃត្រីកោណនេះ ជាអនុគមន៍នៃ $\alpha$ និង $a$ ។




**៨០.** ប្រៀបធៀបចំនួន ក. $\sqrt{6}+\sqrt{5}$ និង $\sqrt{21}$　　ខ. $1+\sqrt[2011]{11+\sqrt{72}}$ និង $2\sqrt[2011]{3+\sqrt{2}}$ ។

**៨១.** រកតម្លៃគត់នៃ $x$ , $y$ និង $z$ ដែលផ្ទៀងផ្ទាត់សមីការ : $x+y+z+4=2\sqrt{x-2}+4\sqrt{y-3}+6\sqrt{z-5}$ ។

**៨២.** គេឱ្យ $\begin{cases} ax^3=by^3=cz^3 \\ \frac{1}{x}+\frac{1}{y}+\frac{1}{z}=1 \end{cases}$ ។ ស្រាយបំភ្លឺថា $\sqrt[3]{ax^2+by^2+cz^2}=\sqrt[3]{a}+\sqrt[3]{b}+\sqrt[3]{c}$ ។

**៨៣.** ស្រាយបញ្ជាក់ថា ទីប្រជុំទម្ងន់$G$ ផ្ចិតរង្វង់ចារឹកក្រៅត្រីកោណ $O$ និងអរតូសង់នៃត្រីកោណ $H$ នៃត្រីកោណមួយ ជាបីចំណុចរត់ត្រង់គ្នា ។

**៨៤.** គេឱ្យ $P=a^2b^2+5a^2+9b^2-6ab^2-30a+45$ ។ ចំពោះគ្រប់តម្លៃនៃចំនួនពិត$a$ និង$b$ បង្ហាញថា $P\geq 0$ ។

**៨៥.** សូមបង្ហាញឱ្យឃើញថា $39^{51}+51^{39}$ ចែកដាច់នឹង $45$ ។

**៨៦.** គណនា $A=101\cdot 10001\cdot 100000001\times\ldots\times 1\underbrace{000\ldots0}_{\text{មាន } 2^n-1 \text{ ដងនៃលេខ 0}}1$ ។

**៨៧.** គណនាតម្លៃ $n$ ដែលនាំឱ្យ $\frac{3}{2011}+\frac{9}{2011}+\frac{15}{2011}+\ldots+\frac{6n-3}{2011}=\frac{300}{2011}$ ។

**៨៨.** ដោះស្រាយប្រព័ន្ធសមីការ　ក. $\begin{cases} x^2=2x-y \\ y^2=2y-z \\ z^2=2z-x \end{cases}$　　ខ. $\begin{cases} \frac{1}{a}+\frac{1}{b}-\frac{1}{c}=-\frac{1}{12} \\ \frac{1}{c}+\frac{1}{b}-\frac{1}{a}=\frac{7}{12} \\ \frac{1}{a}+\frac{1}{c}-\frac{1}{b}=\frac{5}{12} \end{cases}$ ។

**៨៩.** ដោះស្រាយសមីការ:　$\frac{x-4}{2007}+\frac{x-3}{2008}+\frac{x-2}{2009}+\frac{x-1}{2010}=4$ ។

**៩០.** ស្រាយបញ្ជាក់ថា $\frac{\sqrt{\sqrt[4]{8}-\sqrt{\sqrt{2}+1}}}{\sqrt{\sqrt[4]{8}+\sqrt{\sqrt{2}-1}}-\sqrt{\sqrt[4]{8}-\sqrt{\sqrt{2}-1}}}=\frac{1}{\sqrt{2}}$ ។

**៩១.** សម្រួលកន្សោម $B=\left(\frac{2\sqrt{x}+x}{x\sqrt{x}-1}-\frac{1}{\sqrt{x}-1}\right)\div\left(1-\frac{\sqrt{x}+2}{x+\sqrt{x}+1}\right)$ ។

**៩២.** គេឱ្យបីចំនួនរួមមាន : $A=\underbrace{888\ldots88}_{\text{មាន } n \text{ តួនៃលេខ 8}}$　　$B=\underbrace{222\ldots222}_{\text{មាន } n+1 \text{ តួនៃលេខ 2}}$　　និង $C=\underbrace{444\ldots444}_{\text{មាន } 2n \text{ តួនៃលេខ 4}}$

ស្រាយបញ្ជាក់ឱ្យឃើញថា $A+B+C+7$ ជាការេប្រាកដ ។

**៩៣.** កាលណាបាតនៃត្រីកោណមួយកើនឡើង $10\%$ តើកម្ពស់នៃត្រីកោណនោះត្រូវថយចុះប៉ុន្មានភាគរយ ដើម្បីឱ្យវានៅតែរក្សាក្រឡាផ្ទៃឱ្យនៅដដែល ។

**៩៤.** គេឱ្យ $a$ , $b$ និង$c$ ជារង្វាស់ជ្រុងនៃត្រីកោណមួយ ។ស្រាយថា : $ab+bc+ac\leq a^2+b^2+c^2<2(ab+bc+ac)$ ។

**៩៥.** គេឱ្យបីចំនួន $a, b$ និង$c$ ដែល $a+b+c=0$ និង $abc\neq 0$ ។ គណនា $E$ ដែល

$$E=\frac{2011}{b^2-a^2+c^2}-\frac{2011}{b^2-a^2-c^2}+\frac{2011}{a^2+b^2-c^2}$$ ។

**៩៦.** បង្ហាញថា $2010\cdot 2012(2011^2+1)(2011^4+1)(2011^8+1)(2011^{16}+1)=(2011^{32}-1)$ ។

**៩៧.** គេឱ្យ $ABC$ ជាត្រីកោណមួយ ដែលមាន $[AM]$ ជាមេដ្យាន ។ បំភ្លឺថា $2AM<AB+AC$ ។

**៩៨.** ត្រីកោណមួយមានរង្វាស់ជ្រុង $x$ , $x+a$ និង $x+2a$ ដែល $x>0$ និង $a$ ជាចំនួនគត់វិជ្ជមាន ។ រកគ្រប់រង្វាស់ជ្រុងនៃត្រីកោណនេះ ដែលតូចជាង ឬស្មើ 10 ដើម្បីឱ្យវាជាត្រីកោណកែង ។

**៩៩.** ត្រីកោណមួយមានរង្វាស់ជ្រុង 3 , 4 , 5 ។ ត្រីកោណនេះជាត្រីកោណចារឹកក្នុងរង្វង់មួយ ។ តាង $A$ , $B$ , $C$ ជាក្រឡាផ្ទៃផ្នែកប្លង់ ដែលនៅក្នុងរង្វង់ និងក្រៅត្រីកោណ ហើយ $C$ ជាផ្នែកក្រឡាផ្ទៃដែលធំជាងគេ ។ គណនា $A+B$ ជាអនុគមន៍នឹង $C$ ។

**១០០.** គេឱ្យចតុកោណ $ABCD$ ជាចតុកោណព្នាយ និងមាន $MN$ ជាបាតមធ្យមនៃចតុកោណព្នាយនេះ ។ គណនាប្រវែងបាតមធ្យមនៅចន្លោះអង្កត់ទ្រូង x ដូចរូប? បើគេដឹងថា បាតតូច $AB=6cm$ និងបាតធំ $CD=10cm$ ។




**១០១.** ចូរគណនាផលបូក $S=\frac{1^2}{1\cdot 3}+\frac{2^2}{3\cdot 5}+\frac{3^2}{5\cdot 7}+\ldots+\frac{1000^2}{1999\cdot 2001}$ ។

**១០២.** ស្រាយបញ្ជាក់ឱ្យជឿថា $\underbrace{\sqrt{6+\sqrt{6+\sqrt{6+\ldots+\sqrt{6}}}}}_{\text{មាន } n \text{ រ៉ាឌីកាល់}}+\underbrace{\sqrt{30+\sqrt{30+\sqrt{30+\ldots+\sqrt{30}}}}}_{\text{មាន } n \text{ រ៉ាឌីកាល់}}<9$

**១០៣.** ក. ចូរគណនាផលបូក $S=1\cdot 2\cdot 3+2\cdot 3\cdot 4+3\cdot 4\cdot 5+\ldots+n(n+1)(n+2)$

ខ. ស្រាយបញ្ជាក់ថា $4S+1$ ជាការេប្រាកដ ចំពោះគ្រប់ចំនួនគត់វិជ្ជមាន $n$ ។

**១០៤.** គេឱ្យ $0<x_1<x_2<x_3<\ldots<x_{12}$ ។ ស្រាយបញ្ជាក់ថា $\frac{x_1+x_2+x_3+\ldots+x_9}{x_3+x_6+x_9}+\frac{x_1+x_2+x_3+\ldots+x_{12}}{x_4+x_8+x_{12}}<7$ ។

**១០៥.** បើ $x , y$ ជាចំនួនពិតដែលផ្ទៀងផ្ទាត់ $x^2+3xy+y^2=60$ ។ រកតម្លៃធំបំផុតនៃផលគុណ $xy$ ។

**១០៦.** រកផលបូករង្វាស់មុំ (គិតជាដឺក្រេ) នៃមុំ $A,B,C,D,E$ និង $F$ នៅក្នុងរូបខាងស្តាំ ។




**១០៧.** ស្រាយបញ្ជាក់ថាចំនួន $A=111\ldots 11222\ldots 22$ ដែលមានចំនួនតួនៃលេខ1 និងលេខ2 ស្មើគ្នាគឺ 2011 តួ។ ស្រាយបញ្ជាក់ថា $A$ ជាផលគុណនៃពីរចំនួនគត់តគ្នា ។

**១០៨.** ឧបមាថា $x_1$ , $x_2$ ជាឫសនៃសមីការ : $2011x^2-(t-2011)x-2011=0$ ។ រកតម្លៃតូចបំផុតនៃកន្សោម :

$$H=(x_2-x_1)^2+4\left(\frac{x_1-x_2}{2}+\frac{1}{x_1}-\frac{1}{x_2}\right)^2$$ ។

**១០៩.** គណនាតម្លៃលេខនៃ $A=\sqrt{3\sqrt{5\sqrt{3\sqrt{5\sqrt{3\ldots}}}}}$ ។


www.facebook.com/7khmer
fb : Entertainment And Knowledge

**១១០.** គេមានពហុធា $p(x)$ ។ គេដឹងថាសំណល់នៃវិធីចែករវាង $p(x)$ និង $x$ ស្មើ $1$ ហើយសំណល់នៃវិធីចែករវាង $p(x)$ និង $x-1$ ស្មើ $2$ ។ រកសំណល់នៃវិធីចែករវាង $p(x)$ និង $x(x-1)$ ។ (អ្នកអាចប្រៀបធៀបជាមួយលំហាត់ទី៨ ទំព័រទី1)

**១១១.** ស្រាយបញ្ជាក់ថាចំនួន $5^{2011}+5^{2012}+5^{2013}$ ចែកដាច់នឹង $31$ ។

**១១២.** រកលេខនៃតួចុងក្រោយបង្អស់នៃចំនួន $2^{3^4}$ ។

**១១៣.** រកលេខនៃតួចុងក្រោយបង្អស់នៃចំនួន $123456789^{2011}$

**១១៤.** ស្រាយបញ្ជាក់ថាចំនួន $A=\sqrt[3]{\frac{1}{3}\left(\sqrt[3]{2}-1\right)\left(\sqrt[3]{2}+1\right)^3}$ ជាចំនួនគត់វិជ្ជមាន ។

**១១៥.** បញ្ជាក់តម្លៃនៃចំនួនពិត $x$ ដោយប្រើសញ្ញាវិសមភាព។ ដោយដឹងថា $x$ ជាចំនួនដែលមានផ្នែកគត់មានលេខពីរខ្ទង់ កាលណាគេសរសេរវាជាចំនួនទសភាគ។

**១១៦.** ក. ប្រៀបធៀបចំនួន $\left(1+2000^2\right)$ និង $\left(2001^2-2\cdot 2000\right)$

ខ. ដោយមិនប្រើ $2000^2=4000000$ និង $2001^2=4004001$ គណនា $A=\sqrt{1+2000^2+\left(\frac{2000}{2001}\right)^2}+\frac{2000}{2001}$ ។

**១១៧.** គេឱ្យទំនាក់ទំនង $\sqrt{x^2+\sqrt[3]{x^4y^2}}+\sqrt{y^2+\sqrt[3]{x^2y^4}}=a$ ។ ស្រាយបញ្ជាក់ថា $a^{\frac{2}{3}}=x^{\frac{2}{3}}+y^{\frac{2}{3}}$ ។

**១១៨.** ប្រៀបធៀបចំនួន $\sqrt{2001}+\sqrt{2002}$ និង $2\sqrt{2002}$ ។

**១១៩.** ស្រាយបញ្ជាក់ថា : $A=\underbrace{111...111}_{2n\text{ នៃលេខ}1}+\underbrace{444...44}_{n\text{ នៃលេខ}4}+1$ ជាការេប្រាកដនៃចំនួនគត់ ។

**១២០.** សម្រួលកន្សោម : $E=\frac{1}{\left(\sqrt{p}+\sqrt{q}\right)^2}\cdot\left(\frac{1}{p}+\frac{1}{q}\right)+\frac{2}{\left(\sqrt{p}+\sqrt{q}\right)^3}\cdot\left(\frac{1}{\sqrt{p}}+\frac{1}{\sqrt{q}}\right)$ ដែល $(p\,,q>0)$ ។

**១២១.** គណនាតម្លៃលេខនៃកន្សោម : $A=\sqrt[3]{3+\sqrt{9+\frac{125}{27}}}+\sqrt[3]{3-\sqrt{9+\frac{125}{27}}}$ ។

**១២២.** ស្រាយបញ្ជាក់ថា : $\sqrt[3]{\sqrt[3]{2}-1}=\sqrt[3]{\frac{1}{9}}-\sqrt[3]{\frac{2}{9}}+\sqrt[3]{\frac{4}{9}}$ ។

**១២៣.** គណនាតម្លៃលេខនៃកន្សោម $S=\sqrt{6+\sqrt{6+\sqrt{6+\sqrt{6+...}}}}$ ។

**១២៤.** ឧបមាថា $a\neq 0\,,b\neq 0$ និង $\frac{b}{a}=\frac{c}{b}=2011$ ។ គណនាតម្លៃនៃ $\frac{b+c}{a+b}$ ។

**១២៥.** ដោះស្រាយសមីការ : $\frac{x-1}{1991}+\frac{x-5}{1987}+\frac{x-7}{1999}+\frac{x-11}{1981}=4$ ។

**១២៦.** ដោះស្រាយសមីការ : $x^{2000}+\sqrt{6}x^{1998}=\left(\sqrt{2}+\sqrt{3}\right)x^{1999}$ ។

**១២៧.** ដោះស្រាយសមីការ : $\log_2\log_3\log_4 x=2$ ។

**១២៨.** គណនាផលបូក $A=1+11+111+...+\underbrace{111...11}_{n\text{ នៃលេខ}1}$ ។

**១២៩.** ដោះស្រាយសមីការ :ក. $x^{\sqrt{x}}=\sqrt{x^x}$ ខ. $\left(x^x\right)^x=x^{\left(x^x\right)}$ ។



www.facebook.com/7khmer
fb : Entertainment And Knowledge

**១៣០.** គេឱ្យ $a,b,c$ ជាចំនួនពិតដែលផ្ទៀងផ្ទាត់ប្រព័ន្ធសមីការ $\begin{cases} a+b^2+2ac=29 \\ b+c^2+2ab=18 \\ c+a^2+2bc=25 \end{cases}$ ។ ចូរគណនា $a+b+c$ ។

**១៣១.** គណនាផលបូក $S=1+2+3+...+2011$ ។ ( ដោះស្រាយពុំតាមរូបមន្តស្វ៊ីត ) ។

**១៣២.** ថ្នាក់ទី $9B$ មានសិស្សសរុប $28$ នាក់ ។ សិស្សប្រុសមានកម្ពស់មធ្យម $1.68m$ និងសិស្សស្រីមានកម្ពស់មធ្យមគឺ $1.60m$ ។ បើដឹងថាកម្ពស់មធ្យមរបស់សិស្សនៅក្នុងថ្នាក់ទាំងអស់គឺ $1.66m$ ។ រកចំនួនសិស្សស្រីនៅក្នុងថ្នាក់ ។

**១៣៣.** គណនាកន្សោម $A=(a+b+c)^2-(-a+b+c)^2+(a+b-c)^2-(a-b+c)^2$ ។

**១៣៤.** គេឱ្យ $a+b+c=0$ ។ បង្ហាញថា $\dfrac{2011}{b^2+c^2-a^2}+\dfrac{2011}{c^2+a^2-b^2}+\dfrac{2011}{a^2+b^2-c^2}=0$ ។

**១៣៥.** កំណត់តម្លៃ $a$ និង $b$ ដើម្បីឱ្យពហុធា $x^4+2x^3+ax^2+bx+1$ ជាការេនៃត្រីធាដឺក្រេទី2 $x^2+px+q$ ។

**១៣៦.** ចូរស្រាយបំភ្លឺថា $\sqrt[4]{49+20\sqrt{6}}+\sqrt[4]{49-20\sqrt{6}}=2\sqrt{3}$ ។

**១៣៧.** គណនា $E=\left(\sqrt{3-\sqrt{5}}-\sqrt{3+\sqrt{5}}\right)^2-\left(\sqrt{3-\sqrt{5}}+\sqrt{3+\sqrt{5}}\right)^2$ ។

**១៣៨.** កំណត់តម្លៃ $m$ និង $n$ ដើម្បីឱ្យសមីការ $\dfrac{1}{x-3}+\dfrac{m}{x-4}=\dfrac{n}{(x-3)(x-4)}$ មានឫសច្រើនរាប់មិនអស់ ។

**១៣៩.** កំណត់តម្លៃ $a$ ដើម្បីឱ្យប្រព័ន្ធសមីការ $\begin{cases} x+y=a \\ 2x-y=3 \end{cases}$ មានឫសផ្ទៀងផ្ទាត់ $x>y$ ។

**១៤០.** គេឱ្យ $a,b,c$ ផ្ទៀងផ្ទាត់ $a+b+c=0$ និង $ab+bc+ca=0$ ។ គណនា $D=(a-1)^{2010}+(b-1)^{2011}+(c-1)^{2012}$ ។

**១៤១.** គណនា $S=(1\cdot3+2\cdot4+3\cdot5+...+2010\cdot2012)-\left(1^2+2^2+3^2+...+2010^2\right)$ ។

**១៤២.** បង្ហាញថា $A=9^{2011}+8^{2011}+7^{2011}+6^{2011}+5^{2011}-1^{2011}-2^{2011}-3^{2011}-4^{2011}$ ចែកដាច់នឹង $5$ ។

**១៤៣.** គេឱ្យអនុគមន៍ពីរ $f$ និង $g$ កំណត់ដោយ : $f:x\to f(x)=px-2$ ដែល $p$ ជាប៉ារ៉ាម៉ែត្រពិត និង $g:x\to g(x)=4x+3$ ។

ក. គណនា $f\circ g$ និងគណនា $g\circ f$ ។ ខ. កំណត់តម្លៃ $p$ ដើម្បីឱ្យគេបាន $f\circ g=g\circ f$ ។

**១៤៤.** គេមាន $P_n=\cos\dfrac{x}{2}\cos\dfrac{x}{2^2}\cos\dfrac{x}{2^3}\times...\times\cos\dfrac{x}{2^n}$ ។ បង្ហាញថា $P_n=\dfrac{1}{2^n}\cdot\dfrac{\sin x}{\sin\dfrac{x}{2^n}}$ ។

**១៤៥.** ដោះស្រាយប្រព័ន្ធសមីការក្នុង $\mathbb{N}\times\mathbb{N}$ នៃប្រព័ន្ធសមីការ $\begin{cases} x^2-y^2=5440 \\ PGCD(x,y)=8 \end{cases}$ ។

**១៤៦.** ដោះស្រាយសមីការក្នុងសំណុំចំនួនគត់ធម្មជាតិ នៃសមីការ $xy=3x+2y+37$ ។

**១៤៧.** បំភ្លឺថាចំនួន $N=(4n+3)^2-25$ ចែកដាច់នឹង $8$ ។

**១៤៨.** ស្រាយបំភ្លឺថា បើគេមានសមភាព $(a^2+b^2)(c^2+d^2)=(ad+bc)^2$ នោះគេត្រូវបាន $a,b,c$ និង $d$ ជាតួនៃសមាមាត្រមួយ ។

**១៤៩.** គេឱ្យ $ax+by=0$ ។ បង្ហាញថា $\dfrac{a^2}{a^2+b^2}+\dfrac{x^2}{x^2+y^2}=1$ ។


www.facebook.com/7khmer
fb : Entertainment And Knowledge

**១៥០.** គេឱ្យ $a+b+c=0$ និង $\frac{1}{a}+\frac{1}{b}+\frac{1}{c}=0$ ដែល $a\neq 0, b\neq 0, c\neq 0$ ។ គណនាតម្លៃនៃ $K=\frac{a^2+b^2+c^2}{2011}$ ។

**១៥១.** បង្ហាញថា $A=2011\sqrt{\sqrt{5}-\sqrt{3-\sqrt{29-12\sqrt{5}}}}$ ជាចំនួនគត់ ។

**១៥២.** ដោះស្រាយសមីការ $\sqrt{x^2+4x+4}=\sqrt{x^2+2x+1}$ ។

**១៥៣.** គណនាបីចំនួនគត់តគ្នា បើគេដឹងថា ផលចែកនៃផលគុណចំនួនទាំងបី នឹងពាក់កណ្ដាលការេនៃផលបូកចំនួនទាំងបី ស្មើ $\frac{130}{21}$ ។

**១៥៤.** បើ $x^2yz^3=7^3$ និង $xy^2=7^9$ ។ ចូរគណនាតម្លៃលេខនៃ $xyz$ ។

**១៥៥.** រកតម្លៃលេខនៃ $\frac{2^{2012}-2^{2011}}{2^{2012}+2^{2011}}$ ។

**១៥៦.** ចំពោះ $a\neq b\neq c$ គណនាកន្សោម $H=\frac{a^2}{(a-b)(a-c)}+\frac{b^2}{(b-c)(b-a)}+\frac{c^2}{(c-a)(c-b)}$ ។

**១៥៧.** គេដាំកូនឈើ 40ដើម ព័ទ្ធជុំវិញចម្ការមួយមានរាងជាចតុកោណកែង ។ តើចម្ការនោះអាចមានក្រឡាផ្ទៃធំបំផុតប៉ុន្មាន ? បើគេដឹងថា គម្លាតពីដើមឈើមួយទៅដើមឈើមួយទៀតមានប្រវែង $2m$ ។

**១៥៨.** បង្ហាញថាចំនួន $\sqrt{3}$ ពុំមែនជាចំនួនសនិទាន ។ ( ចំនួនសនិទាន ជាចំនួនមានទម្រង់ជាប្រភាគ $\frac{a}{b}$ ដែល ... ) ។

**១៥៩.** បើ $x$ និង $y$ ជាចំនួនពិត ចូរដោះស្រាយសមីការ $x^2+y^2=0$ ។

**១៦០.** គណនា $A=2\frac{3}{4}$  $B=2\cdot\frac{3}{4}$  $C=2\times\frac{3}{4}$  $D=2\left(\frac{3}{4}\right)$  $E=2+\frac{3}{4}$ ។

**១៦១.** គណនា $A=2^{2^2}$  $B=\left(2^2\right)^2$  $C=2^{2\cdot 2}$  $D=2^{2+2}$  $E=2\cdot 2^2$ ។

**១៦២.** សរសេរជាទម្រង់ប្រភាគនៃ $A=1.\overline{2}$  $B=0.\overline{12}$  $C=0.1\overline{2}$  $D=1.2\overline{0}$ ។

**១៦៣.** គេមានការេមួយមានជ្រុង $a$ ។ គណនាអង្កត់ទ្រូង និងចម្ងាយខ្លីបំផុតពីចំណុចប្រសព្វរវាងអង្កត់ទ្រូងទៅជ្រុងការេ ។

**១៦៤.** គេមានត្រីកោណ $ABC$ កែងត្រង់កំពូល $B$ ហើយមានប្រវែងជ្រុង $AB=1$ ។
$D$ ជាចំណុចមួយនៅលើជ្រុង $[BC]$ ដែល $AD=CD=2$ ។ គណនា $AC$ ។




**១៦៥.** ដោះស្រាយសមីការ $\left(\sqrt{2+\sqrt{3}}\cdot\sqrt{2+\sqrt{2+\sqrt{3}}}\cdot\sqrt{2-\sqrt{2+\sqrt{3}}}\right)x-2011=0$ ។

**១៦៦.** ដោះស្រាយសមីការ $(x^2+2x+4)(x^2+2x+3)=x^2+2x+7$ ។

**១៦៧.** ឧបមាថាសមីការ $ax^2+bx+c=0$ មានឫស $x_1$ និង $x_2$ ។ តាង $S_n=x_1^n+x_2^n$ ដែល $n$ ជាចំនួនគត់ធម្មជាតិ ។ ស្រាយបញ្ជាក់ថា $aS_{n+1}+bS_n+cS_{n-1}=0$ ។

**១៦៨.** គេឱ្យ $\frac{x^2+2y^2}{306}=\frac{x^2-2y^2}{294}$ ។ គណនា $\frac{x^2}{y^2}$ ។

**១៦៩.** គណនា $A=(x+2)^2-2(x+2)(x-8)+(x-8)^2$ ចំពោះ $x=2011^{2012}$ ។

**១៧០.** គេឱ្យ $a$ , $b$ និង $c$ ជាបីចំនួនខុសពីសូន្យ ដែល $a+b+c=1$ និង $\frac{1}{a}+\frac{1}{b}+\frac{1}{c}=0$ ។
ស្រាយបំភ្លឺថា $a^2+b^2+c^2=1$ ។


www.facebook.com/7khmer
fb : Entertainment And Knowledge

**១៧១.** រកពីរចំនួនពិតដែលមានផលបូកស្មើ 13 ហើយផលបូកច្រាសរបស់វាស្មើនឹង $\frac{13}{40}$ ។

**១៧២.** គេឱ្យសមីការ $(x+1)(x+2)(x+3)(x+4)=k$ ។

ក. ដោះស្រាយសមីការ ចំពោះ $k=3$ ។ ខ. កំណត់តម្លៃ $k$ ដើម្បីឱ្យសមីការមានឫស ។

**១៧៣.** ប្រៀបធៀបពីរចំនួន : $200^{300}$ និង $300^{200}$ ។

**១៧៤.** ប្រៀបធៀបចំនួន $31^{11}$ និង $17^{14}$ ។

**១៧៥.** បើ $a$ ជាឫសនៃសមីការ $x^{2011}=1$ ហើយ $a\neq 1$ ។ ចូរគណនា $1+a+a^2+a^3+\ldots+a^{2010}$ ។

**១៧៦.** គណនាផលបូក $S=3+3^2+3^3+\ldots+3^n$ ។ (ពុំដោះស្រាយតាមរូបមន្តស្វ៊ីតធរណីមាត្រ) ។

**១៧៧.** គណនា $A=\left(1-\frac{1}{2^2}\right)\left(1-\frac{1}{3^2}\right)\left(1-\frac{1}{4^2}\right)\times\ldots\times\left(1-\frac{1}{n^2}\right)$ ។

**១៧៨.** កំណត់តម្លៃ $m$ នៃប្រព័ន្ធសមីការ $\begin{cases}2x-4y=7\\3x+y=m\end{cases}$ ដើម្បីឱ្យវាមានឫស $x>0$ និង $y<0$ ។

**១៧៩.** គណនា $E=\sqrt{1+2+3+\ldots+2009+2010+2011+2010+2009+\ldots+3+2+1}$ ។

**១៨០.** ដោះស្រាយប្រព័ន្ធសមីការ $\begin{cases}a+b+c=3\\b+a+d=4\\a+c+d=5\\b+c+d=6\end{cases}$ ។

**១៨១.** បង្ហាញថា $\sqrt{7}+\sqrt[3]{7}+\sqrt[4]{7}<7$ ហើយ $\sqrt{4}+\sqrt[3]{4}+\sqrt[4]{4}>4$ ។

**១៨២.** គេឱ្យពហុធា $f(x)=x^n-4x^2+1$ ដែល $n$ ជាចំនួនគត់ធម្មជាតិ ( $n\in\mathbb{N}$ ) ។ កំណត់តម្លៃ $n$ ដើម្បីឱ្យវិធីចែកនៃពហុធាខាលើ និងពហុធា $(x-3)$ មានសំណល់ស្មើ 46 ។

**១៨៣.** ដោះស្រាយសមីការ : $\dfrac{x}{2+\dfrac{x}{2+\dfrac{x}{2+\dfrac{x}{2+\dfrac{x}{1+\sqrt{1+x}}}}}}=1$ ។

**១៨៤.** កំណត់គ្រប់ចំនួនគត់ $n$ ដែលធ្វើឱ្យ $B=4^{27}+4^{1016}+4^n$ ជាការេប្រាកដនៃមួយចំនួនគត់ ។

**១៨៥.** ដោះស្រាយសមីការ $\frac{x^4+x^2+1}{x^2}=\frac{x^2+x+1}{x}$ ។

**១៨៦.** ដោះស្រាយប្រព័ន្ធសមីការ : ក. $\begin{cases}x+y+z=6\\xy+yz+zx=12\\\frac{2}{x}+\frac{2}{y}+\frac{2}{z}=3\end{cases}$ ខ. $\begin{cases}\frac{1}{x}+\frac{1}{y}+\frac{1}{z}=3\\\frac{1}{xy}+\frac{1}{yz}+\frac{1}{zx}=3\\\frac{1}{xyz}=1\end{cases}$ ។

**១៨៧.** គេឱ្យ $4^a+4^{-a}=23$ ។ គណនា $2^a+2^{-a}$ ។

**១៨៨.** រកចំនួនលទ្ធភាពទាំងអស់ ក្នុងការបង្កើតលេខទូរស័ព្ទ ដែលមានក្បាលប្រព័ន្ធ : ក. 011 ខ.097 ។


www.facebook.com/7khmer
fb : Entertainment And Knowledge

**១៨៩.** ដោយប្រើលេខទាំងបួនមាន : 1, 2, 4 និង 9 ។ តើគេអាចបង្កើតបានលេខបួនខ្ទង់ ប៉ុន្មានរបៀបខុសគ្នា?

**១៩០.** ឧបមាថាសមីការ $x^2+px+1=0$ មានឫស $a, b$ និងសមីការ $x^2+qx+2=0$ មានឫស $b, c$ ។

ស្រាយបញ្ជាក់ថា $(b-a)(b-c)=pq-6$ ។

**១៩១.** ស្រាយបំភ្លឺថា បើគេមាន $a+b+c=abc$ និង $\frac{1}{a}+\frac{1}{b}+\frac{1}{c}=2$ នោះយើងបាន $\frac{1}{a^2}+\frac{1}{b^2}+\frac{1}{c^2}=2$ ។

**១៩២.** រកពីរចំនួនដោយដឹងថា ផលបូក ផលគុណ និងផលចែករវាងចំនួនទាំងពីរ ស្មើគ្នា ។

**១៩៣.** គណនាផលគុណ $P=(1+x)(1+x^2)(1+x^4)\times\ldots\times\left(1+x^{2^n}\right)$ ។

**១៩៤.** គណនាផលបូក $S=\frac{1}{1+2}+\frac{1}{1+2+3}+\frac{1}{1+2+3+4}+\ldots+\frac{1}{1+2+3+\ldots+2011}$ ។

**១៩៥.** គណនាផលបូក $S=\frac{1}{x^2+x}+\frac{1}{x^2+3x+2}+\frac{1}{x^2+5x+6}+\frac{1}{x^2+7x+12}+\frac{1}{x^2+9x+20}$ ចំពោះ $x=95$ ។

**១៩៦.** បើ $abc=1$ បង្ហាញថា $\frac{a}{ab+a+1}+\frac{b}{bc+b+1}+\frac{c}{ca+c+1}=\frac{1}{1+a+ab}+\frac{1}{1+b+bc}+\frac{1}{1+c+ca}$ ។

**១៩៧.** រកតម្លៃ $x$ បើ : $\overline{xxx}(x-1)=(x-1)^{x-2}$ ដែល $x$ ជាចំនួនគត់ធម្មជាតិ ។

**១៩៨.** សម្រួលកន្សោម $A=\log_3 2\cdot\log_4 3\cdot\log_5 4\cdot\log_6 5\cdot\log_7 6\cdot\log_8 7$ ។

**១៩៩.** គណនាផលបូក $S=\frac{1}{\log_a x}+\frac{1}{\log_{a^2} x}+\frac{1}{\log_{a^3} x}+\ldots+\frac{1}{\log_{a^k} x}$ ដែល $k$ ជាចំនួនគត់ធម្មជាតិ ។

**២០០.** ដោះស្រាយប្រព័ន្ធសមីការ : $\begin{cases} x_1+x_2+x_3+\ldots+x_{2011}=0 \\ x_1^2+x_2^2+x_3^2+\ldots+x_{2011}^2=0 \\ x_1^3+x_2^3+x_3^3+\ldots+x_{2011}^3=0 \\ \ldots\ldots\ldots\ldots\ldots\ldots \\ x_1^{2011}+x_2^{2011}+x_3^{2011}+\ldots+x_{2011}^{2011}=0 \end{cases}$ ។

**២០១.** ដោះស្រាយប្រព័ន្ធសមីការតាមដេទែមីណង់ : $\begin{cases} 3^{\pi}x+3^{-\pi}y=2 \\ 2\cdot 3^{\pi}x-3^{-\pi}y=1 \end{cases}$ ។

**២០២.** គេឱ្យពីចំនួនពិត $x$ និង $y$ មានសញ្ញាដូចគ្នា។ បង្ហាញថា : ក. $x^2+y^2\geq 2xy$ ខ. $\frac{x}{y}+\frac{y}{x}\geq 2$ ។

**២០៣.** សម្រួលកន្សោម : $E=\frac{\left(\sqrt{a}+\sqrt{b}\right)^2-4\sqrt{ab}}{\sqrt{a}-\sqrt{b}}$ និង $F=\frac{a\sqrt{b}+b\sqrt{a}}{\sqrt{ab}}$ ដែល $a>0, b>0$ ។

រួចគណនា : $E+F$ និង $E\cdot F$ ។

**២០៤.** ចំពោះ $x=100$ គណនាតម្លៃនៃកន្សោម : $A=x^n-100x^{n-1}+x^{n-2}-100x^{n-3}+x^{n-4}-100x^{n-5}$ ។

**២០៥.** គណនាតម្លៃនៃកន្សោម $A=\sqrt[3]{22+\sqrt{30-\sqrt{20+\sqrt{27-\sqrt[3]{8}}}}}$ ។

**២០៦.** គេឱ្យ $a$ និង $b$ ជាពីរចំនួនគត់គត្គា ។ ដោយដឹងថា $a^2-b^2=321$ ចូរគណនាតម្លៃនៃ $a$ និង $b$ ។

**២០៧.** ដូចម្តេចដែលហៅថាមុំទល់កំពូល ? បង្ហាញថាមុំទល់កំពូលជាមុំប៉ុនគ្នា ។

**២០៨.** រកចំនួនគត់វិជ្ជមាន $n$ ដើម្បីឱ្យ $x^2+x+6$ ស្មើនឹង $n^2$ ដែល $x$ ជាចំនួនគត់ ។

**២០៩.** ប្រៀបធៀបកន្សោម : $\frac{(a+b)^2}{a^2-b^2}$ និង $\frac{a^2+b^2}{(a-b)^2}$ ។


www.facebook.com/7khmer
fb : Entertainment And Knowledge

**២១០.** គេមានសមីការ $(m+1)x^2-(m+3)x+3-m=0$ ។

ក. កំណត់តម្លៃ $m$ ដើម្បីឱ្យ $x=1$ ជាឫសនៃសមីការខាងលើ រួចគណនាឫសមួយទៀត ។

ខ. កំណត់តម្លៃ $m$ ដើម្បីឱ្យសមីការមានឫសឌុប រួចគណនាឫសឌុបទាំងនោះ ។

**២១១.** រកពីរចំនួន $x$ និង $y$ ដោយស្គាល់ផលបូក និងផលគុណ : $\begin{cases} x^2+y^2=25 \\ xy=12 \end{cases}$ ។

**២១២.** ដោះស្រាយប្រព័ន្ធសមីការ $\begin{cases} x^2+y^2+x+y=8 \\ x^2+y^2+xy=7 \end{cases}$

**២១៣.** ដូចម្ដេចដែលហៅថាបាតមធ្យមនៃត្រីកោណ ? បង្ហាញថាបាតមធ្យមនៃត្រីកោណ ស្មើនឹងពាក់កណ្ដាលបាតមួយនៃត្រីកោណនោះ ។

**២១៤.** តើមានចំនួនគត់ $n$ ប៉ុន្មានខ្លះដែលផ្ទៀងផ្ទាត់ $\frac{2}{7}<\frac{n}{12}<\frac{4}{5}$ ?




**២១៥.** ត្រីកោណ $ABC$ ត្រូវបានកាត់ចេញពីក្រដាសរាងជាចតុកោណកែង ដូចរូបខាងស្ដាំ ។ តើក្រដាសដែលនៅសល់មានប៉ុន្មានភាគ ?

**២១៦.** ទាញរក $\frac{1}{x+2012}=?$ បើដឹងថា $\frac{1}{x+2011}=2011$ ។




**២១៧.** របារដែកមួយមានប្រវែង $25m$ ត្រូវបានផ្អែកចុងខាងលើ ទៅលើជញ្ជាំងឈរមួយ ដែលចម្ងាយពីជញ្ជាំងទៅចុងរបារខាងក្រោមមានប្រវែង $20m$ ។ បើគេបង្អិតរបាចេញពីជញ្ជាំងថែម $4m$ ទៀត តើចុងរបារបានធ្លាក់ចុះចំនួនប៉ុន្មាន $m$ ?( សូមមើលរូបខាងស្ដាំ )

**២១៨.** ត្រីកោណ $ABC$ មួយកែងត្រង់ $A$ ហើយមានបរិមាត្រ $60\ cm$ និងមានផ្ទៃក្រឡា $120cm^2$ ។ ចូរគណនារង្វាស់ជ្រុងនីមួយៗនៃត្រីកោណ $ABC$ ។

**២១៩.** បង្ហាញថាត្រីកោណដែលមានរង្វាស់មុំទាំងបី $\alpha$ , $2\alpha$ និង $3\alpha$ ជាត្រីកោណកែង ។

**២២០.** បើគេដឹងថា $f(x)\cdot f(x+1)=9$ និង $f(3)=81$ ។ ចូររក $f(9)$ ។

**២២១.** សុខធ្វើដំណើរដោយមធ្យោបាយបីប្រភេទគឺ រថយន្តបាន $\frac{3}{8}$ ហើយម៉ូតូបាន $\frac{3}{5}$ នៃចម្ងាយផ្លូវទាំងអស់ ។

ក. រកប្រភាគតាងចម្ងាយផ្លូវដែលសុខត្រូវដើរ ។    ខ. រកចម្ងាយផ្លូវទាំងអស់បើសុខដើរបាន $2\ km$ ។

**២២២.** ក. សរសេរ $45m$ ជាភាគរយនៃ $1km$ ។    ខ. សរសេរ $1kg$ ជាភាគរយនៃ $800g$ ។

**២២៣.** អង្កត់ $MN$ មានរង្វាស់ $18cm$ ។ $I$ ជាចំណុចមួយនៅលើ $MN$ ហើយ $MI \neq NI$ ។ $A$ និង $B$ ជាចំណុចកណ្ដាលរៀងគ្នានៃ $MI$ និង $NI$ ។ គណនា $AB$ ។

**២២៤.** ស្រាយបញ្ជាក់ថា ផលបូកមុំក្នុងពីរនៃត្រីកោណ ស្មើមុំក្រៅមួយនៃត្រីកោណ ដែលមិនជាប់មុំទាំងពីរនោះ ។

**២២៥.** គណនាតម្លៃនៃកន្សោម $A=\left[\sqrt{4+\sqrt{5\sqrt{3}+5\sqrt{48-10\sqrt{7+4\sqrt{3}}}}}-4\right]^{2011^{2012}}$ ។



www.facebook.com/7khmer
fb : Entertainment And Knowledge

**២២៦.** ដោះស្រាយប្រព័ន្ធសមីការ : $\begin{cases} 2^x+2^y+2^z=7 \\ 2^{-x}+2^{-y}+2^{-z}=\dfrac{7}{4} \\ x+y+z=3 \end{cases}$ ។

**២២៧.** $a$ និង $b$ ជាពីរចំនួនគត់វិជ្ជមានដែល $a+\sqrt{b}=\sqrt{15+\sqrt{216}}$ ។ ចូរគណនា $\left(\dfrac{2a}{b}\right)^{2011}$ ។

**២២៨.** គេដឹងថា $\log 2=0.3010...$ ។ ចូររកចំនួនខ្ទង់នៃផ្នែកគត់វិជ្ជមាននៃ $A=2^{2011}$ ។

**២២៩.** ដោះស្រាយសមីការ $\dfrac{3\sqrt{x}-5}{2}-\dfrac{2\sqrt{x}-7}{3}=\sqrt{x}-1$ ។

**២៣០.** ប្រៀបធៀបចំនួន $ab$ និង $PGCD(a,b)\times PPCM(a,b)$ ចំពោះ $a=90$ , $b=280$ ។

**២៣១.** ផ្ទៀងផ្ទាត់ឯកលក្ខណៈភាព : $(1+\sin x+\cos x)^2=2(1+\sin x)(1+\cos x)$ ។

**២៣២.** ដោះស្រាយប្រព័ន្ធសមីការ : $\begin{cases} x+y=4 \\ xy-z^2+6z=13 \end{cases}$ ។

**២៣៣.** គេមាននិមិត្តសញ្ញាលោការីត : $Logx$ , $\log x$ , $\lg x$ , $\ln x$ , $\log_{10} x$ , $\log_e x$ ។ តើនិមិត្តសញ្ញាណាខ្លះជាលោការីតទសភាគ ( លោការីតគោល 10 ) ហើយលោការីតណាខ្លះជាលោការីតនេពែ ( លោការីតគោល $e$ ) ?

**២៣៤.** ត្រីកោណមួយមានរង្វាស់ជ្រុង 7 , 8 និង 11 ។ រកក្រឡាផ្ទៃរង្វង់ចារឹកក្នុងត្រីកោណនេះ ។

**២៣៥.** គេមានបីចំនួន $a$ , $b$ , $c$ ផ្ទៀងផ្ទាត់ $a+b+c=1$ , $a^2+b^2+c^2=1$ និង $a^3+b^3+c^3=1$ ។ គណនាតម្លៃលេខនៃកន្សោម $P=a^{2010}+b^{2011}+c^{2012}$ ។

**២៣៦.** បង្ហាញថា : $a^2+b^2+c^2+d^2+1\geq a+b+c+d$ ។

**២៣៧.** អាយុឪពុកតិចជាងផលបូកអាយុកូនទាំងបី 3ឆ្នាំ ។ បើដឹងថា : អាយុឪពុក និងកូនទាំងបីសមាមាត្រនឹងចំនួន : 15 , 7 , 5 , 4 ។ រកអាយុម្នាក់ៗ ។

**២៣៨.** ប្រៀបធៀបពីរចំនួន : $\left(\dfrac{9}{25}\right)^{60}$ និង $\left(\dfrac{225}{625}\right)^{50}$ ។

**២៣៩.** គេឱ្យសមាមាត្រ $\dfrac{a}{b}=\dfrac{c}{d}$ ស្រាយបំភ្លឺថាគេបាន : $\dfrac{ab}{cd}=\dfrac{(a+b)^2}{(c+d)^2}$ ។

**២៤០.** រកពីរចំនួនគត់វិជ្ជមានតគ្នា ដោយដឹងថាផលដកការេនៃចំនួនទាំងពីរស្មើនឹង 321 ។

**២៤១.** ក្មេងលេងឃ្លីបីនាក់គឺ A , B និង C មានឃ្លីសមាមាត្រនឹង 3 , 4 , 5 ។ ក្រោយពេលឈប់លេងឃ្លីអ្នកទាំងបីមានសមាមាត្រ 15 , 16 , 17 ។ តើក្មេងណាឈ្នះ ក្មេងណាចាញ់ ?

**២៤២.** ដោះស្រាយសមីការ $\dfrac{x}{3}-\dfrac{x}{6}+\dfrac{x}{9}-\dfrac{x}{12}=-1+\dfrac{1}{2}-\dfrac{1}{3}+\dfrac{1}{4}$ ។

**២៤៣.** ដោះស្រាយប្រព័ន្ធសមីការ : $\begin{cases} x+xy+y=1 \\ y+yz+z=4 \\ z+zx+x=9 \end{cases}$

**២៤៤.** ប្រៀបធៀបចំនួន $2^{2^{2^{\cdot^{\cdot^{2}}}}}$ មានលេខ 2 ចំនួន 1001ដង និង $3^{3^{3^{\cdot^{\cdot^{3}}}}}$ មានលេខ 3 ចំនួន 1000 ដង ។

**២៤៥.** ដោះស្រាយសមីការ : $x=\sqrt{3-x}\cdot\sqrt{4-x}+\sqrt{4-x}\cdot\sqrt{5-x}+\sqrt{5-x}\cdot\sqrt{3-x}$ ។

**២៤៦.** បុរសម្នាក់ធ្វើដំណើរពីរាជធានីភ្នំពេញទៅកាន់ខេត្តស្វាយរៀង។ ក្រោយឆ្លងសាឡាងអ្នកលឿងគាត់ធ្វើដំណើរបន្ត ដល់ត្រង់ចំណុចមួយ គាត់បានចោលភ្នែកឃើញបង្គោលប្រាប់ចម្ងាយដាក់ថា "ស្វាយជ្រំ $17km$" និងបង្គោលបន្ទាប់ ដាក់ថា "ស្វាយរៀង $25km$ "។ សំណួរសួរថា តើចម្ងាយពី ស្វាយជ្រំ ទៅស្វាយរៀងមានប្រវែងប៉ុន្មាន $km$?

**២៤៧.** ចាបមួយហ្វូងហើរទំលើផ្កាឈូកនៃស្រះមួយ។ បើចាបមួយទំលើផ្កាឈូកមួយ នោះមានចាបមួយគ្មានផ្កាឈូកទំ ។ តែបើចាបពីរទំផ្កាឈូកមួយ នោះមានផ្កាឈូកមួយគ្មានចាបទំ។ ចូររកចំនួនចាប និងចំនួនផ្កាឈូក ។

**២៤៨.** សត្វខ្វែកទំលើមែកខ្វារ បាក់មែកប្រាវងាប់បីរស់ពីរ ចុះបើសត្វ 120 ងាប់ប៉ុន្មាន ? រស់ប៉ុន្មាន ?

**២៤៩.** ដាវី មានអាយុតាងដោយ $x$ បើគិតគូឱ្យខិចិច $x$ ជាពហុគុណនៃ8 ដោយដឹងថា $x$ ធំជាង10 និងតូចជាង 20 ។ តើសព្វថ្ងៃ ដាវីស្រីមានអាយុប៉ុន្មាន ?

**២៥០.** កសិកម្នាក់មានចំណីសម្រាប់ផ្គត់ផ្គង់គោរបស់គាត់ 40 ក្បាលបាន 35 ថ្ងៃ។ បើគាត់ទិញគោ 10 ក្បាលបន្ថែមទៀត តើគាត់អាចផ្គត់ផ្គង់ចំណីដដែលឱ្យគោបានប៉ុន្មានថ្ងៃ ?

**២៥១.** គេឱ្យបីចំនួនពិត $a_1$ , $a_2$ និង $a_3$ ដែល $a_1=\sin a_1$ , $a_2=\cos a_1\cdot\sin a_2$ និង $a_3=\cos a_1\cdot\cos a_2$ ។ បង្ហាញថា $a_1^2+a_2^2+a_3^2=1$ ។

**២៥២.** គណនាផលគុណ $P_n=(1-x+x^2)(1-x^2+x^4)(1-x^4+x^8)\times\ldots\times(1-x^{2^n}+x^{2^{n+1}})$ ។

**២៥៣.** បើ $a>0$, $b>0$ និង $c>0$ បង្ហាញថា $\dfrac{3}{a+b+c}<\dfrac{1}{a+b}+\dfrac{1}{b+c}+\dfrac{1}{c+a}$ ។

**២៥៤.** គណនាផលបូក $S_n=1\cdot1!+2\cdot2!+3\cdot3!+\ldots+n\cdot n!$ ដែល $n!=n(n-1)(n-2)\times\ldots\times3\times2\times1$ ។

**២៥៥.** គណនាផលបូក $\sum_{n=1}^{9999}\left(\dfrac{1}{(\sqrt{n}+\sqrt{n+1})(\sqrt[4]{n}+\sqrt[4]{n+1})}\right)$ ។

**២៥៦.** សម្រួលកន្សោម : $A=\dfrac{a^3+b^3+c^3-3abc}{a^2+b^2+c^2-ab-bc-ca}$ ។

**២៥៧.** ស្រាយបញ្ជាក់ថា បើគេមាន $\dfrac{a}{b}=\dfrac{c}{d}$ នោះគេបាន : $\left(\dfrac{a-b}{c-d}\right)^4=\dfrac{a^4+b^4}{c^4+d^4}$ ។

**២៥៨.** គេមាន $6^2-5^2=11$ , $56^2-45^2=1111$ , $556^2-445^2=111111$ , $5556^2-4445^2=11111111$ , ... ។ ពីការបង្ហាញឧទាហរណ៍ខាងលើចូររករូបមន្តទូទៅ និងស្រាយបញ្ជាក់រូបមន្តនោះផង។

**២៥៩.** គណនាផលបូក : $S=\cos^2 1^o+\cos^2 2^o+\cos^2 3^o+\ldots+\cos^2 89^o$ ។

**២៦០.** គណនាផលបូក : $S=\sin^2 0^o+\sin^2 1^o+\sin^2 2^o+\ldots+\sin^2 90^o$ ។

**២៦១.** ចូរកំណត់តម្លៃ $a$ និង $b$ ដើម្បីឱ្យចំនួន $\overline{abba}$ ជាគូបប្រាកដនៃមួយចំនួនគត់ ។

**២៦២.** ក. កំណត់តម្លៃលេខនៃអញ្ញាត $a$ , $b$ , $c$ និង $d$ នៃចំនួន $\overline{abcd}$ ដោយដឹងថា $\overline{abcd}\times9=\overline{dcba}$ ។

ខ. បញ្ជាក់ថា $\overline{abcd}$ និង $\overline{dcba}$ សុទ្ធតែជាការេប្រាកដនៃមួយចំនួនគត់។

**២៦៣.** ពីរចំនួនដែលជាការេប្រាកដ ដោយដឹងថាផលគុណវា លើសផលបូកវាចំនួន 4844 ។


www.facebook.com/7khmer
fb : Entertainment And Knowledge

**២៦៤.** ត្រីកោណកែងមួយមានផ្ទៃក្រឡា $24cm^2$ និងមានបរិមាត្រ $24cm$ ។ គណនារង្វាស់ជ្រុងនីមួយៗរបស់ត្រីកោណ ។

**២៦៥.** មានពីរចំនួនគត់តគ្នា ដែលចំនួនទីមួយជាចំនួនបឋម និងចំនួនធំបន្ទាប់ជាការេប្រាកដ ។ ចូររកចំនួនទាំងពីនោះ ។

**២៦៦.** គេមានរង្វង់ប៉ុនៗគ្នាហើយត្រូវបាន គេរៀបដូចរូបខាងស្តាំ ដែលមាន កម្ពស់ស្មើនឹង $2m$ ។ រកកាំរង្វង់ ។




**២៦៧.** ស្រាយឱ្យឃើញថា ត្រីកោណចារឹកកន្លះរង្វង់ជាត្រីកោណកែងជានិច្ច ។

**២៦៨.** ពហុកោណមួយមានផលបូកមុំក្នុងមិនលើសពី $2011^\circ$ ។ តើពហុកោណនេះអាចមានចំនួនជ្រុងច្រើនបំផុតប៉ុន្មាន ?

**២៦៩.** ចូរស្រាយថា រង្វាស់ជ្រុងនីមួយៗរបស់ត្រីកោណត្រូវតែតូចជាងកន្លះបរិមាត្ររបស់វាជានិច្ច ។

**២៧០.** បុរសម្នាក់មានបារីមូលដោយដៃ 10 ដើម ។ គាត់ជក់បារីដោយរក្សាកន្ទុយបារី បើជក់អស់បីដើម នោះគាត់អាចយកបន្ទុយបារីដែលសល់មូលបានមួយដើមថ្មីវិញ ។ តើគាត់ជក់ប៉ុន្មានដងទើបអស់បារីទាំង 10 ដើមគ្មានសល់ ?

**២៧១.** ដោះស្រាយសមីការ ក. $3^x+4^x=5^x$ ខ. $3^x+4^x+5^x=6^x$ ។

**២៧២.** ស្រាយបញ្ជាក់ ពីសមភាព $(y-z)^2+(z-x)^2+(x-y)^2=(y+z-2x)^2+(z+x-2y)^2+(x+y-2z)^2$

នោះគេបាន $x=y=z$ ។

**២៧៣.** ចូរគណនា $S=ab+cd$ ដោយដឹងថា $a^2+b^2=c^2+d^2=2011$ និង $ac+bd=0$ ។

**២៧៤.** ក. ស្រាយបញ្ជាក់ថា $\dfrac{1}{\sin 2a}=\cot a-\cot 2a$ ។

ខ. ចូរគណនាផលបូក $S_n=\dfrac{1}{\sin a}+\dfrac{1}{\sin\frac{a}{2}}+\dfrac{1}{\sin\frac{a}{2^2}}+\dfrac{1}{\sin\frac{a}{2^3}}+\ldots+\dfrac{1}{\sin\frac{a}{2^n}}$ ។

**២៧៥.** ក. ស្រាយបញ្ជាក់ថា $1+\dfrac{1}{\cos x}=\dfrac{\cot\frac{x}{2}}{\cot x}$ ។

ខ. ចូរគណនាផលគុណ $P_n=\left(1+\dfrac{1}{\cos x}\right)\left(1+\dfrac{1}{\cos\frac{x}{2}}\right)\left(1+\dfrac{1}{\cos\frac{x}{2^2}}\right)\times\ldots\times\left(1+\dfrac{1}{\cos\frac{x}{2^n}}\right)$ ។

**២៧៦.** គេឱ្យបួនចំនួន $x$ , $y$ , $z$ និង $t$ វិជ្ជមាន ដោយដឹងថា $\dfrac{x}{2}=\dfrac{y}{3}=\dfrac{z}{4}=\dfrac{t}{6}$ និង $\dfrac{yzt}{x}+\dfrac{ztx}{y}+\dfrac{txy}{z}+\dfrac{xyz}{t}=14625$ ។

គណនា $x$ , $y$ , $z$ និង $t$ ។

**២៧៧.** គេមានពហុធា $P=x^2+x+1$ និង $Q=2+x-x^2$ ។

ក. កំណត់តម្លៃ $x$ ដើម្បីឱ្យ $P$ មានតម្លៃអប្បបរមា។ ខ. កំណត់តម្លៃ $x$ ដើម្បីឱ្យ $Q$ មានតម្លៃអតិបរមា។

**២៧៨.** រកចំនួនគត់វិជ្ជមាន $n$ តូចបំផុត ដែល $n$ មានសំណល់ 1 , 2 , 3 , 4 , 5 ពេលចែកនឹង 2,3,4,5,6 រៀងគ្នា ។

**២៧៩.** រកចំនួនគត់ $n$ តូចបំផុត ដែល $n$ ចែកដាច់នឹង 7 តែបើចែកនឹង 2 , 3 , 4 , 5 , 6 ឱ្យសំណល់ស្មើ 1 ជានិច្ច ។

**២៨០.** ស្រាយបញ្ជាក់ថាកន្សោម $E=\cos^6 x+\sin^6 x+3\sin^2 x\cos^2 x$ មានតម្លៃថេរ គ្រប់តម្លៃរបស់ $x$ ។


www.facebook.com/7khmer
fb : Entertainment And Knowledge

**២៨១.** ដោះស្រាយប្រព័ន្ធសមីការ : $\begin{cases} x^3+y^3=9 \\ xy=2 \end{cases}$ ។

**២៨២.** ដោះស្រាយសមីការ $(3^{2011}-3^{2010})(3^{2009}-3^{2008})=4\times 3^x$ ។

**២៨៣.** សរសេរ $N$ ជាផលគុណកត្តាដឺក្រេទី១ ដែល $N=(3a-1)^2-4(a^2+6a+9)$ ។

**២៨៤.** ស្រាយបញ្ជាក់ថា ចំនួន $N=4(4a+1)^2-100$ ចែកដាច់នឹង $32$ ។

**២៨៥.** គេឱ្យ $a+b=1$ ។ ចូរគណនាតម្លៃលេខនៃកន្សោម $P=2(a^3+b^3)-3(a^2+b^2)+1$ ។

**២៨៦.** រកពីរចំនួនគត់វិជ្ជមាន $a$ និង $b$ ដោយដឹងថា $a^2-b^2=24$ ។

**២៨៧.** ការេពីរមានផលដកក្រឡាផ្ទៃស្មើ $1152m^2$ និងមានផលដកប្រវែងជ្រុងស្មើ $16m$ ។ គណនាជ្រុងការេនីមួយៗ ។

**២៨៨.** គណនាកន្សោម $A=\dfrac{1}{(x-1)(x-2)}+\dfrac{2}{(2-x)(3-x)}+\dfrac{3}{(1-x)(x-3)}$ ។

**២៨៩.** រកមួយចំនួន ដោយដឹងថា បីដងនៃចំនួននេះ និងការេនៃចំនួនដដែលនេះ ជាចំនួនផ្ទុយគ្នា ។

**២៩០.** គេមានចំនួន $N=12345678910111213...998999$ ដែលចំនួននេះសរសេរពីលេខ $1$ ដល់លេខ $999$ ។
តើលេខប៉ុន្មាននៅត្រង់ទីតាំងតួទី $2011$ រាប់ពីខាងឆ្វេងដៃ ?

**២៩១.** គេឱ្យអនុគមន៍ $f$ កំណត់ $\forall x\in\Re-\{-1,0\}$ ដោយ $x(2x+1)f(x)+f\left(\dfrac{1}{x}\right)=x+1$ ។ ចូរគណនា ផលបូក
$S=f(1)+f(2)+f(3)+\ldots+f(2011)$ ។

**២៩២.** ប្រអប់មួយមានរាងជាប្រលេពីប៉ែតកែង មានវិមាត្រ $180mm$, $600mm$, $90mm$ ។ រកចំនួនគូបតិចបំផុតដែលអាចរៀបបំពេញក្នុងប្រអប់នេះ ។

**២៩៣.** ដោះស្រាយប្រព័ន្ធសមីការ $\begin{cases} 2x+2y=3xy \\ 6x+y=4xy \end{cases}$ ។

**២៩៤.** រកពីរចំនួនគត់ $a$ និង $b$ ដែល $a>b$ ។ បើគេដឹងថា ផលបូករបស់វាជាពហុគុណនៃ $15$ ហើយផលដកការេរបស់វាស្មើនឹង $45$ ។

**២៩៥.** $x,y,z$ ជាចំនួនសនិទានខុសពីសូន្យ ។ បើ $A=\dfrac{y}{z}+\dfrac{z}{y}$ , $B=\dfrac{z}{x}+\dfrac{x}{z}$ , $C=\dfrac{x}{y}+\dfrac{y}{x}$ ។ បង្ហាញថា តម្លៃនៃ $A^2+B^2+C^2-ABC$ មិនអាស្រ័យនឹង $x,y,z$ ។

**២៩៦.** យុវជនបីនាក់គឺ $A$, $B$, $C$ ធ្វើការរត់ប្រណាំងគ្នាចម្ងាយ $100\ m$ ។ ពេលរត់ប្រណាំងគេសង្កេតឃើញថា : ខណៈពេល $A$ រត់ដល់ទី $B$ នៅខ្វះ $10\ m$ ទៀត និងខណៈពេល $B$ រត់ដល់ទី $C$ នៅខ្វះ $10\ m$ ទៀត ។ គេសន្មត់ថាអ្នកទាំងបីរត់ក្នុងល្បឿនថេរ ។ សួរថា ខណៈពេលដែល $A$ រត់ដល់ទី តើ $C$ នៅចម្ងាយប៉ុន្មានម៉ែត្រ ពី $A$ ?

**២៩៧.** ដោះស្រាយប្រព័ន្ធសមីការ : $\begin{cases} -x+y+z=xyz \\ x-y+z=xyz \\ x+y-z=xyz \end{cases}$ ។

**២៩៨.** គេមាន $a,b,c$ ជាបីចំនួនខុសគ្នា ។ គណនាផលបូក $S=\dfrac{a}{(a-b)(a-c)}+\dfrac{b}{(b-c)(b-a)}+\dfrac{c}{(c-a)(c-b)}$ ។


www.facebook.com/7khmer
fb : Entertainment And Knowledge

**២៩៩.** រកគ្រប់បណ្តាគូនៃចំនួនគត់វិជ្ជមាន $(x\,,\,y)$ ផ្ទៀងផ្ទាត់សមីការ $x^2+x+13=y^2$ ។

**៣០០.** គេមានចំនួន $A=2^n\cdot5^{2n+1}$ ដែល $n$ ជាចំនួនគត់វិជ្ជមាន ។ តើចំនួន $A$ បញ្ចប់ដោយលេខសូន្យ (0) ប៉ុន្មាន ?

**៣០១.** គេឱ្យបីចំនួនវិជ្ជមាន $a\,,b\,,c$ ។ ដោះស្រាយសមីការ $\frac{x-a}{bc}+\frac{x-b}{ac}+\frac{x-c}{ab}=2\left(\frac{1}{a}+\frac{1}{b}+\frac{1}{c}\right)$ ។

**៣០២.** រកឬសគូបនៃ $Z=\left(8\,,\frac{\pi}{4}\right)$ ។

**៣០៣.** គេមានគូបចំនួន 7 មានទំហំប៉ុនៗគ្នា ហើយផ្គុំភ្ជាប់គ្នាបានដូចរូបសូលីតខាងស្តាំ : ដោយដឹងថាសូលីតនេះមានមាឌ $448cm^3$ ចូររកផ្ទៃក្រឡាទាំងអស់របស់សូលីតនេះ ។



**៣០៤.** គេមានត្រីកោណ $ABC$ មួយ និងមាន $[AM]$ ជាមេដ្យាន ។ បង្ហាញឱ្យឃើញថា $2AM<AB+AC$ ។

**៣០៥.** អ្នកបើកបរម្នាក់ចេញពីទីក្រុង $A$ ទៅទីក្រុង $B$ ដោយល្បឿនថេរជារាងរាល់ថ្ងៃ ។ គាត់ចាប់អារម្មណ៍ឃើញថា : បើគាត់បន្ថែមល្បឿន $3km/h$ នោះគាត់ទៅដល់គោលដៅ មុនពេលកំណត់ 1 ម៉ោង ។ តែបើគាត់បន្ថយល្បឿន $2km/h$ នោះគាត់ទៅដល់គោលដៅ ក្រោយពេលកំណត់ 1 ម៉ោងដែរ ។ គណនា រយៈពេលធម្មតា ល្បឿនធម្មតា និងចម្ងាយពីទីក្រុង $A$ ទៅទីក្រុង $B$ ។

**៣០៦.** មួយចំនួនមានផលគុណខ្លួនឯងស្មើនឹងផលបូកខ្លួនឯង ។ គណនាមួយចំនួននោះ ។

**៣០៧.** ក្នុងកិច្ចប្រជុំមួយមានមនុស្ស 10 នាក់ បានចូលរួម ហើយអ្នកទាំងនោះបានចាប់ដៃស្វាគមន៍គ្នាទៅវិញទៅមក ។ បើដឹងថាអ្នកទាំងអស់បានចាប់ដៃគ្នា គ្រប់ៗគ្នា ។ ចូររកចំនួននៃការចាប់ដៃគ្នាទាំងអស់ ។

**៣០៨.** ស្រាយបញ្ជាក់ថាចំនួន $2^9+3^9$ ចែកដាច់នឹង 35 ។

**៣០៩.** សម្រួលប្រភាគសនិទាន : $E=\frac{a^2-3ab+2b^2}{a^2-5ab+6b^2}$ ។

**៣១០.** ត្រីកោណមួយមានបរិមាត្រ $24\ cm$ ។ បើប្រវែងជ្រុងទាំងបីសមាមាត្ររៀងគ្នាគឺ $3:4:5$ ចូរគណនារង្វាស់ជ្រុងនីមួយៗរបស់វា ។

**៣១១.** ចំនួនគត់មួយមានលេខពីរខ្ទង់ ដែលមានផលបូកលេខតាមខ្ទង់ស្មើនឹង 9 ។ បើគេដូរខ្ទង់រាយទៅជាខ្ទង់ដប់វិញ នោះគេបានចំនួនថ្មីច្រើនជាងចំនួនចាស់ 63 ។ គណនាចំនួនគត់នោះ ។

**៣១២.** បរិមាត្រនៃប្រលេឡូក្រាម $ABCD$ មានរង្វាស់ស្មើ $48\ cm$ ។ រង្វាស់កម្ពស់នៃប្រលេឡូក្រាមសមាមាត្រ $5:7$ ។ គណនារង្វាស់ជ្រុងនៃប្រលេឡូក្រាម $ABCD$ ។

**៣១៣.** រកតម្លៃ $x$ ដែលធ្វើឱ្យកន្សោម $P=(x-1)(x+2)(x+3)(x+6)$ មានតម្លៃតូចបំផុត ? រកតម្លៃតូចបំផុតនោះ ។

**៣១៤.** មនុស្សមួយក្រុមឡើងជិះឡាន ។ បើម្នាក់អង្គុយកៅអីមួយ នោះនៅសល់មនុស្ស 4 នាក់គ្មានកន្លែងអង្គុយ ។ តែបើមនុស្សពីរនាក់ អង្គុយកៅអីមួយ នោះនៅសល់កៅអី 4 គ្មានមនុស្សអង្គុយ ។ រកចំនួនមនុស្ស និងចំនួនកៅអី ។

**៣១៥.** ផលបូកនៃពីរចំនួនស្មើនឹង 1 ។ បង្ហាញថាផលគុណវាតូចជាង ឬស្មើនឹង $\frac{1}{4}$ ។

**៣១៦.** ការេមួយមានក្រឡាផ្ទៃ $100\ cm^2$ ចារឹកក្នុងកន្លះរង្វង់មួយ ។ រកក្រឡាផ្ទៃនៃការេដែលចារឹកក្នុងរង្វង់ទាំងមូល ។


www.facebook.com/7khmer
fb : Entertainment And Knowledge

**៣១៧.** កំណត់តម្លៃនៃចំនួនពិត $a$ និង $b$ ដោយដឹងថា $a^2+b^2=0$ ។

**៣១៨.** ដោះស្រាយប្រព័ន្ធសមីការ : $\begin{cases} \frac{x}{2}=\frac{y}{3}=\frac{z}{4} \\ xy+yz+zx=26 \end{cases}$ ។

**៣១៩.** គណនាតម្លៃគត់កន្សោមលេខ : $E=\sqrt[3]{2+\sqrt{5}}+\sqrt[3]{2-\sqrt{5}}$ ។

**៣២០.** ពីរចំនួនមានផលបូកស្មើ12 និងមានផលគុណស្មើ4 ។ គណនាផលបូកច្រាសចំនួនទាំងពីរតាមពីររបៀបផ្សេងគ្នា ។

**៣២១.** បើ $x^2+3x+8$ ជាកត្តាមួយនៃកន្សោម $x^4+rx^2+s$ ចូរគណនារក $r$ និង $s$ ។

**៣២២.** គណនា $A=2\times4\times6\times...\times2n$ ។

**៣២៣.** គេមាន $S=(1+2)(1+2^2)(1+2^4)(1+2^8)\times...\times(1+2^{1024})$ ។ ចូរគណនា $\sqrt[1024]{S+1}$ ។

**៣២៤.** ដោយមិនប្រើម៉ាស៊ីនគិតលេខ ចូរគណនារកតម្លៃនៃ $A=\frac{2012}{1234568^2-1234567\times12345679}$ ។

**៣២៥.** រកចំនួនគត់វិជ្ជមាន $n$ ដើម្បីឱ្យ $4+n^4$ ជាចំនួនបឋម ។

**៣២៦.** រកលេខខាងចុងនៃផលគុណ $7^{2012}\times2013^{2010}\times7^{2000}\times2013^{2012}$ ។

**៣២៧.** គណនារកលេខខាងចុងនៃ $A$ ដែល $A=2012^{2013}$ ។

**៣២៨.** រកគ្រប់ចំនួនគត់វិជ្ជមាន $n$ ដែលធ្វើឱ្យ $2^n-1$ ចែកដាច់នឹង $7$ ។

**៣២៩.** បង្ហាញថា $12^{2012}-2^{2008}$ ចែកដាច់នឹង $10$ ។

**៣៣០.** គេមានចំនួន $A$ ដែល $A=n^5-n$ ។ បង្ហាញថា ចំពោះគ្រប់ចំនួនគត់វិជ្ជមាន $n$ នោះ $A$ ចែកដាច់នឹង $30$ ។

**៣៣១.** គេឱ្យ $f$ ជាអនុគមន៍ពហុធាកំណត់ដោយ $f(x)=x^3-3x$ ។ ចូរគណនា $f(x)$ ចំពោះ

$x=\sqrt[3]{\sqrt{3}+\sqrt{2}}+\sqrt[3]{\sqrt{3}-\sqrt{2}}$ ។

**៣៣២.** រកពីរចំនួនគត់វិជ្ជមាន $a$ និង $b$ ដែលមានផលបូកស្មើ $92$ និង $a+1$ ជាពហុគុណនៃ $b$ ។

**៣៣៣.** ចំពោះចំនួនគត់វិជ្ជមាន $n$, គេឱ្យ $P=(n+1)(n+2)(n+3)\times...\times(n+n)$ និង $P'=1\times3\times5\times...\times(2n-1)$ ។

បង្ហាញថា $P$ ចែកដាច់នឹង $P'$ និងរកផលចែករបស់វាផង ។

**៣៣៤.** គេឱ្យ $\overline{2a3}+326=\overline{5b9}$ ដែល $\overline{2a3}$ និង $\overline{5b9}$ ជាចំនួនមានលេខបីខ្ទង់ ។ បើ $\overline{5b9}$ ចែកដាច់នឹង $9$ គណនា $a+b$ ។

**៣៣៥.** ឧបមាថា $a^2+a=-1$ ចូរគណនាតម្លៃលេខនៃកន្សោម $A=a^4+2a^3+4a^2+3a+3$ ។

**៣៣៦.** គណនាកន្សោម $A$ ដោយឱ្យលទ្ធផលជាផលគុណបីកត្តា ដែល $A=\frac{\sqrt{2}-2}{\sqrt{12}+\sqrt{8}+3+\sqrt{6}}$ ។

**៣៣៧.** គណនាតម្លៃលេខនៃ $S=\frac{2^2+4^2+6^2+...+200^2}{3^2+6^2+9^2+...+300^2}$ ។

**៣៣៨.** ត្រីកោណកែងមួយមានអ៊ីប៉ូតេនុសស្មើ $13\,cm$ និងផលបូកជ្រុងពីរទៀតស្មើ $17\,cm$ ។ រករង្វាស់ជ្រុងមុំកែងទាំងពីរ ។

**៣៣៩.** ស្រាយបញ្ជាក់ថា : $3^{\sqrt{2}}>2^{\sqrt{3}}$ ។

**៣៤០.** បង្ហាញថា $A<6$ ដែល $A=\sqrt{6+\sqrt{6+\sqrt{6+...+\sqrt{6}}}}+\sqrt[3]{24+\sqrt[3]{24+\sqrt[3]{24+...+\sqrt[3]{24}}}}$ ។

**៣៤១.** ដោះស្រាយសមីការ : $\frac{x-4}{2008}+\frac{x-3}{2009}-\frac{x-2}{2010}-\frac{x-1}{2011}=0$ ។

**៣៤២.** រកបីចំនួនគត់វិជ្ជមានខុសគ្នា $x$ , $y$ និង $z$ ដែលផ្ទៀងផ្ទាត់ប្រព័ន្ធសមីការ $\begin{cases} x+y=6 \\ y+z=10 \end{cases}$ ។

**៣៤៣.** ដោះស្រាយសមីការ : $\sqrt{x+1}=x-1$ ។

**៣៤៤.** គេមានបន្ទាត់ពីរស្របគ្នាគឺ $(d)\parallel(l)$ ។

គណនាមុំ : $\angle x$ នៃរូបខាងស្តាំ ។




**៣៤៥.** គេមានត្រីកោណសម័ង្សពីរ គឺ $\Delta ABC$ និង $\Delta DEF$ ដែលមានរង្វាស់ជ្រុងស្មើ $3\ cm$ ដូចគ្នា ។ ត្រីកោណទាំងពីរផ្គុំគ្នាដូចរូបខាងស្តាំ បានត្រីកោណសម័ង្សតូចៗចំនួន ៦ ដែលមានរង្វាស់ជ្រុងស្មើ $1\ cm$ ដូចគ្នា ។ គណនាក្រឡាផ្ទៃនៃរូបខាងស្តាំ ។




**៣៤៦.** គេមានចំនួន $1, 2, 3, 4, 5, 6, 7, 8, 9$ ។ ចូរយកលេខទាំងនេះទៅបំពេញក្នុងប្រអប់ការេខាងស្តាំ ដើម្បីឱ្យផលបូកជួរដេក ស្មើផលបូកជួរឈរ ស្មើផលបូកអង្កត់ទ្រូង ស្មើនឹង 15 ។

| | | |
|---|---|---|
| | | |
| | | |
| | | |

**៣៤៧.** ត្រីកោណមួយមានរង្វាស់ជ្រុង $a$ , $b$ និង $c$ ដែលផ្ទៀងផ្ទាត់ $\frac{a}{24}=\frac{b}{18}=\frac{c}{12}$ ។

ក. គណនារង្វាស់ជ្រុងនៃត្រីកោណ បើគេដឹងថា $b+c=10\ cm$ ។

ខ. គណនារង្វាស់កម្ពស់នៃត្រីកោណ ដែលត្រូវនឹងជ្រុង $a$ ។

**៣៤៨.** ក្នុងថ្នាក់រៀនមួយគេរៀបសិស្សជាក្រុម ។ បើរៀបសិស្ស ៨ នាក់ក្នុងមួយក្រុម នៅសល់សិស្ស ៤ នាក់ទៀត ។ តែបើរៀបសិស្ស ៩ នាក់ក្នុងមួយក្រុម នោះនៅខ្វះសិស្ស ២ នាក់ទៀត ។ រកចំនួនសិស្សក្នុងថ្នាក់រៀននោះ ។

**៣៤៩.** រកមួយចំនួនបើដឹងថា ចំនួននោះមិនធំជាងពីរ ហើយក៏មិនតូចជាងពីរដែរ ។

**៣៥០.** រកមួយចំនួន ដែលមានផលបូកស្មើផលគុណនៃខ្លួនឯង ។

**៣៥១.** មធ្យមនៃពីរចំនួនស្មើ 2012 និងមធ្យមនៃបីចំនួនក៏ស្មើនឹង 2012 ដែរ ។ ចូររកចំនួនទី 3 ។

**៣៥២.** $x$ ជាចំនួនគត់វិជ្ជមាន មានលេខពីរខ្ទង់ ។ ចូរគណនា $x$ បើដឹងថា 44 ចែកដាច់នឹង $x$ សល់សំណល់ 10 ។

**៣៥៣.** ដោះស្រាយសមីការ $\overline{HE}^2=\overline{SHE}$ ។

**៣៥៤.** កំណត់តម្លៃ $a$ និង $b$ ដើម្បីឱ្យកន្សោម $ax^3+bx^2+54x+27$ អាចសរសេរជាគូបនៃទ្វេធាមួយបាន ។ រួចកំណត់ទ្វេធានោះ ។

**៣៥៥.** ត្រីកោណ $ABC$ កែងត្រង់ $A$ មានអ៊ីប៉ូតេនុស $BC=17cm$ និង $AB+AC=23cm$ ។ គណនា $AB$ និង $AC$ ។

**៣៥៦.** គេឱ្យប្រព័ន្ធសមីការ $\begin{cases} 3x+7y=m \\ 2x+5y=20 \end{cases}$ ។ កំណត់តម្លៃ $m$ ដើម្បីឱ្យគូចម្លើយនៃប្រព័ន្ធសមីការវិជ្ជមាន ។

**៣៥៧.** គណនាកាំរង្វង់នៃរូបខាងស្តាំ :




**៣៥៨.** គណនាចំនួនគត់ធម្មជាតិ $n$ ដែលធ្វើឱ្យចំនួន $n+13$ និងចំនួន $n-76$ ជាការេប្រាកដ ។



www.facebook.com/7khmer
fb : Entertainment And Knowledge

**៣៥៩.** គណនាតម្លៃមុំ $x$ គិតជាដឺក្រេ នៃរូបខាងស្តាំ :




**៣៦០.** ដោះស្រាយប្រព័ន្ធសមីការ ដែលមានសមីការនីមួយៗគឺ $\frac{2x^2}{1+x^2}=y\ (1)$ , $\frac{2y^2}{1+y^2}=z\ (2)$ , $\frac{2z^2}{1+z^2}=x\ (3)$ ។

**៣៦១.** ស្រាយបញ្ជាក់ឱ្យឃើញថា ផលបូកមុំក្នុងទាំងបីនៃត្រីកោណស្មើនឹង $180^o$ ។

**៣៦២.** ចូរស្រាយបញ្ជាក់ពីទ្រឹស្តីបទពីតាគ័រ ដែលថាក្នុងត្រីកោណកែង $a^2+b^2=c^2$ មាន $c$ ជាអ៊ីប៉ូតេនុស ។

**៣៦៣.** ចូររកចំនួនមួយដែលមានលេខបួនខ្ទង់គឺ $\overline{abca}$ ដោយដឹងថា $\overline{abca}=(5c+1)^2$ ។

**៣៦៤.** គេមានពីរចំនួន $a>b>0$ ។ បង្ហាញថា គ្រប់ចំនួនគត់ធម្មជាតិ $n$ នោះគេបាន $a^n>b^n$ ។

**៣៦៥.** គណនាផលគុណ $P=\frac{\sqrt{2}}{2}\times\frac{\sqrt{6}}{3}\times\frac{\sqrt{12}}{4}\times\ldots\times\frac{\sqrt{9900}}{100}$ ។

**៣៦៦.** ដាក់កន្សោម $P=(x-y)^3+(y-z)^3+(z-x)^3$ ជាផលគុណកត្តា ។

**៣៦៧.** គេឱ្យ $a>b>0$ ដែលផ្ទៀងផ្ទាត់លក្ខខណ្ឌ $3a^2+3b^2=10ab$ ។ គណនាតម្លៃនៃកន្សោម $P=\frac{a-b}{a+b}$ ។

**៣៦៨.** គេឱ្យកន្សោម $A=\frac{x-1}{x-3}$ ។ កំណត់តម្លៃ $x$ វិជ្ជមាន ដើម្បីឱ្យ $A$ ជាចំនួនគត់វិជ្ជមាន ។

**៣៦៩.** បង្ហាញថា បើ $a+b+c=0$ ហើយ $a\neq0\,,b\neq0\,,c\neq0$ នោះគេបាន $a^3+b^3+c^3=3abc$ ។

**៣៧០.** ដោះស្រាយសមីការ $(x+2012)^{2012}-x^{2012}=0$ ។

**៣៧១.** គណនាតម្លៃនៃកន្សោម $A=\left(x^4-x^3-x^2+2x-1\right)^{2012}$ ចំពោះ $x=\frac{2}{\frac{1}{\sqrt{\sqrt{2}+1}-1}-\frac{1}{\sqrt{\sqrt{2}+1}+1}}$ ។

**៣៧២.** សួនច្បារមួយមានរាងជាចតុកោណកែង ដែលមានផ្ទៃក្រឡា 720 $\text{m}^2$ ។ បើគេថែមបណ្តោយ 6m និងបន្ថយទទឹង 4m នោះផ្ទៃក្រឡារបស់សួន មិនមានការផ្លាស់ប្តូរទេ ។ គណនាវិមាត្រនៃសួនច្បារនោះ ។

**៣៧៣.** គេឱ្យពីរចំនួនដែលតូច ឬធំជាងគ្នា 3 ឯកតា ។ បើដឹងថាផលបូកការេនៃចំនួនទាំងពីរស្មើ 89 ចូររកចំនួនទាំងពីរ ។

**៣៧៤.** គណនាតម្លៃ $x\,,y$ ដែល $y\geq0$ ពីសមីការ : $x^2-4x+y-6\sqrt{y}+13=0$ ។

**៣៧៥.** ក. ប្រៀបធៀប $3-\sqrt{3}$ និង $\sqrt{6\left(2-\sqrt{3}\right)}$ ។

ខ. ប្រៀបធៀប $\frac{1}{4}\sqrt{48}$ និង $\sqrt[4]{7-4\sqrt{3}}\cdot\sqrt[4]{7+4\sqrt{3}}$ ។

**៣៧៦.** ដោះស្រាយសមីការ $(x-2)^4+(x-3)^4=1$ ។

**៣៧៧.** រកចំនួនដែលមានលេខពីរខ្ទង់ $\overline{AB}$ ដែលផ្ទៀងផ្ទាត់ $\overline{AB}^2-\overline{BA}^2=1980$ ។

**៣៧៨.** បើ $ab=4\,,ac=5\,,bc=20$ ។ គណនា $a\,,b\,,c$ ។

**៣៧៩.** គណនា $A=\left(2025-1^2\right)\left(2025-2^2\right)\left(2025-3^2\right)\times\ldots\times\left(2025-50^2\right)$ ។

**៣៨០.** តើចំនួន $P=1\times2\times3\times\ldots\times100$ បញ្ចប់ដោយលេខសូន្យចំនួនប៉ុន្មានខ្ទង់ ?



www.facebook.com/7khmer
fb : Entertainment And Knowledge

**៣៨១.** តើចំនួន 2012! មានលេខសូន្យនៅខាងចុងប៉ុន្មាន ?

**៣៨២.** គណនា $N=\sqrt{4+\sqrt{15}}+\sqrt{4-\sqrt{15}}-2\sqrt{3-\sqrt{5}}$ ។

**៣៨៣.** ក្នុងថង់មួយមានឃ្លីពណ៌ស និងឃ្លីពណ៌ខ្មៅចំនួន 12 គ្រាប់ ។ រកចំនួនឃ្លី ស ដើម្បីឱ្យប្រូបាប នៃឃ្លីខ្មៅស្មើ $\frac{1}{3}$ ។

**៣៨៤.** គេឱ្យ $\Delta ABC$ ដែលមានមេដ្យាន $AM$ , $BN$ និង $CP$ ។

ក. ស្រាយបំភ្លឺថា $AM+BN+CP<AB+BC+AC$ ។

ខ. ស្រាយបំភ្លឺថា $AM+BN+CP>\dfrac{AB+BC+AC}{2}$ ។

**៣៨៥.** គេឱ្យបីចំនួនគត់រ៉ឺឡាទីបតគ្នា $a$ , $b$ , $c$ ដែល $a<b<c$ ។

ក. គណនាផលបូក $S=a+b+c$ ជាអនុគមន៍នៃ $b$ ។

ខ. ទាញរកតម្លៃនៃ $a$ , $b$ , $c$ ដោយដឹងថា $S=-333$ ។

**៣៨៦.** កុកមួយហើរជួបក្រសាមួយហ្វូងក៏ស្រែកសួរថា "សួស្តីមិត្តទាំង 100 "។ មេខ្យល់នៃហ្វូងក្រសាបានឆ្លើយតបវិញថា "ទេចំនួនពួកយើងមិនគ្រប់ 100 ទេ" ។ ចំនួនពួកយើងបូកចំនួនពួកយើង បន្ថែមពាក់កណ្ដាលនៃចំនួនពួកយើង ហើយថែម $\frac{1}{4}$ នៃពួកយើង ព្រមទាំងមិត្តឯងទៀតទើបគ្រប់ 100 ។ ចូររកចំនួនក្រសាក្នុងហ្វូងទាំងអស់ ។

**៣៨៧.** ដោះស្រាយប្រព័ន្ធសមីការ $\begin{cases} x^2+y^2+z^2=xy+yz+xz \\ x^{2011}+y^{2011}+z^{2011}=3^{2012} \end{cases}$ ។

**៣៨៨.** បរិមាត្រនៃត្រីកោណ $ABC$ មួយមានរង្វាស់ស្មើ 80 cm ។ បើជ្រុងទាំងបីមានសមាមាត្ររៀងគ្នា 5 , 7 , 4 ។ ចូរគណនារង្វាស់ជ្រុងនីមួយៗ ។

**៣៨៩.** គេឱ្យ $\frac{1}{a}+\frac{1}{b}+\frac{1}{c}=0$ ។ គណនាតម្លៃនៃកន្សោម $P=\frac{ab}{c^2}+\frac{bc}{a^2}+\frac{ac}{b^2}$ ។

**៣៩០.** ដោះស្រាយប្រព័ន្ធសមីការ $\begin{cases} \sqrt{x+3}-2\sqrt{y+1}=2 \\ 2\sqrt{x+3}-\sqrt{y+1}=4 \end{cases}$ ។

**៣៩១.** គេមាន $a>1$ , $b>1$ និង $a>b$ ។ ចូរប្រៀបធៀប $\frac{a-1}{b-1}$ , $\frac{a}{b}$ និង $\frac{a+1}{b+1}$ ។

**៣៩២.** ប្រៀបធៀប $A=\sqrt[3]{5\sqrt{2}+7}-\sqrt[3]{5\sqrt{2}-7}$ និង $B=\sqrt{51+10\sqrt{2}}-\sqrt{51-10\sqrt{2}}$ ។

**៣៩៣.** ដោះស្រាយសមីការ $\frac{1+x}{x}+\frac{2+x}{x}+\frac{3+x}{x}+\ldots+\frac{2013+x}{x}=0$ ។

**៣៩៤.** ក. ដាក់ជាផលគុណកត្តានូវសមភាព $\frac{1}{a}+\frac{1}{b}+\frac{1}{c}=\frac{1}{a+b+c}$ ។

ខ. បង្ហាញថាបីចំនួនពិតមិនសូន្យ $a$ , $b$ , $c$ ហើយមានពីរចំនួនផ្ទុយគ្នាមួយយ៉ាងតិចក្នុងចំណោម $a$ , $b$ , $c$ នោះ គេបានទំនាក់ទំនង $\frac{1}{a}+\frac{1}{b}+\frac{1}{c}=\frac{1}{a+b+c}$ ។

**៣៩៥.** ដោះស្រាយសមីការ $3^{2+x}+3^{2-x}=30$ ។

**៣៩៦.** សម្រួលប្រភាគ $A=\dfrac{|x-1|+|x|+x}{3x^2-4x+1}$ ដោយ $x<0$ ។



www.facebook.com/7khmer
fb : Entertainment And Knowledge

**៣៩៧.** ដោះស្រាយប្រព័ន្ធសមីការ $\begin{cases} \dfrac{x+y}{xyz}=\dfrac{1}{2} \\ \dfrac{y+z}{xyz}=\dfrac{5}{6} \\ \dfrac{x+z}{xyz}=\dfrac{2}{3} \end{cases}$ ។

**៣៩៨.** ត្រីកោណកែងមួយមានរង្វាស់ជ្រុង ជាបីចំនួនគូតគ្នា ។ គណនាបរិមាត្រ និងក្រឡាផ្ទៃរបស់ត្រីកោណនេះ ។

**៣៩៩.** សម្រួលកន្សោម $F=\dfrac{x^2-1}{|x-1|}$ ។

**៤០០.** គណនាចម្ងាយពីចំណុច $A(6\,,6)$ ទៅបន្ទាត់ $(D): y=-x+4$ ក្នុងតម្រុយអរតូណរមេ ។

**៤០១.**

**៤០២.** ដាក់កន្សោម $(x+1)(x+3)(x+5)(x+7)+24$ ជាផលគុណកត្តា ។

**៤០៣.** គេមានបីចំនួន $a\,,b\,,c$ ផ្ទៀងផ្ទាត់ទំនាក់ទំនង $a^2+b^2+c^2=1$ និង $a^3+b^3+c^3=1$ ។

ស្រាយបញ្ជាក់ឱ្យឃើញថា : $a+b^2+c^3=1$ ។

**៤០៤.** គេឱ្យ $ax+by+cz=0$ និង $a+b+c=\dfrac{1}{2005}$ ។ គណនា $A=\dfrac{ax^2+by^2+cz^2}{bc(y-z)^2+ac(x-z)^2+ab(x-y)^2}$ ។

**៤០៥.** ចូរកំណត់តម្លៃ $x$ និង $y$ ដើម្បីឱ្យចំនួន $N=\overline{3x82y}$ ចែកដាច់នឹង $3$ផង និងចែកដាច់នឹង $11$ផង ។

**៤០៦.** គេមានចំនួន $A=2^{2004}$ ។ ចូររកលេខ : ក. មួយខ្ទង់ខាងចុង ខ. ពីរខ្ទង់ខាងចុង គ. បីខ្ទង់ខាងចុង ។

**៤០៧.** គណនាផលបូក $S_n=\dfrac{1}{10}+\dfrac{2}{10^2}+\dfrac{3}{10^3}+...+\dfrac{n}{10^n}$ ។

**៤០៨.** ដោះស្រាយប្រព័ន្ធសមីការ : $\begin{cases} (3x+y)^{x-y}=9 \\ \sqrt[x-y]{324}=18x^2+12xy+2y^2 \end{cases}$ ។

**៤០៩.** គេឱ្យ $a$ ជាចំនួនគត់ធម្មជាតិ ។ បង្ហាញថា $\forall n\in\aleph\,,\ (a+1)^{n+1}-a(n+1)-1$ ជាពហុគុណនៃ $a^2$ ។

**៤១០.** ដាក់កន្សោមខាងស្តាំជាផលគុណកត្តាដឺក្រេទី1 : $(a^2-4b^2)+2(a^3+2a^3)x+a^4-b^4=0$ ។

**៤១១.** ស្រាយបញ្ជាក់ថា $4a^4-4a^3+5a^2-4a+1\geq 0$ , $a$ ជាចំនួនពិត ។

**៤១២.** គេឱ្យសមីការ $(x+a+b)(x+b+c)(x+c+a)(a+b+c)=abcx$ ។ ដោះស្រាយសមីការបើ $a=2,b=3,c=4$ ។

**៤១៣.** គេឱ្យ $x\,,y\,,z$ ជាបីចំនួនវិជ្ជមានមិនសូន្យ ។ ចូរបង្ហាញថា $\dfrac{1}{x^2}+\dfrac{1}{y^2}+\dfrac{1}{z^2}\geq\dfrac{9}{x^2+y^2+z^2}$ ។

**៤១៤.** នៅក្នុងតម្រុយអរតូណរមេគេឱ្យបីចំណុច $A(1,2),B(2,3),C(3,4)$ ។ បន្ទាត់ $(D)$ និង $(L)$ កាត់តាម $C$ ។

ក. សរសេរសមីកាបន្ទាត់$(AB)$ ខ. រកសមីការបន្ទាត់ $(D)$ ស្របនឹង $(AB)$ គ. រកបន្ទាត់ $(L)$ កែងនឹង$(AB)$ ។

**៤១៥.** ដោះស្រាយសមីការ $\dfrac{x+1}{x^2+2x}+\dfrac{x+6}{x^2+12x+35}=\dfrac{x+2}{x^2+4x+3}+\dfrac{x+5}{x^2+10x+24}$ ។

**៤១៦.** ដោះស្រាយសមីការ $(24x-1)(12x-1)(8x-1)(6x-1)=330$ ។

**៤១៧.** ដោះស្រាយសមីការ $(x^2+3x-4)^3+(2x^2-5x+3)^3=(3x^2-2x-1)^3$ ។

**៤១៨.** បង្ហាញថា $\frac{1}{15}<\frac{1}{2}\times\frac{3}{4}\times\frac{5}{6}\times\ldots\times\frac{99}{100}<\frac{1}{10}$ ។

**៤១៩.** ដាក់ជាផលគុណកត្តានូវសមីការ $16x^5-20x^3+5x+1=0$ បើគេដឹងថា $(-1)$ ជាឬសនៃសមីការនេះ ។

**៤២០.** បើ $a\neq0\,,b\neq0\,,c\neq0$ ដែល $a>b>c$ ។ ចូរស្រាយបំភ្លឺថា $\frac{1}{a}<\frac{ab+bc+ca}{3abc}$ ។

**៤២១.** រកបីចំនួនគត់រ៉ឺឡាទីប $a\,,b\,,c$ ដោយដឹងថា ចំពោះគ្រប់តម្លៃ $x$ គេបាន : $(x-a)(x-10)+1=(x+b)(x+c)$ ។

**៤២២.** ដោះស្រាយប្រព័ន្ធសមីការ $\begin{cases}x_1+x_2+x_3+\ldots+x_{2000}=1\\x_1+x_3+x_4+\ldots+x_{2000}=2\\x_1+x_2+x_4+\ldots+x_{2000}=3\\\ldots\ldots\ldots\ldots\ldots\ldots\\x_1+x_2+x_3+\ldots+x_{1999}=2000\end{cases}$ ដែលមានចំនួន 2000 សមីការ ។

**៤២៣.** ដោះស្រាយសមីការ $(x+1)(x+2)(x+3)(x+4)=3$ ។

**៤២៤.** គេមានចតុកោណព្នាយ $ABCD$ មួយមានបាត $AB=80\ cm\,,CD=40\ cm$ ។ គណនាផ្ទៃក្រឡានៃចតុកោណព្នាយនេះ បើដឹងថាជ្រុង $AD=68\ cm$ និង $AC=84\ cm$ ។

**៤២៥.** ថ្នាក់ទី 9C មានសិស្សបីប្រភេទគឺ ពូកែ មធ្យម ខ្សោយ ។ នៅដើមឆ្នាំចំនួនសិស្សសមាមាត្រនឹង 3 , 4 , 7 លុះដល់ចុងឆ្នាំចំនួនសិស្សសមាមាត្រនឹង 2 , 5 , 7 ។ បើដឹងថាចុងឆ្នាំសិស្សខ្សោយថយចុះ 10 នាក់ ចូររកចំនួនសិស្សសរុប ។

**៤២៦.** គេឱ្យ $\frac{a}{x}=\frac{b}{y}=\frac{c}{z}=k^2$ ដែល $k$ ជាចំនួនគត់ធម្មជាតិ ។ បង្ហាញថា $\sqrt{ax}+\sqrt{by}+\sqrt{cz}=\sqrt{(a+b+c)(x+y+z)}$ ។

**៤២៧.** ក. រកបីចំនួនគត់សេសតគ្នា បើផលបូកចំនួនទាំងបីស្មើនឹង 909 ។

ខ. រកបួនចំនួនគត់គូតគ្នា បើដឹងថាផលបូកចំនួនទាំងបួនស្មើនឹង 1028 ។

**៤២៨.** ដោះស្រាយសមីការ $\overline{0.17}\div2.\overline{3}=x\div0.\overline{3}$ ។

**៤២៩.** ខ្យងមួយនៅក្នុងអណ្តូងលូ មានជម្រៅ 7m ។ពេលយប់ខ្យងនេះវារឡើងលើបាន 3m តែនៅពេលថ្ងៃក្រោមអំណាចនៃកម្តៅវាធ្លាក់ចុះ 1m វិញ ។ ឧបមាថា ខ្យងព្យាយាមវារឡើងរហូត តើប៉ុន្មានថ្ងៃទើបខ្យងចេញរួចពីអណ្តូង ។

**៤៣០.** នៅម៉ោង 6:30 mn នារីមួយក្រុមចាប់ផ្តើមស្ទូងស្រូវពីភ្លឺម្ខាង ទៅភ្លឺម្ខាងទៀត ដែលមានចម្ងាយ 100m ដោយល្បឿន 30m/h ហើយបុរសមួយក្រុមទៀតចាប់ផ្តើមស្ទូងពីភ្លឺម្ខាងដោយល្បឿន 20m/h ។

ក.តើក្រុមទាំងពីរស្ទូងជួបគ្នានៅម៉ោងប៉ុន្មាន ?

ខ. តើមួយក្រុមៗស្ទូងបានប្រវែងប៉ុន្មាន m ?

**៤៣១.** គណនាកន្សោម $F=\sqrt{x+2+3\sqrt{2x-5}}+\sqrt{x-2-3\sqrt{2x-5}}$ ។

**៤៣២.** គេមានការេ $ABCD$ និងចំណុច $K$ នៅលើអង្កត់ទ្រូង $AC$ ។ បង្ហាញថា $KA^2+KC^2=2KD^2$ ។

**៤៣៣.** គណនាកន្សោម $x^4+\frac{1}{y^4}$ បើដឹងថា $\left(x+\frac{1}{y}\right)^4=1296$ និង $\frac{x}{y}=4$ ។

**៤៣៤.** ដោះស្រាយប្រព័ន្ធសមីការ $\begin{cases}ab=8\\\sqrt[3]{a}+\sqrt[3]{b}=3\end{cases}$ ។


www.facebook.com/7khmer
fb : Entertainment And Knowledge

**៤៣៥.** គេឱ្យត្រីកោណសមបាត $COB$ ដែលមានបាត $OB$ និងកម្ពស់ $OA$ ។ ស្រាយថា $AC^2+OB^2=AB^2+OC^2$ ។

**៤៣៦.** $ABC$ ជាត្រីកោណកែងត្រង់កំពូល $A$ មានបរិមាត្រស្មើ $12\ cm$ និងមានក្រឡាផ្ទៃស្មើ $6\ cm^2$ ។ គណនារង្វាស់ជ្រុងនីមួយៗ នៃត្រីកោណកែង $ABC$ នេះ ។

**៤៣៧.** រកចំនួនគត់ដែលនៅចន្លោះ 40 និង 50 ដោយដឹងថា បើគេប្តូរលំដាប់លេខ នោះគេនឹងបានជួបចំនួនថ្មីមួយទៀតដែលស្មើនឹង $\frac{32}{23}$ នៃចំនួននោះ ។

**៤៣៨.** តាមចំណុច O ក្នុងត្រីកោណសម័ង្ស ABC គេគូសអង្កត់កែងទៅនឹងជ្រុងទាំងបីនៃត្រីកោណនោះ ។ បង្ហាញថាផលបូកចម្ងាយពីចំណុច O ទៅជ្រុងទាំងបីស្មើនឹងរង្វាស់កម្ពស់នៃត្រីកោណនោះ ។

**៤៣៩.** បំបាត់រ៉ាឌីកាល់ពីភាគបែង $A=\dfrac{20}{3+\sqrt{5}+\sqrt{2+2\sqrt{5}}}$ ។

**៤៤០.** ដោះស្រាយប្រព័ន្ធសមីការ $\begin{cases} x+y=-3 \\ x+z=-2 \\ xy+yz+zx=2 \end{cases}$ ។

**៤៤១.** គេឱ្យត្រីកោណ $ABC$ មានរង្វាស់ជ្រុង $a$ , $b$ , $c$ និងត្រីកោណ $A'B'C'$ មានរង្វាស់ជ្រុង $a'$ , $b'$ , $c'$ ។ ឧបមាថា $\Delta ABC$ ដូចនឹង $\Delta A'B'C'$ បង្ហាញថា $\sqrt{aa'}+\sqrt{bb'}+\sqrt{cc'}=\sqrt{(a+b+c)(a'+b'+c')}$ ។

**៤៤២.** $ABC$ ជាត្រីកោណកែងត្រង់ $A$ ដែលមាន $BC=2a$ និង $\angle B=60^o$ ។ កំណត់តម្លៃ $a$ ដើម្បីឱ្យតម្លៃបរិមាត្រស្មើនឹងតម្លៃផ្ទៃក្រឡា ។

**៤៤៣.** នៅមានលំហាត់បន្តជាច្រើនទៀត... ។

## ១. រកគ្រប់គូនៃចំនួនគត់វិជ្ជមាននៃ $a$ , $b$

យើងមាន : $a^2+b^2=a+b+8$

យើងបាន : $4a^2+4b^2=4a+4b+32$

$4a^2-4a+1+4b^2-4b+1=34$

$(2a-1)^2+(2b-1)^2=34$

ដោយ $34<36=6^2$ ហើយ $2a-1$ និង $2b-1$ ជាចំនួនសេស

នោះ 34 ជាផលបូកការេចំនួនសេសតូចជាង 6 ។

ចំនួនសេសតូចជាង 6 មាន 1,3,5

មានតែ $3^2+5^2=34$ ឬ $5^2+3^2=34$ យើងបាន :

- $2a-1=3$ និង $2b-1=5$ នោះ $a=2\,,b=3$ ឬ
- $2a-1=5$ និង $2b-1=3$ នោះ $a=3\,,b=2$

ដូចនេះ គូចំនួនផ្ទៀងផ្ទាត់គឺ : $\begin{cases} a=2\,,b=3 \\ a=3\,,b=2 \end{cases}$ ។

## ២. ស្រាយបញ្ជាក់ថា E ជាការេប្រាកដ

យើងមាន :

$$E=(x+1000)(x+2000)(x+3000)(x+4000)+1000^4$$

តាង $y=1000$ យើងបាន :

$$E=(x+y)(x+2y)(x+3y)(x+4y)+y^4$$
$$=(x+y)(x+4y)(x+2y)(x+3y)+y^4$$
$$=(x^2+4xy+xy+4y^2)(x^2+3xy+2xy+6y^2)+y^4$$
$$=(x^2+5xy+4y^2)(x^2+5xy+6y^2)+y^4$$
$$=(x^2+5xy+5y^2-y^2)(x^2+5xy+5y^2+y^2)+y^4$$
$$=\left[(x^2+5xy+5y^2)^2-y^4\right]+y^4$$
$$=(x^2+5xy+5y^2)^2$$

ដូចនេះ $E=(x^2+5xy+5y^2)^2$ ជាការេប្រាកដ ។

## ៣. រកលេខនៅខ្ទង់រាយនៃចំនួន $A$ :

យើងមាន $A=3^{2011}\cdot7^{2012}+3^{2013}\cdot7^{2014}$

- ពិនិត្យលេខចុងស្វ័យគុណនៃ 3 :

$3^1=3$ , $3^2=9$ , $3^3=27$ , $3^4=81$

$3^5=243$ , $3^6=729$ , $3^7=2187$ , $3\ \ =6561$ , ...

យើងទាញបានទូទៅ ស្វ័យគុណនៃ3 : យើងមាន $3^{4k+A}, k\in N$

-បើ $A=0$ នោះលេខចុងនៃ$3^{4k+A}$ គឺ : 1

-បើ $A=1$ នោះលេខចុងនៃ$3^{4k+A}$ គឺ : 3

-បើ $A=2$ នោះលេខចុងនៃ$3^{4k+A}$ គឺ : 9

-បើ $A=3$ នោះលេខចុងនៃ$3^{4k+A}$ គឺ : 7

នាំឱ្យ $3^{2011}=3^{4\cdot502+3}$ មានលេខចុង 7

$3^{2013}=3^{4\cdot503+1}$ មានលេខចុង 3

- ពិនិត្យលេខចុងស្វ័យគុណនៃ 7 :

$7^1=7$ , $7^2=49$ , $7^3=343$ , $7^4=2401$

$7^5=16807$ , $7^6=...9$ , $7^7=...3$ , $7^8=...1$ , ...

យើងទាញបានទូទៅ ស្វ័យគុណនៃ7 : យើងមាន $7^{4k+A}, k\in N$

-បើ $A=0$ នោះលេខខាងចុងនៃ$3^{4k+A}$ គឺ : 1

-បើ $A=1$ នោះលេខខាងចុងនៃ$3^{4k+A}$ គឺ : 7

-បើ $A=2$ នោះលេខខាងចុងនៃ$3^{4k+A}$ គឺ : 9

-បើ $A=3$ នោះលេខខាងចុងនៃ$3^{4k+A}$ គឺ : 3

នាំឱ្យ $7^{2012}=7^{4\cdot503+0}$ មានលេខចុង 1

$7^{2014}=7^{4\cdot503+2}$ មានលេខចុង 9

យើងបាន :

លេខចុង $A$ =លេខចុង7 $\times$ លេខចុង1 + លេខចុង 3 $\times$ លេខចុង 9

= លេខចុង7 + លេខចុង7

= លេខចុង 4

ដូចនេះ ចំនួន $A$ មានលេខ 4 នៅខាងចុង ។

## ៤. គណនាកន្សោម $P$ :

យើងមានកន្សោម

$$P=\frac{\sqrt{3-2\sqrt2}}{\sqrt{17-12\sqrt2}}-\frac{\sqrt{3+2\sqrt2}}{\sqrt{17+12\sqrt2}}$$
$$=\frac{\sqrt{2-2\sqrt2+1}}{\sqrt{9-12\sqrt2+8}}-\frac{\sqrt{2+2\sqrt2+1}}{\sqrt{9+12\sqrt2+8}}$$
$$=\frac{\sqrt{\sqrt2^2-2\sqrt2+1^2}}{\sqrt{3^2-12\sqrt2+(2\sqrt2)^2}}-\frac{\sqrt{\sqrt2^2+2\sqrt2+1^2}}{\sqrt{3^2+12\sqrt2+(2\sqrt2)^2}}$$
$$=\frac{\sqrt{(\sqrt2-1)^2}}{\sqrt{(3-2\sqrt2)^2}}-\frac{\sqrt{(\sqrt2+1)^2}}{\sqrt{(3+2\sqrt2)^2}}$$
$$=\frac{\sqrt2-1}{3-2\sqrt2}-\frac{\sqrt2+1}{3+2\sqrt2}$$
$$=\frac{(\sqrt2-1)(3+2\sqrt2)-(\sqrt2+1)(3-2\sqrt2)}{3^2-(2\sqrt2)^2}$$
$$=3\sqrt2+4-3-2\sqrt2-3\sqrt2+4-3+2\sqrt2=2$$

ដូចនេះ កន្សោម $P=2$ ។



www.facebook.com/7khmer
fb : Entertainment And Knowledge

**៥. គណនាតម្លៃ $x$ ដើម្បីឱ្យ $F$ មានតម្លៃអប្បបរមា**

យើងមាន :

$$
\begin{aligned}
F &= (x-1)(x+2)(x+3)(x+6) \\
&= (x-1)(x+6)(x+2)(x+3) \\
&= (x^2+6x-x-6)(x^2+3x+2x+6) \\
&= (x^2+5x-6)(x^2+5x+6) \\
&= (x^2+5x)^2-36
\end{aligned}
$$

ដោយ $(x^2+5x)^2 \geq 0$ នោះ $(x^2+5x)^2-36 \geq -36$

នាំឱ្យ $F$ មានតម្លៃអប្បបរមាគឺ $F=-36$

យើងបាន $(x^2+5x)^2-36=-36$

$$
\begin{aligned}
(x^2+5x)^2 &= 0 \\
x^2+5x &= 0 \\
x(x+5) &= 0
\end{aligned}
$$

នាំឱ្យ $x=0$ , $x=-5$

ដូចនេះ តម្លៃគណនាបានគឺ $\boxed{x=0\ ,\ x=-5}$ ។

**៦. គណនាតម្លៃនៃ $x^2+y^2$ :**

យើងមាន : $x+y=30$

$$
\begin{aligned}
(x+y)^3 &= 30^3 \\
x^3+3x^2y+3xy^2+y^3 &= 27000 \\
x^3+y^3+3xy(x+y) &= 27000
\end{aligned}
$$

ដោយ $x^3+y^3=8100$ និង $x+y=30$

យើងបាន : $8100+3xy\cdot 30=27000$

$$
\begin{aligned}
90xy &= 27000-8100 \\
xy &= \frac{18900}{90}=210
\end{aligned}
$$

តែ $x^3+y^3=(x+y)(x^2-xy+y^2)$

$$
\begin{aligned}
8100 &= 30(x^2-210+y^2) \\
(x^2-210+y^2) &= 270 \\
x^2+y^2 &= 270+210 \\
x^2+y^2 &= 480
\end{aligned}
$$

ដូចនេះ តម្លៃគណនាបានគឺ : $\boxed{x^2+y^2=480}$ ។

**៧. ស្រាយបញ្ជាក់ថា :** $\frac{1}{1\cdot 2}+\frac{1}{2\cdot 3}+\frac{1}{3\cdot 4}+\ldots+\frac{1}{n\cdot(n+1)}<1$

ពិនិត្យ : $\frac{1}{n}-\frac{1}{n+1}=\frac{n+1-n}{n(n+1)}=\frac{1}{n(n+1)}$

តាមលំនាំខាងលើគេអាចបំបែកបាន ដូចខាងក្រោម :

បូកអង្គនឹងអង្គ
$$
\begin{cases}
\frac{1}{1\cdot 2}=\frac{1}{1}-\frac{1}{2} \\
\frac{1}{2\cdot 3}=\frac{1}{2}-\frac{1}{3} \\
\frac{1}{3\cdot 4}=\frac{1}{3}-\frac{1}{4} \\
\ldots\ldots\ldots\ldots\ldots\ldots\ldots \\
\frac{1}{n\cdot(n+1)}=\frac{1}{n}-\frac{1}{n+1}
\end{cases}
$$

$$\frac{1}{1\cdot 2}+\frac{1}{2\cdot 3}+\frac{1}{3\cdot 4}+\ldots+\frac{1}{n\cdot(n+1)}=\frac{1}{1}-\frac{1}{n+1}$$

ឬ $\frac{1}{1\cdot 2}+\frac{1}{2\cdot 3}+\frac{1}{3\cdot 4}+\ldots+\frac{1}{n\cdot(n+1)}=\frac{n}{n+1}$

ចំពោះ $n$ ជាចំនួនគត់វិជ្ជមានហើយធំជាង1

គេបាន $n<n+1$ ឬ $\frac{n}{n+1}<1$

នាំឱ្យ $\frac{1}{1\cdot 2}+\frac{1}{2\cdot 3}+\frac{1}{3\cdot 4}+\ldots+\frac{1}{n\cdot(n+1)}<1$

ដូចនេះ $\boxed{\frac{1}{1\cdot 2}+\frac{1}{2\cdot 3}+\frac{1}{3\cdot 4}+\ldots+\frac{1}{n\cdot(n+1)}<1}$ ។

**៨. ក. រកសំណល់បើ $n$ ចែកនឹង** 56

សម្មតិកម្ម : $n$ ចែកនឹង 7 ឱ្យសំណល់ 5

បើតាង $q_1\in\aleph$ ជាផលចែក នោះគេបាន $n=7q_1+5$

$n$ ចែកនឹង 8 ឱ្យសំណល់ 3

បើតាង $q_2\in\aleph$ ជាផលចែក នោះគេបាន $n=8q_2+3$

យើងបានប្រព័ន្ធសមីការ $\begin{cases} n=7q_1+5 & \times 8 \\ n=8q_2+3 & \times 7 \end{cases}$

ដកអង្គនឹងអង្គ
$$
-\begin{cases} 8n=56q_1+40 \\ 7n=56q_2+21 \end{cases}
$$
$$n=56(q_1-q_2)+19$$

បើតាង $q$ ជាចំនួនគត់ធម្មជាតិ ដែល $q=q_1-q_2$

យើងបាន $n=56q+19$

ដូចនេះ $\boxed{\text{តម្លៃសំណល់ដែល } n \text{ ចែកនឹង 56 គឺ 19}}$ ។

**ខ. រកចំនួន $n$ : ដោយ** $5616<n<5626$

នាំឱ្យ $5616<56q+19<5626$

$$
\begin{aligned}
5597 &< 56q < 5607 \\
99.946 &< q < 100.125
\end{aligned}
$$



www.facebook.com/7khmer
fb : Entertainment And Knowledge

ដោយ $q$ ជាចំនួនគត់ធម្មជាតិ នោះ $q=100$

យើងបាន $n=56\cdot100+19=5619$

ដូចនេះ | ចំនួន $n$ ដែលរកបានគឺ : $n=5619$ | ។

**៩. បង្ហាញថា** $A=\frac{1}{a_1}+\frac{1}{a_2}+\frac{1}{a_3}+...+\frac{1}{a_{20}}$ **ជាចំនួនគត់**

យើងមាន : $a_n=\sqrt{1+\left(1+\frac{1}{n}\right)^2}+\sqrt{1+\left(1-\frac{1}{n}\right)^2}$ នាំឱ្យ

$$\frac{1}{a_n}=\frac{1}{\sqrt{1+\left(1+\frac{1}{n}\right)^2}+\sqrt{1+\left(1-\frac{1}{n}\right)^2}}$$

$$=\frac{\sqrt{1+\left(1+\frac{1}{n}\right)^2}-\sqrt{1+\left(1-\frac{1}{n}\right)^2}}{1+\left(1+\frac{1}{n}\right)^2-1-\left(1-\frac{1}{n}\right)^2}$$

$$=\frac{\sqrt{1+\left(1^2+2\cdot1\cdot\frac{1}{n}+\left(\frac{1}{n}\right)^2\right)}-\sqrt{1+\left(1^2-2\cdot1\cdot\frac{1}{n}+\left(\frac{1}{n}\right)^2\right)}}{1^2+2\cdot1\cdot\frac{1}{n}+\left(\frac{1}{n}\right)^2-\left(1^2-2\cdot1\cdot\frac{1}{n}+\left(\frac{1}{n}\right)^2\right)}$$

$$=\frac{\sqrt{\frac{2n^2+2n+1}{n^2}}-\sqrt{\frac{2n^2-2n+1}{n^2}}}{\frac{4}{n}}$$

$$=\frac{n}{4}\cdot\left(\sqrt{\frac{2n^2+2n+1}{n^2}}-\sqrt{\frac{2n^2-2n+1}{n^2}}\right)$$

$$=\frac{1}{4}\left(\sqrt{2n^2+2n+1}-\sqrt{2n^2-2n+1}\right)$$

យើងបាន :

$$+\begin{cases}\frac{1}{a_1}=\frac{1}{4}\left(\sqrt{5}-\sqrt{1}\right)\\ \frac{1}{a_2}=\frac{1}{4}\left(\sqrt{13}-\sqrt{5}\right)\\ \frac{1}{a_3}=\frac{1}{4}\left(\sqrt{25}-\sqrt{13}\right)\\ \dots\dots\dots\dots\\ \frac{1}{a_{20}}=\frac{1}{4}\left(\sqrt{841}-\sqrt{761}\right)\end{cases}$$

$$\frac{1}{a_1}+\frac{1}{a_2}+\frac{1}{a_3}+...+\frac{1}{a_{20}}=\frac{1}{4}\left(\sqrt{841}-\sqrt{1}\right)$$

$$=\frac{1}{4}(29-1)=7$$

ដូចនេះ | គណនាបាន $A=7$ ជាចំនួនគត់ | ។

**១០. គណនាតម្លៃលេខនៃកន្សោមលេខ** $A$

យើងមាន : $A=\sqrt[3]{182+\sqrt{33125}}+\sqrt[3]{182-\sqrt{33125}}$

តាមរូបមន្ត $(a+b)^3=a^3+3a^2b+3ab^2+b^3$

នាំឱ្យ : $=a^3+b^3+3ab(a+b)$

$$A^3=\left(\sqrt[3]{182+\sqrt{33125}}+\sqrt[3]{182-\sqrt{33125}}\right)^3$$

$$A^3=182+\sqrt{33125}+182-\sqrt{33125}+$$
$$+3\left(\sqrt[3]{182+\sqrt{33125}}\cdot\sqrt[3]{182-\sqrt{33125}}\right)^3\cdot A$$

$$A^3=364+3\sqrt[3]{182^2-\sqrt{33125^2}}\cdot A$$

$$A^3=364+3\sqrt[3]{33124-33125}\cdot A$$

$$A^3=364-3A$$

$$A^3+3A-364=0$$

ដោយមើលឃើញឫសងាយ $A=7$ យើងបាន :

$$A^3+3A-364=0$$
$$A^3-7A^2+7A^2-49A+52A-364=0$$
$$A^2(A-7)+7A(A-7)+52(A-7)=0$$
$$(A-7)(A^2+7A+52)=0$$

ទាញបាន $\begin{cases}(A-7)=0\\ A^2+7A+52=0\end{cases}$

នាំឱ្យ • $A-7=0 \Rightarrow A=7$

• $A^2+7A+52\neq0$ ព្រោះគ្មានឫស ដោយសារ $\Delta<0$

ដូចនេះ | តម្លៃលេខនៃកន្សោម $A=7$ | ។

**១១. គណនា** $A=\sqrt{x^{2011}}+\sqrt{y^{2011}}$

យើងមាន : $2xy-y=4x^2-2x-1$

$$y(2x-1)=4x^2-2x-1$$
$$y=\frac{4x^2-2x-1}{2x-1}$$
$$y=\frac{2x(2x-1)-1}{2x-1}$$
$$y=2x-\frac{1}{2x-1}$$

សម្មតិកម្ម $x$ , $y$ ជាចំនួនគត់ នេះមានន័យថា

$y=2x-\frac{1}{2x-1}$ ជាចំនួនគត់លុះត្រាតែ $\frac{1}{2x-1}$ ជាចំនួនគត់



www.facebook.com/7khmer
fb : Entertainment And Knowledge

ហើយ $\frac{1}{2x-1}$ ជាចំនួនគត់លុះត្រាតែ $2x-1=1$

នាំឱ្យ $x=1$ ទាញបាន $y=2x-\frac{1}{2x-1}$

$$=2\cdot1-\frac{1}{2\cdot1-1}=2-1=1$$

យើងបាន : $A=\sqrt{x^{2011}}+\sqrt{y^{2011}}=\sqrt{1^{2011}}+\sqrt{1^{2011}}=2$

ដូចនេះ | គណនាបាន $A=\sqrt{x^{2011}}+\sqrt{y^{2011}}=2$ | ។

## ១២. គណនា $f(12)$ : យើងមាន :

$$f(x)=x^{2011}-13x^{2010}+13x^{2009}-13x^{2008}+$$
$$+\ldots-13x^2+13x-1$$
$$=x^{2011}-12x^{2010}-x^{2010}+12x^{2009}+$$
$$+x^{2009}-12x^{2008}-x^{2008}+$$
$$+\ldots-12x^2-x^2+12x+x-1$$
$$=x^{2010}(x-12)-x^{2009}(x-12)+$$
$$+x^{2008}(x-12)-x^{2007}(x-12)+$$
$$+\ldots-x(x-12)+(x-1)$$
$$=(x-12)(x^{2010}-x^{2009}+x^{2008}-x^{2007}+$$
$$+\ldots-x)+(x-1)$$

ចំពោះ $x=12$ ជំនួសចូល យើងបាន :

$$f(12)=(12-12)(12^{2010}-12^{2009}+12^{2008}-12^{2007}+$$
$$+\ldots-12)+(12-1)$$

$$f(12)=0+11=11$$

ដូចនេះ | ក្រោយពីគណនា $f(12)=11$ | ។

## ១៣. គណនារង្វាស់ជ្រុងនៃប្រលេឡូក្រាម $ABCD$




យើងមានរូបមន្តក្រឡាផ្ទៃប្រលេឡូក្រាម

$S_{ABCD}=AB\cdot h_1$ ឬ $S_{ABCD}=AD\cdot h_2$

ទាញបាន $AB\cdot h_1=AD\cdot h_2$

បានសមាមាត្រ $\frac{h_1}{h_2}=\frac{AD}{AB}$

សម្មតិកម្ម សមាមាត្រកម្ពស់ $5:7$ មានន័យថា $\frac{h_1}{h_2}=\frac{5}{7}$

នាំឱ្យ $\frac{AD}{AB}=\frac{5}{7}$ សមមូល $\frac{AD}{5}=\frac{AB}{7}=\frac{AD+AB}{12}$

តែប្រលេឡូក្រាមមានបរិមាត្រ $48cm$

នាំឱ្យ $2(AB+AD)=48$ នោះ $AB+AD=24$

យើងបាន $\frac{AD}{5}=\frac{AB}{7}=\frac{AD+AB}{12}=\frac{24}{12}=2$

ទំនាក់ទំនងសមាមាត្រ $\frac{AD}{5}=2\Rightarrow AD=10cm$

$\frac{AB}{7}=2\Rightarrow AB=14cm$

ដូចនេះ | រង្វាស់ជ្រុងប្រលេឡូក្រាមគឺ $10cm$ និង $14cm$ | ។

## ១៤. រកសមីការមេដ្យាទ័រនៃអង្កត់ $[AB]$

សមីការមេដ្យាទ័រនៃអង្កត់ $[AB]$ ជាសមីការបន្ទាត់ដែលកាត់តាមចំណុចកណ្ដាលអង្កត់ $[AB]$ ហើយកែងនឹងអង្កត់ $[AB]$ ។

យើងមាន : $A(2,3)$ និង $B(4,4)$

នាំឱ្យកូអរដោនេចំណុចកណ្ដាលនៃអង្កត់ $[AB]$ គឺ :

$$I\left(\frac{x_A+x_B}{2},\frac{y_A+y_B}{2}\right)=I\left(\frac{2+4}{2},\frac{3+4}{2}\right)=I\left(3,\frac{7}{2}\right)$$

-បន្ទាត់ $(AB)$ កាត់តាម $A(2,3)$ នោះ $A\in(AB)$

នាំឱ្យកូអរដោនេចំណុច $A$ ផ្ទៀងផ្ទាត់សមីការ:

$3=2a+b$ អាចសរសេរជា $2a+b=3$ $(1)$

-បន្ទាត់ $(AB)$ កាត់តាម $B(4,4)$ នោះ $B\in(AB)$

នាំឱ្យកូអរដោនេចំណុច $B$ ផ្ទៀងផ្ទាត់សមីការ:

$4=4a+b$ អាចសរសេរជា $4a+b=4$ $(2)$

យកសមីការ $(2)-(1)$ យើងបាន :

$$-\begin{cases}4a+b=4 & (2)\\ 2a+b=3 & (1)\end{cases}$$
$$2a=1$$

នាំឱ្យ $a=\frac{1}{2}$

-សមីការមេដ្យាទ័រត្រូវរកមានរាង $y=a'x+b'$

ដោយ $y=a'x+b'\perp(AB)$ នោះ $a\times a'=-1$

ឬ $\frac{1}{2}\times a'=-1\Rightarrow a'=-2$

ហើយ មេដ្យាទ័រកាត់ចំណុចកណ្ដាល $I$ នោះ $I\in(y=a'x+b')$



www.facebook.com/7khmer
fb : Entertainment And Knowledge

យើងបាន : $\frac{7}{2}=(-2)\cdot 3+b' \quad \Rightarrow \quad b'=\frac{7}{2}+6=\frac{19}{2}$

នាំឱ្យសមីការមេដ្យាទ័រដែលត្រូវរកអាចសរសេរ: $y=-2x+\frac{19}{2}$

ដូចនេះ | សមីការមេដ្យាទ័រនៃអង្កត់ $[AB]$គឺ: $y=-2x+\frac{19}{2}$ | ។

## ១៥. រកប្រូបាបចាប់បានឃ្លី2 មិនមែនពណ៌ខៀវ

ព្រឹត្តិការណ៍ចាប់មិនបានឃ្លីពណ៌ខៀវ មានន័យថា :

បានឃ្លីក្រហមទាំង2 ឬ លឿងទាំង2 ឬ ក្រហម1លឿង1

-ប្រូបាបចាប់បានឃ្លីក្រហមទាំង2គឺ $P$ (ក.ក) $=\frac{2}{12}\times\frac{1}{11}=\frac{1}{66}$

-ប្រូបាបចាប់បានឃ្លីលឿងទាំង2គឺ $P$ (ល.ល) $=\frac{4}{12}\times\frac{3}{11}=\frac{1}{11}$

-ប្រូបាបចាប់បានឃ្លីក្រហម1លឿង1គឺ :

$P$ (ក1.ល1) $=$ $P$ (ក.ល) $+$ $P$ (ល.ក) $=\left(\frac{2}{12}\times\frac{4}{11}\right)+\left(\frac{4}{12}\times\frac{2}{11}\right)=\frac{4}{33}$

នាំឱ្យ ប្រូបាបចាប់ឃ្លី2មិនមែនពណ៌ខៀវគឺ :

$P$ (មិនមែនខៀវ) $=P$ (ក.ក) $+P$ (ល.ល) $+P$ (ក1.ល1)

$$=\frac{1}{66}+\frac{1}{11}+\frac{4}{33}$$

$$=\frac{1+6+8}{66}=\frac{15}{66}=\frac{5}{22}$$

ដូចនេះ | ប្រូបាបចាប់មិនបានឃ្លីពណ៌ខៀវគឺ $P=\frac{5}{22}$ | ។

## ១៦. គណនាកន្សោម $A$ : យើងមាន

$$A=\frac{(6+12+18+...+96)^2}{(12+24+36+...+192)^2}+\frac{3}{4}$$

$$=\frac{(6+12+18+...+96)^2}{(2\cdot 6+2\cdot 12+2\cdot 18+...+2\cdot 96)^2}+\frac{3}{4}$$

$$=\frac{(6+12+18+...+96)^2}{[2(6+12+18+...+96)]^2}+\frac{3}{4}$$

$$=\frac{(6+12+18+...+96)^2}{2^2(6+12+18+...+96)^2}+\frac{3}{4}$$

$$=\frac{1}{4}+\frac{3}{4}=1$$

ដូចនេះ | ក្រោយពីគណនា $A=1$ | ។

## ១៧. គណនា $E=\frac{x+y}{x-y}$

ចំពោះ $E=\frac{x+y}{x-y}$ សមមូល $E^2=\frac{(x+y)^2}{(x-y)^2}$

យើងមាន : $2x^2+2y^2=5xy$

នាំឱ្យ

$$2x^2+2y^2=5xy$$
$$2(x^2+y^2)=5xy$$
$$x^2+y^2=\frac{5}{2}xy \quad (*)$$

-ថែម $2xy$ លើអង្គទាំងពីរនៃសមីការ $(*)$

យើងបាន $x^2+2xy+y^2=\frac{5}{2}xy+2xy$

សមមូល $(x+y)^2=\frac{9}{2}xy$

-ថែម $-2xy$ លើអង្គទាំងពីរនៃសមីការ $(*)$

យើងបាន $x^2-2xy+y^2=\frac{5}{2}xy-2xy$

សមមូល $(x-y)^2=\frac{1}{2}xy$

យើងបាន : $E^2=\frac{(x+y)^2}{(x-y)^2}=\frac{\frac{9}{2}xy}{\frac{1}{2}xy}=9$

ទាញបាន $E=\sqrt{9}=3$ ព្រោះ $x>y>0$ នោះ $E>0$

ដូចនេះ | ក្រោយពីគណនា $E=3$ | ។

## ១៨. សម្រួលកន្សោម $E$ : យើងមាន

$$E=\sqrt{2x^2-y^2+2x\sqrt{x+y}\cdot\sqrt{x-y}}-\sqrt{(x+y)(x-y)}$$

$$=\sqrt{(x^2-y^2)+2x\sqrt{(x^2-y^2)}+x^2}-\sqrt{(x^2-y^2)}$$

$$=\sqrt{\sqrt{(x^2-y^2)}^2+2x\sqrt{(x^2-y^2)}+x^2}-\sqrt{(x^2-y^2)}$$

$$=\sqrt{\left[\sqrt{(x^2-y^2)}+x\right]^2}-\sqrt{(x^2-y^2)}$$

$$=\sqrt{(x^2-y^2)}+x-\sqrt{(x^2-y^2)}=x$$

ដូចនេះ | ក្រោយពីសម្រួលរួច $E=x$ | ។



www.facebook.com/7khmer
fb : Entertainment And Knowledge

## ១៩. គណនាផលគុណ

ក. $A=(1-\cot 1^o)(1-\cot 2^o)(1-\cot 3^o)\times\cdots\times(1-\cot 44^o)$

តាមរូបមន្ត $\dfrac{\cos a}{\sin a}=\cot a$ យើងបាន

$$A=\left(1-\frac{\cos 1^o}{\sin 1^o}\right)\left(1-\frac{\cos 2^o}{\sin 2^o}\right)\left(1-\frac{\cos 3^o}{\sin 3^o}\right)\times\cdots\times\left(1-\frac{\cos 44^o}{\sin 44^o}\right)$$

$$A=\left(\frac{\sin 1^o-\cos 1^o}{\sin 1^o}\right)\left(\frac{\sin 2^o-\cos 2^o}{\sin 2^o}\right)\left(\frac{\sin 3^o-\cos 3^o}{\sin 3^o}\right)\times\cdots\times\left(\frac{\sin 44^o-\cos 44^o}{\sin 44^o}\right)$$

ដោយដឹងថា $\sin a-\cos a=\sqrt{2}\sin(45^o-a)$

$$A=\left(\frac{\sqrt{2}\sin 44^o}{\sin 1^o}\right)\left(\frac{\sqrt{2}\sin 43^o}{\sin 2^o}\right)\left(\frac{\sqrt{2}\sin 42^o}{\sin 3^o}\right)\times\cdots\times\left(\frac{\sqrt{2}\sin 1^o}{\sin 44^o}\right)$$

$$A=\sqrt{2}^{44}\times\left(\frac{\sin 44^o}{\sin 1^o}\right)\left(\frac{\sin 43^o}{\sin 2^o}\right)\left(\frac{\sin 42^o}{\sin 3^o}\right)\times\cdots\times\left(\frac{\sin 1^o}{\sin 44^o}\right)$$

ក្រោយពីសម្រួល យើងបាន $A=2^{22}=4\,194\,304$

ដូចនេះ **លទ្ធផលនៃផលគុណគឺ $A=2^{22}=4\,194\,304$** ។

ខ. $B=(\sqrt{3}+\tan 1^o)(\sqrt{3}+\tan 2^o)(\sqrt{3}+\tan 3^o)\times\cdots\times(\sqrt{3}+\tan 29^o)$

តាមរូបមន្ត $\dfrac{\sin a}{\cos a}=\tan a$ យើងបាន

$$B=\left(\sqrt{3}+\frac{\sin 1^o}{\cos 1^o}\right)\left(\sqrt{3}+\frac{\sin 2^o}{\cos 2^o}\right)\times\cdots\times\left(\sqrt{3}+\frac{\sin 29^o}{\cos 29^o}\right)$$

$$B=\left(\frac{\sqrt{3}\cos 1^o+\sin 1^o}{\cos 1^o}\right)\left(\frac{\sqrt{3}\cos 2^o+\sin 2^o}{\cos 2^o}\right)\times\cdots\times\left(\frac{\sqrt{3}\cos 29^o+\sin 29^o}{\cos 29^o}\right)$$

ដោយដឹងថា $\sqrt{3}\cos a+\sin a=2\cos(30^o-a)$

$$B=\left(\frac{2\cos 29^o}{\cos 1^o}\right)\left(\frac{2\cos 28^o}{\cos 2^o}\right)\left(\frac{2\cos 27^o}{\cos 3^o}\right)\times\cdots\times\left(\frac{2\cos 1^o}{\cos 29^o}\right)$$

$$B=2^{29}\left(\frac{\cos 29^o}{\cos 1^o}\right)\left(\frac{\cos 28^o}{\cos 2^o}\right)\left(\frac{\cos 27^o}{\cos 3^o}\right)\times\cdots\times\left(\frac{\cos 1^o}{\cos 29^o}\right)$$

ក្រោយពីសម្រួល យើងបាន $B=2^{29}=536\,870\,912$

ដូចនេះ **លទ្ធផលនៃផលគុណគឺ $B=2^{29}=536\,870\,912$** ។

## ២០. ចូរបង្ហាញថា : $(a+b)(b+c)(c+a)\geq 8abc$

ដោយ $a\,,b\,,c$ ជាចំនួនពិតវិជ្ជមាន យើងបាន :

- $(\sqrt{a}-\sqrt{b})^2\geq 0$

  $\sqrt{a^2}-2\cdot\sqrt{a}\cdot\sqrt{b}+\sqrt{b^2}\geq 0$

  $(a+b)\geq 2\sqrt{ab}\quad (i)$

ដូចគ្នានេះដែរ យើងបាន :

- $(b+c)\geq 2\sqrt{bc}\quad (ii)$
- $(c+a)\geq 2\sqrt{ca}\quad (iii)$

ដោយគុណអង្គនឹងអង្គនៃ $(i)\times(ii)\times(iii)$ យើងបាន :

$$(a+b)\times(b+c)\times(c+a)\geq 2\sqrt{ab}\times 2\sqrt{bc}\times 2\sqrt{ca}$$
$$(a+b)(b+c)(c+a)\geq 8\sqrt{ab\cdot bc\cdot ca}$$
$$(a+b)(b+c)(c+a)\geq 8abc$$

ដូចនេះ **យើងឃើញថា $(a+b)(b+c)(c+a)\geq 8abc$ មែន** ។

## ២១. បង្ហាញថា $a^2+b^2+c^2\geq ab+bc+ca$ :

ដោយ $a\,,b\,,c$ ជាចំនួនពិតវិជ្ជមាន យើងបាន :

- $(a-b)^2\geq 0\Leftrightarrow a^2-2ab+b^2\geq 0\Leftrightarrow a^2+b^2\geq 2ab\ (i)$
- $(b-c)^2\geq 0\Leftrightarrow b^2-2ab+c^2\geq 0\Leftrightarrow b^2+c^2\geq 2bc\ (ii)$
- $(c-a)^2\geq 0\Leftrightarrow c^2-2ab+a^2\geq 0\Leftrightarrow c^2+a^2\geq 2ca\ (iii)$

ដោយបូកអង្គនឹងអង្គនៃ $(i)+(ii)+(iii)$ យើងបាន :

$$(a^2+b^2)+(b^2+c^2)+(c^2+a)^2\geq 2ab+2bc+2ca$$
$$2(a^2+b^2+c^2)+\geq 2(ab+bc+ca)$$
$$a^2+b^2+c^2\geq ab+bc+ca$$

ដូចនេះ **ឃើញថា $a^2+b^2+c^2\geq ab+bc+ca$ មែន** ។

## ២២. រកឫសគត់របស់សមីការ

យើងមាន $2(x+y)+16=3xy$

$$2x+2y+16=3xy$$
$$3xy-2x-2y=16$$
$$3xy-2x-2y+\frac{4}{3}=16+\frac{4}{3}\quad (\text{ថែម } \tfrac{4}{3})$$
$$x(3y-2)-\frac{2}{3}(3y-2)=\frac{48+4}{3}$$
$$\left(x-\frac{2}{3}\right)(3y-2)=\frac{52}{3}$$
$$3\left(x-\frac{2}{3}\right)(3y-2)=52$$
$$(3x-2)(3y-2)=52$$

ដោយចង់រកតែឫសគត់នៃ $x$ និង $y$ ដែលផ្ទៀងផ្ទាត់

ហើយ $52=\begin{cases}1\times 52\\ 2\times 26\\ 4\times 13\end{cases}$ ឬ $52=\begin{cases}52\times 1\\ 26\times 2\\ 13\times 4\end{cases}$



www.facebook.com/7khmer
fb : Entertainment And Knowledge

-ចំពោះ $\begin{cases}3x-2=1\\3y-2=52\end{cases} \Leftrightarrow \begin{cases}3x=3\\3y=54\end{cases} \Rightarrow \begin{cases}x=1\\y=18\end{cases}$

-ចំពោះ $\begin{cases}3x-2=2\\3y-2=26\end{cases} \Leftrightarrow \begin{cases}3x=4\\3y=28\end{cases}$ ( មិនយកព្រោះមិនគត់ )

-ចំពោះ $\begin{cases}3x-2=4\\3y-2=13\end{cases} \Leftrightarrow \begin{cases}3x=6\\3y=15\end{cases} \Rightarrow \begin{cases}x=2\\y=5\end{cases}$

ដូចនេះ គូឫសគត់ដែលរកឃើញរួមមាន: $\begin{cases}x=1\\y=18\end{cases}, \begin{cases}x=2\\y=5\end{cases}$ ឬ $\begin{cases}x=18\\y=1\end{cases}, \begin{cases}x=5\\y=2\end{cases}$ ។

## ២៣. ស្រាយបញ្ជាក់ថាសមីការដែលឱ្យមានឫសជានិច្ច

យើងមាន $(x-a)(x-b)+(x-b)(x-c)+(x-c)(x-a)=0$

ដោយពន្លាតសមីការខាងលើ យើងបាន :

$$x^2-bx-ax+ab+x^2-cx-bx+bc+x^2-ax-cx+ac=0$$
$$3x^2-2ax-2bx-2cx+ab+bc+ac=0$$
$$3x^2-2(a+b+c)x+(ab+bc+ac)=0$$

ឃើញថាក្រោយពីបង្រួមរួចវាជាសមីការដឺក្រេទី2

ដើម្បីឱ្យសមីការដឺក្រេទី2មានឫសជានិច្ច លុះត្រាតែ $\Delta'\ge 0$

យើងបាន $\Delta'=b'^2-ac$ ដែល $b'=\frac{b}{2}$

$$\Delta'=[-(a+c+c)]^2-3(ab+bc+ac)$$
$$=a^2+b^2+c^2+2(ab+bc+ac)-3(ab+bc+ac)$$
$$=a^2+b^2+c^2-(ab+bc+ac)$$
$$=\frac{1}{2}(2a^2+2b^2+2c^2-2ab-2bc-2ac)$$
$$=\frac{1}{2}(a^2-2ab+b^2+b^2-2bc+c^2+c^2-2ac+a^2)$$
$$=\frac{1}{2}\left[(a-b)^2+(b-c)^2+(c-a)^2\right]$$

ដោយ $a, b, c$ ជាចំនួនពិត នោះយើងបាន :

- $(a-b)^2\ge 0$
- $(b-c)^2\ge 0$
- $(c-a)^2\ge 0$

$$(a-b)^2+(b-c)^2+(c-a)^2\ge 0$$

នាំឱ្យ $\frac{1}{2}\left[(a-b)^2+(b-c)^2+(c-a)^2\right]\ge 0$ មែន

ដូចនេះ សមីការមានឫសជានិច្ច ។

## ២៤. ក. គណនា $f(x)+f(y)$

យើងមានទំនាក់ទំនង $f(x)=\frac{4^x}{4^x+2}$

នាំឱ្យ $f(y)=\frac{4^y}{4^y+2}$

យើងបាន $f(x)+f(y)=\frac{4^x}{4^x+2}+\frac{4^y}{4^y+2}$

$$=\frac{4^x(4^y+2)+4^y(4^x+2)}{(4^x+2)(4^y+2)}$$
$$=\frac{4^{x+y}+2\cdot 4^x+4^{x+y}+2\cdot 4^y}{4^{x+y}+2\cdot 4^x+2\cdot 4^y+2^2}$$

ដោយដឹងថា $x+y=1$ នោះយើងបាន

$$f(x)+f(y)=\frac{4+2\cdot 4^x+4+2\cdot 4^y}{4+2\cdot 4^x+2\cdot 4^y+2^2}$$
$$=\frac{8+2\cdot 4^x+2\cdot 4^y}{8+2\cdot 4^x+2\cdot 4^y}=1$$

ដូចនេះ $f(x)+f(y)=1$ តាមលក្ខខណ្ឌដែលឱ្យ ។

### ខ. ទាញរកផលបូក $S$ : យើងមាន

$$S=f\left(\frac{1}{2011}\right)+f\left(\frac{2}{2011}\right)+f\left(\frac{3}{2011}\right)+\dots+f\left(\frac{2010}{2011}\right)$$

ដោយយល់ថា $f(x)+f(y)=1$ កាលណា $x+y=1$

ហើយឃើញថា

$\frac{1}{2011}+\frac{2010}{2011}=1$ នោះ $f\left(\frac{1}{2011}\right)+f\left(\frac{2010}{2011}\right)=1$

$\frac{2}{2011}+\frac{2009}{2011}=1$ នោះ $f\left(\frac{2}{2011}\right)+f\left(\frac{2009}{2011}\right)=1$

.................................................................................

$\frac{1005}{2011}+\frac{1006}{2011}=1$ នោះ $f\left(\frac{1005}{2011}\right)+f\left(\frac{1006}{2011}\right)=1$

ដោយបូកអង្គនឹងអង្គ

$$f\left(\frac{1}{2011}\right)+f\left(\frac{2}{2011}\right)+\dots+f\left(\frac{2010}{2011}\right)=\underbrace{1+1+\dots+1}_{\text{មាន 1005 តួ}}$$

$$f\left(\frac{1}{2011}\right)+f\left(\frac{2}{2011}\right)+\dots+f\left(\frac{2010}{2011}\right)=1\times 1005$$

ដូចនេះ យើងទាញបានផលបូក $S=1005$ ។



www.facebook.com/7khmer
fb : Entertainment And Knowledge

**២៥.** **គណនាលីមីត** $\lim\limits_{x\to 0} x^x$

តាង $y=x^x$ នាំឱ្យ $\ln y=\ln x^x$ សមមូល $\ln y = x\ln x$

យើងអាចបំលែងបាន $\ln y=\dfrac{\ln x}{\frac{1}{x}}$ (លក្ខខណ្ឌ $x>0$)

យើងបាន $\lim\limits_{x\to 0}\ln y=\lim\limits_{x\to 0}\dfrac{\ln x}{\frac{1}{x}}$ (រាងមិនកំណត់)

-យើងអាចដោះស្រាយតាមរបៀបទី1 (ដោះដោយតាង):

តាង $u=\dfrac{1}{x}$ នាំឱ្យ $x=\dfrac{1}{u}$  បើ $x\to 0^+$ នោះ $u\to+\infty$

(បានជាយ៉ាងដាក់ $x\to 0^+$ ព្រោះ $x>0$ ខិតជិតពីខាងស្តាំ)

យើងបាន :

$$\lim_{x\to 0}\frac{\ln x}{\frac{1}{x}}=\lim_{u\to+\infty}\frac{\ln\frac{1}{u}}{u}=\lim_{u\to+\infty}\frac{\ln u^{-1}}{u}=-\lim_{u\to+\infty}\frac{\ln u}{u}=0$$

(ព្រោះតាមរូបមន្ត $\frac{1}{a}=a^{-1}$ , $\log_a b^x = x\log_a b$ , $\lim\limits_{u\to+\infty}\frac{\ln u}{u}=0$ )

នាំឱ្យ $\lim\limits_{x\to 0}\ln y=0 \iff \ln\left(\lim\limits_{x\to 0} y\right)=0$

$\lim\limits_{x\to 0} y=e^0 \iff \lim\limits_{x\to 0}x^x=1$ ។

- យើងអាចដោះស្រាយតាមរបៀបទី2 (ឡូពីតាល់):

ចំពោះ $\lim\limits_{x\to 0}\ln y=\lim\limits_{x\to 0}\dfrac{\ln x}{\frac{1}{x}}=\lim\limits_{x\to 0}\dfrac{\frac{1}{x}}{-\frac{1}{x^2}}=\lim\limits_{x\to 0}(-x)=0$

(ធ្វើដេរីវេទាំងភាគយក និងភាគបែង)

នាំឱ្យ $\lim\limits_{x\to 0}\ln y=0 \iff \ln\left(\lim\limits_{x\to 0} y\right)=0$

$\lim\limits_{x\to 0} y=e^0 \iff \lim\limits_{x\to 0}x^x=1$ ។

ដូចនេះ **ក្រោយពីគណនាឃើញថា $\lim\limits_{x\to 0}x^x=1$** ។

**២៦.** **គណនា** $A$: យើងមាន

$A=2010(2011^{2010}+2011^{2009}+2011^{2008}+\dots+2011^2+2012)+1$

$A=(2011-1)(2011^{2010}+2011^{2009}+2011^{2008}+$

$+\dots+2011^2+2011+1)+1$

$A=(2011^{2011}-1^{2011})+1=2011^{2011}-1+1=2011^{2011}$

ដូចនេះ **គណនាបាន $A=2011^{2011}$** ។

**២៧.** **បង្ហាញថា**

$(a+b)(a^2+b^2)(a^4+b^4)-(a^8-b^8)=0$

ពិនិត្យ $a^8-b^8=(a^4-b^4)(a^4+b^4)$

$=(a^2-b^2)(a^2+b^2)(a^4+b^4)$

$=(a-b)(a+b)(a^2+b^2)(a^4+b^4)$

តែបម្រាប់ ∵ $a-b=1$

យើងបាន $a^8-b^8=(a+b)(a^2+b^2)(a^4+b^4)$ នាំឱ្យ

$(a+b)(a^2+b^2)(a^4+b^4)-(a^8-b^8)=0$

$(a+b)(a^2+b^2)(a^4+b^4)-(a+b)(a^2+b^2)(a^4+b^4)=0$

$0=0$

ដូចនេះ **$(a+b)(a^2+b^2)(a^4+b^4)-(a^8-b^8)=0$** ។

**២៨.** **គណនា** $A=\left(1-\frac{1}{2}\right)\times\left(1-\frac{1}{3}\right)\times\left(1-\frac{1}{4}\right)\times\dots\times\left(1-\frac{1}{2011}\right)$

$A=\left(1-\frac{1}{2}\right)\times\left(1-\frac{1}{3}\right)\times\left(1-\frac{1}{4}\right)\times\dots\times\left(1-\frac{1}{2011}\right)$

$=\left(\frac{2-1}{2}\right)\times\left(\frac{3-1}{3}\right)\times\left(\frac{4-1}{4}\right)\times\dots\times\left(\frac{2011-1}{2011}\right)$

$=\frac{1}{2}\times\frac{2}{3}\times\frac{3}{4}\times\dots\times\frac{2010}{2011}=\frac{1}{2011}$

ដូចនេះ **ក្រោយពីគណនា $A=\dfrac{1}{2011}$** ។

**២៩.** **ដោះស្រាយសមីការ** : $4x^4-5x^2+1=0$

យើងមាន : $4x^4-5x^2+1=0$

$4x^4-4x^2-x^2+1=0$

$4x^2(x^2-1)-(x^2-1)=0$

$(x^2-1)(4x^2-1)=0$

$(x-1)(x+1)(2x-1)(2x+1)=0$

ផលគុណកត្តាស្មើ 0 លុះត្រាកត្តានីមួយៗស្មើ 0 :

យើងបាន :
- $x-1=0 \Rightarrow x=1$
- $x+1=0 \Rightarrow x=-1$
- $2x-1=0 \Rightarrow x=\frac{1}{2}$
- $2x+1=0 \Rightarrow x=-\frac{1}{2}$

ដូចនេះ **សមីការមានឫសបួនគឺ $x=\left\{-1,-\frac{1}{2},\frac{1}{2},1\right\}$** ។



www.facebook.com/7khmer
fb : Entertainment And Knowledge

**៣០.** **បង្ហាញថា** $\dfrac{1}{ab+a+1}+\dfrac{1}{bc+b+1}+\dfrac{1}{ca+c+1}=1$

ពិនិត្យអង្គទីមួយ :

- $\dfrac{1}{ab+a+1}=\dfrac{1}{ab+a+1}$
- $\dfrac{1}{bc+b+1}=\dfrac{1}{bc+b+1}\times\dfrac{a}{a}=\dfrac{a}{abc+ab+a}$

  $=\dfrac{a}{1+ab+a}$ ព្រោះ $abc=1$
- $\dfrac{1}{ca+c+1}=\dfrac{1}{ca+c+1}\times\dfrac{ab}{ab}=\dfrac{ab}{a\cdot abc+abc+ab}$

  $=\dfrac{ab}{a+1+ab}$ ព្រោះ $abc=1$

យើងបាន : $\dfrac{1}{ab+a+1}+\dfrac{1}{bc+b+1}+\dfrac{1}{ca+c+1}$

$$=\frac{1}{1+a+ab}+\frac{a}{1+a+ab}+\frac{ab}{1+a+ab}$$

$$=\frac{1+a+ab}{1+a+ab}=1$$

ដូចនេះ $\boxed{\dfrac{1}{ab+a+1}+\dfrac{1}{bc+b+1}+\dfrac{1}{ca+c+1}=1}$ ពិតមែន ។

**៣១.** **គណនា**

$$S=\frac{1}{2\sqrt{1}+1\sqrt{2}}+\frac{1}{3\sqrt{2}+2\sqrt{3}}+\frac{1}{4\sqrt{3}+3\sqrt{4}}+\ldots+\frac{1}{100\sqrt{99}+99\sqrt{100}}$$

ពិនិត្យ :

$$\frac{1}{(n+1)\sqrt{n}+n\sqrt{n+1}}$$

$$=\frac{1}{\sqrt{(n+1)n}\left(\sqrt{n+1}+\sqrt{n}\right)}$$

$$=\frac{\left(\sqrt{n+1}-\sqrt{n}\right)}{\sqrt{(n+1)n}\left(\sqrt{n+1}+\sqrt{n}\right)\left(\sqrt{n+1}-\sqrt{n}\right)}$$

$$=\frac{\sqrt{n+1}-\sqrt{n}}{\sqrt{(n+1)n}\,(n+1-n)}=\frac{\sqrt{n+1}-\sqrt{n}}{\sqrt{(n+1)n}}$$

$$=\frac{\sqrt{n+1}}{\sqrt{(n+1)n}}-\frac{\sqrt{n}}{\sqrt{(n+1)n}}=\frac{1}{\sqrt{n}}-\frac{1}{\sqrt{n+1}}$$

យើងបាន :

$$+\begin{cases}\dfrac{1}{2\sqrt{1}+1\sqrt{2}}=\dfrac{1}{\sqrt{1}}-\dfrac{1}{\sqrt{2}}\\[2mm] \dfrac{1}{3\sqrt{2}+2\sqrt{3}}=\dfrac{1}{\sqrt{2}}-\dfrac{1}{\sqrt{3}}\\[2mm] \dfrac{1}{4\sqrt{3}+3\sqrt{4}}=\dfrac{1}{\sqrt{3}}-\dfrac{1}{\sqrt{4}}\\ \ldots\ldots\ldots\ldots\ldots\ldots\ldots\ldots\\ \dfrac{1}{100\sqrt{99}+99\sqrt{100}}=\dfrac{1}{\sqrt{99}}-\dfrac{1}{\sqrt{100}}\end{cases}$$

$$\frac{1}{2\sqrt{1}+1\sqrt{2}}+\frac{1}{3\sqrt{2}+2\sqrt{3}}+\ldots+\frac{1}{100\sqrt{99}+99\sqrt{100}}=\frac{1}{\sqrt{1}}-\frac{1}{\sqrt{100}}$$

$$\frac{1}{2\sqrt{1}+1\sqrt{2}}+\frac{1}{3\sqrt{2}+2\sqrt{3}}+\ldots+\frac{1}{100\sqrt{99}+99\sqrt{100}}=1-\frac{1}{10}=\frac{9}{10}$$

ដូចនេះ $\boxed{S=\dfrac{1}{2\sqrt{1}+1\sqrt{2}}+\dfrac{1}{3\sqrt{2}+2\sqrt{3}}+\ldots+\dfrac{1}{100\sqrt{99}+99\sqrt{100}}=\dfrac{9}{10}}$ ។

**៣២.** **បង្ហាញថា** $2002^{2003}-2002^{1979}$ **ចែកដាច់នឹង** $6$

យើងមាន :

$$2002^{2003}-2002^{1979}$$
$$=2002^{1979}\left(2002^{24}-1\right)$$
$$=2002^{1979}(2002-1)\left(2002^{23}+2002^{22}+\ldots+2002+1\right)$$
$$=2\cdot 2002^{1978}\cdot 2001\left(2002^{23}+2002^{22}+\ldots+2002+1\right)$$
$$=2\cdot 2002^{1978}\cdot 3\cdot 667\left(2002^{23}+2002^{22}+\ldots+2002+1\right)$$
$$=6\cdot 2002^{1978}\cdot 667\left(2002^{23}+2002^{22}+\ldots+2002+1\right)$$

តាមលទ្ធផល ចំនួន $2002^{2003}-2002^{1979}$ ជាពហុគុណនៃ $6$

ដូចនេះ $\boxed{\text{ចំនួន } 2002^{2003}-2002^{1979} \text{ ចែកដាច់នឹង } 6}$ ។

**៣៣.** **បង្ហាញថា** $a^2+b^2+c^2\geq\dfrac{1}{3}$

យើងមាន $a+b+c=1$ លើកជាការេ យើងបាន

$$a^2+b^2+c^2+2ab+2bc+2ca=1$$
$$a^2+b^2+c^2=1-2ab-2bc-2ca \quad (i)$$

គ្រប់ចំនួនពិត $a\,,b\,,c$ នោះយើងបានវិសមភាព :

$$+\begin{cases}a^2+b^2\geq 2ab\\ b^2+c^2\geq 2bc\\ c^2+a^2\geq 2ca\end{cases}$$

$$2a^2+2b^2+c^2\geq 2ab+2bc+2ca \quad (ii)$$



www.facebook.com/7khmer
fb : Entertainment And Knowledge

ដោយយក $(i)+(ii)$ នោះយើងបាន :

$$+\begin{cases} a^2+b^2+c^2=1-2ab-2bc-2ca & (i) \\ 2a^2+2b^2+2c^2\geq 2ab+2bc+2ca & (ii) \end{cases}$$
$$3a^2+3b^2+3c^2\geq 1$$

ទាញបាន $3(a^2+b^2+c^2)\geq 1 \Leftrightarrow \quad a^2+b^2+c^2\geq \frac{1}{3}$

ដូចនេះ | ឃើញថា $a^2+b^2+c^2\geq \frac{1}{3}$ ប្រាកដមែន | ។

**៣៤. បង្ហាញថា** $\log_a b\times \log_b c\times \log_c d\times ...\times \log_x y\times \log_y a=1$

តាមរូបមន្តប្តូរគោល $\log_a b=\frac{\log b}{\log a}$ យើងបាន :

$$\log_a b\times \log_b c\times \log_c d\times ...\times \log_x y\times \log_y a=1$$
$$\frac{\log b}{\log a}\times \frac{\log c}{\log b}\times \frac{\log d}{\log c}\times ...\times \frac{\log y}{\log x}\times \frac{\log a}{\log y}=1$$
$$1=1$$

ដូចនេះ | $\log_a b\times \log_b c\times \log_c d\times ...\times \log_x y\times \log_y a=1$ | ។

**៣៥. បង្ហាញថា** $f(x)+f(y)=f\left(\frac{x+y}{1+xy}\right)$

យើងមាន : $f(x)=\log\left(\frac{1+x}{1-x}\right)$

នាំឱ្យបាន : $f(y)=\log\left(\frac{1+y}{1-y}\right)$

យើងបាន : $f(x)+f(y)=\log\left(\frac{1+x}{1-x}\right)+\log\left(\frac{1+y}{1-y}\right)$

$$=\log\left[\left(\frac{1+x}{1-x}\right)\left(\frac{1+y}{1-y}\right)\right]$$
$$=\log\left(\frac{1+x+y+xy}{1-x-y+xy}\right)$$
$$=\log\left(\frac{(1+xy)+(x+y)}{(1+xy)-(x+y)}\right)$$

ដោយចែកទាំងភាគយក និងភាគបែងនឹង $(1+xy)$

នាំឱ្យបាន : $f(x)+f(y)=\log\left(\dfrac{\frac{(1+xy)+(x+y)}{(1+xy)}}{\frac{(1+xy)-(x+y)}{(1+xy)}}\right)$

$$=\log\left(\dfrac{1+\frac{x+y}{1+xy}}{1-\frac{x+y}{1+xy}}\right)=f\left(\frac{x+y}{1+xy}\right)$$

ដូចនេះ | ឃើញថា $f(x)+f(y)=f\left(\frac{x+y}{1+xy}\right)$ មែន | ។

**៣៦. ដោះស្រាយសមីការ** $\left(\sqrt{7+\sqrt{48}}\right)^x+\left(\sqrt{7-\sqrt{48}}\right)^x=14$

ឃើញថា : $\left(\sqrt{7+\sqrt{48}}\right)\left(\sqrt{7-\sqrt{48}}\right)=\sqrt{49-48}=1$

ទាញបាន $\left(\sqrt{7+\sqrt{48}}\right)=\frac{1}{\left(\sqrt{7-\sqrt{48}}\right)}=\left(\sqrt{7-\sqrt{48}}\right)^{-1}$

យើងបានសមីការថ្មី ( ជំនួស $\sqrt{7+\sqrt{48}}$ ដោយ $\frac{1}{\sqrt{7-\sqrt{48}}}$ )

$$\left(\frac{1}{\sqrt{7-\sqrt{48}}}\right)^x+\left(\sqrt{7-\sqrt{48}}\right)^x=14$$

តាង $t=\left(\sqrt{7-\sqrt{48}}\right)^x$

សមីការទៅជា $\frac{1}{t}+t=14$ សមមូល $t^2-14t+1=0$

មាន $\Delta'=(-7)^2-1=48$

នាំឱ្យ $t_1=\frac{-(-7)-\sqrt{48}}{1}=7-\sqrt{48}=\left(\sqrt{7-\sqrt{48}}\right)^2$

$$t_2=\frac{-(-7)+\sqrt{48}}{1}=7+\sqrt{48}=\frac{1}{7-\sqrt{48}}$$
$$=\left(7-\sqrt{48}\right)^{-1}$$
$$=\left(\sqrt{7-\sqrt{48}}\right)^{-2}$$

ចំពោះ $t_1=\left(\sqrt{7-\sqrt{48}}\right)^2$

នោះ $\left(\sqrt{7-\sqrt{48}}\right)^x=\left(\sqrt{7-\sqrt{48}}\right)^2$

ទាញបាន $x=2$

ចំពោះ $t_2=\left(\sqrt{7-\sqrt{48}}\right)^{-2}$

នោះ $\left(\sqrt{7-\sqrt{48}}\right)^x=\left(\sqrt{7-\sqrt{48}}\right)^{-2}$

ទាញបាន $x=-2$

ដូចនេះ | សមីការមានឬស $x=2\vee x=-2$ | ។



www.facebook.com/7khmer
fb : Entertainment And Knowledge

## ៣៧. បង្ហាញថា :

$(\log_a b+\log_b a+2)(\log_a b-\log_{ab} b)\cdot\log_b a-1=\log_a b$

ពិនិត្យ :

$(\log_a b+\log_b a+2)(\log_a b-\log_{ab} b)\cdot\log_b a-1$

$=\left(\frac{\log b}{\log a}+\frac{\log a}{\log b}+2\right)\left(\frac{\log b}{\log a}-\frac{\log b}{\log ab}\right)\cdot\frac{\log a}{\log b}-1$

$=\left(\frac{\log^2 a+2\log a\log b+\log^2 b}{\log a\log b}\right)\left(1-\frac{\log a}{\log ab}\right)-1$

$=\left(\frac{(\log a+\log b)^2}{\log a\log b}\right)\left(1-\frac{\log a}{\log a+\log b}\right)-1$

$=\left(\frac{(\log a+\log b)^2}{\log a\log b}\right)\left(\frac{\log a+\log b-\log a}{\log a+\log b}\right)-1$

$=\left(\frac{(\log a+\log b)^2}{\log a\log b}\right)\left(\frac{\log b}{\log a+\log b}\right)-1$

$=\left(\frac{\log a+\log b}{\log a}\right)-1=1+\log_a b-1=\log_a b$

ដូចនេះ ក្រោយពីបង្ហាញរួចឃើញថា

$(\log_a b+\log_b a+2)(\log_a b-\log_{ab} b)\cdot\log_b a-1=\log_a b$

## ៣៨. បង្ហាញថា $\frac{1+\cos a}{1-\cos a}-\frac{1-\cos a}{1+\cos a}=\frac{4\cot a}{\sin a}$

ពិនិត្យ ព្រមទាំងគណនាអង្គទីមួយ យើងបាន :

$\frac{1+\cos a}{1-\cos a}-\frac{1-\cos a}{1+\cos a}$

$=\frac{(1+\cos a)^2-(1-\cos a)^2}{(1-\cos a)(1+\cos a)}$

$=\frac{(1+\cos a-1+\cos a)(1+\cos a+1-\cos a)}{(1-\cos a)(1+\cos a)}$

$=\frac{2\cos a\times 2}{1-\cos^2 a}=\frac{4\cos a}{\sin^2 a}=\frac{4}{\sin a}\cdot\frac{\cos a}{\sin a}=\frac{4\cot a}{\sin a}$

ដូចនេះ $\frac{1+\cos a}{1-\cos a}-\frac{1-\cos a}{1+\cos a}=\frac{4\cot a}{\sin a}$ ពិតមែន ។

## ៣៩. ដោះស្រាយសមីការ : $5^{\log x}=50-x^{\log 5}$

ពិនិត្យ $5^{\log x}$ បំពាក់លោការីតនេពែរ គេបាន

$\ln 5^{\log x}=\log x\cdot\ln 5$

ហើយ $5^{\log x}$ បំពាក់លោការីតនេពែរ គេបាន

$\ln x^{\log 5}=\log 5\cdot\ln x$

ឃើញថា $\log x\cdot\ln 5=\log 5\cdot\ln x$

នាំឱ្យ $5^{\log x}=x^{\log 5}$

ជំនួស $x^{\log 5}$ ដោយ $5^{\log x}$

យើងបានសមីការ $5^{\log x}=50-5^{\log x}$

$2\times 5^{\log x}=50 \Leftrightarrow 5^{\log x}=25$

$5^{\log x}=25 \Leftrightarrow 5^{\log x}=5^2$

ទាញបាន $\log x=2 \Rightarrow x=10^2=100$ ។

ដូចនេះ សមីការមានឫសគឺ $x=100$ ។

## ៤០. គណនាប្រូបាបដែលបោះបានលេខសេស ឬ លេខធំជាង5

-គ្រាប់ឡុកឡាក់មានមុខ 6 នាំឱ្យចំនួនករណីអាចស្មើ 6

-លេខសេសរួមមាន : 1 , 3 , 5 មាន 3 ករណី

នាំឱ្យប្រូបាបបោះបានលេខសេសគឺ $P$ (សេស) $=\frac{3}{6}$

-លេខធំជាង5 គឺមានតែលេខ 6 មាន 1 ករណី

នាំឱ្យប្រូបាបបោះបានលេខធំជាង5 គឺ $P$ ( លេខធំជាង 5 ) $=\frac{1}{6}$

យើងបាន : ប្រូបាបដែលបោះបានលេខសេស ឬ លេខធំជាង5

គឺ $P$ (សេស) ឬ $P$ ( លេខធំជាង 5 ) $=\frac{3}{6}+\frac{1}{6}=\frac{2}{3}$

ដូចនេះ ប្រូបាបបោះបានលេខសេស ឬ លេខធំជាង៥ស្មើនឹង $\frac{2}{3}$ ។

## ៤១. ដោះស្រាយសមីការ

យើងមាន $\sqrt{x+\sqrt{4x+\sqrt{16x+...+\sqrt{4^n x+3}}}}=\sqrt{x}+1$

លើកអង្គទាំងពីរជាការេ និងគណនាជាបន្តបន្ទាប់ យើងបាន :



www.facebook.com/7khmer
fb : Entertainment And Knowledge

$$\sqrt{x+\sqrt{4x+\sqrt{16x+...+\sqrt{4^n x+3}}}}=\sqrt{x}+1$$

$$x+\sqrt{4x+\sqrt{16x+...+\sqrt{4^n x+3}}}=x+2\sqrt{x}+1$$

$$\sqrt{4x+\sqrt{16x+...+\sqrt{4^n x+3}}}=2\sqrt{x}+1$$

$$4x+\sqrt{16x+...+\sqrt{4^n x+3}}=4x+4\sqrt{x}+1$$

$$\sqrt{16x+...+\sqrt{4^n x+3}}=4\sqrt{x}+1$$

$$16x+...+\sqrt{4^n x+3}=16x+8\sqrt{x}+1$$

$$...+\sqrt{4^n x+3}=8\sqrt{x}+1$$

..................................................

$$\sqrt{4^n x+3}=2^n\sqrt{x}+1$$

$$4^n x+3=4^n x+2\cdot 2^n\sqrt{x}+1$$

$$2=2\cdot 2^n\sqrt{x}$$

$$2^n\sqrt{x}=1$$

$$2^{2n}x=1$$

$$x=\frac{1}{4^n}$$

ដូចនេះ | សមីការមានឫស $x=\frac{1}{4^n}$ | ។

## ៤២. គណនាផលបូក

$$f(1)+f(3)+f(5)+...+f(999997)+f(999999)$$

$$f(n)=\frac{1}{\sqrt[3]{n^2+2n+1}+\sqrt[3]{n^2-1}+\sqrt[3]{n^2-2n+1}}$$

$$=\frac{1}{\sqrt[3]{(n+1)^2}+\sqrt[3]{n^2-1}+\sqrt[3]{(n-1)^2}}$$

$$=\frac{\left(\sqrt[3]{n+1}-\sqrt[3]{n-1}\right)}{\left(\sqrt[3]{n+1}-\sqrt[3]{n-1}\right)\left(\sqrt[3]{(n+1)^2}+\sqrt[3]{n^2-1}+\sqrt[3]{(n-1)^2}\right)}$$

$$=\frac{1}{n+1-n+1}\left(\sqrt[3]{n+1}-\sqrt[3]{n-1}\right)$$

$$=\frac{1}{2}\left(\sqrt[3]{n+1}-\sqrt[3]{n-1}\right)$$

នាំឱ្យយើងបាន ៖

$$+\begin{cases} f(1)=\frac{1}{2}\left(\sqrt[3]{2}-\sqrt[3]{0}\right)\\ f(3)=\frac{1}{2}\left(\sqrt[3]{4}-\sqrt[3]{2}\right)\\ f(5)=\frac{1}{2}\left(\sqrt[3]{6}-\sqrt[3]{4}\right)\\ \text{.............................}\\ f(999999)=\frac{1}{2}\left(\sqrt[3]{1000000}-\sqrt[3]{999998}\right)\end{cases}$$

$$f(1)+f(3)+f(5)+...+f(999997)+f(999999)=\frac{1}{2}\left(\sqrt[3]{10^6}-0\right)$$

$$=\frac{1}{2}\cdot 100=50$$

ដូចនេះ | $f(1)+f(3)+f(5)+...+f(999997)+f(999999)=50$ | ។

## ៤៣. ដោះស្រាយប្រព័ន្ធសមីការ

$a/\ \begin{cases} 5(\log_y x+\log_x y)=26 & (i)\\ xy=64 & (ii)\end{cases}$

( អ្នកគួចាំរូបមន្តប្តូរគោល $\log_y x=\frac{1}{\log_x y}$ )

-តាម $(i)$ ៖ $5(\log_y x+\log_x y)=26$

$$\frac{1}{\log_x y}+\log_x y=\frac{26}{5}$$

$$5\log_x^2 y-26\log_x y+5=0$$

តាង $\log_x y=t$ យើងបានសមីការថ្មីគឺ ៖

$5t^2-26t+5=0$ ( តាមឌីសគ្រីមីណង់ $\Delta'$ )

មាន $\Delta'=(-13)^2-25=169-25=144$

នាំឱ្យ $t_1=\frac{-(-13)-12}{5}=\frac{1}{5}$ , $t_1=\frac{-(-13)+12}{5}=5$

ចំពោះ $t=\frac{1}{5}$ នាំឱ្យ $\log_x y=\frac{1}{5} \Rightarrow y=x^{\frac{1}{5}}$

ចំពោះ $t=5$ នាំឱ្យ $\log_x y=5 \Rightarrow y=x^5$

-តាម $(ii)$ ៖ $xy=64$

ករណី $y=x^{\frac{1}{5}}$ នោះ $x\cdot x^{\frac{1}{5}}=64 \Leftrightarrow x^{\frac{6}{5}}=2^6 \Rightarrow x=2^5$

នាំឱ្យ $y=x^{\frac{1}{5}} \Leftrightarrow y=\left(2^5\right)^{\frac{1}{5}} \Rightarrow y=2$

ករណី $y=x^5$ នោះ $x\cdot x^5=64 \Leftrightarrow x^6=2^6 \Rightarrow x=2$



www.facebook.com/7khmer
fb : Entertainment And Knowledge

នាំឱ្យ $y=x^5 \Leftrightarrow y=2^5 \Rightarrow y=32$

ដូចនេះ ប្រព័ន្ធសមីការមានគូចម្លើយពីរគឺ : $(x=32\,,\,y=2)$ ឬ $(x=2\,,\,y=32)$ ។

$$b/\ \begin{cases}4^x\cdot5^y=\dfrac{1}{400} & (*)\\ 5^x\cdot6^y=\dfrac{1}{900} & (**)\end{cases}$$

តាម $(*)$ : $4^x\cdot5^y=\dfrac{1}{400}$ (បំពាក់ ln លើអង្គទាំងពីរ)

$$\ln(4^x\cdot5^y)=\ln\left(\frac{1}{400}\right)$$
$$\ln4^x+\ln5^y=\ln1-\ln400$$
$$x\ln4+y\ln5=0-\ln20^2$$
$$x\ln4+y\ln5=-2[\ln(4\cdot5)]$$
$$x\ln4+y\ln5=-2\ln4-2\ln5 \quad (i)$$

តាម $(**)$ : $5^x\cdot6^y=\dfrac{1}{900}$ (បំពាក់ ln លើអង្គទាំងពីរ)

$$\ln(5^x\cdot6^y)=\ln\left(\frac{1}{900}\right)$$
$$\ln5^x+\ln6^y=\ln1-\ln900$$
$$x\ln5+y\ln6=0-\ln30^2$$
$$x\ln5+y\ln6=-2[\ln(5\cdot6)]$$
$$x\ln5+y\ln6=-2\ln5-2\ln6 \quad (ii)$$

តាម $(i)$ និង $(ii)$ យើងបានប្រព័ន្ធសមីការ :

$$\begin{cases}x\ln4+y\ln5=-2\ln4-2\ln5\\ x\ln5+y\ln6=-2\ln5-2\ln6\end{cases}$$

ដោះស្រាយតាមដេទែមីណង់ :

$$D=\ln4\ln6-\ln^2 5$$
$$D_x=(-\ln4-2\ln5)\ln6-(-2\ln5-2\ln6)\ln5$$
$$=-2\ln4\ln6-2\ln5\ln6+2\ln^2 5+2\ln5\ln6$$
$$=-2\ln4\ln6+2\ln^2 5$$
$$=-2(\ln4\ln6-\ln^2 5)$$
$$D_y=\ln4(-2\ln5-2\ln6)-\ln5(-2\ln4-2\ln5)$$
$$=-2\ln4\ln5-2\ln4\ln6+2\ln5\ln4+2\ln^2 5$$
$$=-2\ln4\ln6+2\ln^2 5$$
$$=-2(\ln4\ln6-\ln^2 5)$$

នាំឱ្យ
$$\begin{cases}x=\dfrac{D_x}{D}=\dfrac{-2(\ln4\ln6-\ln^2 5)}{(\ln4\ln6-\ln^2 5)}=-2\\ y=\dfrac{D_y}{D}=\dfrac{-2(\ln4\ln6-\ln^2 5)}{(\ln4\ln6-\ln^2 5)}=-2\end{cases}$$

ដូចនេះ ប្រព័ន្ធសមីការមានគូចម្លើយគឺ : $x=-2\ ,\ y=-2$ ។

## ៤៤. បង្ហាញថា

$$(1+a_1)(1+a_2)(1+a_3)\times\ldots\times(1+a_n)\ge2^n$$

ដោយ $a$ ជាចំនួនវិជ្ជមាន នោះយើងបាន :

$$\times\begin{cases}1+a_1\ge2\sqrt{a_1}\\ 1+a_2\ge2\sqrt{a_2}\\ 1+a_3\ge2\sqrt{a_3}\\ \ldots\ldots\ldots\ldots\ldots\\ 1+a_n\ge2\sqrt{a_n}\end{cases}$$
$$(1+a_1)(1+a_2)(1+a_3)\times\ldots\times(1+a_n)\ge2^n\sqrt{a_1a_2a_3\ldots a_n}$$

សម្មតិកម្ម ផលគុណ $a_1\cdot a_2\cdot a_3\times\ldots\times a_n=1$

នោះយើងបាន $(1+a_1)(1+a_2)(1+a_3)\times\ldots\times(1+a_n)\ge2^n$

ដូចនេះ $(1+a_1)(1+a_2)(1+a_3)\times\ldots\times(1+a_n)\ge2^n$ ។

## ៤៥. ដោះស្រាយប្រព័ន្ធសមីការ

$$a/\ \begin{cases}7x^3-3x^2y-21xy^2+26y^3=342\\ 9x^3-21x^2y+33xy^2-28y^3=344\end{cases}$$

ដោយបូកអង្គនឹងអង្គ យើងបាន :

$$+\begin{cases}7x^3-3x^2y-21xy^2+26y^3=342\\ 9x^3-21x^2y+33xy^2-28y^3=344\end{cases}$$
$$16x^3-24x^2y+12xy^2-2y^3=686$$
$$8x^3-12x^2y+6xy^2-y^3=343$$
$$(2x)^3-3\cdot(2x)^2\cdot y+3\cdot(2x)\cdot y^2-y^3=7^3$$
$$(2x-y)^3=7^3$$
$$2x-y=7 \quad (i)$$

ដោយដកអង្គនឹងអង្គ យើងបាន :



www.facebook.com/7khmer
fb : Entertainment And Knowledge

$$-\begin{cases}7x^3-3x^2y-21xy^2+26y^3=342\\9x^3-21x^2y+33xy^2-28y^3=344\end{cases}$$
$$-2x^3+18x^2y-54xy^2+54y^3=-2$$
$$x^3-9x^2y+27xy^2-27y^3=1$$
$$x^3-3\cdot x^2\cdot(3y)+3\cdot x\cdot(3y)^2-(3y)^3=1$$
$$(x-3y)^3=1^3$$
$$x-3y=1 \quad (ii)$$

តាមរយៈ $(i)$ និង $(ii)$ យើងបានប្រព័ន្ធសមីការថ្មីគឺ:

$$\begin{cases}2x-y=7\\x-3y=1\end{cases} \text{ សមមូល } \begin{cases}2x-y=7\\-2x+6y=-2\end{cases}$$
$$5y=5 \Rightarrow y=1$$

នាំឱ្យ $x=1+3y=1+3=4$

ដូចនេះ **ប្រព័ន្ធសមីការមានគូចម្លើយ $x=4 \wedge y=1$** ។

$b/\ \begin{cases}4^x\cdot 3^{y+1}+27^y=171\\8^x+2^x\cdot 3^{1+2y}=172\end{cases}$ យើងអាចសរសេរជា

$\begin{cases}(2^x)^2\cdot 3\cdot 3^y+(3^y)^3=171\\(2^x)^3+2^x\cdot 3\cdot(3^y)^2=172\end{cases}$ រៀបឱ្យតាមលំដាប់

ដោយបូកអង្គនឹងអង្គ :

$$+\begin{cases}3\cdot(2^x)^2\cdot 3^y+(3^y)^3=171\\(2^x)^3+3\cdot 2^x\cdot(3^y)^2=172\end{cases}$$
$$(2^x)^3+3\cdot(2^x)^2\cdot 3^y+3\cdot 2^x\cdot(3^y)^2+(3^y)^3=343$$
$$(2^x+3^y)^3=7^3$$
$$2^x+3^y=7 \quad (i)$$

ដោយដកអង្គនឹងអង្គ :

$$-\begin{cases}3\cdot(2^x)^2\cdot 3^y+(3^y)^3=171\\(2^x)^3+3\cdot 2^x\cdot(3^y)^2=172\end{cases}$$
$$(3^y)^3-3\cdot 2^x\cdot(3^y)^2+3\cdot(2^x)^2\cdot 3^y-(2^x)^3=-1$$
$$(3^y-2^x)^3=(-1)^3$$
$$3^y-2^x=-1 \quad (ii)$$

ដោយយក $(i)+(ii)$ យើងបាន :

$$+\begin{cases}2^x+3^y=7\\3^y-2^x=-1\end{cases}$$
$$2\cdot 3^y=2\cdot 3$$
$$3^y=3 \quad \Rightarrow y=1$$

ចំពោះ $y=1$ នោះ $2^x+3^y=7$

$$2^x=7-3$$
$$2^x=2^2 \quad \Rightarrow x=2$$

ដូចនេះ **ប្រព័ន្ធសមីការមានគូចម្លើយ $x=2$ និង $y=1$** ។

## ៤៦. រកចំនួនមានលេខប្រាំខ្ទង់នោះ

-ចំនួនតាមខ្ទង់នីមួយៗត្រូវតែ ធំជាង0 (ព្រោះខ្ទង់ដើមគឺ $x$ បើ $x=0$ វាពុំមែនជាលេខប្រាំខ្ទង់ទេ វាគឺជាលេខបួនខ្ទង់ ) និងតូចជាង ឬស្មើ 9 (ព្រោះ បើធំជាង៩ វាជាលេខច្រើនខ្ទង់ នាំឱ្យចំនួនខ្ទង់លើសពី៥) ។

យើងមានចំនួន : $x\,,\,x+1\,,\,x+2\,,\,3x\,,\,x+3$ នាំឱ្យ

$$\begin{cases}0<x\le 9\\0<x+1\le 9\\0<x+2\le 9\\0<3x\le 9\\0<x+3\le 9\end{cases} \text{ សមមូល } \begin{cases}0<x\le 9\\0<x\le 8\\0<x\le 7\\0<x\le 3\\0<x\le 6\end{cases}$$

តាមរយៈលក្ខខណ្ឌទាំង៥ខាងលើ លក្ខខណ្ឌរួមគឺ $0<x\le 3$

មានន័យថា : $x=\{1\,,\,2\,,\,3\}$

ចំពោះ $x=1$ ចំនួននោះគឺ 12334 មិនយក (ព្រោះមិនជាការេប្រាកដ)

ចំពោះ $x=2$ ចំនួននោះគឺ 23465 មិនយក (ព្រោះមិនជាការេប្រាកដ)

ចំពោះ $x=3$ ចំនួននោះគឺ $34596=186^2$ (ជាការេប្រាកដ)

ដូចនេះ **ចំនួនមានលេខប្រាំខ្ទង់នោះគឺ 34596** ។

## ៤៧. គណនាផលបូក $S$ : យើងមាន

$$S=\frac{1}{1+\sqrt2}+\frac{1}{\sqrt2+\sqrt3}+\frac{1}{\sqrt3+\sqrt4}+\dots+\frac{1}{\sqrt{2024}+\sqrt{2025}}$$

ពិនិត្យ រួចបូកអង្គនិងអង្គ នៃកន្សោមខាងក្រោម

$$(\sqrt2-1)(\sqrt2+1)=1 \quad \Rightarrow \frac{1}{\sqrt2+1}=\sqrt2-1$$
$$(\sqrt3-\sqrt2)(\sqrt3+\sqrt2)=1 \quad \Rightarrow \frac{1}{\sqrt3+\sqrt2}=\sqrt3-\sqrt2$$
$$(\sqrt4-\sqrt3)(\sqrt4+\sqrt3)=1 \quad \Rightarrow \frac{1}{\sqrt4+\sqrt3}=\sqrt4-\sqrt3$$

.......................................................................................

$$(\sqrt{2025}-\sqrt{2024})(\sqrt{2025}+\sqrt{2024})=1 \Rightarrow \frac{1}{\sqrt{2025}+\sqrt{2024}}=\sqrt{2025}-\sqrt{2024}$$
$$S=\frac{1}{1+\sqrt2}+\frac{1}{\sqrt2+\sqrt3}+\dots+\frac{1}{\sqrt{2024}+\sqrt{2025}}=\sqrt{2025}-1$$
$$=45-1=44$$

ដូចនេះ **ផលបូកគណនាបាន $S=44$** ។



www.facebook.com/7khmer
fb : Entertainment And Knowledge

**៤៨.** **ស្រាយបញ្ជាក់ថា** : $f(n)=3^{2n}+7$ **ចែកដាច់នឹង** 8

យើងមាន $f(n)=3^{2n}+7$

ចំពោះ $n=0: f(0)=3^0+7=1+7=8$ ចែកដាច់នឹង 8

$n=1: f(1)=3^2+7=9+7=16$ ចែកដាច់នឹង 8

.................................................................

ឧបមាថា វាពិតដល់ $n=k: f(k)=3^{2k}+7$ ចែកដាច់នឹង8

យើងនឹងស្រាយបញ្ជាក់ថា $n=k+1$ ក៏ចែកដាច់នឹង8 ដែរ

ចំពោះ $n=k+1: f(k+1)=3^{2(k+1)}+7$

$=3^{2k+2}+7$

$=9\cdot 3^{2k}+7$

$=8\cdot 3^{2k}+(3^{2k}+7)$

ដោយ $8\cdot 3^{2k}$ ចែកដាច់នឹង8 (ព្រោះ $8\cdot 3^{2k}$ ជាពហុគុណនៃ8 )

និង $3^{2k}+7$ ចែកដាច់នឹង8 (ឧបមាថាពិត ខាងលើ )

នាំឱ្យ $f(k+1)=8\cdot 3^{2k}+(3^{2k}+7)$ ចែកដាច់នឹង 8

ដូចនេះ $f(n)=3^{2n}+7$ ចែកដាច់នឹង8 គ្រប់ $n$ ជាចំនួនគត់ ។

***យើងអាចបកស្រាយតាមវិធីម្យ៉ាងទៀត***

$9\equiv 1\,[8]$ (មានន័យថា 9 ចែកដាច់នឹង 8 ឱ្យសំណល់ 1 )

$9^n\equiv 1^n\,[8]$ (អាចលើកជាស្វ័យគុណបាន គ្រប់ $n$ ជាចំនួនគត់)

$3^{2n}\equiv 1\,[8]$ (ព្រោះ $9=3^2$ ហើយ $1^n=1$ )

$3^{2n}+7\equiv 1+7\,[8]$ សមមូល $3^{2n}+7\equiv 8\,[8]$

តែ $8\equiv 0\,[8]$ នាំឱ្យ $3^{2n}+7\equiv 0\,[8]$ ដែរ

ដូចនេះ $f(n)=3^{2n}+7$ ចែកដាច់នឹង8 គ្រប់ $n$ ជាចំនួនគត់ ។

**៤៩.** **គណនា** $g(3)$ :

យើងមាន $f(x)=2x+1$

ឱ្យ $f(x)=3$ សមមូល $2x+1=3 \Rightarrow x=1$

ហើយមាន $g[f(x)]=x^2+3x+1$

នាំឱ្យ $g(3)=1^2+3\cdot 1+1$ (ព្រោះ $f(x)=3$ និង $x=1$ )

$g(3)=5$

ដូចនេះ ក្រោយពីគណនា $g(3)=5$ ។

**៥០.** **ស្រាយបំភ្លឺថា** $\frac{n}{3}+\frac{n^2}{2}+\frac{n^3}{6}$ **ជាចំនួនគត់វិជ្ជមាន**

តាង $A=\frac{n}{3}+\frac{n^2}{2}+\frac{n^3}{6}$

យើងបាន $A=\frac{2n+3n^2+n^3}{6}$

$=\frac{n(2+3n+n^2)}{6}$

$=\frac{n(n+1)(n+2)}{6}$

បើ $A$ ជាចំនួនគត់ លុះត្រាតែ $n(n+1)(n+2)$ ចែកដាច់នឹង6

មានន័យថា $n(n+1)(n+2)$ ចែកដាច់នឹង 2 ផង និង3 ផង

-បើ $n$ ជាចំនួនគត់ នោះ$n,(n+1),(n+2)$ ជាបីចំនួនគត់តគ្នា

-បីចំនួនគត់តគ្នាយ៉ាងហោចណាស់ ក៏មានចំនួនគូមួយដែរ

នាំឱ្យ $n(n+1)(n+2)$ ចែកដាច់នឹង2

-បីចំនួនគត់តគ្នាយ៉ាងហោចណាស់ ក៏មានចំនួនមួយជាពហុគុណនៃ3 ដែរ នាំឱ្យ $n(n+1)(n+2)$ ចែកដាច់នឹង2

នោះយើងបាន $n(n+1)(n+2)$ ចែកដាច់នឹង6

ដូចនេះ គ្រប់ចំនួនគត់វិជ្ជមាន $n$ នោះ $\frac{n}{3}+\frac{n^2}{2}+\frac{n^3}{6}$ ក៏ជាចំនួនគត់វិជ្ជមានដែរ ។

**៥១.** **គណនា** $S=\frac{1}{1\cdot 2}+\frac{1}{2\cdot 3}+\frac{1}{3\cdot 4}+...+\frac{1}{2010\cdot 2011}$

ពិនិត្យ : $\frac{1}{n}-\frac{1}{n+1}=\frac{n+1-n}{n(n+1)}=\frac{1}{n(n+1)}$

តាមលំនាំខាងលើគេអាចបំបែកបាន ដូចខាងក្រោម :

បូកអង្គនឹងអង្គ
$$\begin{cases}\frac{1}{1\cdot 2}=\frac{1}{1}-\frac{1}{2}\\ \frac{1}{2\cdot 3}=\frac{1}{2}-\frac{1}{3}\\ \frac{1}{3\cdot 4}=\frac{1}{3}-\frac{1}{4}\\ \dots\dots\dots\dots\\ \frac{1}{2010\cdot 2011}=\frac{1}{2010}-\frac{1}{2011}\end{cases}$$

$$\frac{1}{1\cdot 2}+\frac{1}{2\cdot 3}+\frac{1}{3\cdot 4}+...+\frac{1}{2010\cdot 2011}=\frac{1}{1}-\frac{1}{2011}$$



www.facebook.com/7khmer
fb : Entertainment And Knowledge

ឬ $\frac{1}{1\cdot2}+\frac{1}{2\cdot3}+\frac{1}{3\cdot4}+\dots+\frac{1}{2010\cdot2011}=\frac{2010}{2011}$

ដូចនេះ **ក្រោយពីគណនាផលបូក $S=\frac{2010}{2011}$** ។

### ៥២. គណនា $x^{2011}+\frac{1}{x^{2011}}$

យើងមាន $x^2+x+1=0$ ទាញបាន $x+\frac{1}{x}=-1$ នោះ

- $\left(x+\frac{1}{x}\right)\left(x+\frac{1}{x}\right)=(-1)(-1)\Leftrightarrow x^2+2+\frac{1}{x^2}=1\Leftrightarrow x^2+\frac{1}{x^2}=-1$
- $\left(x+\frac{1}{x}\right)\left(x^2+\frac{1}{x^2}\right)=(-1)(-1)\Leftrightarrow x^3+\frac{1}{x^3}+x+\frac{1}{x}=1\Leftrightarrow x^3+\frac{1}{x^3}=2$
- $\left(x+\frac{1}{x}\right)\left(x^3+\frac{1}{x^3}\right)=(-1)\cdot2\Leftrightarrow x^4+\frac{1}{x^4}+x^2+\frac{1}{x^2}=-2\Leftrightarrow x^4+\frac{1}{x^4}=-1$
- $\left(x+\frac{1}{x}\right)\left(x^4+\frac{1}{x^4}\right)=(-1)(-1)\Leftrightarrow x^5+\frac{1}{x^5}+x^3+\frac{1}{x^3}=1\Leftrightarrow x^5+\frac{1}{x^5}=-1$
- $\left(x+\frac{1}{x}\right)\left(x^5+\frac{1}{x^5}\right)=(-1)(-1)\Leftrightarrow x^6+\frac{1}{x^6}+x^4+\frac{1}{x^4}=1\Leftrightarrow x^6+\frac{1}{x^6}=2$

..............................................................................................

តាមលំនាំនេះ យើងអាចទាញបានតួទូទៅគឺ ៖

- $x^n+\frac{1}{x^n}=\begin{cases}-1 & \text{បើ } n\neq 3k\\ 2 & \text{បើ } n=3k\end{cases}$ ដែល $k$ ជាចំនួនគត់ធម្មជាតិ

ដោយ $2011=3\cdot670+1$ មានទម្រង់ខុសពី $3k$

នាំឱ្យ $x^{2011}+\frac{1}{x^{2011}}=-1$

ដូចនេះ **ក្រោយពីគណនា ឃើញថា $x^{2011}+\frac{1}{x^{2011}}=-1$** ។

### ៥៣. រកចំនួន $\overline{abcd}$ នោះ

តាមបម្រាប់ប្រធាន ចំនួន $\overline{abcd}$ ជាការេប្រាកដ

យើងបាន $\overline{abcd}=n^2$ ដែល $n$ ជាចំនួនគត់

យើងសរសេរបាន $\overline{ab00}+\overline{cd}=n^2$

នោះទាញបាន $100\overline{ab}+\overline{cd}=n^2$ (1)

បម្រាប់បន្ថែម $\overline{ab}-\overline{cd}=1$ ឬ $\overline{ab}=1+\overline{cd}$ (2)

យក (2) ជំនួសក្នុង (1) ៖

$$100(1+\overline{cd})+\overline{cd}=n^2$$
$$100+100\overline{cd}+\overline{cd}=n^2$$
$$101\overline{cd}=n^2-100$$
$$\overline{cd}=\frac{(n-10)(n+10)}{101}$$

-យល់ថា ៖ $\overline{cd}$ ជាចំនួនគត់ នោះត្រូវតែមានកត្តាមួយ ក្នុងចំណោមកត្តា$(n-10)$និង $(n+10)$ដែលត្រូវតែចែកដាច់នឹង 101 ព្រោះ 101ជាចំនួនបឋម ។ នោះយើងទាញបាន ៖

$$n-10=101 \text{ ឬ } n+10=101$$

នាំឱ្យ $n=111$ ឬ $n=91$

-ចំពោះ $n=111$ មិនយក ព្រោះ $n^2$ ជាលេខ៥ខ្ទង់ នោះ $n<100$

-ចំពោះ $n=91$ នោះ $n^2=8281$ យក

ដូចនេះ **ចំនួននោះគឺ $\overline{abcd}=n^2=8281$** ។

### ៥៤. បង្ហាញថា $n!>3^n$ ចំពោះ $n\geq7$

យើងមាន $n!>3^n$

-ចំពោះ $n=7$ នោះ $7!=5040>3^7=2187$ ៖ ពិត

-ចំពោះ $n=8$ នោះ $8!=40320>3^8=6561$ ៖ ពិត

..............................................................................................

-ឧបមាថាវាពិតរហូតដល់ $n=k$ នោះ $k!>3^k$ ៖ ពិត

-យើងនឹងស្រាយបញ្ជាក់ថា វានៅតែពិតចំពោះ $n=k+1$

យើងបាន $(k+1)!>3^{k+1}$

$$(k+1)\cdot k!>3\cdot3^k$$

ដោយ $k!>3^k$ ហើយ $(k+1)>7>3$

នោះយើងបាន $(k+1)\cdot k!>3\cdot3^k$ គឺជាការពិត

ដូចនេះ **ឃើញថា $n!>3^n$ ចំពោះគ្រប់ចំនួនពិតវិជ្ជមាន $n\geq7$** ។

-ព្រោះបើ $k!>3^k$ និង $(k+1)>3$ នាំឱ្យ $(k+1)k!>3\cdot3^k$ ឬ $(k+1)!>3^{k+1}$ ។

### ៥៥. បង្ហាញឱ្យឃើញថា $f$ ជាអនុគមន៍ខួប

អនុគមន៍ $f$ មានដែនកំណត់ $D=[0\,,+\infty)$

ចំពោះ គ្រប់$x\in D$ នោះ $x+2a\in D$ ព្រោះ $a>0$

យើងមាន ៖ $f(x+a)=\frac{1}{2}+\sqrt{f(x)-f(x)^2}$

នាំឱ្យ $f(x+2a)=f((x+a)+a)$

$$=\frac{1}{2}+\sqrt{f(x+a)-f(x+a)^2}$$
$$=\frac{1}{2}+\sqrt{\left(\frac{1}{2}+\sqrt{f(x)-f(x)^2}\right)-\left(\frac{1}{2}+\sqrt{f(x)-f(x)^2}\right)^2}$$



www.facebook.com/7khmer
fb : Entertainment And Knowledge

$=\frac{1}{2}+\sqrt{\left(\frac{1}{2}+\sqrt{f(x)-f(x)^2}\right)-\left(\frac{1}{4}+\sqrt{f(x)-f(x)^2}+f(x)-f(x)^2\right)}$

$=\frac{1}{2}+\sqrt{\frac{1}{2}+\sqrt{f(x)-f(x)^2}-\frac{1}{4}-\sqrt{f(x)-f(x)^2}-f(x)+f(x)^2}$

$=\frac{1}{2}+\sqrt{\frac{1}{4}-f(x)+f(x)^2}$

$=\frac{1}{2}+\sqrt{\left(f(x)-\frac{1}{2}\right)^2}$

$=\frac{1}{2}+f(x)-\frac{1}{2}$

$=f(x)$

ព្រោះ $f(x)\geq\frac{1}{2}$ ចំពោះ $x\geq 0$

យើងបាន $f(x+2a)=f(x)$ ចំពោះ គ្រប់ $x\in[0,+\infty)$

ដូចនេះ **អនុគមន៍ $f$ ជាអនុគមន៍ខួបនៅលើ $[0,+\infty)$** ។

## ៥៦. បង្ហាញឱ្យឃើញថា $0!=1$

យើងមាន : $n!=n\times(n-1)\times(n-2)\times\ldots\times 3\times 2\times 1$

វាពិតចំពោះ $n$ ជាចំនួនគត់វិជ្ជមាន

មានន័យថា $n=\{1,2,3,\ldots\}$

យើងអាចសរសេរបានដូចទម្រង់ខាងក្រោម :

$n!=n\times(n-1)!$

ព្រោះដោយសារ $(n-1)!=(n-1)\times(n-2)\times\ldots\times 3\times 2\times 1$

យើងទាញបាន $(n-1)!=\frac{n!}{n}$

គណនាតម្លៃជាលេខ ចំពោះ $n=1$

នាំឱ្យ $(1-1)!=\frac{1!}{1} \Leftrightarrow 0!=\frac{1}{1}=1$

ដូចនេះ **ឃើញថា $0!=1$ ពិតប្រាកដមែន** ។

ព្រោះ $1!=1$

## ៥៧. បង្ហាញថា $F=\frac{21n+4}{14n+3}$ ជាប្រភាគសម្រួលមិនបាន

តាង $d$ ជាតួចែករួមធំបំផុតនៃ $21n+4$ និង $14n+3$

យើងបាន $21n+4=ad$ ដែល $a$ ជាចំនួនគត់វិជ្ជមាន

$14n+3=bd$ ដែល $b$ ជាចំនួនគត់វិជ្ជមាន

ចងជាប្រព័ន្ធ $\begin{cases}21n+4=ad & (\times 2)\\ 14n+3=bd & (\times 3)\end{cases}$

$\Leftrightarrow\begin{cases}42n+8=2ad & (i)\\ 42n+9=3bd & (ii)\end{cases}$

ដោយយក $(ii)-(i)$ យើងបាន :

$$-\begin{cases}42n+9=3bd\\ 42n+8=2ad\end{cases}$$
$$1=(3b-2a)d$$

ដោយ $a$ និង $b$ ជាចំនួនគត់ នោះ $3b-2a$ ក៏ជាចំនួនគត់ដែរ

ហើយ $d$ ជាតួចែករួមធំបំផុត ត្រូវតែជាចំនួនគត់

-យល់ថា : ផលគុណពីរចំនួនគត់ស្មើ 1 មានតែមួយករណីគត់ គឺចំនួនគត់នីមួយៗស្មើគ្នា ហើយស្មើនឹង 1 ។

ទាញបាន $d=1$

ដូចនេះ **$F=\frac{21n+4}{14n+3}$ ជាប្រភាគសម្រួលមិនបាន** ។

## ៥៨. រកចំនួនគត់ធម្មជាតិតូចបំផុត

-តាមបម្រាប់ : យើងពុំដឹងចំនួនខ្ទង់ នៃចំនួននោះទេ តែវាមានលេខ 6 នៅខ្ទង់ឯកតា ( ខ្ទង់រាយ)

-យើងអាចតាងចំនួននោះដោយ : $\overline{a_1a_2a_3\ldots a_n6}$ ដែលទីនេះ $0\leq a_1,a_2,a_3,\ldots a_n\leq 9$ និង $\overline{a_1a_2a_3\ldots a_n}$ ជាចំនួនគត់

-យើងបានចំនួនថ្មី $\overline{6a_1a_2a_3\ldots a_n}$

-តាមបម្រាប់យើងបានទំនាក់ទំនង :

$$4\times\overline{a_1a_2a_3\ldots a_n6}=\overline{6a_1a_2a_3\ldots a_n}$$
$$4\left(\overline{a_1a_2a_3\ldots a_n0}+6\right)=6000\ldots0+\overline{a_1a_2a_3\ldots a_n}$$
$$4\left(\overline{a_1a_2a_3\ldots a_n}\times 10+6\right)=6\times 10^n+\overline{a_1a_2a_3\ldots a_n}$$

ដើម្បីឱ្យងាយស្រួលក្នុងការសរសេរ តាង $\overline{a_1a_2a_3\ldots a_n}=A$

យើងបាន : $4(10A+6)=6\cdot 10^n+A$

$40A+24=6\cdot 10^n+A$

$39A=6\cdot 10^n-24$

$A=\frac{2\cdot 10^n-8}{13}=\frac{2(10^n-4)}{13}$

-ដោយ $A$ ជាចំនួនគត់ ហើយ 2 ចែកមិនដាច់នឹង 13 នោះ មានតែ $10^n-4$ ចែកដាច់នឹង 13



www.facebook.com/7khmer
fb : Entertainment And Knowledge

-យើងនឹងឱ្យតម្លៃ $n$ បន្តបន្ទាប់តូចបំផុតដើម្បីឱ្យ $13|10^n-4$

( មានន័យថា 13 ជាតួចែកនៃ $10^n-4$ )

-ចំពោះ $n=1:10-4=6$ ចែកមិនដាច់នឹង 13

$n=2:100-4=96$ ចែកមិនដាច់នឹង 13

$n=3:1000-4=996$ ចែកមិនដាច់នឹង 13

$n=4:10000-4=9996$ ចែកមិនដាច់នឹង 13

$n=5:100000-4=99996$ ចែកដាច់នឹង 13

..............................................................................

-ចំពោះ $n=5$ យើងបាន $A=\dfrac{2(10^5-4)}{13}=15384$

ដូចនេះ **ចំនួននោះគឺ 153846** ។

## ៥៩. តើបុរសណា ជាគូនឹងនារីណា ?

-ឃើញថាមានបុរសបីនាក់ចូលស្តីដណ្តឹងនារីបីនាក់ ។ បុរសដែលចូលស្តីដណ្តឹងដំបូង មានជម្រើសបី បុរសចូលស្តីបន្ទាប់មានជម្រើសពីរ និងបុរសចុងក្រោយមានជម្រើសតែមួយគត់

-តាមគោលការណ៍ផលគុណ : ចំនួនជម្រើសទាំងអស់គឺ

$3\times2\times1=3!=6$ ជម្រើស ដែលជម្រើសទាំងនោះរួមមាន:

1) $A$ ជាគូនឹង1 , $B$ ជាគូនឹង2 , $C$ ជាគូនឹង3 (ខុសលក្ខខណ្ឌ គ)

2) $A$ ជាគូនឹង1 , $B$ ជាគូនឹង3 , $C$ ជាគូនឹង2 (ខុសលក្ខខណ្ឌ ក)

3) $A$ ជាគូនឹង2 , $B$ ជាគូនឹង1 , $C$ ជាគូនឹង3 (ខុសលក្ខខណ្ឌ គ)

4) $A$ ជាគូនឹង2 , $B$ ជាគូនឹង3 , $C$ ជាគូនឹង1 (ខុសលក្ខខណ្ឌ គ)

5) $A$ ជាគូនឹង3 , $B$ ជាគូនឹង1 , $C$ ជាគូនឹង2 (ខុសលក្ខខណ្ឌ ខ)

6) $A$ ជាគូនឹង3 , $B$ ជាគូនឹង2 , $C$ ជាគូនឹង1

-ឃើញថាដើម្បីគោរពតាមលក្ខខណ្ឌមានតែមួយជម្រើសមួយគត់គឺ:

$A$ ជាគូនឹង3 , $B$ ជាគូនឹង2 , $C$ ជាគូនឹង1

ដូចនេះ គូស្វាមីភរិយាថ្មី ដែលគោរពតាមលក្ខខណ្ឌគឺ :

**បុរស $A$ ជាគូនឹងនារី3 បុរស $B$ ជាគូនឹងនារី2 បុរស $C$ ជាគូនឹងនារី1** ។

## ៦០. រក 11 ចំនួននោះ ដែលមិនអវិជ្ជមាន

តាង11ចំនួននោះដោយ : $x_1\ ,\ x_2\ ,\ x_3\ ,\ \dots\ ,\ x_{11}\ge 0$

តាមបម្រាប់ប្រធាន យើងបាន :

$x_1=(x_2+x_3+x_4+\dots+x_{11})^2$ (1)

$x_2=(x_1+x_3+x_4+\dots+x_{11})^2$ (2)

$x_3=(x_1+x_2+x_4+..+x_{11})^2$ (3)

............................................ ...

$x_{11}=(x_1+x_2+x_3+..+x_{10})^2$ (11)

-ដោយដកអង្គនិងអង្គនៃ (1)-(2) យើងបាន :

$$x_1-x_2=(x_2+x_3+x_4+\dots+x_{11})^2-(x_1+x_3+x_4+\dots+x_{11})^2$$

តាមរូបមន្ត $a^2-b^2=(a-b)(a+b)$ នោះ

$$x_1-x_2=[(x_2+x_3+x_4+\dots+x_{11})-(x_1+x_3+x_4+\dots+x_{11})]\times[(x_2+x_3+x_4+\dots+x_{11})+(x_1+x_3+x_4+\dots+x_{11})]$$

$$=(x_2-x_1)(x_1+x_2+2x_3+2x_4+\dots+2x_{11})^2$$

$$=-(x_1-x_2)(x_1+x_2+2x_3+2x_4+\dots+2x_{11})^2$$

$$(x_1-x_2)+(x_1-x_2)(x_1+x_2+2x_3+2x_4+\dots+2x_{11})^2=0$$

$$(x_1-x_2)(1+x_1+x_2+2x_3+2x_4+\dots+2x_{11})^2=0$$

នាំឱ្យ $(x_1-x_2)=0\Rightarrow x_1=x_2$

ហើយ $(1+x_1+x_2+2x_3+2x_4+\dots+2x_{11})^2\neq 0$

ដោយយក (1)-(3) , (1)-(4), . . . . , (1)-(11) តាមលំនាំខាងលើនោះយើងបាន : $x_1=x_2=x_3=\dots=x_{11}$

នាំឱ្យ $x_1=(x_1+x_1+x_1+\dots+x_1)^2$

$x_1=(10x_1)^2$

$x_1=100x_1^2$

$x_1(1-100x_1)=0$

ទាញបាន $x_1=0$ , $1-100x_1=0\Rightarrow x_1=\dfrac{1}{100}$

ដូចនេះ **ចំនួនទាំង 11 ដែលរកឃើញគឺ**

$x_1=x_2=x_3=\dots=x_{11}=0$ ឬ

$x_1=x_2=x_3=\dots=x_{11}=\dfrac{1}{100}$ ។



www.facebook.com/7khmer
fb : Entertainment And Knowledge

**៦១.** **គណនា** $A=(a-1)^{2010}+(b-1)^{2011}+(a-1)^{2012}$

គេឱ្យ $a$ , $b$ , $c$ ផ្ទៀងផ្ទាត់ $\begin{cases} a+b+c=0 \\ ab+bc+ca=0 \end{cases}$

ចំពោះ $a+b+c=0$

$(a+b+c)^2=0$

$a^2+b^2+c^2+2(ab+bc+ca)=0$

ដោយ $ab+bc+ca=0$ នោះយើងបាន

$a^2+b^2+c^2=0$

-យល់ថា : ផលបូកការេនៃមួយចំនួនពិតស្មើ 0 មានន័យថា ចំនួនពិតទាំងនោះមានតម្លៃស្មើៗគ្នា ហើយស្មើនឹង 0

-នាំឱ្យ $a=b=c=0$

គេបាន : $A=(a-1)^{2010}+(b-1)^{2011}+(a-1)^{2012}$

$=(0-1)^{2010}+(0-1)^{2011}+(0-1)^{2012}$

$=1+(-1)+1=1$

ដូចនេះ ក្រោយពីគណនាឃើញថា $A=1$ ។

**៦២.** **គណនា**

$$S=\sqrt{1+\frac{1}{1^2}+\frac{1}{2^2}}+\sqrt{1+\frac{1}{2^2}+\frac{1}{3^2}}+...+\sqrt{1+\frac{1}{2010^2}+\frac{1}{2011^2}}$$

ឃើញថា $S$ ជាផលបូកមានតួទូទៅគឺ $\sqrt{1+\frac{1}{n^2}+\frac{1}{(n+1)^2}}$

ដែលមានចំនួនតួសរុប 2010 តួ

គេអាចសរសេរជា $S=\sum_{n=1}^{2010}\sqrt{1+\frac{1}{n^2}+\frac{1}{(n+1)^2}}$

$$S=\sum_{n=1}^{2010}\sqrt{1+\frac{1}{n^2}+\frac{1}{(n+1)^2}}$$

$$=\sum_{n=1}^{2010}\sqrt{\frac{n^2(n+1)^2+(n+1)^2+n^2}{n^2(n+1)^2}}$$

$$=\sum_{n=1}^{2010}\sqrt{\frac{n^2(n^2+2n+1)+(n^2+2n+1)+n^2}{n^2(n+1)^2}}$$

$$=\sum_{n=1}^{2010}\sqrt{\frac{n^4+2n^3+n^2+n^2+2n+1+n^2}{n^2(n+1)^2}}$$

$$=\sum_{n=1}^{2010}\sqrt{\frac{n^4+2n^3+3n^2+2n+1}{n^2(n+1)^2}}$$

$$=\sum_{n=1}^{2010}\sqrt{\frac{n^4+n^3+n^2+n^3+n^2+n+n^2+n+1}{n^2(n+1)^2}}$$

$$=\sum_{n=1}^{2010}\sqrt{\frac{n^2(n^2+n+1)+n(n^2+n+1)+(n^2+n+1)}{n^2(n+1)^2}}$$

$$=\sum_{n=1}^{2010}\sqrt{\frac{(n^2+n+1)^2}{n^2(n+1)^2}}$$

$$=\sum_{n=1}^{2010}\frac{n^2+n+1}{n(n+1)}=\sum_{n=1}^{2010}\frac{n(n+1)+1}{n(n+1)}=\sum_{n=1}^{2010}\left[1+\frac{1}{n(n+1)}\right]$$

$$=\sum_{n=1}^{2010}1+\sum_{n=1}^{2010}\frac{1}{n(n+1)}=2010+\sum_{n=1}^{2010}\left(\frac{1}{n}-\frac{1}{n+1}\right)$$

យើងបាន $S=2010+\sum_{n=1}^{2010}\left(\frac{1}{n}-\frac{1}{n+1}\right)$

$=2010+\left(\frac{1}{1}-\frac{1}{2011}\right)$

$=2011-\frac{1}{2011}=\frac{2011^2-1^2}{2011}$

$=\frac{(2011-1)(2011+1)}{2011}=\frac{2010\cdot 2012}{2011}$

ដូចនេះ ក្រោយពីគណនាផលបូក $S=\frac{2010\cdot 2012}{2011}$ ។

* មូលហេតុ $\sum_{n=1}^{2010}\left(\frac{1}{n}-\frac{1}{n+1}\right)=\left(\frac{1}{1}-\frac{1}{2011}\right)$ មើលលំហាត់ទី៥១ ។

**៦៣.** **ដោះស្រាយសមីការ :**

ក. $x^{2010}+x^{2011}+x^{2012}+x^{2013}=4$

$(x^{2010}-1)+(x^{2011}-1)+(x^{2012}-1)+(x^{2013}-1)=0$

តាមរូបមន្ត: $a^n-1=(a-1)(a^{n-1}+a^{n-2}+...+a+1)$

- $x^{2010}-1=(x-1)(x^{2009}+x^{2008}+...+x+1)$
- $x^{2011}-1=(x-1)(x^{2010}+x^{2009}+...+x+1)$
- $x^{2012}-1=(x-1)(x^{2011}+x^{2010}+...+x+1)$
- $x^{2013}-1=(x-1)(x^{2012}+x^{2011}+...+x+1)$

ដើម្បីឱ្យងាយសម្រួលក្នុងការសរសេរ យើងតាង

$X=x^{2009}+x^{2008}+...+x+1$ នោះយើងបាន

$$+\begin{cases} x^{2010}-1=(x-1)X \\ x^{2011}-1=(x-1)(x^{2010}+X) \\ x^{2012}-1=(x-1)(x^{2011}+x^{2010}+X) \\ x^{2013}-1=(x-1)(x^{2012}+x^{2011}+x^{2010}+X) \end{cases}$$



www.facebook.com/7khmer
fb : Entertainment And Knowledge

$$(x^{2010}-1)+(x^{2011}-1)+(x^{2012}-1)+(x^{2013}-1)=(x-1)(x^{2012}+2x^{2011}+3x^{2010}+4X)$$

នាំឱ្យ $(x-1)(x^{2012}+2x^{2011}+3x^{2010}+4X)=0$

ទាញបាន : • $x-1=0 \Rightarrow x=1$

• $x^{2012}+2x^{2011}+3x^{2010}+4X\neq 0$

ព្រោះ $x$ ជាចំនួនគត់

ដូចនេះ **សមីការមានឫស $x=1$** ។

ខ. $x^{2010}+x^{2011}+x^{2012}+x^{2013}=0$

$$x^{2010}(1+x+x^2+x^3)=0$$

ទាញបាន : • $x^{2010}=0 \Rightarrow x=0$

• $1+x+x^2+x^3\neq 0$ (ព្រោះ $x$ ជាចំនួនគត់)

ដូចនេះ **សមីការមានឫស $x=0$** ។

## ៦៨. ដោះស្រាយសមីការ : $\overline{2x9y}=2^x\cdot 9^y$

-លក្ខខណ្ឌ $0\le x\le 9$ , $0\le y\le 9$ និង $x,y$ ជាចំនួនគត់

-ពិនិត្យ $2^x$ ជាចំនួនគូ នោះ $2^x\cdot 9^y$ ជាចំនួនគូដែរ

នាំឱ្យ $\overline{2x9y}$ ជាចំនួនគូ មានន័យថា $y$ ជាចំនួនគូ ឬ 0 (1)

-ពិនិត្យ បើ $y>4$ នោះ $9^4=6561>\overline{2x9y}$ នាំឱ្យ

$y$ ជាចំនួនគត់តូចជាង៤ មានន័យថា $y=\{0,1,2,3\}$ (2)

-តាម (1) និង (2) ទាញបាន $y=0$ ឬ $y=2$

-ចំពោះ $y=0$ នោះ $\overline{2x90}=2^x\cdot 1 \Leftrightarrow \overline{2x90}=2^x$

តែ $2^x$ ជាចំនួនមិនមានលេខ 0 នៅខាងចុងជាដាច់ខាត

នាំឱ្យ $\overline{2x90}=2^x$ ជាករណីមិនពិត គ្រប់ $x$ ជាចំនួនគត់

-ចំពោះ $y=2$ នោះ $\overline{2x92}=2^x\cdot 9^2 \Leftrightarrow \overline{2x92}=81\cdot 2^x$

ដោយចំនួន $81\cdot 2^x$ ជាពហុគុណនៃ9 នោះ $\overline{2x92}$ ជាពហុគុណនៃ9 ដែរ មានន័យថា $\overline{2x92}$ ចែកដាច់នឹង9 ។

-ហើយ $\overline{2x92}$ ចែកដាច់នឹង9 លុះត្រាផលបូកលេខតាមខ្ទង់ គឺ $2+x+9+2=13+x=1+3+x=4+x$ ចែកដាច់នឹង9

មានតែ ចំនួនគត់ $x=5$ តែមួយគត់ដែលនាំឱ្យ $4+x$ ចែកដាច់នឹង9 ( ព្រោះ $0\le x\le 9$ )

-ផ្ទៀងផ្ទាត់ : $\overline{2x9y}=2^x\cdot 9^y$

$$2592=2^5\cdot 9^2$$
$$2592=32\cdot 81$$
$$2592=2592$$

ដូចនេះ **សមីការមានចម្លើយ $x=5, y=2$** ។

( កុំឃើញវែងថាពិបាក គេគ្រាន់តែសម្រាយឱ្យយើងយល់ពីមូលហេតុរបស់វាបានច្បាស់លាស់ប៉ុណ្ណោះ )

## ៦៩. រកគ្រប់ចំនួនគត់ធម្មជាតិ $N=\overline{a_1a_2a_3...a_n}$

យើងមាន $\dfrac{\overline{2a_1a_2a_3...a_n1}}{\overline{1a_1a_2a_3...a_n2}}=\dfrac{21}{12}$ ដែល

$N=\overline{a_1a_2a_3...a_n}$ មានចំនួន $n$ តួ នាំឱ្យយើងបាន :

• $\overline{2a_1a_2a_3...a_n1}=2\cdot 10^{n+1}+10(\overline{a_1a_2a_3...a_n})+1$

$=2\cdot 10^{n+1}+10N+1$

• $\overline{1a_1a_2a_3...a_n2}=1\cdot 10^{n+1}+10(\overline{a_1a_2a_3...a_n})+2$

$=10^{n+1}+10N+2$

យើងបាន $\dfrac{2\cdot 10^{n+1}+10N+1}{10^{n+1}+10N+2}=\dfrac{21}{12}$ នាំឱ្យ

$$21(10^{n+1}+10N+2)=12(2\cdot 10^{n+1}+10N+1)$$
$$21\cdot 10^{n+1}+210N+42=24\cdot 10^{n+1}+120N+12$$
$$210N-120N=24\cdot 10^{n+1}-21\cdot 10^{n+1}+12-42$$
$$90N=3\cdot 10^{n+1}-30$$
$$N=\frac{30\cdot 10^n-30}{90}$$
$$N=\frac{10^n-1}{3}$$

ពិនិត្យ $10^n=\underbrace{100...000}_{n \text{ ដងលេខ } 0}$ នាំឱ្យ $10^n-1=\underbrace{99...999}_{n \text{ ដងលេខ } 9}$

យើងបាន $N=\dfrac{10^n-1}{3}=\dfrac{99...999}{3}=\underbrace{33...333}_{n \text{ ដងលេខ } 3}$

នេះមានន័យថា $N=\{3, 33, 333, 3333, ...\}$



www.facebook.com/7khmer
fb : Entertainment And Knowledge

ផ្ទៀងផ្ទាត់ : បើ $N=3$ , $\frac{231}{132}=\frac{21\times 11}{12\times 11}=\frac{21}{12}$ ពិត

ដូចនេះ គ្រប់ចំនួនគត់រកបានគឺ $N=\underbrace{33...333}_{n \text{ ដងលេខ } 3}$ ។

## ៦៦. គណនាផលបូក :

$$S=\frac{1}{1\cdot 2\cdot 3}+\frac{1}{2\cdot 3\cdot 4}+\frac{1}{3\cdot 4\cdot 5}+...+\frac{1}{n(n+1)(n+2)}$$

ពិនិត្យ : $\frac{1}{n(n+1)}-\frac{1}{(n+1)(n+2)}=\frac{(n+2)-n}{n(n+1)(n+2)}$

$$=\frac{2}{n(n+1)(n+2)}$$

ទាញបាន $\frac{1}{n(n+1)(n+2)}=\frac{1}{2}\left[\frac{1}{n(n+1)}-\frac{1}{(n+1)(n+2)}\right]$

តាមលំនាំនេះ យើងអាចសរសេរបានដូចខាងក្រោម :

$$+\begin{cases}\frac{1}{1\cdot 2\cdot 3}=\frac{1}{2}\left[\frac{1}{1\cdot 2}-\frac{1}{2\cdot 3}\right]\\ \frac{1}{2\cdot 3\cdot 4}=\frac{1}{2}\left[\frac{1}{2\cdot 3}-\frac{1}{3\cdot 4}\right]\\ \frac{1}{3\cdot 4\cdot 5}=\frac{1}{2}\left[\frac{1}{3\cdot 4}-\frac{1}{4\cdot 5}\right]\\ \cdots\cdots\cdots\cdots\\ \frac{1}{n(n+1)(n+2)}=\frac{1}{2}\left[\frac{1}{n(n+1)}-\frac{1}{(n+1)(n+2)}\right]\end{cases}$$

$$S=\frac{1}{2}\left[\frac{1}{1\cdot 2}-\frac{1}{(n+1)(n+2)}\right]$$

$$S=\frac{1}{2}\left[\frac{n^2+3n+2-2}{2(n^2+3n+2)}\right]$$

$$S=\frac{n^2+3n}{4(n^2+3n+2)}$$

ដូចនេះ ក្រោយពីគណនាឃើញថា $S=\frac{n^2+3n}{4(n^2+3n+2)}$ ។

## ៦៧. សម្រួលកន្សោម : $\left(2+\sqrt{3}\right)^{2011}\cdot\left(2-\sqrt{3}\right)^{2012}+\sqrt{3}$

តាង $E=\left(2+\sqrt{3}\right)^{2011}\cdot\left(2-\sqrt{3}\right)^{2012}+\sqrt{3}$

$$=\left(2+\sqrt{3}\right)^{2011}\cdot\left(2-\sqrt{3}\right)^{2011}\cdot\left(2-\sqrt{3}\right)+\sqrt{3}$$

$$=\left[\left(2+\sqrt{3}\right)\cdot\left(2-\sqrt{3}\right)\right]^{2011}\cdot\left(2-\sqrt{3}\right)+\sqrt{3}$$

$$=(4-3)^{2011}\cdot\left(2-\sqrt{3}\right)+\sqrt{3}$$

$$=2-\sqrt{3}+\sqrt{3}$$

$$=2$$

ដូចនេះ សម្រួលបាន $\left(2+\sqrt{3}\right)^{2011}\cdot\left(2-\sqrt{3}\right)^{2011}+\sqrt{3}=2$ ។

## ៦៨. បង្ហាញថា : $\frac{1}{x-1}-\frac{1}{x+1}-\frac{2}{x^2+1}-\frac{4}{x^4+1}=\frac{8}{x^8-1}$

ពិនិត្យ : $\left(\frac{1}{x-1}-\frac{1}{x+1}\right)-\frac{2}{x^2+1}-\frac{4}{x^4+1}$

$$=\left(\frac{(x+1)-(x-1)}{(x-1)(x+1)}\right)-\frac{2}{x^2+1}-\frac{4}{x^4+1}$$

$$=\frac{2}{x^2-1}-\frac{2}{x^2+1}-\frac{4}{x^4+1}$$

$$=\frac{2(x^2+1)-2(x^2-1)}{(x^2-1)(x^2+1)}-\frac{4}{x^4+1}$$

$$=\frac{2x^2+2-2x^2+2}{x^4-1}-\frac{4}{x^4+1}$$

$$=\frac{4}{x^4-1}-\frac{4}{x^4+1}=\frac{4(x^4+1)-4(x^4-1)}{(x^4-1)(x^4+1)}$$

$$=\frac{4x^4+4-4x^4+4}{x^8-1}=\frac{8}{x^8-1}$$

ដូចនេះ $\frac{1}{x-1}-\frac{1}{x+1}-\frac{2}{x^2+1}-\frac{4}{x^4+1}=\frac{8}{x^8-1}$ ។

## ៦៩. គណនាផលបូក $S=\frac{1}{2!}+\frac{2}{3!}+\frac{3}{4!}+...+\frac{n}{(n+1)!}$

ពិនិត្យ : $\frac{n}{(n+1)!}=\frac{(n+1)-1}{(n+1)!}$

$$=\frac{(n+1)}{(n+1)!}-\frac{1}{(n+1)!}$$

$$=\frac{(n+1)}{(n+1)\cdot n!}-\frac{1}{(n+1)!}=\frac{1}{n!}-\frac{1}{(n+1)!}$$

( ព្រោះ $(n+1)!=(n+1)\cdot n!$ ឧទា. $5!=5\cdot 4!$ )

ឃើញថា គេអាចបំបែក $\frac{n}{(n+1)!}=\frac{1}{n!}-\frac{1}{(n+1)!}$

យើងអាចបំបែកតួនីមួយៗ រួចបូកអង្គនិងអង្គ ដូចខាងក្រោម:

$$+\begin{cases}\frac{1}{2!}=\frac{1}{1!}-\frac{1}{2!}\\ \frac{2}{3!}=\frac{1}{2!}-\frac{1}{3!}\\ \frac{3}{4!}=\frac{1}{3!}-\frac{1}{4!}\\ \cdots\cdots\cdots\cdots\\ \frac{n}{(n+1)!}=\frac{1}{n!}-\frac{1}{(n+1)!}\end{cases}$$

$$\frac{1}{2!}+\frac{2}{3!}+\frac{3}{4!}+...+\frac{n}{(n+1)!}=\frac{1}{1!}-\frac{1}{(n+1)!}$$

$$S=1-\frac{1}{(n+1)!}$$



www.facebook.com/7khmer
fb : Entertainment And Knowledge

ដូចនេះ $\boxed{S=1-\frac{1}{(n+1)!}=\frac{(n+1)!-1}{(n+1)!}}$ ។

**៧០. កំណត់លេខចុងនៃ** $\Sigma=1^2+2^2+3^2+...+2010^2+2011^2$

(យល់ដឹង: គេសរសេរ $[13^2]=9$ មានន័យ លេខខាងចុងនៃ $13^2=169$ មានលេខ 9 នៅខាងចុង ។)

ពិនិត្យ

$[1^2]=[11^2]=[21^2]=...=[2001^2]=1$

$[2^2]=[12^2]=[22^2]=...=[2002^2]=4$

$[3^2]=[13^2]=[23^2]=...=[2003^2]=9$

$[4^2]=[14^2]=[24^2]=...=[2004^2]=6$

$[5^2]=[15^2]=[25^2]=...=[2005^2]=5$

$[6^2]=[16^2]=[26^2]=...=[2006^2]=6$

$[7^2]=[17^2]=[27^2]=...=[2007^2]=9$

$[8^2]=[18^2]=[28^2]=...=[2008^2]=4$

$[9^2]=[19^2]=[29^2]=...=[2009^2]=1$

$[10^2]=[20^2]=[30^2]=...=[2010^2]=0$

ដោយផលបូកលេខចុងៗ នៃដប់ៗតួជាបន្តបន្ទាប់ស្មើៗគ្នា គឺ

$1+4+9+6+5+6+9+4+1+0=45$ ហើយ

$$\Sigma=\underbrace{1^2+2^2+3^2+...+2010^2}_{\text{មាន 201 នៃដប់ៗតួ}}+2011^2$$

នាំឱ្យ $[\Sigma]=[1^2+2^2+3^2+...+2010^2]+[2011^2]$

$=[201\times45]+[2011^2]$

$=[5+1]=6$

ដូចនេះ $\boxed{\text{លេខខាងចុងនៃ } \Sigma \text{ គឺ } [\Sigma]=6}$ ។

**៧១. កំណត់លេខចុងនៃ** $\Sigma=1!+2!+3!+...+2010!+2011!$

(អ្នកគួគិតថា មួយចំនួនដែលគុណនឹង 10 ឬ បានពីផលគុណនៃ 2 និង5 សុទ្ធសឹងតែផ្តល់ ចំនួនដែលមានលេខ0 ខាងចុង)

រូបមន្ត ហ្វាក់តូរ្យែល $n!=n\times(n-1)\times(n-2)\times...\times3\times2\times1$

យើងបាន :

$[1!]=1 \quad [2!]=2 \quad [3!]=6 \quad [4!]=4 \quad [5!]=0$

$[6!]=0 \quad [7!]=0 \quad [8!]=0 \quad [9!]=0 \quad ........$

យើងពិនិត្យឃើញថា លេខខាងចុងនៃចំនួនទាំងឡាយ ដែលធំជាង 4 សុទ្ធតែជាលេខសូន្យដូចៗគ្នា ទាំងអស់ នាំឱ្យ :

$\Sigma=1!+2!+3!+...+2010!+2011!$

$[\Sigma]=[1!]+[2!]+[3!]+...+[2010!]+[2011!]$

$=[1+2+6+4+0+0+...+0+0+0]$

$=3$

ដូចនេះ $\boxed{\text{លេខខាងចុងនៃ } \Sigma \text{ គឺ } [\Sigma]=3}$ ។

**៧២. គណនាតម្លៃ** $A=a^{2012}+ab^{2011}$

យើងមាន $\left(a+\sqrt{a^2+1}\right)\left(b+\sqrt{b^2+1}\right)=1 \quad (*)$

-គុណ $(*)$ នឹង $\left(a-\sqrt{a^2+1}\right)$ នោះយើងបាន :

$\left(a-\sqrt{a^2+1}\right)\left(a+\sqrt{a^2+1}\right)\left(b+\sqrt{b^2+1}\right)=\left(a-\sqrt{a^2+1}\right)$

$\left(a^2-a^2-1\right)\left(b+\sqrt{b^2+1}\right)=\left(a-\sqrt{a^2+1}\right)$

$-b-\sqrt{b^2+1}=a-\sqrt{a^2+1} \quad (1)$

-គុណ $(*)$ នឹង $\left(b-\sqrt{b^2+1}\right)$ វិញម្តង នោះយើងបាន :

$\left(a+\sqrt{a^2+1}\right)\left(b+\sqrt{b^2+1}\right)\left(b-\sqrt{b^2+1}\right)=\left(b-\sqrt{b^2+1}\right)$

$\left(a+\sqrt{a^2+1}\right)\left(b^2-b^2-1\right)=\left(b-\sqrt{b^2+1}\right)$

$-a-\sqrt{a^2+1}=b-\sqrt{b^2+1} \quad (2)$

-តាម $(1)$ និង $(2)$ ចងជាប្រព័ន្ធ បូកអង្គ និងសម្រួល

យើងបាន : $+\begin{cases}-b-\sqrt{b^2+1}=a-\sqrt{a^2+1}\\ -a-\sqrt{a^2+1}=b-\sqrt{b^2+1}\end{cases}$

$-a-b=a+b$

$-2a=2b$

$a=-b$

-នាំឱ្យ $A=a^{2012}+ab^{2011}$

$=a^{2012}+a(-a)^{2011}=a^{2012}+a(-a)^{2011}$

$=a^{2012}+a\cdot(-1)^{2011}\cdot a^{2011}=a^{2012}+(-1)\cdot a^{2012}$

$=a^{2012}-a^{2012}=0$

ដូចនេះ $\boxed{\text{ក្រោយពីគណនា បានផលមក } A=0}$ ។



www.facebook.com/7khmer
fb : Entertainment  And Knowledge

## ៧៣. ដោះស្រាយសមីការ :

យើងមាន $2011^{\log_{2012}x}+x^{\log_{2012}2011}=4022$

-តាង $A=2011^{\log_{2012}x}$

នាំឱ្យ $\log_{2012}A=\log_{2012}2011^{\log_{2012}x}$

$\log_{2012}A=\log_{2012}x\cdot\log_{2012}2011 \quad (i)$

-តាង $B=x^{\log_{2012}2011}$

នាំឱ្យ $\log_{2012}B=\log_{2012}x^{\log_{2012}2011}$

$\log_{2012}B=\log_{2012}2011\cdot\log_{2012}x \quad (ii)$

ដោយផ្ទឹម $(i)$ និង $(ii)$

យើងបាន $\log_{2012}A=\log_{2012}B$ សមមូល $A=B$

-សមីការទៅជា $2011^{\log_{2012}x}+2011^{\log_{2012}x}=4022$

$2\cdot 2011^{\log_{2012}x}=2\cdot 2011$

$2011^{\log_{2012}x}=2011^1$

$\log_{2012}x=1$

$x=2012$

ដូចនេះ | ក្រោយពីដោះស្រាយសមីការមានឫស $x=2012$ | ។

## ៧៤. ស្រាយថា $a^5+b^5=(a^3+b^3)(a^2+b^2)-(a+b)$

ពិនិត្យ $(a^3+b^3)(a^2+b^2)-(a+b)$

$=(a^5+a^3b^2+a^2b^3+b^5)-(a+b)$

$=a^5+b^5+a^2b^2(a+b)-(a+b)$

$=a^5+b^5+(a+b)(a^2b^2-1)$

ដោយសម្មតិកម្ម គេឱ្យ $ab=1$ នោះ $a^2b^2=1$

យើងបាន $(a^3+b^3)(a^2+b^2)-(a+b)$

$=a^5+b^5+(a+b)(1-1)$

$=a^5+b^5+0=a^5+b^5$

ដូចនេះ | ឃើញថា $a^5+b^5=(a^3+b^3)(a^2+b^2)-(a+b)$ | ។

## ៧៥. គណនាកន្សោម : $A=x^{2010}+y^{2011}+x^{2012}$

យើងមាន $\begin{cases}x^2+2y+1=0\\ y^2+2z+1=0\\ z^2+2x+1=0\end{cases}$ (បូកអង្គនិងអង្គ)

$x^2+2y+1+y^2+2z+1+z^2+2x+1=0$

ឬ $(x^2+2x+1)+(y^2+2y+1)+(z^2+2z+1)=0$

$(x+1)^2+(y+1)^2+(z+1)^2=0$

ដោយ $(x+1)^2\geq 0$ , $(y+1)^2\geq 0$ , $(z+1)^2\geq 0$

មានតែមួយករណីគត់ ដែលផ្ទៀងផ្ទាត់សមីការខាងលើគឺ តម្លៃនៃកន្លានីមួយៗស្មើ 0

យើងបាន: $\begin{cases}(x+1)^2=0 \Leftrightarrow x+1=0 \Rightarrow x=-1\\ (y+1)^2=0 \Leftrightarrow y+1=0 \Rightarrow y=-1\\ (z+1)^2=0 \Leftrightarrow z+1=0 \Rightarrow z=-1\end{cases}$

នាំឱ្យ $A=x^{2010}+y^{2011}+x^{2012}$

$=(-1)^{2010}+(-1)^{2011}+(-1)^{2012}$

$=1+(-1)+1=1$

ដូចនេះ | ក្រោយពីគណនាឃើញថា $A=1$ | ។

## ៧៦. បង្ហាញថា $\dfrac{ad+bc}{2ab}=\dfrac{2cd}{ad+bc}$

យើងមាន $\dfrac{a}{b}=\dfrac{c}{d}$ នាំឱ្យ $\dfrac{a}{c}=\dfrac{b}{d}$ យើងបាន :

$\dfrac{a}{c}=\dfrac{ad}{cd}=\dfrac{ab}{cb} \quad (1)$ ហើយ $\dfrac{b}{d}=\dfrac{bc}{dc}=\dfrac{ab}{ad} \quad (2)$

នាំឱ្យ $\dfrac{ad}{cd}=\dfrac{bc}{dc}=\dfrac{ad+bc}{cd+dc}=\dfrac{ad+bc}{2cd} \quad (i)$

$\dfrac{ab}{cb}=\dfrac{ab}{ad}=\dfrac{ab+ab}{cb+ad}=\dfrac{2ab}{cb+ad} \quad (ii)$

តាម (1) នោះ $(i)=(ii)$ យើងបាន :

$\dfrac{ad+bc}{2cd}=\dfrac{2ab}{cb+ad}$ នាំឱ្យ $\dfrac{ad+bc}{2ab}=\dfrac{2cd}{cb+ad}$

ដូចនេះ | ឃើញថា $\dfrac{ad+bc}{2ab}=\dfrac{2cd}{ad+bc}$ | ។

## ៧៧. សម្រួលកន្សោម

$$A=\left(\sqrt{\frac{a}{b}}+\sqrt{\frac{b}{a}}+\sqrt{2}\right)\left(\sqrt{\frac{a}{b}}+\sqrt{\frac{b}{a}}-\sqrt{2}\right)\left(\frac{a^2+b^2}{2011ab}\right)^{-1}$$

$$=\left[\left(\sqrt{\frac{a}{b}}+\sqrt{\frac{b}{a}}\right)^2-\sqrt{2}^2\right]\left(\frac{a^2+b^2}{2011ab}\right)^{-1}$$

$$=\left[\left(\sqrt{\frac{a}{b}}\right)^2+2\cdot\sqrt{\frac{a}{b}}\cdot\sqrt{\frac{b}{a}}+\left(\sqrt{\frac{b}{a}}\right)^2-2\right]\left(\frac{a^2+b^2}{2011ab}\right)^{-1}$$



www.facebook.com/7khmer
fb : Entertainment And Knowledge

$$=\left(\frac{a}{b}+2\sqrt{\frac{ab}{ba}}+\frac{b}{a}-2\right)\left(\frac{a^2+b^2}{2011ab}\right)^{-1}$$

$$=\left(\frac{a}{b}+2+\frac{b}{a}-2\right)\left(\frac{2011ab}{a^2+b^2}\right)$$

$$=\left(\frac{a}{b}+\frac{b}{a}\right)\left(\frac{2011ab}{a^2+b^2}\right)$$

$$=\left(\frac{a^2+b^2}{ab}\right)\left(\frac{2011ab}{a^2+b^2}\right)=2011$$

ដូចនេះ | ក្រោយពីសម្រួល $A=2011$ | ។

## ៧៨. គណនា $P=xy+yz+zx$

យើងមាន $\frac{x}{a}=\frac{y}{b}=\frac{z}{c}=m$

ទាញបាន $x=am$ , $y=bm$ , $z=cm$

នាំឱ្យ $P=xy+yz+zx$

$$=(am)(bm)+(bm)(cm)+(cm)(am)$$

$$=abm^2+bcm^2+cam^2$$

$$=(ab+bc+ca)m^2$$

យើងមាន $a+b+c=1$

$$a^2+b^2+c^2+2ab+2bc+2ca=1$$

$$a^2+b^2+c^2+2(ab+bc+ca)=1$$

តែសម្មតិកម្មបន្ថែមគឺ $a^2+b^2+c^2=1$

នាំឱ្យ $1+2(ab+bc+ca)=1$

$$2(ab+bc+ca)=0$$

$$ab+bc+ca=0$$

យើងបាន $P=(ab+bc+ca)m^2$

$$=0\cdot m^2=0$$

ដូចនេះ | ឃើញថា $P=xy+yz+zx=0$ | ។

## ៧៩. គណនាក្រឡាផ្ទៃត្រីកោណនេះ ជាអនុគមន៍នៃ $\alpha$ និង $a$

យើងមាន ត្រីកោណសមបាទ

ដោយធ្វើចំណោលកែងពីមុំពុំមែន$\alpha$

នោះយើងបានរូបដូចខាងស្តាំ




ក្នុងត្រីកោណកែងធំមាន $\sin\alpha=\frac{h}{a}$ $\Rightarrow h=a\sin a$

ក្រឡាផ្ទៃនៃត្រីកោណ=( បាត x កម្ពស់) /2

នាំឱ្យ $S=\frac{1}{2}ah=\frac{1}{2}a\cdot a\sin\alpha=\frac{1}{2}a^2\sin\alpha$

ដូចនេះ | ផ្ទៃត្រីកោណសមបាតនេះគឺ $S=\frac{1}{2}a^2\sin\alpha$ | ។

## ៨០. ប្រៀបធៀបចំនួន

ក. $\sqrt{6}+\sqrt{5}$ និង $\sqrt{21}$

ឧបមាថា : $\sqrt{6}+\sqrt{5}>\sqrt{21}$

$$6+2\sqrt{30}+5>21$$ (លើកជាការេ)

$$2\sqrt{30}>10$$

$$4\times30>100$$ (លើកជាការេម្តងទៀត)

$$120>100$$ ពិតប្រាកដមែន

នាំឱ្យការឧបមាគឺត្រឹមត្រូវ មានន័យថា $\sqrt{6}+\sqrt{5}>\sqrt{21}$

ដូចនេះ | ក្រោយពីប្រៀបធៀបគឺ $\sqrt{6}+\sqrt{5}>\sqrt{21}$ | ។

ខ. $1+\sqrt[2011]{11+\sqrt{72}}$ និង $2\sqrt[2011]{3+\sqrt{2}}$

ពិនិត្យ : $1+\sqrt[2011]{11+\sqrt{72}}$

$$=1+\sqrt[2011]{9+2+\sqrt{4\cdot18}}$$

$$=1+\sqrt[2011]{\sqrt{9}^2+2\sqrt{9}\cdot\sqrt{2}+\sqrt{2}^2}$$

$$=1+\sqrt[2011]{\left(3+\sqrt{2}\right)^2}$$

ដោយ $\left(1-\sqrt[2011]{3+\sqrt{2}}\right)^2>0$

$$1-2\sqrt[2011]{3+\sqrt{2}}+\sqrt[2011]{\left(3+\sqrt{2}\right)^2}>0$$

$$1+\sqrt[2011]{\left(3+\sqrt{2}\right)^2}>2\sqrt[2011]{3+\sqrt{2}}$$

ឬអាចសរសេរ $1+\sqrt[2011]{11+\sqrt{72}}>2\sqrt[2011]{3+\sqrt{2}}$

ដូចនេះ | លទ្ធផល $1+\sqrt[2011]{11+\sqrt{72}}>2\sqrt[2011]{3+\sqrt{2}}$ | ។



www.facebook.com/7khmer
fb : Entertainment And Knowledge

**៨១.** **រកតម្លៃគត់នៃ $x$ , $y$ និង $z$**

យើងមាន សមីការ

$$x+y+z+4=2\sqrt{x-2}+4\sqrt{y-3}+6\sqrt{z-5}$$

$$\Leftrightarrow x-2\sqrt{x-2}+y-4\sqrt{y-3}+z-6\sqrt{z-5}+4=0$$

$$\Leftrightarrow (x-2)-2\sqrt{x-2}+1+(y-3)-4\sqrt{y-3}+4+$$
$$+(z-5)-6\sqrt{z-5}+9=0$$

$$\Leftrightarrow \left(\sqrt{x-2}-1\right)^2+\left(\sqrt{y-3}-2\right)^2+\left(\sqrt{z-5}-3\right)^2=0$$

ដោយ $\begin{cases}\left(\sqrt{x-2}-1\right)^2\geq 0\\ \left(\sqrt{y-3}-2\right)^2\geq 0\\ \left(\sqrt{z-5}-3\right)^2\geq 0\end{cases}$ ដើម្បីឱ្យផ្ទៀងផ្ទាត់សមីការ

ខាងលើគឺមានតែមួយករណីគត់គឺ :

$$\begin{cases}\left(\sqrt{x-2}-1\right)^2=0\\ \left(\sqrt{y-3}-2\right)^2=0\\ \left(\sqrt{z-5}-3\right)^2=0\end{cases}\Leftrightarrow\begin{cases}\sqrt{x-2}-1=0\\ \sqrt{y-3}-2=0\\ \sqrt{z-5}-3=0\end{cases}$$

$$\begin{cases}\sqrt{x-2}=1\\ \sqrt{y-3}=2\\ \sqrt{z-5}=3\end{cases}\Leftrightarrow\begin{cases}x-2=1\\ y-3=4\\ z-5=9\end{cases}\Rightarrow\begin{cases}x=3\\ y=7\\ z=14\end{cases}$$

ដូចនេះ **តម្លៃគត់ដែលរកឃើញ $(x,y,z)=(3,7,14)$** ។

**៨២.** **ស្រាយបំភ្លឺថា $\sqrt[3]{ax^2+by^2+cz^2}=\sqrt[3]{a}+\sqrt[3]{b}+\sqrt[3]{c}$**

យើងមាន $\dfrac{1}{x}+\dfrac{1}{y}+\dfrac{1}{z}=1$

នាំឱ្យ $\dfrac{ax^2}{ax^3}+\dfrac{by^2}{by^3}+\dfrac{cz^2}{cz^3}=1$

ដោយ $ax^3=by^3=cz^3$ យើងបាន

$\dfrac{ax^2+by^2+cz^2}{ax^3}=1$ ទាញបាន $\sqrt[3]{a}=\dfrac{\sqrt[3]{ax^2+by^2+cz^2}}{x}$ (1)

$\dfrac{ax^2+by^2+cz^2}{by^3}=1$ ទាញបាន $\sqrt[3]{b}=\dfrac{\sqrt[3]{ax^2+by^2+cz^2}}{y}$ (2)

$\dfrac{ax^2+by^2+cz^2}{cz^3}=1$ ទាញបាន $\sqrt[3]{c}=\dfrac{\sqrt[3]{ax^2+by^2+cz^2}}{z}$ (3)

ដោយយក $(1)+(2)+(3)$ យើងបាន

$$\sqrt[3]{a}+\sqrt[3]{b}+\sqrt[3]{c}=\left(\frac{1}{x}+\frac{1}{y}+\frac{1}{z}\right)\cdot\sqrt[3]{ax^2+by^2+cz^2}$$
$$=\sqrt[3]{ax^2+by^2+cz^2}$$

ដូចនេះ **ឃើញថា $\sqrt[3]{ax^2+by^2+cz^2}=\sqrt[3]{a}+\sqrt[3]{b}+\sqrt[3]{c}$** ។

**៨៣.** **ស្រាយបញ្ជាក់ថា $H$ ,$G$ និង $O$ ជាបីចំណុចរត់ត្រង់គ្នា**




(មើលទៅរូបដូចស្មុគស្មាញ តែបើគ្រប់គ្រងបាន គ្មានអ្វីពិបាក!!!)

-ឧបមាថា $O$ ជាផ្ចិតរង្វង់ចារឹកក្រៅត្រីកោណ $ABC$ និង $H$ ជាអរតូសង់នៃត្រីកោណ (ចំណុចប្រសព្វកម្ពស់ទាំងបី)

ហើយ $[BD]$ ជាអង្កត់ផ្ចិតនៃរង្វង់ផ្ចិត $O$

យើងបាន $B\hat{A}D=B\hat{C}D=90^o$ (មុំចារឹកកន្លះរង្វង់)

ទាញបាន $[AB]\perp[AD]$ និង $[BC]\perp[CD]$

ហើយ $[AB]\perp[CH]$ និង $[BC]\perp[AH]$

នាំឱ្យ $[AD]\parallel[CH]$ និង $[CD]\parallel[AH]$

យើងបាន $AHCD$ ជាប្រលេឡូក្រាម នោះ $[AH]=[CD]$ (1)

-យក $[AM]$ ជាមេដ្យាននៃត្រីកោណ $ABC$ នាំឱ្យ $M$ ជាចំណុចកណ្ដាលនៃជ្រុង $[BC]$

យើងបាន $[OM]$ ជាបាតមធ្យមនៃ $\Delta BCD$

នាំឱ្យ $[OM]$ ស្របនឹង $[CD]$ និង $[OM]=\dfrac{1}{2}[CD]$ (2)

តាម $(1)\&(2)$ : $[OM]=\dfrac{1}{2}[AH]$ ឬ $\dfrac{AH}{MO}=2$ (3)

-ត្រីកោណ $AHG$ និង $\Delta MOC$ មាន :

មុំ $A\hat{H}G=M\hat{O}G$ មុំឆ្លាស់ក្នុង (ព្រោះ $[OM]$ ស្រប$[AH]$)

មុំ $A\hat{G}H=M\hat{G}O$ មុំទល់កំពូល

នាំឱ្យ ត្រីកោណ $AHG$ និង $\Delta MOC$ ជាត្រីកោណដូចគ្នា

តាមករណី ម.ម (មុំពីរប៉ុនរៀងគ្នា)



www.facebook.com/7khmer
fb : Entertainment And Knowledge

វិបាក : $\Delta AHG \sim \Delta MOG \Rightarrow \frac{AH}{MO} = \frac{AG}{MG}$ (4)

តាម (3)&(4) : នាំឱ្យ $\frac{AG}{MG} = 2$ or $AG = 2MG$

នេះបញ្ជាក់ឱ្យឃើញថា $G$ ពិជាទីប្រជុំទំងន់របស់ $\Delta ABC$

ដូចនេះ **$H$ ,$G$ និង $O$ ជាបីចំណុចរត់ត្រង់គ្នាប្រាកដមែន** ។

**៨៤. បង្ហាញថា** $P \geq 0$ យើងមាន :

$$P = a^2b^2 + 5a^2 + 9b^2 - 6ab^2 - 30a + 45$$
$$= a^2b^2 - 6ab^2 + 9b^2 + 5a^2 - 30a + 45$$
$$= b^2(a^2 - 6a + 9) + 5(a^2 - 6a + 9)$$
$$= (a^2 - 6a + 9)(b^2 + 5)$$
$$= (a-3)^2(b^2 + 5)$$

ដោយ $(a-3)^2 \geq 0$ គ្រប់ $a$ ជាចំនួនពិត

$(b^2 + 5) > 0$ គ្រប់ $b$ ជាចំនួនពិត

នាំឱ្យផលគុណ $(a-3)^2(b^2+5) \geq 0$ ជានិច្ច

ដូចនេះ **ក្រោយពីបង្ហាញឃើញថា $P \geq 0$ ជានិច្ច** ។

**៨៥. បង្ហាញថា** $39^{51} + 51^{39}$ **ចែកដាច់នឹង** 45

• ពិនិត្យ $39^1$ លេខចុងគឺ 9 $39^2$ លេខចុងគឺ 1

$39^3$ លេខចុងគឺ 9 $39^4$ លេខចុងគឺ 1

........................................................

មានទម្រង់ $9^n = \begin{cases} ...9 & \text{បើ } n \text{ ជាចំនួនគត់សេស} \\ ...1 & \text{បើ } n \text{ ជាចំនួនគត់គូ} \end{cases}$

នាំឱ្យ ចំនួន $39^{51}$ ជាចំនួនដែលមានលេខ 9 នៅខាងចុង ។

• ពិនិត្យ $51^1$ លេខចុងគឺ 1 $51^2$ លេខចុងគឺ 1

$51^3$ លេខចុងគឺ 1 $51^4$ លេខចុងគឺ 1

........................................................

ឃើញថា ស្វ័យគុណនៃ51 ជាចំនួនដែលមានលេខ1 ចុងជានិច្ច

នាំឱ្យ ចំនួន $51^{39}$ ជាចំនួនដែលមានលេខ 1 នៅខាងចុង ។

-យើងបានផលបូក $39^{51} + 51^{39}$ ជាចំនួនមានលេខ 0 ចុង

នាំឱ្យ ផលបូក $39^{51} + 51^{39}$ ជាចំនួនចែកដាច់នឹង5 $(*)$

**-ម្យ៉ាងទៀត**

• $39^{51} = (13 \times 3)^{51} = 13^{51} \cdot 3^{51} = 13^{51} \cdot 3^{49} \cdot 3^2 = 13^{51} \cdot 3^{49} \cdot 9$

នាំឱ្យ ចំនួន $39^{51}$ ចែកដាច់នឹង 9

• $51^{39} = (17 \times 3)^{39} = 17^{39} \cdot 3^{39} = 17^{39} \cdot 3^{37} \cdot 3^2 = 17^{39} \cdot 3^{37} \cdot 9$

នាំឱ្យ ចំនួន $51^{39}$ ចែកដាច់នឹង 9

យើងបានផលបូក $39^{51} + 51^{39}$ ចែកនឹង 9 $(**)$

-តាមរយៈ $(*)$ និង $(**)$ : $39^{51} + 51^{39}$ ចែកដាច់នឹង $9 \times 5$

ដូចនេះ **$39^{51} + 51^{39}$ ចែកដាច់នឹង 45** ។

**៨៦. គណនា** $A$ : យើងមាន

$$A = 101 \cdot 10001 \cdot 100000001 \times ... \times \underbrace{1000...001}_{\text{មាន } 2^n - 1 \text{ ដងនៃលេខ } 0}$$

$$= (100+1)(10000+1)(100000000+1) \times ... \times (\underbrace{1000...00}_{\text{មាន } 2^n \text{ ដងនៃលេខ } 0} + 1)$$

$$= (10^2+1)(10^4+1)(10^8+1) \times ... \times (10^{2^n}+1)$$

$$= \frac{1}{(10^2-1)}(10^2-1)(10^2+1)(10^4+1)(10^8+1) \times ... \times (10^{2^n}+1)$$

$$= \frac{1}{(10^2-1)}(10^4-1)(10^4+1)(10^8+1) \times ... \times (10^{2^n}+1)$$

$$= \frac{1}{(10^2-1)}(10^8-1)(10^8+1) \times ... \times (10^{2^n}+1)$$

$= ........................................................$

$$= \frac{1}{(10^2-1)}(10^{2^n}-1)(10^{2^n}+1)$$

$$= \frac{1}{99}(10^{2^{n+1}}-1)$$

$$= \frac{1}{99}(\underbrace{1000...00}_{\text{មាន } 2^{n+1} \text{ ដងនៃលេខ } 0} - 1)$$

$$= \frac{1}{99}(\underbrace{999...99}_{\text{មាន } 2^{n+1} \text{ ដងនៃលេខ } 9})$$

$= 10101...01$ ( មាន $2^{n+1} - 1$ ខ្ទង់)

ដូចនេះ **$A = 10101...01$ ( មាន $2^{n+1} - 1$ ខ្ទង់)** ។

ឧទាហរណ៍: $101 \times 10001 = 1010101$ ពិត ។



www.facebook.com/7khmer
fb : Entertainment And Knowledge

## ៨៧. គណនាតម្លៃ $n$ : យើងមាន

$$\frac{3}{2011}+\frac{9}{2011}+\frac{15}{2011}+\dots+\frac{6n-3}{2011}=\frac{300}{2011}$$
$$\frac{3+9+15+\dots+(6n-3)}{2011}=\frac{300}{2011}$$
$$3+9+15+\dots+(6n-3)=300$$
$$3[1+3+5+\dots+(2n-1)]=3\cdot100$$
$$1+3+5+\dots+(2n-1)=100$$
$$n^2=10^2$$
$$n=10$$

អ្នកត្រូវចាំថា $1+3+5+\dots+(2n-1)=n^2$

ដូចនេះ **តម្លៃគណនាបានគឺ $n=10$** ។

## ៨៨. ដោះស្រាយប្រព័ន្ធសមីការ :

ក. $\begin{cases}x^2=2x-y\\ y^2=2y-z\\ z^2=2z-x\end{cases}$ យើងបាន:

$$\begin{cases}x^2-2x=-y\\ y^2-2y=-z\\ z^2-2z=-x\end{cases}\Leftrightarrow\begin{cases}x^2-2x+1=1-y\\ y^2-2y+1=1-z\\ z^2-2z+1=1-x\end{cases}$$

$$\begin{cases}x^2-2x+1=1-y\\ y^2-2y+1=1-z\\ z^2-2z+1=1-x\end{cases}\Leftrightarrow\begin{cases}(x-1)^2=1-y\\ (y-1)^2=1-z\\ (z-1)^2=1-x\end{cases}$$

$$\begin{cases}(1-x)^2=(1-y)\\ (1-y)^2=(1-z)\\ (1-z)^2=(1-x)\end{cases}$$

ដោយតាង $A=1-x$ , $B=1-y$ , $C=1-z$

យើងបាន: $\begin{cases}A^2=C & (1)\\ C^2=B & (2)\\ B^2=A & (3)\end{cases}$

-តាម $(1)$: $A^2=C$

-តាម $(2)$: $C^2=B \Rightarrow A^4=B$

-តាម $(3)$: $B^2=A \Rightarrow A^8=A$

នាំឱ្យ $A^8=A \Leftrightarrow A^8-A=0$

$$A(A^7-1)=0$$

នោះ $A=0$ ឬ $A^7-1=0 \Leftrightarrow A^7=1 \Rightarrow A=1$

-ចំពោះ $A=0$ យើងបាន:

$C=A^2=0^2=0$ ហើយ $B=A^4=0^4=0$

នាំឱ្យ $\begin{cases}A=1-x\\ B=1-y\\ C=1-z\end{cases}\Leftrightarrow\begin{cases}0=1-x\\ 0=1-y\\ 0=1-z\end{cases}\Rightarrow\begin{cases}x=1\\ y=1\\ z=1\end{cases}$

-ចំពោះ $A=1$ យើងបាន:

$C=A^2=1^2=1$ ហើយ $B=A^4=1^4=1$

នាំឱ្យ $\begin{cases}A=1-x\\ B=1-y\\ C=1-z\end{cases}\Leftrightarrow\begin{cases}1=1-x\\ 1=1-y\\ 1=1-z\end{cases}\Rightarrow\begin{cases}x=0\\ y=0\\ z=0\end{cases}$

-យកគូចម្លើយនៃតម្លៃ $A,B,C$ ជំនួសរក $x,y,z$

ដូចនេះ **គូចម្លើយនៃប្រព័ន្ធគឺ $\begin{cases}x=0\\ y=0\\ z=0\end{cases}$ ឬ $\begin{cases}x=1\\ y=1\\ z=1\end{cases}$** ។

ខ. $\begin{cases}\frac{1}{a}+\frac{1}{b}-\frac{1}{c}=-\frac{1}{12} & (1)\\ \frac{1}{c}+\frac{1}{b}-\frac{1}{a}=\frac{7}{12} & (2)\\ \frac{1}{a}+\frac{1}{c}-\frac{1}{b}=\frac{5}{12} & (3)\end{cases}$ ដោះស្រាយដោយបូកអង្គ

-ដោយបូកអង្គនឹងអង្គនៃសមីការ $(1)\&(2)$ យើងបាន :

$$\frac{1}{b}+\frac{1}{b}=-\frac{1}{12}+\frac{7}{12}\Leftrightarrow\frac{2}{b}=\frac{6}{12}\Rightarrow b=\frac{2\cdot12}{6}=4$$

-ដោយបូកអង្គនឹងអង្គនៃសមីការ $(1)\&(3)$ យើងបាន :

$$\frac{1}{a}+\frac{1}{a}=-\frac{1}{12}+\frac{5}{12}\Leftrightarrow\frac{2}{a}=\frac{4}{12}\Rightarrow a=\frac{2\cdot12}{4}=6$$

-ដោយបូកអង្គនឹងអង្គនៃសមីការ $(1)\&(3)$ យើងបាន :

$$\frac{1}{c}+\frac{1}{c}=\frac{7}{12}+\frac{5}{12}\Leftrightarrow\frac{2}{c}=\frac{12}{12}\Rightarrow c=\frac{2\cdot12}{12}=2$$

ដូចនេះ **ប្រព័ន្ធសមីការមានគូចម្លើយ $(a,b,c)=(6,4,2)$** ។

## ៨៩. ដោះស្រាយសមីការ យើងមានសមីការ

$$\frac{x-4}{2007}+\frac{x-3}{2008}+\frac{x-2}{2009}+\frac{x-1}{2010}=4$$
$$\frac{x-4}{2007}-1+\frac{x-3}{2008}-1+\frac{x-2}{2009}-1+\frac{x-1}{2010}-1=0$$
$$\left(\frac{x-4}{2007}-1\right)+\left(\frac{x-3}{2008}-1\right)+\left(\frac{x-2}{2009}-1\right)+\left(\frac{x-1}{2010}-1\right)=0$$
$$\left(\frac{x-4-2007}{2007}\right)+\left(\frac{x-3-2008}{2008}\right)+\left(\frac{x-2-2009}{2009}\right)+\left(\frac{x-1-2010}{2010}\right)=0$$
$$\left(\frac{x-2011}{2007}\right)+\left(\frac{x-2011}{2008}\right)+\left(\frac{x-2011}{2009}\right)+\left(\frac{x-2011}{2010}\right)=0$$



www.facebook.com/7khmer
fb : Entertainment And Knowledge

$$(x-2011)\left(\frac{1}{2007}+\frac{1}{2008}+\frac{1}{2009}+\frac{1}{2010}\right)=0$$

នាំឱ្យ $x-2011=0 \Rightarrow x=2011$

ហើយ $\left(\frac{1}{2007}+\frac{1}{2008}+\frac{1}{2009}+\frac{1}{2010}\right)\neq 0$

ដូចនេះ **សមីការមានឫសតែមួយគត់គឺ $x=2011$** ។

## ៩០. ស្រាយបញ្ជាក់ថា $\dfrac{\sqrt{\sqrt[4]{8}-\sqrt{\sqrt{2}+1}}}{\sqrt{\sqrt[4]{8}+\sqrt{\sqrt{2}-1}}-\sqrt{\sqrt[4]{8}-\sqrt{\sqrt{2}-1}}}=\dfrac{1}{\sqrt{2}}$

តាង $n=\sqrt{\sqrt[4]{8}+\sqrt{\sqrt{2}-1}}-\sqrt{\sqrt[4]{8}-\sqrt{\sqrt{2}-1}}\ ,n>0$ នោះ

$$n^2=\left(\sqrt{\sqrt[4]{8}+\sqrt{\sqrt{2}-1}}-\sqrt{\sqrt[4]{8}-\sqrt{\sqrt{2}-1}}\right)^2$$

$$=\left(\sqrt[4]{8}+\sqrt{\sqrt{2}-1}\right)+\left(\sqrt[4]{8}-\sqrt{\sqrt{2}-1}\right)$$

$$-2\sqrt{\left(\sqrt[4]{8}+\sqrt{\sqrt{2}-1}\right)\left(\sqrt[4]{8}-\sqrt{\sqrt{2}-1}\right)}$$

$$=2\sqrt[4]{8}-2\sqrt{\left(\sqrt[4]{8}\right)^2-\left(\sqrt{\sqrt{2}-1}\right)^2}$$

$$n^2=2\sqrt[4]{8}-2\sqrt{\left(\sqrt[4]{8}\right)^2-\left(\sqrt{\sqrt{2}-1}\right)^2}$$

$$=2\sqrt[4]{8}-2\sqrt{\sqrt{8}-\left(\sqrt{2}-1\right)}$$

$$=2\sqrt[4]{8}-2\sqrt{2\sqrt{2}-\sqrt{2}+1}$$

$$=2\sqrt[4]{8}-2\sqrt{\sqrt{2}+1}$$

$$=2\left(\sqrt[4]{8}-\sqrt{\sqrt{2}+1}\right)$$

ទាញរក $n$ វិញ យើងបាន:

$$n^2=2\left(\sqrt[4]{8}-\sqrt{\sqrt{2}+1}\right)$$

$$n=\sqrt{2\left(\sqrt[4]{8}-\sqrt{\sqrt{2}+1}\right)}$$ ព្រោះ $n>0$ ពុំមែន $\pm$ ទេ

$$=\sqrt{2}\cdot\sqrt{\sqrt[4]{8}-\sqrt{\sqrt{2}+1}}$$

ដោយផ្ទឹមតម្លៃរបស់ $n$ យើងបាន :

$$\sqrt{\sqrt[4]{8}+\sqrt{\sqrt{2}-1}}-\sqrt{\sqrt[4]{8}-\sqrt{\sqrt{2}-1}}=\sqrt{2}\cdot\sqrt{\sqrt[4]{8}-\sqrt{\sqrt{2}+1}}$$

នាំឱ្យ $$\frac{\sqrt{\sqrt[4]{8}-\sqrt{\sqrt{2}+1}}}{\sqrt{\sqrt[4]{8}+\sqrt{\sqrt{2}-1}}-\sqrt{\sqrt[4]{8}-\sqrt{\sqrt{2}-1}}}$$

$$=\frac{\sqrt{\sqrt[4]{8}-\sqrt{\sqrt{2}+1}}}{\sqrt{2}\cdot\sqrt{\sqrt[4]{8}-\sqrt{\sqrt{2}+1}}}=\frac{1}{\sqrt{2}}$$

ដូចនេះ $$\boxed{\frac{\sqrt{\sqrt[4]{8}-\sqrt{\sqrt{2}+1}}}{\sqrt{\sqrt[4]{8}+\sqrt{\sqrt{2}-1}}-\sqrt{\sqrt[4]{8}-\sqrt{\sqrt{2}-1}}}=\frac{1}{\sqrt{2}}}$$ ។

## ៩១. សម្រួលកន្សោម

$$B=\left(\frac{2\sqrt{x}+x}{x\sqrt{x}-1}-\frac{1}{\sqrt{x}-1}\right)\div\left(1-\frac{\sqrt{x}+2}{x+\sqrt{x}+1}\right)$$

$$=\left(\frac{2\sqrt{x}+x}{\sqrt{x^3}-1}-\frac{1}{\sqrt{x}-1}\right)\div\left(1-\frac{\sqrt{x}+2}{x+\sqrt{x}+1}\right)$$

$$=\left(\frac{2\sqrt{x}+x}{\left(\sqrt{x}-1\right)\left(x+\sqrt{x}+1\right)}-\frac{1}{\sqrt{x}-1}\right)\div\left(1-\frac{\sqrt{x}+2}{x+\sqrt{x}+1}\right)$$

$$=\frac{\left(2\sqrt{x}+x\right)-\left(x+\sqrt{x}+1\right)}{\left(\sqrt{x}-1\right)\left(x+\sqrt{x}+1\right)}\div\frac{\left(x+\sqrt{x}+1\right)-\left(\sqrt{x}+2\right)}{x+\sqrt{x}+1}$$

$$=\frac{2\sqrt{x}+x-x-\sqrt{x}-1}{\left(\sqrt{x}-1\right)\left(x+\sqrt{x}+1\right)}\div\frac{x+\sqrt{x}+1-\sqrt{x}-2}{x+\sqrt{x}+1}$$

$$=\frac{\sqrt{x}-1}{\left(\sqrt{x}-1\right)\left(x+\sqrt{x}+1\right)}\div\frac{x-1}{x+\sqrt{x}+1}$$

$$=\frac{\sqrt{x}-1}{\left(\sqrt{x}-1\right)\left(x+\sqrt{x}+1\right)}\times\frac{x+\sqrt{x}+1}{x-1}=\frac{1}{x-1}\ ,0<x\neq 1$$

ដូចនេះ **ក្រោយពីសម្រួល $B=\dfrac{1}{x-1}$** ។

## ៩២. ស្រាយបញ្ជាក់ឱ្យឃើញថា $A+B+C+7$ ជាការេប្រាកដ

-តាង $x=\underbrace{111...11}_{\text{មាន } n \text{ តួនៃលេខ } 1}$ នាំឱ្យ $\underbrace{999...99}_{\text{មាន } n \text{ តួនៃលេខ } 1}=9x$

ទាញបាន : $10^n-1=9x \Rightarrow 10^n=9x+1$ (សូមគិត)

-យើងបាន $A=\underbrace{888...88}_{\text{មាន } n \text{ តួនៃលេខ } 1}=8\cdot\underbrace{(111...11)}_{\text{មាន } n \text{ តួនៃលេខ } 1}=8x$

ហើយ $B=\underbrace{222...222}_{\text{មាន } n+1 \text{ តួនៃលេខ } 2}=\underbrace{222...220}_{\text{មាន } n \text{ តួនៃលេខ } 2}+2$

$$=\underbrace{222...22}_{\text{មាន } n \text{ តួនៃលេខ } 2}\times 10+2=2x\times 10+2=20x+2$$

និង $C=\underbrace{444...444}_{\text{មាន } 2n \text{ តួនៃលេខ } 4}=\underbrace{444..44}_{\text{មាន } n \text{ តួនៃលេខ } 4}\times 10^n+\underbrace{444..44}_{\text{មាន } n \text{ តួនៃលេខ } 4}$

$$=4x(9x+1)+4x=36x^2+4x+4x=36x^2+8x$$



www.facebook.com/7khmer
fb : Entertainment And Knowledge

នាំឱ្យ $A+B+C+7$

$$=8x+(20x+2)+(36x^2+8x)+7$$
$$=36x^2+36x+9$$
$$=(6x)^2+2\cdot 6x\cdot 3+3^2$$
$$=(6x+3)^2=(\underbrace{666...66}_{\text{មាន } n \text{ តួនៃលេខ 6}}+3)^2=\underbrace{666...6}_{\text{មាន } n-1 \text{ តួនៃលេខ 6}}9^2$$

ដូចនេះ | $A+B+C+7$ ជាការេប្រាកដ | ។

## ៩៣. រកភាគរយនៃកម្ពស់ដែលត្រូវថយចុះ




ក្រឡាផ្ទៃត្រីកោណ $S=\frac{1}{2}bh$

-តាង $x$ ជាភាគរយនៃកម្ពស់ដែលត្រូវថយចុះ

-បាតត្រីកោណថ្មីបន្ទាប់ពីកើន 10% គឺ $(b+10\%b)$

-កម្ពស់ត្រីកោណថ្មីក្រោយពីថយចុះ $x$ គឺ $(h-xh)$

នាំឱ្យក្រឡាផ្ទៃនៃត្រីកោណថ្មីគឺ $S'=\frac{1}{2}\left(b+\frac{10}{100}b\right)(h-xh)$

-តាមបម្រាប់ប្រធានក្រឡាផ្ទៃនៃត្រីកោណទាំងពីរស្មើគ្នា

យើងបាន $\frac{1}{2}bh=\frac{1}{2}(b+0.1b)(h-xh)$

$$1=1.1(1-x) \quad \Leftrightarrow \quad 1=1.1-1.1x$$
$$\Rightarrow x=\frac{1.1-1}{1.1}=\frac{0.1}{1.1}\approx 0.09091=9.09\%$$

ដូចនេះ | កម្ពស់ត្រូវថយចុះ $\frac{1}{11}$ or 9.09% | ។

## ៩៤. ស្រាយថា $ab+bc+ac\le a^2+b^2+c^2<2(ab+bc+ac)$

-គ្រប់ $a$ , $b$ និង $c$ ជាចំនួនពិតយើងបាន:

- $(a-b)^2\ge 0 \quad\Rightarrow\quad a^2+b^2\ge 2ab \quad (1)$
- $(b-c)^2\ge 0 \quad\Rightarrow\quad b^2+c^2\ge 2bc \quad (2)$
- $(a-c)^2\ge 0 \quad\Rightarrow\quad a^2+c^2\ge 2ac \quad (3)$

ដោយយក $(1)+(2)+(3)$: យើងបាន

$$2(a^2+b^2+c^2)\ge 2(ab+bc+ac)$$
$$a^2+b^2+c^2\ge ab+bc+ac \quad (*)$$

-ម្យ៉ាងទៀត $a$ , $b$ និង $c$ ជារង្វាស់ជ្រុងនៃត្រីកោណ

យើងបាន :

- $a<b+c \quad\Rightarrow\quad a^2<ab+ac \quad (4)$
- $b<a+c \quad\Rightarrow\quad b^2<ab+bc \quad (5)$
- $c<a+b \quad\Rightarrow\quad c^2<ac+bc \quad (6)$

ដោយយក $(5)+(6)+(7)$: យើងបាន

$$a^2+b^2+c^2<2(ab+bc+ac) \quad (**)$$

-តាមរយៈ $(*)\&(**)$ យើងបាន :

$$ab+bc+ac\le a^2+b^2+c^2<2(ab+bc+ac)$$

ដូចនេះ | $ab+bc+ac\le a^2+b^2+c^2<2(ab+bc+ac)$ | ។

## ៩៥. គណនា $E$ : យើងមាន

$$E=\frac{2011}{b^2-a^2+c^2}-\frac{2011}{b^2-a^2-c^2}+\frac{2011}{a^2+b^2-c^2}$$

-តាមសម្មតិកម្ម $a+b+c=0$ យើងទាញបាន:

- $a+b+c=0 \quad\Leftrightarrow\quad b+c=-a$

$$(b+c)^2=(-a)^2 \quad\Leftrightarrow\quad b^2+2bc+c^2=a^2$$

នាំឱ្យ $b^2-a^2+c^2=-2bc \quad (1)$

- $a+b+c=0 \quad\Leftrightarrow\quad a+c=-b$

$$(a+c)^2=(-b)^2 \quad\Leftrightarrow\quad a^2+2ac+c^2=b^2$$

នាំឱ្យ $b^2-a^2-c^2=2ac \quad (2)$

- $a+b+c=0 \quad\Leftrightarrow\quad a+b=-c$

$$(a+b)^2=(-c)^2 \quad\Leftrightarrow\quad a^2+2ab+b^2=c^2$$

នាំឱ្យ $a^2+b^2-c^2=-2ab \quad (3)$

-តាម $(1)$, $(2)\&(3)$ យើងបាន

$$E=\frac{2011}{b^2-a^2+c^2}-\frac{2011}{b^2-a^2-c^2}+\frac{2011}{a^2+b^2-c^2}$$
$$E=\frac{2011}{-2bc}-\frac{2011}{2ac}+\frac{2011}{-2ab}$$
$$=-\frac{2011}{2bc}-\frac{2011}{2ac}-\frac{2011}{2ab}$$
$$=\frac{-2011a-2011b-2011c}{2abc}$$
$$=-2011\left(\frac{a+b+c}{2abc}\right)=0$$

ព្រោះ $a+b+c=0$ និង $abc\ne 0$

ដូចនេះ | ក្រោយពីគណនាឃើញថា $E=0$ |



www.facebook.com/7khmer
fb : Entertainment And Knowledge

## ៩៦. បង្ហាញថា

$2010\cdot 2012(2011^2+1)(2011^4+1)(2011^8+1)(2011^{16}+1)=(2011^{32}-1)$

ពិនិត្យអង្គទី1 : ( ដោយប្រើរូបមន្ត $(a-b)(a+b)=a^2-b^2$ )

$2010\cdot 2012(2011^2+1)(2011^4+1)(2011^8+1)(2011^{16}+1)$

$=(2011-1)(2011+1)(2011^2+1)(2011^4+1)(2011^8+1)(2011^{16}+1)$

$=(2011^2-1)(2011^2+1)(2011^4+1)(2011^8+1)(2011^{16}+1)$

$=(2011^4-1)(2011^4+1)(2011^8+1)(2011^{16}+1)$

$=(2011^8-1)(2011^8+1)(2011^{16}+1)$

$=(2011^{16}-1)(2011^{16}+1)$

$=(2011^{32}-1)$

ដូចនេះ ក្រោយពីការបង្ហាញ ឃើញថា

$2010\cdot 2012(2011^2+1)(2011^4+1)(2011^8+1)(2011^{16}+1)=(2011^{32}-1)$

## ៩៧. បំភ្លឺថា $2AM<AB+AC$




-យក $N$ កណ្ដាល $[AC]$

នាំឱ្យ $AN=\dfrac{AC}{2}$ (1)

-បម្រាប់ $[AM]$ ជាមេដ្យាន

នាំឱ្យ $M$ កណ្ដាល $[BC]$

ទាញបាន $MN$ ជាបាតមធ្យមនៃត្រីកោណ $ABC$

ហើយ $MN=\dfrac{AB}{2}$ (2)

-តាមច្បាប់វិសមភាពក្នុងត្រីកោណ $AMN$

គេបាន : $AM<MN+AN$ (3)

-ដោយយក $(1)\&(2)$ ជំនួយក្នុង $(3)$

យើងបាន $AM<\dfrac{AB}{2}+\dfrac{AC}{2}\Leftrightarrow 2AM<AB+AC$

ដូចនេះ ឃើញថា $2AM<AB+AC$ ប្រាកដមែន ។

## ៩៨. រកគ្រប់រង្វាស់ជ្រុងនៃត្រីកោណកែង

-ដោយ $a$ ជាចំនួនគត់វិជ្ជមាន

នោះយើងបានរង្វាស់ជ្រុង $x<x+a<x+2a$

-ដោយវាជាត្រីកោណកែង តាមពីតាគ័រ

យើងបាន $x^2+(x+a)^2=(x+2a)^2$

$x^2+x^2+2ax+a^2=x^2+4ax+4a^2$

$x^2-2ax-3a^2=0$

មាន $\Delta'=(-a)^2-(-3a^2)=a^2+3a^2=4a^2$

នាំឱ្យ $x=\dfrac{-(-a)+\sqrt{4a^2}}{1}=a+2a=3a$ យក

$x=\dfrac{-(-a)-\sqrt{4a^2}}{1}=a-2a=-a$ មិនយក

-យើងបានរង្វាស់ជ្រុងនៃត្រីកោណគឺ $3a$ , $4a$ , $5a$

រង្វាស់ជ្រុងវែងជាងគេ គឺតូចជាង ឬស្មើ 10 មានន័យថា

$5a\le 10\ \Rightarrow\ a\le 2$

ហើយ $a$ ជាចំនួនគត់វិជ្ជមាន នោះ $a=1$ និង $a=2$

- ចំពោះ $a=1$ នោះត្រីកោណមានរង្វាស់ជ្រុង 3, 4, 5
- ចំពោះ $a=2$ នោះត្រីកោណមានរង្វាស់ជ្រុង 6, 8, 10

ដូចនេះ រង្វាស់ជ្រុងនៃត្រីកោណកែងតូចជាង ឬស្មើ10 គឺ: 3, 4, 5 និង 6, 8, 10 ។

## ៩៩. គណនា $A+B$ ជាអនុគមន៍នឹង $C$

ពិនិត្យលក្ខណៈជ្រុងរបស់ត្រីកោណ

-តាមពីតាគ័រ ឃើញថា:

$3^2+4^2=5^2$ មានន័យថាវាជាត្រីកោណកែង

-ហើយវាជាត្រីកោណចារឹកក្នុងរង្វង់នោះយើងទាញថា

ប្រវែងជ្រុងវែងជាងគេមានរង្វាស់ស្មើ 5 ជាអង្កត់ផ្ចិត

-យើងគូសរូបបាបដូចខាងក្រោម:




រង្វង់នេះមាន កាំ $R=\dfrac{5}{2}$

-ក្រឡាផ្ទៃត្រីកោណ $S_\Delta=\dfrac{1}{2}\cdot 3\cdot 4=6$ ឯកតាផ្ទៃ

-ក្រឡាផ្ទៃរង្វង់ $S=\pi R^2=\pi\cdot\left(\dfrac{5}{2}\right)^2=\dfrac{25\pi}{4}$ ឯកតាផ្ទៃ

-ក្រឡាផ្ទៃផ្នែក $C$ គឺ $C=\dfrac{\pi R^2}{2}=\dfrac{S}{2}=\dfrac{25\pi}{8}$ ឯកតាផ្ទៃ

នាំឱ្យ $A+B=S-(S_\Delta+C)$

$=\dfrac{25\pi}{4}-\left(6+\dfrac{25\pi}{8}\right)=\dfrac{25\pi}{8}-6=C-6$

ដូចនេះ $A+B=C-6$ ។



www.facebook.com/7khmer
fb : Entertainment And Knowledge

## ១០០ គណនាប្រវែងបាតមធ្យមនៅចន្លោះអង្កត់ទ្រូង x




-តាង $P$ និង $Q$ ជាចំណុចប្រសព្វរវាងអង្កត់ទ្រូង និងបាតមធ្យម យើងបាន :

- $MP$ ជាបាតមធ្យមនៃ $\Delta DAB$ ព្រោះ $MP$ កាត់តាមចំណុចចំណុចកណ្ដាល $AD$ ហើយស្របនឹង $AB$ (បាតមធ្យមចតុ.ព្នាយ)

នាំឱ្យ $MP=\dfrac{AB}{2}=\dfrac{6cm}{2}=3cm$

- $MQ$ ជាបាតមធ្យមនៃ $\Delta ACD$ ព្រោះ $MQ$ កាត់តាមចំណុចចំណុចកណ្ដាល $AD$ ហើយស្របនឹង $CD$ (បាតមធ្យមចតុ.ព្នាយ)

នាំឱ្យ $MQ=\dfrac{CD}{2}=\dfrac{10cm}{2}=5cm$

-យើងបាន $x=PQ=MQ-MP=5cm-3cm=2cm$

ដូចនេះ **ប្រវែងចន្លោះអង្កត់ទ្រូងគឺ $x=2cm$** ។

## ១០១ គណនាផលបូក $S=\dfrac{1^2}{1\cdot 3}+\dfrac{2^2}{3\cdot 5}+\dfrac{3^2}{5\cdot 7}+\dots+\dfrac{1000^2}{1999\cdot 2001}$

-ពិនិត្យ រាងទូទៅនៃតួនីមួយៗរបស់ $S$

$$\frac{n^2}{(2n-1)(2n+1)}=\frac{4n^2}{4(2n-1)(2n+1)}$$
$$=\frac{2n^2+n+2n^2-n}{4(2n-1)(2n+1)}$$
$$=\frac{n(2n+1)+n(2n-1)}{4(2n-1)(2n+1)}$$
$$=\frac{1}{4}\left[\frac{n(2n+1)}{(2n-1)(2n+1)}+\frac{n(2n-1)}{(2n-1)(2n+1)}\right]$$
$$=\frac{1}{4}\left[\frac{n}{(2n-1)}+\frac{n}{(2n+1)}\right]$$

យើងឱ្យតម្លៃ $n=1,2,3,\dots,1000$ យើងបាន :

បើ $n=1$: $\dfrac{1^2}{1\cdot 3}=\dfrac{1}{4}\left[\dfrac{1}{1}+\dfrac{1}{3}\right]$

បើ $n=2$: $\dfrac{2^2}{3\cdot 5}=\dfrac{1}{4}\left[\dfrac{2}{3}+\dfrac{2}{5}\right]$

បើ $n=3$: $+$ $\dfrac{3^2}{5\cdot 7}=\dfrac{1}{4}\left[\dfrac{1}{5}+\dfrac{1}{7}\right]$

.................... ...................................

បើ $n=1000$: $\dfrac{1000^2}{1999\cdot 2001}=\dfrac{1}{4}\left[\dfrac{1000}{1999}+\dfrac{1000}{2001}\right]$

$$S=\frac{1}{4}\left(\frac{1}{1}+\frac{1}{3}+\frac{2}{3}+\frac{2}{5}+\frac{3}{5}+\dots+\frac{1000}{1999}+\frac{1000}{2001}\right)$$

$$4S=\left(\frac{1}{1}+\frac{1}{3}+\frac{2}{3}+\frac{2}{5}+\frac{3}{5}+\dots+\frac{1000}{1999}+\frac{1000}{2001}\right)$$

$$4S=1+\underbrace{\left(\frac{1}{3}+\frac{2}{3}\right)+\left(\frac{2}{5}+\frac{3}{5}\right)+\dots+\left(\frac{999}{1999}+\frac{1000}{1999}\right)}_{\text{មាន 999 តួនៃតួផលបូក}}+\frac{1000}{2001}$$

$$4S=1+\underbrace{(1+1+1+\dots+1)}_{\text{មានលេខ1 ចំនួន999 តួ}}+\frac{1000}{2001}$$

$$4S=1000+\frac{1000}{2001}=\frac{2001000+1000}{2001}=\frac{2002000}{2001}$$

$$\Rightarrow S=\frac{4\cdot 500500}{4\cdot 2001}=\frac{500500}{2001}$$

ដូចនេះ **ផលបូកគណនាបានគឺ $S=\dfrac{500500}{2001}$** ។

## ១០២ ស្រាយបញ្ជាក់ថា :

$$\sqrt{6+\sqrt{6+\sqrt{6+\dots+\sqrt{6}}}}+\sqrt{30+\sqrt{30+\sqrt{30+\dots+\sqrt{30}}}}<9$$

យើងពិនិត្យមើលអង្គទី1 ដូចបង្ហាញខាងក្រោម :

-ចំពោះ $\sqrt{6+\sqrt{6+\sqrt{6+\dots+\sqrt{6}}}}<\sqrt{6+\sqrt{6+\sqrt{6+\dots+\sqrt{9}}}}$

តែ $\sqrt{6+\sqrt{6+\sqrt{6+\dots+\sqrt{9}}}}=3$ (បញ្ចេញពីរ៉ាឌីកាល់)

នាំឱ្យបាន : $\sqrt{6+\sqrt{6+\sqrt{6+\dots+\sqrt{6}}}}<3 \quad (i)$

-ចំពោះ $\sqrt{30+\sqrt{30+\sqrt{30+\dots+\sqrt{30}}}}<\sqrt{30+\sqrt{30+\sqrt{30+\dots+\sqrt{36}}}}$

តែ $\sqrt{30+\sqrt{30+\sqrt{30+\dots+\sqrt{36}}}}=6$ (បញ្ចេញពីរ៉ាឌីកាល់)

នាំឱ្យបាន : $\sqrt{30+\sqrt{30+\sqrt{30+\dots+\sqrt{30}}}}<6 \quad (ii)$

-ដោយបូកអង្គនិងអង្គ : $(i)+(ii)$ យើងបាន :

$$+\begin{cases}\sqrt{6+\sqrt{6+\sqrt{6+\dots+\sqrt{6}}}}<3 & (i)\\ \sqrt{30+\sqrt{30+\sqrt{30+\dots+\sqrt{30}}}}<6 & (ii)\end{cases}$$

$$\sqrt{6+\sqrt{6+\sqrt{6+\dots+\sqrt{6}}}}+\sqrt{30+\sqrt{30+\sqrt{30+\dots+\sqrt{30}}}}<9$$

ដូចនេះ យើងអាចស្រាយបញ្ជាក់បានថា :

$$\boxed{\sqrt{6+\sqrt{6+\sqrt{6+\dots+\sqrt{6}}}}+\sqrt{30+\sqrt{30+\sqrt{30+\dots+\sqrt{30}}}}<9}$$

បញ្ជាក់ : ការដោះស្រាយខាងលើគឺមាន n រ៉ាឌីកាល់ដូចគ្នា ។

(អ្នកអាចសង្ខេបការដោះស្រាយឱ្យខ្លីជាងនេះក៏បាន)



www.facebook.com/7khmer
fb : Entertainment And Knowledge

**១០៣ ក. ចូរគណនាផលបូក**

$S=1\cdot2\cdot3+2\cdot3\cdot4+3\cdot4\cdot5+\ldots+n(n+1)(n+2)$

យើងពិនិត្យតួនីមួយៗនៃ $S$ មានរាងជា $k(k+1)(k+2)$

តែ $k(k+1)(k+2)$

$$=k(k+1)(k+2)\times\frac{1}{4}\times4$$
$$=\frac{1}{4}k(k+1)(k+2)(4+k-k)$$
$$=\frac{1}{4}k(k+1)(k+2)[(k+3)-(k-1)]$$
$$=\frac{1}{4}[(k+3)k(k+1)(k+2)-(k-1)k(k+1)(k+2)]$$
$$=\frac{1}{4}[k(k+1)(k+2)(k+3)-(k-1)k(k+1)(k+2)]$$

ដោយតម្លៃ $k=1,2,3,\ldots,n$ យើងបាន :

$$+\begin{cases}1\cdot2\cdot3=\frac{1}{4}[1\cdot2\cdot3\cdot4-0\cdot1\cdot2\cdot3]\\2\cdot3\cdot4=\frac{1}{4}[2\cdot3\cdot4\cdot5-1\cdot2\cdot3\cdot4]\\3\cdot4\cdot5=\frac{1}{4}[3\cdot4\cdot5\cdot6-2\cdot3\cdot4\cdot5]\\\ldots\ldots\ldots\ldots\\n(n+1)(n+2)=\frac{1}{4}[n(n+1)(n+2)(n+3)-\\\qquad(n-1)n(n+1)(n+2)]\end{cases}$$

$$1\cdot2\cdot3+2\cdot3\cdot4+3\cdot4\cdot5+\ldots+n(n+1)(n+2)=\frac{1}{4}n(n+1)(n+2)(n+3)$$

ដូចនេះ $\boxed{\text{ក្រោយពីគណនា } S=\frac{1}{4}n(n+1)(n+2)(n+3)}$

**ខ. ស្រាយបញ្ជាក់ថា $4S+1$ ជាការេប្រាកដ**

យើងមាន $S=\frac{1}{4}n(n+1)(n+2)(n+3)$

នាំឱ្យ $4S+1=4\times\frac{1}{4}n(n+1)(n+2)(n+3)+1$

$$=n(n+3)(n+1)(n+2)+1$$
$$=(n^2+3n)(n^2+3n+2)+1$$

បើតាង $t=n^2+3n$ យើងងាយស្រួលគុណ នោះ

$$4S+1=t(t+2)+1$$
$$=t^2+2t+1$$
$$=(t+1)^2$$

ឬអាចសរសេរបាន: $4S+1=[(n^2+3n)+1]^2$

ដូចនេះ $\boxed{4S+1 \text{ ជាការេប្រាកដ}}$ ។

**១០៤ ស្រាយបញ្ជាក់ថា :**

$$\frac{x_1+x_2+x_3+\ldots+x_9}{x_3+x_6+x_9}+\frac{x_1+x_2+x_3+\ldots+x_{12}}{x_4+x_8+x_{12}}<7$$

យើងមាន : $0<x_1<x_2<x_3<\ldots<x_{12}$

នាំឱ្យ $x_1+x_2+x_3<x_3+x_3+x_3=3x_3 \quad (1)$

$x_4+x_5+x_6<x_6+x_6+x_6=3x_6 \quad (2)$

$x_7+x_8+x_9<x_9+x_9+x_9=3x_9 \quad (3)$

ដោយយក $(1)+(2)+(3)$ យើងបាន :

$$+\begin{cases}x_1+x_2+x_3<3x_3\\x_4+x_5+x_6<3x_6\\x_7+x_8+x_9<3x_9\end{cases}$$
$$x_1+x_2+x_3+\ldots+x_9<3(x_3+x_6+x_9)$$

ឬសរសេរបាន : $\frac{x_1+x_2+x_3+\ldots+x_9}{x_3+x_6+x_9}<3 \quad (i)$

ហើយ $x_1+x_2+x_3+x_4<x_4+x_4+x_4+x_4=4x_4 \quad (4)$

$x_5+x_6+x_7+x_8<x_8+x_8+x_8+x_8=4x_8 \quad (5)$

$x_9+x_{10}+x_{11}+x_{12}<x_{12}+x_{12}+x_{12}+x_{12}=4x_{12} \quad (6)$

ដោយយក $(4)+(5)+(6)$ យើងបាន :

$$+\begin{cases}x_1+x_2+x_3+x_4<4x_4\\x_5+x_6+x_7+x_8<4x_8\\x_9+x_{10}+x_{11}+x_{12}<4x_{12}\end{cases}$$
$$x_1+x_2+x_3+\ldots+x_{12}<4(x_4+x_8+x_{12})$$

ឬសរសេរបាន : $\frac{x_1+x_2+x_3+\ldots+x_{12}}{x_4+x_8+x_{12}}<4 \quad (ii)$

ជាលទ្ធផលគ្រាន់តែយក $(i)+(ii)$ ជាការស្រេច

$$+\begin{cases}\frac{x_1+x_2+x_3+\ldots+x_9}{x_3+x_6+x_9}<3\\\frac{x_1+x_2+x_3+\ldots+x_{12}}{x_4+x_8+x_{12}}<4\end{cases}$$

ដូចនេះ

$$\boxed{\frac{x_1+x_2+x_3+\ldots+x_9}{x_3+x_6+x_9}+\frac{x_1+x_2+x_3+\ldots+x_{12}}{x_4+x_8+x_{12}}<7}$$



www.facebook.com/7khmer
fb : Entertainment And Knowledge

## ១០៥ រកតម្លៃធំបំផុតនៃផលគុណ $xy$

យើងមាន $x^2+3xy+y^2=60$

អាចថែមថយ $x^2-2xy+y^2+5xy=60$

$(x-y)^2+5xy=60$

$xy=\dfrac{60-(x-y)^2}{5}$

$xy=12-\dfrac{(x-y)^2}{5}$

ដោយ $(x-y)^2\ge 0 \Rightarrow \dfrac{(x-y)^2}{5}\ge 0$

នាំឱ្យ $xy=12-0=12$ ជាតម្លៃធំបំផុត ចំពោះ $x=y$

ដូចនេះ តម្លៃផលគុណធំបំផុតនៃផលគុណ $xy=12$ ។

## ១០៦ រកផលបូករង្វាស់មុំ $A,B,C,D,E$ និង $F$

ថែមចំណុច $M$ និង $N$ ត្រង់ប្រសព្វដូចរូប :




ពិនិត្យផលបូកមុំក្នុងនៃ :

-ត្រីកោណ $ANF$ : $A+N_1+F=180^o$ (1)

-ត្រីកោណ $BMC$ : $B+M_1+C=180^o$ (2)

-ចតុកោណ $DMNE$ : $D+M_2+N_2+E=360^o$ (3)

ដោយបូក (1)+(2)+(3) យើងបានផលបូកមុំ :

$A+B+C+D+E+F+M_1+M_2+N_1+N_2=720^o$

តែមុំ $M_1+M_2=180^o$ , $N_1+N_2=180^o$

នាំឱ្យ $A+B+C+D+E+F+180^o+180^o=720^o$

ឬ $A+B+C+D+E+F=360^o$

ដូចនេះ ផលបូកមុំ $A+B+C+D+E+F=360^o$ ។

## ១០៧ ស្រាយបញ្ជាក់ថា $A$ ជាផលគុណនៃពីរចំនួនគត់តគ្នា

យើងមាន $A=111...11222...22$ មាន 2011តួដូចគ្នា

(ពិនិត្យដោយយកចិត្តទុកដាក់ពីមួយចំណុចទៅមួយចំណុច)

យើងអាចបំបែក A ជាទម្រង់ងាយដូចខាងក្រោម :

$$
\begin{aligned}
A&=111...11222...22\\
&=111...11\cdot 10^{2011}+2(111...11)\\
&=(111...11)(10^{2011}+2)\\
&=\frac{1}{9}(999...99)(10^{2011}+2)\\
&=\frac{1}{9}(999...99)(10^{2011}-1+3)\\
&=\frac{1}{9}(999...99)(999...99+3)\\
&=\frac{1}{3}(999...99)\times\frac{1}{3}(999...99+3)\\
&=(333...33)(333...33+1)
\end{aligned}
$$

ដែលមាន លេខ3ចំនួន 2011 តួ

ដូចនេះ

$A=111...11222...22=(333...33)(333...33+1)$

ដែលមានចំនួនតួនៃលេខ1 ,2និងលេខ3 ស្មើគ្នាគឺ 2011 តួ ។

## ១០៨ រកតម្លៃតូចបំផុតនៃកន្សោម $H$ :

បើ $x_1$ , $x_2$ ជាឫសមីការ $2011x^2-(t-2011)x-2011=0$

តាមរូបមន្ត ផលបូកផលគុណឫស យើងបាន :

$x_1+x_2=-\dfrac{b}{a}=\dfrac{t-2011}{2011}$

$x_1x_2=\dfrac{c}{a}=\dfrac{-2011}{2011}=-1$

យើងមាន : $H=(x_2-x_1)^2+4\left(\dfrac{x_1-x_2}{2}+\dfrac{1}{x_1}-\dfrac{1}{x_2}\right)^2$

$$
\begin{aligned}
H&=(x_2-x_1)^2+4\left(\frac{x_1-x_2}{2}+\frac{x_2-x_1}{x_1x_2}\right)^2\\
&=(x_2-x_1)^2+4(x_2-x_1)^2\left(\frac{-1}{2}+\frac{1}{x_1x_2}\right)^2\\
&=(x_2-x_1)^2\left[1+4\left(\frac{-1}{2}+\frac{1}{x_1x_2}\right)^2\right]\\
&=(x_2^2-2x_1x_2+x_1^2)\left[1+4\left(\frac{-1}{2}+\frac{1}{x_1x_2}\right)^2\right]\\
&=\left[(x_1+x_2)^2-4x_1x_2\right]\left[1+4\left(\frac{-1}{2}+\frac{1}{x_1x_2}\right)^2\right]
\end{aligned}
$$



www.facebook.com/7khmer

fb : Entertainment And Knowledge

ដោយជំនួសតម្លៃនៃផលបូកនិង ផលគុណ យើងបាន :

$$H=\left[\left(\frac{t-2011}{2011}\right)^2-4(-1)\right]\left[1+4\left(\frac{-1}{2}+\frac{1}{-1}\right)^2\right]$$

$$=\left[\left(\frac{t-2011}{2011}\right)^2+4\right]\cdot 10$$

$$=10\left(\frac{t-2011}{2011}\right)^2+40$$

ដោយ $\left(\frac{t-2011}{2011}\right)^2\geq 0$ នាំឱ្យ $10\left(\frac{t-2011}{2011}\right)^2+40\geq 40$

ដូចនេះ | តម្លៃតូចបំផុតនៃ $H=40$ ចំពោះ $t=2011$ | ។

**១០៩ គណនាតម្លៃលេខនៃ** $A=\sqrt{3\sqrt{5\sqrt{3\sqrt{5\sqrt{3...}}}}}$

យើងមាន : $A=\sqrt{3\sqrt{5\sqrt{3\sqrt{5\sqrt{3...}}}}}$

$A^2=3\sqrt{5\sqrt{3\sqrt{5\sqrt{3...}}}}$

$A^4=9\times 5\sqrt{3\sqrt{5\sqrt{3\sqrt{5\sqrt{3...}}}}}$

$A^4=45\cdot\sqrt{3\sqrt{5\sqrt{3\sqrt{5\sqrt{3...}}}}}$

$A^4=45A$

អាចសរសេរ $A^4-45A=0 \Leftrightarrow A(A^3-45)=0$

នាំឱ្យបាន • $A=0$ មិនយកព្រោះ $A>0$

• $A^3-45=0 \Rightarrow A=\sqrt[3]{45}$ យក

ដូចនេះ | ក្រោយពីគណនា $A=\sqrt[3]{45}$ | ។

**១១០ រកសំណល់នៃវិធីចែករវាង** $p(x)$ **និង** $x(x-1)$

*( អ្នកត្រូវចាំថា : សំណល់នៃវិធីចែក $f(x)$ និង $(x-a)$ គឺ $r=f(a)$ ដែល $f(x)$ ជាពហុធា និង $r=f(a)$ ជាសំណល់ ។)*

បម្រាប់ $p(x)$ ចែកនឹង $x$ បានសំណល់ 1

មានន័យថា $p(0)=1$

ហើយ $p(x)$ ចែកនឹង $x-1$ បានសំណល់ 2

មានន័យថា $p(1)=2$

-ដឺក្រេនៃសំណល់ចែក ត្រូវតូចជាងដឺក្រេនៃតួចែក

ដោយ $x(x-1)$ ជាពហុធាដឺក្រេទី2 នោះ សំណល់ជាពហុធាដឺក្រេទី1 មានរាងជា $r(x)=ax+b$ ។

-ឧបមាថា $q(x)$ ជាផលចែកនៃ $p(x)$ នឹង $x(x-1)$

យើងបាន : $p(x)=x(x-1)\,q(x)+ax+b$

-ចំពោះ $p(0)=1$ និង $p(1)=2$ យើងបានប្រព័ន្ធសមីការ:

$$\begin{cases}p(0)=1\\p(1)=2\end{cases}\Leftrightarrow\begin{cases}0(0-1)q(x)+a\cdot 0+b=1\\1(1-1)q(x)+a\cdot 1+b=2\end{cases}$$

$$\begin{cases}b=1\\a+b=2\end{cases}\Leftrightarrow\begin{cases}b=1\\a=1\end{cases}$$

នោះសំណល់គឺ $r(x)=ax+b=x+1$

ដូចនេះ | សំណល់នៃវិធីចែកគឺ $r(x)=x+1$ | ។

**១១១ ស្រាយបញ្ជាក់** $5^{2011}+5^{2012}+5^{2013}$ **ចែកដាច់នឹង** $31$

យើងមាន $5^{2011}+5^{2012}+5^{2013}$

$=5^{2011}(1+5+5^2)$

$=31\cdot 5^{2011}$

ដូចនេះ | $5^{2011}+5^{2012}+5^{2013}$ ចែកដាច់នឹង 31 | ។

**១១២ រកលេខនៃតួចុងក្រោយបង្អស់នៃចំនួន** $2^{3^4}$

ពិនិត្យស្វ័យគុណនៃ 2 ដូចខាងក្រោម :

| | | | |
|---|---|---|---|
| $[2^1]=2$ | $[2^5]=2$ | $[2^9]=2$ | |
| $[2^2]=4$ | $[2^6]=4$ | $[2^{10}]=4$ | |
| $[2^3]=8$ | $[2^7]=8$ | $[2^{11}]=8$ | ... |
| $[2^4]=6$ | $[2^8]=6$ | $[2^{12}]=6$ | |

ឃើញថា លេខចុងស្វ័យគុណនៃ 2 មានខួបស្មើ4វិលទៅមក

ហើយ $3^4=81$

នាំឱ្យ $[2^{81}]=[2^{80}\cdot 2]=[2^{80}]\cdot[2]=[2^{4\cdot 20}]\cdot[2]=[6\cdot 2]=2$

ដូចនេះ | ចំនួន $2^{3^4}$ មានលេខ 2 នៅខាងចុងគេបង្អស់ | ។

សម្គាល់ : គេកំណត់សរសេរ $[2^{11}]=8$ មានន័យថា លេខខាងចុងនៃ $[2^{11}]$ គឺលេខ 8 ។



www.facebook.com/7khmer
fb : Entertainment And Knowledge

## ១១៣ រកលេខនៃតួចុងក្រោយបង្អស់នៃចំនួន $123456789^{2011}$

លេខខាងចុងនៃចំនួន $123456789^{2011}$ គឺអាស្រ័យតែលើស្វ័យគុណលេខខាងចុងនៃចំនួននេះប៉ុណ្ណោះ មានន័យថា លេខខាងចុង $123456789^{2011}$ = លេខខាងចុង $9^{2011}$

-ពិនិត្យលេខខាងចុងស្វ័យគុណនៃលេខ 9 :

$[9^1]=9$ , $[9^2]=1$ , $[9^3]=9$ , $[9^4]=1$ , ...

នាំឱ្យ $[9^n]=\begin{cases}9 & \text{បើ n សេស}\\ 1 & \text{បើ n គូ}\end{cases}$

យើងបាន $[9^{2011}]=9$ ព្រោះ 2011 ជាចំនួនសេស

ដូចនេះ លេខខាងចុងបង្អស់នៃ $123456789^{2011}$ គឺ 9 ។

## ១១៤ ស្រាយបញ្ជាក់ថាចំនួន $A$ ជាចំនួនគត់វិជ្ជមាន

យើងមាន $A=\sqrt[3]{\frac{1}{3}(\sqrt[3]{2}-1)(\sqrt[3]{2}+1)^3}$

$$A=\sqrt[3]{\frac{1}{3}(\sqrt[3]{2}-1)(\sqrt[3]{2}+1)^3}$$
$$=\sqrt[3]{\frac{1}{3}(\sqrt[3]{2}-1)\left(\sqrt[3]{2}^3+3\cdot\sqrt[3]{2}^2+3\cdot\sqrt[3]{2}+1\right)}$$
$$=\sqrt[3]{\frac{1}{3}(\sqrt[3]{2}-1)\left(2+3\cdot\sqrt[3]{2}^2+3\cdot\sqrt[3]{2}+1\right)}$$
$$=\sqrt[3]{(\sqrt[3]{2}-1)\left(1+\sqrt[3]{2}^2+\sqrt[3]{2}\right)}$$
$$=\sqrt[3]{\sqrt[3]{2}+\sqrt[3]{2}^3+\sqrt[3]{2}^2-1-\sqrt[3]{2}^2-\sqrt[3]{2}}$$
$$=\sqrt[3]{2-1}=1$$

ដូចនេះ $A=1$ ជាចំនួនគត់វិជ្ជមាន ។

## ១១៥ បញ្ជាក់តម្លៃនៃចំនួនពិត $x$ ដោយប្រើសញ្ញាវិសមភាព

-បម្រាប់ : $x$ ជាចំនួនពិត

មានន័យថា $x$ អាចជាចំនួនវិជ្ជមាន ឬអវិជ្ជមាន

-សម្មតិកម្ម : $x$ ជាចំនួនដែលមានផ្នែកគត់មានលេខពីរខ្ទង់

មានន័យថា $10\le x<100$ (ទម្រង់នេះធ្វើឱ្យ $x$ ជាចំនួនដែលមានផ្នែកគត់មានលេខពីរខ្ទង់ជានិច្ច)

-បើតម្លៃ $x$ អវិជ្ជមានយើងបាន $-10\ge x>-100$

ដូចនេះ តម្លៃនៃចំនួនពិតបញ្ជាក់បានគឺ : $10\le x<100$ ឬ $-10\ge x>-100$ ។

## ១១៦ ក.ប្រៀបធៀបចំនួន $(1+2000^2)$ និង $(2001^2-2\cdot 2000)$

ពិនិត្យ : $2001^2-2\cdot 2000$
$$=(1+2000)^2-2\cdot 2000$$
$$=1^2+2\cdot 1\cdot 2000+2000^2-2\cdot 2000$$
$$=1+2000^2$$

ដូចនេះ $(1+2000^2)=(2001^2-2\cdot 2000)$ ។

### ខ. គណនា $A=\sqrt{1+2000^2+\left(\frac{2000}{2001}\right)^2}+\frac{2000}{2001}$

យើងមាន : $A=\sqrt{1+2000^2+\left(\frac{2000}{2001}\right)^2}+\frac{2000}{2001}$

ដោយ $(1+2000^2)=(2001^2-2\cdot 2000)$ យើងបាន :

$$A=\sqrt{2001^2-2\cdot 2000+\left(\frac{2000}{2001}\right)^2}+\frac{2000}{2001}$$
$$=\sqrt{\left(2001-\frac{2000}{2001}\right)^2}+\frac{2000}{2001}$$
$$=2001-\frac{2000}{2001}+\frac{2000}{2001}$$
$$=2001$$

ដូចនេះ ក្រោយពីគណនាឃើញថា $A=2001$ ។

## ១១៧ ស្រាយបញ្ជាក់ថា $a^{\frac{2}{3}}=x^{\frac{2}{3}}+y^{\frac{2}{3}}$

យើងមាន : $\sqrt{x^2+\sqrt[3]{x^4y^2}}+\sqrt{y^2+\sqrt[3]{x^2y^4}}=a$

$$a=\sqrt{x^2+\sqrt[3]{x^4y^2}}+\sqrt{y^2+\sqrt[3]{x^2y^4}}$$
$$=\sqrt{\sqrt[3]{x^6}+\sqrt[3]{x^4y^2}}+\sqrt{\sqrt[3]{y^6}+\sqrt[3]{x^2y^4}}$$
$$=\sqrt{\sqrt[3]{x^4}\left(\sqrt[3]{x^2}+\sqrt[3]{y^2}\right)}+\sqrt{\sqrt[3]{y^4}\left(\sqrt[3]{y^2}+\sqrt[3]{x^2}\right)}$$
$$=\sqrt[3]{x^2}\sqrt{\left(\sqrt[3]{x^2}+\sqrt[3]{y^2}\right)}+\sqrt[3]{y^2}\sqrt{\left(\sqrt[3]{y^2}+\sqrt[3]{x^2}\right)}$$
$$=\sqrt{\left(\sqrt[3]{x^2}+\sqrt[3]{y^2}\right)}\cdot\left(\sqrt[3]{x^2}+\sqrt[3]{y^2}\right)$$
$$=\sqrt{\left(\sqrt[3]{x^2}+\sqrt[3]{y^2}\right)^3}$$



www.facebook.com/7khmer
fb : Entertainment And Knowledge

ចំពោះ $a = \sqrt{\left(\sqrt[3]{x^2}+\sqrt[3]{y^2}\right)^3}$

យើងអាចទាញបានជា : $a^2 = \left(\sqrt[3]{x^2}+\sqrt[3]{y^2}\right)^3$

ឬ $\sqrt[3]{a^2} = \sqrt[3]{x^2}+\sqrt[3]{y^2}$

តាមរូបមន្ត : $\sqrt[n]{a^m} = a^{\frac{m}{n}}$

យើងបាន : $a^{\frac{2}{3}} = x^{\frac{2}{3}} + y^{\frac{2}{3}}$

ដូចនេះ | យើងស្រាយបានថា $a^{\frac{2}{3}} = x^{\frac{2}{3}} + y^{\frac{2}{3}}$ | ។

## ១១៨ ប្រៀបធៀបចំនួន $\sqrt{2001}+\sqrt{2002}$ និង $2\sqrt{2002}$

យើងដឹងថា $\sqrt{2001} < \sqrt{2002}$

ថែមអង្គទាំងពីរនៃវិសមភាពនឹង $\sqrt{2002}$ យើងបាន :

$$\sqrt{2001}+\sqrt{2002} < \sqrt{2002}+\sqrt{2002}$$

សមមូល $\sqrt{2001}+\sqrt{2002} < 2\sqrt{2002}$

ដូចនេះ | ប្រៀបធៀបបាន $\sqrt{2001}+\sqrt{2002} < 2\sqrt{2002}$ | ។

## ១១៩ ស្រាយបញ្ជាក់ថា $A$ ជាការេប្រាកដនៃចំនួនគត់

យើងមាន $A = \underbrace{111...111}_{2n \text{ នៃលេខ}1} + \underbrace{444...44}_{n \text{ នៃលេខ}4} + 1$

$$A = \frac{1}{9}\big(\underbrace{999...999}_{2n \text{ នៃលេខ}9}\big) + \frac{4}{9}\big(\underbrace{999...99}_{n \text{ នៃលេខ}9}\big) + 1$$

$$A = \frac{1}{9}\left(10^{2n}-1\right) + \frac{4}{9}\left(10^{n}-1\right) + 1$$

$$= \frac{1}{9}\cdot 10^{2n} - \frac{1}{9} + \frac{4}{9}\cdot 10^{n} - \frac{4}{9} + 1$$

$$= \frac{1}{9}\cdot 10^{2n} + \frac{4}{9}\cdot 10^{n} + \frac{4}{9}$$

$$= \frac{1}{9}\left(10^{2n} + 4\cdot 10^{n} + 4\right)$$

$$= \frac{1}{3^2}\left(10^{n}+2\right)^2 = \left[\frac{1}{3}\left(10^{n}-1+3\right)\right]^2$$

$$= \left(\frac{10^{n}-1}{3}+1\right)^2 = \left(\frac{999...99}{3}+1\right)^2$$

$$= \big(\underbrace{333...33}_{n \text{ នៃលេខ}3}+1\big)^2 = \underbrace{333...34}_{(n-1) \text{ នៃលេខ}3}{}^2$$

ដូចនេះ | ចំនួន $A$ ជាការេប្រាកដនៃចំនួនគត់ | ។

## ១២០ សម្រួលកន្សោម $E$ :

យើងមាន :

$$E = \frac{1}{\left(\sqrt{p}+\sqrt{q}\right)^2}\cdot\left(\frac{1}{p}+\frac{1}{q}\right) + \frac{2}{\left(\sqrt{p}+\sqrt{q}\right)^3}\cdot\left(\frac{1}{\sqrt{p}}+\frac{1}{\sqrt{q}}\right)$$

$$= \frac{1}{\left(\sqrt{p}+\sqrt{q}\right)^2}\cdot\left(\frac{p+q}{pq}\right) + \frac{2}{\left(\sqrt{p}+\sqrt{q}\right)^3}\cdot\left(\frac{\sqrt{p}+\sqrt{q}}{\sqrt{pq}}\right)$$

$$= \frac{1}{\left(\sqrt{p}+\sqrt{q}\right)^2}\left(\frac{p+2\sqrt{pq}+q-2\sqrt{pq}}{pq}\right) + \frac{2}{\left(\sqrt{p}+\sqrt{q}\right)^2\sqrt{pq}}$$

$$= \frac{1}{\left(\sqrt{p}+\sqrt{q}\right)^2}\left(\frac{\left(\sqrt{p}+\sqrt{q}\right)^2-2\sqrt{pq}}{pq}\right) + \frac{2}{\left(\sqrt{p}+\sqrt{q}\right)^2\sqrt{pq}}$$

$$= \frac{1}{\left(\sqrt{p}+\sqrt{q}\right)^2}\left(\frac{\left(\sqrt{p}+\sqrt{q}\right)^2}{pq} - \frac{2\sqrt{pq}}{pq}\right) + \frac{2}{\left(\sqrt{p}+\sqrt{q}\right)^2\sqrt{pq}}$$

$$= \frac{1}{pq} - \frac{2}{\left(\sqrt{p}+\sqrt{q}\right)^2\sqrt{pq}} + \frac{2}{\left(\sqrt{p}+\sqrt{q}\right)^2\sqrt{pq}}$$

$$= \frac{1}{pq}$$

ដូចនេះ | សម្រួលបាន $E = \frac{1}{pq}$ | ។

## ១២១ សម្រួលកន្សោម $E$ :

យើងមាន : $A = \sqrt[3]{3+\sqrt{9+\frac{125}{27}}} + \sqrt[3]{3-\sqrt{9+\frac{125}{27}}}$

( ស្រដៀងលំហាត់លេខ ១០ ទំព័រ1 )

តាមរូបមន្ត : $(a+b)^3 = a^3+3a^2b+3ab^2+b^3$

$$= a^3+b^3+3ab(a+b)$$

យើងបាន :

$$A^3 = \left(3+\sqrt{9+\frac{125}{27}}\right) + \left(3-\sqrt{9+\frac{125}{27}}\right) + 3\sqrt[3]{\left(3+\sqrt{9+\frac{125}{27}}\right)\left(3-\sqrt{9+\frac{125}{27}}\right)}A$$

$$= 6+3\sqrt[3]{3^2-\left(\sqrt{9+\frac{125}{27}}\right)^2}A$$

$$= 6+3\sqrt[3]{-\frac{125}{27}}A$$



www.facebook.com/7khmer
fb : Entertainment And Knowledge

នាំឱ្យបាន : $A^3=6-5A$

$A^3+5A-6=0$

$A^3-A+6A-6=0$

$A(A^2-1)+6(A-1)=0$

$(A-1)(A^2+A+6)=0$

នាំឱ្យ $A-1=0 \Rightarrow A=1$

ហើយ $A^2+A+6>0$

ព្រោះ $\begin{cases} a=1>0 \\ \Delta=1-24<0 \end{cases}$

ដូចនេះ ក្រោយពីសម្រួលបែបបច្ចេកទេស $A=1$ ។

**១២២ ស្រាយបញ្ជាក់ថា** $\sqrt[3]{\sqrt[3]{2}-1}=\sqrt[3]{\frac{1}{9}}-\sqrt[3]{\frac{2}{9}}+\sqrt[3]{\frac{4}{9}}$

តាង $A=\sqrt[3]{\sqrt[3]{2}-1}$

$A^3=\sqrt[3]{2}-1$

$=\frac{(\sqrt[3]{2}-1)(1+\sqrt[3]{2}+\sqrt[3]{2^2})}{(1+\sqrt[3]{2}+\sqrt[3]{2^2})}$

$A^3=\frac{\sqrt[3]{2}^3-1^3}{(1+\sqrt[3]{2}+\sqrt[3]{4})}=\frac{1}{1+\sqrt[3]{2}+\sqrt[3]{4}}$

ហើយ $B=\sqrt[3]{\frac{1}{9}}-\sqrt[3]{\frac{2}{9}}+\sqrt[3]{\frac{4}{9}}$

$B=\sqrt[3]{\frac{1}{9}}-\sqrt[3]{\frac{2}{9}}+\sqrt[3]{\frac{4}{9}}$

$=\frac{1}{\sqrt[3]{9}}(1-\sqrt[3]{2}+\sqrt[3]{4})$

$=\frac{1}{\sqrt[3]{9}(1+\sqrt[3]{2})}(1+\sqrt[3]{2})(1-\sqrt[3]{2}+\sqrt[3]{4})$

$=\frac{1}{\sqrt[3]{9}(1+\sqrt[3]{2})}(1^3+\sqrt[3]{2^3})$

$B=\frac{3}{\sqrt[3]{9}(1+\sqrt[3]{2})}$

$B^3=\frac{27}{9(1+\sqrt[3]{2})^3}=\frac{3}{1+3\cdot1^2\cdot\sqrt[3]{2}+3\cdot1\cdot\sqrt[3]{2^2}+\sqrt[3]{2^3}}$

$=\frac{3}{3+3\sqrt[3]{2}+3\sqrt[3]{4}}=\frac{1}{1+\sqrt[3]{2}+\sqrt[3]{4}}$

ឃើញថា $A^3=B^3 \Rightarrow A=B$

ដូចនេះ ស្រាយបានថា $\sqrt[3]{\sqrt[3]{2}-1}=\sqrt[3]{\frac{1}{9}}-\sqrt[3]{\frac{2}{9}}+\sqrt[3]{\frac{4}{9}}$ ។

**១២៣ គណនាតម្លៃលេខនៃកន្សោម $S$ :**

យើងមាន : $S=\sqrt{6+\sqrt{6+\sqrt{6+\sqrt{6+...}}}}$ , $S>0$

នាំឱ្យ $S^2=6+\sqrt{6+\sqrt{6+\sqrt{6+\sqrt{6+...}}}}$

$S^2=6+\sqrt{6+\sqrt{6+\sqrt{6+\sqrt{6+...}}}}$

$S^2=6+S$

$S^2-S-6=0$

មាន $\Delta=b^2-4ac=(-1)^2-4(1)(-6)=25=5^2$

យើងបាន $\begin{cases} S_1=\frac{-(-1)-5}{2(1)}=-2 \\ S_2=\frac{-(-1)+5}{2(1)}=3 \end{cases}$

ចំពោះ $S_1=-2$ មិនយក ព្រោះ $S>0$

ដូចនេះ តម្លៃលេខគណនាបានគឺ $S=3$ ។

**១២៤ គណនាតម្លៃនៃ $\frac{b+c}{a+b}$ :**

យើងមាន $\frac{b}{a}=\frac{c}{b}=2011$ ដែល $a\neq0\,,b\neq0$

ទាញបាន $\frac{b}{a}=2011 \Rightarrow b=2011a$

ហើយ $\frac{c}{b}=2011 \Rightarrow c=2011b$

នាំឱ្យ $\frac{b+c}{a+b}=\frac{2011a+2011b}{a+b}=\frac{2011(a+b)}{a+b}=2011$

ដូចនេះ តម្លៃគណនាបានគឺ $\frac{b+c}{a+b}=2011$ ។

**១២៥ ដោះស្រាយសមីការ**

យើងមាន $\frac{x-1}{1991}+\frac{x-5}{1987}+\frac{x-7}{1999}+\frac{x-11}{1981}=4$

$\frac{x-1}{1991}-1+\frac{x-5}{1987}-1+\frac{x-7}{1999}-1+\frac{x-11}{1981}-1=0$

$\frac{x-1-1991}{1991}+\frac{x-5-1987}{1987}+\frac{x-7-1999}{1999}+\frac{x-11-1981}{1981}=0$

$\frac{x-1992}{1991}+\frac{x-1992}{1987}+\frac{x-1992}{1999}+\frac{x-1992}{1981}=0$

$(x-1992)\left(\frac{1}{1991}+\frac{1}{1987}+\frac{1}{1999}+\frac{1}{1981}\right)=0$



www.facebook.com/7khmer
fb : Entertainment And Knowledge

នាំឱ្យ $x-1992=0 \quad \Rightarrow \quad x=1992$

ដូចនេះ សមីការមានឫស $x=1992$ ។

## ១២៦ ដោះស្រាយសមីការ

យើងមានសមីការ $x^{2000}+\sqrt{6}x^{1998}=(\sqrt{2}+\sqrt{3})x^{1999}$

ទាញបាន $x^{2000}-(\sqrt{2}+\sqrt{3})x^{1999}+\sqrt{6}x^{1998}=0$

$\left[x^2-(\sqrt{2}+\sqrt{3})x+\sqrt{6}\right]x^{1998}=0$

នាំឱ្យ $x^{1998}=0 \quad \Rightarrow \quad x=0$

$x^2-(\sqrt{2}+\sqrt{3})x+\sqrt{6}=0$

សមីការនេះមាន $S=\sqrt{2}+\sqrt{3}$ , $P=\sqrt{2}\cdot\sqrt{3}=\sqrt{6}$

យើងបាន $\sqrt{2}$ និង $\sqrt{3}$ ជាឫនៃសមីការ

ដូចនេះ សមីការមានឫសបីគឺ $x=\{0, \sqrt{2}, \sqrt{3}\}$ ។

## ១២៧ ដោះស្រាយសមីការ $\log_2\log_3\log_4 x=2$

យើងមាន $\log_2\log_3\log_4 x=2$

យើងបាន $\log_2\log_3\log_4 x=2\log_2 2$

$\log_2\log_3\log_4 x=\log_2 2^2$

$\log_3\log_4 x=4$

$\log_3\log_4 x=4\log_3 3$

$\log_4 x=3^4$

$\log_4 x=81\log_4 4$

$x=4^{81}$

ដូចនេះ សមីការមានឫស $x=4^{81}$ ។

( រូបមន្តលោការីត $\log_a x=k \quad \Leftrightarrow \quad x=a^k$ )

## ១២៨ គណនាផលបូក $A=1+11+111+...+111...11$

យើងមាន : $A=1+11+111+...+111...11$ តួចុងមានលេខ 1 ចំនួន $n$ ដង យើងអាចសរសេរ :

$9A=9+99+999+...+999...99$ ( តួចុងមាន $n$ ដងលេខ9 )

$9A=(10-1)+(100-1)+(1000-1)+...+(10^n-1)$

$9A=10+100+1000+...+10^n-n \qquad (*)$

ដោយគុណ ( * ) នឹង 10 យើងបាន :

$90A=100+1000+10000+...+10^{n+1}-10n \qquad (**)$

យើងយក ( * * ) -( * ) យើងបាន :

$$-\begin{cases}90A=100+1000+10000+...+10^{n+1}-10n\\ 9A=10+100+1000+...+10^n-10\end{cases}$$

$$81A=10^{n+1}-9n-10$$

ឬអាចសរសេរ : $A=\dfrac{10^{n+1}-9n-10}{81}$

ដូចនេះ ផលបូកគឺ $A=\dfrac{10^{n+1}-9n-10}{81}$ ។

## ១២៩ ដោះស្រាយសមីការ ក. $x^{\sqrt{x}}=\sqrt{x^x}$

អ្នកត្រូវចាំ

រូបមន្ត : $[f(x)]^{u(x)}=[f(x)]^{v(x)}$

នាំឱ្យបាន $\begin{cases}f(x)>0\\ [f(x)-1][u(x)-v(x)]=0\end{cases}$

យើងមាន : $x^{\sqrt{x}}=\sqrt{x^x}$

អាចសរសេរ $x^{\sqrt{x}}=x^{\frac{x}{2}}$

នាំឱ្យបាន $\begin{cases}x>0\\ [x-1]\left[\sqrt{x}-\dfrac{x}{2}\right]=0\end{cases}$

យើងបាន • $x-1=0 \quad \Rightarrow \quad x=1$

• $\sqrt{x}-\dfrac{x}{2}=0 \Leftrightarrow \sqrt{x}=\dfrac{x}{2} \Leftrightarrow x=\dfrac{x^2}{4}$

ឬ $4x=x^2 \Leftrightarrow 4x-x^2=0 \Leftrightarrow x(4-x)=0$

នាំឱ្យ $x=0$ , $x=4$

ចំពោះ $x=0$ មិនយក ព្រោះ $x>0$

ដូចនេះ សមីការមានឫស $x=1 \vee x=4$ ។

ខ. $(x^x)^x=x^{(x^x)}$ ( លំនាំដូចសំណួរ ក. )

យើងបាន : $x^{x\cdot x}=x^{(x^x)} \quad \Leftrightarrow \quad x^{x^2}=x^{(x^x)}$

នាំឱ្យបាន $\begin{cases}x>0\\ [x-1][x^2-x^x]=0\end{cases}$

យើងបាន • $x-1=0 \quad \Rightarrow \quad x=1$

• $x^2-x^x=0 \Leftrightarrow x^2=x^x \Rightarrow x=2$

ដូចនេះ សមីការមានឫស $x=1$ ឬ $x=2$ ។



www.facebook.com/7khmer
fb : Entertainment And Knowledge

**១៣០ គណនា** $a+b+c$

យើងមាន $\begin{cases} a+b^2+2ac=29 \\ b+c^2+2ab=18 \\ c+a^2+2bc=25 \end{cases}$

ដោយបូកអង្គនិងអង្គ យើងបាន :

$a^2+b^2+c^2+2ab+2bc+2ac+a+b+c=72$

$(a+b+c)^2+(a+b+c)=72$

$(a+b+c)^2+(a+b+c)-72=0$

តាង $t=a+b+c$ យើងបាន :

សមីការថ្មីងាយសរសេរ និងងាយគិត $t^2+t-72=0$

មាន $\Delta=1+288=289=17^2$

នាំឱ្យ $\begin{cases} t=\dfrac{-1-17}{2}=-9 \\ t=\dfrac{-1+17}{2}=8 \end{cases} \Leftrightarrow \begin{cases} a+b+c=-9 \\ a+b+c=8 \end{cases}$

ដូចនេះ | គណនាបាន $(a+b+c)=\{-9,8\}$ | ។

**១៣១ គណនាផលបូក** $S=1+2+3+...+2011$

យើងមាន $S=1+2+3+...+2011$ (1)

ឬសរសេរ $S=2011+2010+2009+...+1$ (2)

ដោយយក (1)+(2) យើងបាន :

$+\begin{cases} S=1+2+3+...+2011 \\ S=2011+2010+2009+...+1 \end{cases}$

$2S=2012+2012+2012+...+2012$

ដែលមានលេខ 2012 ចំនួន 2011 ដង

យើងបាន :

$2S=2012\times 2011$

$S=\dfrac{2012\times 2011}{2}=1006\times 2011=2023066$

ដូចនេះ | ផលបូកគណនាបានគឺ $S=2023066$ | ។

**១៣២ រកចំនួនសិស្សស្រីនៅក្នុងថ្នាក់**

តាង $x$ ជាចំនួនសិស្សប្រុស

$y$ ជាចំនួនសិស្សស្រី ដែល $x>0\ ,\ y>0$

បម្រាប់ : កម្ពស់ មធ្យមសិស្សប្រុស $1.68m$

កម្ពស់ មធ្យមសិស្សស្រី $1.60m$

កម្ពស់ មធ្យមសិស្សនៅក្នុងថ្នាក់ $1.66m$

យើងបានសមីការ : $1.68x+1.60y=1.66\cdot 28$

$1.68x+1.60y=46.48 \quad (1)$

សិស្សសរុបក្នុងថ្នាក់ : $x+y=28$

ឬ $1.68x+1.68y=28\cdot 1.68$

$1.68x+1.68y=47.04 \quad (2)$

ដោយយក (2)-(1) យើងបាន :

$-\begin{cases} 1.68x+1.68y=47.04 \\ 1.68x+1.60y=46.48 \end{cases}$

$0.08y=0.56 \quad \Rightarrow y=\dfrac{0.56}{0.08}=7$

ដូចនេះ | ចំនួនសិស្សស្រីនៅក្នុងថ្នាក់គឺ 7 នាក់ | ។

**១៣៣ គណនាកន្សោម** $A$

យើងមាន :

$A=(a+b+c)^2-(-a+b+c)^2+(a+b-c)^2-(a-b+c)^2$

ដោយប្រើរូបមន្ត $a^2-b^2=(a-b)(a+b)$ យើងបាន :

$A=[(a+b+c)-(-a+b+c)][(a+b+c)+(-a+b+c)]+$
$+[(a+b-c)-(a-b+c)][(a+b-c)+(a-b+c)]$

$A=[a+b+c+a-b-c][a+b+c-a+b+c]+$
$+[a+b-c-a+b-c][a+b-c+a-b+c]$

$A=(2a)(2b+2c)+(2b-2c)(2a)$

$A=2a(2b+2c+2b-2c)=2a\times 4b=8ab$

ដូចនេះ | កន្សោមដែលគណនាបានគឺ $A=8ab$ | ។

**១៣៤ បង្ហាញថា** $\dfrac{2011}{b^2+c^2-a^2}+\dfrac{2011}{c^2+a^2-b^2}+\dfrac{2011}{a^2+b^2-c^2}=0$

យើងមាន $a+b+c=0$ នាំឱ្យ :

$\bullet\, b+c=-a \Leftrightarrow (b+c)^2=(-a)^2$

$\Leftrightarrow b^2+2bc+c^2=a^2$

$\Leftrightarrow b^2+c^2-a^2=-2bc \quad (1)$

$\bullet\, c+a=-b \Leftrightarrow (c+a)^2=(-b)^2$

$\Leftrightarrow c^2+2ca+a^2=b^2$

$\Leftrightarrow c^2+a^2-b^2=-2ca \quad (2)$



www.facebook.com/7khmer
fb : Entertainment And Knowledge

$\bullet\; a+b=-c \Leftrightarrow (a+b)^2=(-c)^2$

$\Leftrightarrow a^2+2ab+b^2=c^2$

$\Leftrightarrow a^2+b^2-c^2=-2ab \quad (3)$

តាមរយៈ (1) , (2) & (3) យើងបាន :

$$\frac{2011}{b^2+c^2-a^2}+\frac{2011}{c^2+a^2-b^2}+\frac{2011}{a^2+b^2-c^2}$$

$$=\frac{2011}{-2bc}+\frac{2011}{-2ca}+\frac{2011}{-2ab}$$

$$=\frac{2011a+2011b+2011c}{-2abc}$$

$$=\frac{2011(a+b+c)}{-2abc}$$

$$=0$$

ដូចនេះ $\boxed{\frac{2011}{b^2+c^2-a^2}+\frac{2011}{c^2+a^2-b^2}+\frac{2011}{a^2+b^2-c^2}=0}$ ។

## ១៣៥ កំណត់តម្លៃ $a$ និង $b$

យើងមាន : $(x^2+px+q)^2$

$=x^4+p^2x^2+q^2+2px^3+2qx^2+2pqx$

$=x^4+2px^3+(p^2+2q)x^2+2pqx+q^2$

បម្រាប់ : $x^4+2x^3+ax^2+bx+1=(x^2+px+q)^2$

យើងបាន

$x^4+2x^3+ax^2+bx+1$

$=x^4+2px^3+(p^2+2q)x^2+2pqx+q^2$

ទាញបាន : $\begin{cases}2p=2\\ p^2+2q=a\\ 2pq=b\\ q^2=1\end{cases}$ សមមូល $\begin{cases}p=1\\ p^2+2q=a\\ 2pq=b\\ q=\pm1\end{cases}$

ចំពោះ $\begin{cases}p^2+2q=a\\ 2pq=b\end{cases}$

-ករណី $p=1\ \&\ q=1$

នាំឱ្យ $\begin{cases}1^2+2\cdot1=a\\ 2\cdot1\cdot1=b\end{cases} \Leftrightarrow \begin{cases}a=3\\ b=2\end{cases}$

-ករណី $p=1\ \&\ q=-1$

នាំឱ្យ $\begin{cases}1^2+2\cdot(-1)=a\\ 2\cdot1\cdot(-1)=b\end{cases} \Leftrightarrow \begin{cases}a=-1\\ b=-2\end{cases}$

ដូចនេះ តម្លៃកំណត់បានគឺ $\begin{cases}(a=3\,,\ b=2)\\ (a=-1\,,\ b=-2)\end{cases}$ ។

## ១៣៦ ចូរស្រាយបំភ្លឺថា $\sqrt[4]{49+20\sqrt{6}}+\sqrt[4]{49-20\sqrt{6}}=2\sqrt{3}$

ពិនិត្យ :

$$\sqrt[4]{49+20\sqrt{6}}+\sqrt[4]{49-20\sqrt{6}}$$

$$=\sqrt[4]{25+20\sqrt{6}+24}+\sqrt[4]{25-20\sqrt{6}+24}$$

$$=\sqrt[4]{5^2+20\sqrt{6}+(2\sqrt{6})^2}+\sqrt[4]{5^2+20\sqrt{6}+(2\sqrt{6})^2}$$

$$=\sqrt[4]{(5+2\sqrt{6})^2}+\sqrt[4]{(5-2\sqrt{6})^2}$$

$$=\sqrt{5+2\sqrt{6}}+\sqrt{5-2\sqrt{6}}$$

$$=\sqrt{\sqrt{3}^2+2\sqrt{6}+\sqrt{2}^2}+\sqrt{\sqrt{3}^2-2\sqrt{6}+\sqrt{2}^2}$$

$$=\sqrt{\left(\sqrt{(\sqrt{3}+\sqrt{2})^2}\right)^2}+\sqrt{(\sqrt{3}-\sqrt{2})^2}$$

$$=\sqrt{3}+\sqrt{2}+\sqrt{3}-\sqrt{2}=2\sqrt{3}$$

ដូច្នេះ $\boxed{\text{យើងបំភ្លឺបានថា } \sqrt[4]{49+20\sqrt{6}}+\sqrt[4]{49-20\sqrt{6}}=2\sqrt{3}}$ ។

## ១៣៧ គណនា $E$ :

$$E=\left(\sqrt{3-\sqrt{5}}-\sqrt{3+\sqrt{5}}\right)^2-\left(\sqrt{3-\sqrt{5}}+\sqrt{3+\sqrt{5}}\right)^2$$

$$=\left[\left(\sqrt{3-\sqrt{5}}-\sqrt{3+\sqrt{5}}\right)-\left(\sqrt{3-\sqrt{5}}+\sqrt{3+\sqrt{5}}\right)\right]\times$$
$$\left[\left(\sqrt{3-\sqrt{5}}-\sqrt{3+\sqrt{5}}\right)+\left(\sqrt{3-\sqrt{5}}+\sqrt{3+\sqrt{5}}\right)\right]$$

$$=\left(\sqrt{3-\sqrt{5}}-\sqrt{3+\sqrt{5}}-\sqrt{3-\sqrt{5}}-\sqrt{3+\sqrt{5}}\right)\times$$
$$\left(\sqrt{3-\sqrt{5}}-\sqrt{3+\sqrt{5}}+\sqrt{3-\sqrt{5}}+\sqrt{3+\sqrt{5}}\right)$$

$$=\left(-2\sqrt{3+\sqrt{5}}\right)\left(2\sqrt{3-\sqrt{5}}\right)$$

$$=-4\sqrt{(3+\sqrt{5})(3-\sqrt{5})}$$

$$=-4\sqrt{9-5}=-4\sqrt{4}=-8$$

ដូចនេះ $\boxed{\text{គណនាបាន } E=-8}$ ។

## ១៣៨ កំណត់តម្លៃ $m$ និង $n$

យើងមាន $\dfrac{1}{x-3}+\dfrac{m}{x-4}=\dfrac{n}{(x-3)(x-4)}$

ប្រភាគមានន័យកាលណា $x\neq3\,,\ x\neq4$

តម្រូវភាគបែង រួចលុបភាគបែងចោល យើងបាន :



www.facebook.com/7khmer
fb : Entertainment And Knowledge

$$x-4+m(x-3)=n$$
$$x-4+mx-3m=n$$
$$x+mx=n+3m+4$$
$$x=\frac{n+3m+4}{1+m}$$

ដើម្បីឱ្យប្រភាគ $x$ មានតម្លៃច្រើនរាប់មិនអស់ លុះត្រាតែភាគយកស្មើសូន្យ និងភាគបែងស្មើសូន្យ ដូចគ្នា

-យើងបាន :

$$\begin{cases}n+3m+4=0\\1+m=0\end{cases}\Leftrightarrow\begin{cases}n=-3m-4\\m=-1\end{cases}\Leftrightarrow\begin{cases}n=-1\\m=-1\end{cases}$$

ដូចនេះ | តម្លៃកំណត់បានគឺ $m=n=-1$ | ។

## ១៣៩ កំណត់តម្លៃ $a$

យើងមានប្រព័ន្ធសមីការ : $\begin{cases}x+y=a & (1)\\2x-y=3 & (2)\end{cases}$

ដោយបូកអង្គនិងអង្គ :

$$+\begin{cases}x+y=a\\2x-y=3\end{cases}$$
$$3x=a+3\Rightarrow x=\frac{a+3}{3}$$

តាមសមីការ $(1)$: $y=a-x=a-\frac{a+3}{3}=\frac{2a-3}{3}$

ដើម្បីឱ្យផ្ទៀងផ្ទាត់ $x>y$

យើងបាន : $\frac{a+3}{3}>\frac{2a-3}{3}$

$$a+3>2a-3$$
$$a<6$$

ដូចនេះ | តម្លៃកំណត់បានគឺ $a<6$ | ។

## ១៤០ គណនា $D=(a-1)^{2010}+(b-1)^{2011}+(c-1)^{2012}$

សម្មតិកម្ម $a+b+c=0$ និង $ab+bc+ca=0$

នាំឱ្យបាន $(a+b+c)^2=0$

$$a^2+b^2+c^2+2ab+2ac+2bc=0$$
$$a^2+b^2+c^2+2(ab+ac+bc)=0$$
$$a^2+b^2+c^2+2\times0=0$$
$$a^2+b^2+c^2=0$$

យើងបានដឹងហើយថា បើ $a,b,c$ នោះ

$a^2\geq0$ , $b^2\geq0$ & $c^2\geq0$

-មានតែមួយករណីគត់ដែលធ្វើឱ្យ $a^2+b^2+c^2=0$

គឺមានន័យថា $a^2=0$ , $b^2=0$ & $c^2=0$

នាំឱ្យ $a=0$ , $b=0$ & $c=0$

យើងបាន : $D=(a-1)^{2010}+(b-1)^{2011}+(c-1)^{2012}$

$$=(0-1)^{2010}+(0-1)^{2011}+(0-1)^{2012}$$
$$=(-1)^{2010}+(-1)^{2011}+(-1)^{2012}=1-1+1=1$$

ដូចនេះ | គណនាបាន $D=1$ | ។

## ១៤១ គណនា $S$ :

យើងមាន : $S=(1\cdot3+2\cdot4+3\cdot5+...+2010\cdot2012)-(1^2+2^2+3^2+...+2010^2)$

ពិនិត្យ

$$1\cdot3+2\cdot4+3\cdot5+...+2010\cdot2012$$
$$=(2-1)(2+1)+(3-1)(3+1)+(4-1)(4+1)+...+(2011-1)(2011+1)$$
$$=(2^2-1)+(3^2-1)+(4^2-1)+...+(2011^2-1)$$
$$=2^2+3^2+4^2+...+2011^2-2010$$

នាំឱ្យ

$$S=(2^2+3^2+4^2+...+2011^2-2010)-(1^2+2^2+3^2+...+2010^2)$$
$$=2^2+3^2+4^2+...+2011^2-2010-1^2-2^2-3^2-...-2010^2$$
$$=2011^2-2010-1^2$$
$$=2011^2-2011$$
$$=2011(2011-1)$$
$$=2011\times2010=4042110$$

ដូចនេះ | គណនាបានគឺ $S=2011\cdot2010=4042110$ | ។

## ១៤២ បង្ហាញថា $A$ ចែកដាច់នឹង 5 :

យើងមាន :

$$A=9^{2011}+8^{2011}+7^{2011}+6^{2011}+5^{2011}-1^{2011}-2^{2011}-3^{2011}-4^{2011}$$
$$A=(9^{2011}-4^{2011})+(8^{2011}-3^{2011})+(7^{2011}-2^{2011})+(6^{2011}-1^{2011})+5^{2011}$$

តាមរូបមន្ត :

$$a^n-b^n=(a-b)(a^{n-1}b+a^{n-2}b^2+...+a^2b^{n-2}+ab^{n-1})$$

យើងឃើញថា :

• $9^{2011}-4^{2011}=(9-4)(9^{2010}\cdot4+9^{2009}\cdot4^2+...+9\cdot4^{2010})$

$=5k_1$ , $k_1=(9^{2010}\cdot4+9^{2009}\cdot4^2+...+9\cdot4^{2010})$



www.facebook.com/7khmer
fb : Entertainment And Knowledge

$\bullet\ 8^{2011}-3^{2011}=(8-3)(8^{2010}\cdot 3+8^{2009}\cdot 3^2+...+8\cdot 3^{2010})$

$=5k_2\ ,\ k_2=(8^{2010}\cdot 3+8^{2009}\cdot 3^2+...+8\cdot 3^{2010})$

$\bullet\ 7^{2011}-2^{2011}=(7-2)(7^{2010}\cdot 2+7^{2009}\cdot 2^2+...+7\cdot 2^{2010})$

$=5k_3\ ,\ k_3=(7^{2010}\cdot 2+7^{2009}\cdot 2^2+...+7\cdot 2^{2010})$

$\bullet\ 6^{2011}-1^{2011}=(6-1)(6^{2010}\cdot 1+6^{2009}\cdot 1^2+...+6\cdot 1^{2010})$

$=5k_4\ ,\ k_4=(6^{2010}\cdot 1+6^{2009}\cdot 1^2+...+6\cdot 1^{2010})$

$\bullet\ 5^{2011}=5\cdot 5^{2010}$

$=5k_5\ ,\ k_5=5^{2010}$

យើងបាន : $A=5k_1+5k_2+5k_3+5k_4+5k_5$

$=5(k_1+k_2+k_3+k_4+k_5)$

ឃើញថា $A$ ជាពហុគុណនៃ5 មានន័យថា $A$ ចែកដាច់នឹង5

ដូចនេះ | បង្ហាញបានថា $A$ ចែកដាច់នឹង 5 | ។

## ១៤៣ ក. គណនា $fog$ និងគណនា $gof$

យើងមាន $f:x\to f(x)=px-2$

$g:x\to g(x)=4x+3$

នាំឱ្យ $fog=f[g(x)]$

$=f[4x+3]$

$=p(4x+3)-2$

$=4px+3p-2$

ហើយ $gof=g[f(x)]$

$=g[px-2]$

$=4(px-2)+3$

$=4px-8+3$

$=4px-5$

ដូចនេះ | គណនាបាន $fog=4px+3p-2$ ហើយ $gof=4px-5$ | ។

### ខ. គណនា $p$ ដើម្បីឱ្យ $fog=gof$

យើងមាន $fog=4px+3p-2$ និង $gof=4px-5$

នាំឱ្យ $fog=gof$

នោះ $4px+3p-2=4px-5$

$3p=-5+2$

$p=-1$

ដូចនេះ | តម្លៃគណនាបានគឺ $p=-1$ | ។

## ១៤៤ បង្ហាញថា $P_n=\dfrac{1}{2^n}\cdot\dfrac{\sin x}{\sin\dfrac{x}{2^n}}$

យើងមាន $P_n=\cos\dfrac{x}{2}\cos\dfrac{x}{2^2}\cos\dfrac{x}{2^3}\times...\times\cos\dfrac{x}{2^n}$

តាមរូបមន្ត : $\sin a=2\sin\dfrac{a}{2}\cos\dfrac{a}{2}$

យើងឱ្យតម្លៃ $a=x\ ,\dfrac{x}{2},\dfrac{x}{4},\dfrac{x}{8},...,\dfrac{x}{2^{n-1}}$

$$\times\begin{cases}\sin x=2\sin\dfrac{x}{2}\cos\dfrac{x}{2}\\ \sin\dfrac{x}{2}=2\sin\dfrac{x}{4}\cos\dfrac{x}{4}\\ \sin\dfrac{x}{4}=2\sin\dfrac{x}{8}\cos\dfrac{x}{8}\\ \cdots\cdots\cdots\cdots\cdots\cdots\\ \sin\dfrac{x}{2^{n-1}}=2\sin\dfrac{x}{2^n}\cos\dfrac{x}{2^n}\end{cases}$$

$$\sin x=2^n\sin\frac{x}{2^n}\underbrace{\cos\frac{x}{2}\cos\frac{x}{4}\cos\frac{x}{8}\times...\times\cos\frac{x}{2^n}}_{P_n}$$

$\sin x=2^n\sin\dfrac{x}{2^n}P_n$

ទាញបាន $P_n=\dfrac{1}{2^n}\cdot\dfrac{\sin x}{\sin\dfrac{x}{2^n}}$

ដូចនេះ | បង្ហាញបានថា $P_n=\dfrac{1}{2^n}\cdot\dfrac{\sin x}{\sin\dfrac{x}{2^n}}$ | ។

## ១៤៥ ដោះស្រាយប្រព័ន្ធសមីការក្នុង $\aleph\times\aleph$

យើងមាន : $\begin{cases}x^2-y^2=5440 & (1)\\ PGCD(x,y)=8 & (2)\end{cases}$

-តាម (2) : $PGCD(x,y)=8$ មានន័យថា

$x=8a$ & $y=8b$ ដែល $a\ ,b$ ជាចំនួនបឋមរវាងគ្នា

ហើយ $a>b$ ព្រោះ $x^2-y^2=5440>0$

-តាម (1) : $x^2-y^2=5440$

$(x-y)(x+y)=5440$

$(8a-8b)(8a+8b)=5440$

$8^2(a-b)(a+b)=5440$



www.facebook.com/7khmer
fb : Entertainment And Knowledge

$(a-b)(a+b)=85$

ដោយ $a$ , $b$ ជាចំនួនគត់ធម្មជាតិ និងដោះស្រាយក្នុង $\aleph\times\aleph$

យើងបានផលគុណកត្តានៃ $85=\begin{cases}1\times 85\\ 5\times 17\end{cases}$ ដោយ $a>b$

នោះយើងបាន : $\begin{cases}a-b=1\\ a+b=85\end{cases}(i)$ or $\begin{cases}a-b=5\\ a+b=17\end{cases}(ii)$

$(i)$ : $+\begin{cases}a-b=1\\ a+b=85\end{cases}$ ; $2a=86 \Rightarrow a=43$

ហើយ $b=85-a=85-43=42$

$(ii)$ : $+\begin{cases}a-b=5\\ a+b=17\end{cases}$ ; $2a=22 \Rightarrow a=11$

ហើយ $b=17-a=17-11=6$

-ចំពោះ $a=43$ , $b=42$

នាំឱ្យ $\begin{cases}x=8a=8\cdot 43=344\\ y=8b=8\cdot 42=336\end{cases}$

-ចំពោះ $a=11$ , $b=6$

នាំឱ្យ $\begin{cases}x=8a=8\cdot 11=88\\ y=8b=8\cdot 6=48\end{cases}$

ដូចនេះ ប្រព័ន្ធសមីការមានគូចម្លើយពីរគឺ $(x,y)=(344,336)$ ឬ $(x,y)=(88,48)$ ។

## ១៤៦ ដោះស្រាយសមីការក្នុងសំណុំចំនួនគត់ធម្មជាតិ

យើងមាន : $xy=3x+2y+37$

$xy-3x-2y=37$

$xy-3x-2y+6=37+6$

$x(y-3)-2(y-3)=43$

$(y-3)(x-2)=43$

ដោយដោះស្រាយក្នុងសំណុំចំនួនគត់ធម្មជាតិ

មានន័យថា $(y-3)$ និង $(x-2)$ ជាចំនួនគត់ធម្មជាតិ

ហើយផលគុណចំនួនធម្មជាតិស្មើ 43 មានតែពីរករណីគឺ

$43=\begin{cases}43\times 1\\ 1\times 43\end{cases}$ យើងបានកត្តានីមួយៗគឺ :

• $\begin{cases}y-3=43\\ x-2=1\end{cases} \Rightarrow \begin{cases}y=46\\ x=3\end{cases}$

ឬ • $\begin{cases}y-3=1\\ x-2=43\end{cases} \Rightarrow \begin{cases}y=4\\ x=45\end{cases}$

ដូចនេះ សមីការមានឫស $(x=3, y=46)$ ឬ $(x=35, y=4)$ ។

## ១៤៧ បំភ្លឺថាចំនួន $N=(4n+3)^2-25$ ចែកដាច់នឹង 8

យើងមាន : $N=(4n+3)^2-25$

$=(4n+3)^2-5^2$

$=(4n+3-5)(4n+3+5)$

$=(4n-2)(4n+8)$

$=2(2n-1)\times 4(n+2)$

$=8(2n-1)(n+2)$

ឃើញថា $N$ ជាពហុគុណនៃ 8 មានន័យថា $N$ ចែកដាច់នឹង8

ដូចនេះ ឃើញថា $N=(4n+3)^2-25$ ចែកដាច់នឹង8 ។

## ១៤៨ បំភ្លឺថាចំនួន $a,b,c$ និង $d$ ជាតួនៃ សមាមាត្រ

សម្មតិកម្ម $(a^2+b^2)(c^2+d^2)=(ad+bc)^2$

$a^2c^2+a^2d^2+b^2c^2+b^2d^2=a^2d^2+2adbc+b^2c^2$

$a^2c^2-2adbc+b^2d^2=0$

$(ac-bd)^2=0$

$ac-bd=0$

$ac=bd$

$\frac{a}{b}=\frac{c}{d}$

ដូចនេះ យើងបានតួនៃសមមាត្រ $\frac{a}{b}=\frac{c}{d}$ ។

## ១៤៩ បង្ហាញថា $\frac{a^2}{a^2+b^2}+\frac{x^2}{x^2+y^2}=1 \quad (*)$

សម្មតិកម្ម : $ax+by=0$

នាំឱ្យ $x=-\frac{by}{a} \Leftrightarrow x^2=\frac{b^2y^2}{a^2}$

យកតម្លៃ $x^2=\frac{b^2y^2}{a^2}$ ជំនួសចូល $(*)$ យើងបាន :



www.facebook.com/7khmer
fb : Entertainment And Knowledge

$$\frac{a^2}{a^2+b^2}+\frac{\frac{b^2y^2}{a^2}}{\frac{b^2y^2}{a^2}+y^2}=1$$

$$\frac{a^2}{a^2+b^2}+\frac{\frac{b^2y^2}{a^2}}{\frac{b^2y^2+a^2y^2}{a^2}}=1$$

$$\frac{a^2}{a^2+b^2}+\frac{b^2y^2}{a^2}\times\frac{a^2}{b^2y^2+a^2y^2}=1$$

$$\frac{a^2}{a^2+b^2}+\frac{b^2y^2}{(b^2+a^2)y^2}=1$$

$$\frac{a^2}{a^2+b^2}+\frac{b^2}{a^2+b^2}=1$$

$$\frac{a^2+b^2}{a^2+b^2}=1$$

$1=1$ ពិត

ដូចនេះ **ឃើញថា $\frac{a^2}{a^2+b^2}+\frac{x^2}{x^2+y^2}=1$** ។

## ១៩០ គណនាតម្លៃនៃ $K=\frac{a^2+b^2+c^2}{2011}$

សម្មតិកម្ម : $\frac{1}{a}+\frac{1}{b}+\frac{1}{c}=0$

$$\frac{bc+ac+ab}{abc}=0$$

នាំឱ្យ $ab+bc+ac=0$ ដែល $a\neq 0, b\neq 0, c\neq 0$

សម្មតិកម្មបន្ថែម : $a+b+c=0$

នាំឱ្យ $(a+b+c)^2=0$

$$a^2+b^2+c^2+2ab+2bc+2ac=0$$

$$a^2+b^2+c^2+2(ab+bc+ac)=0$$

$$a^2+b^2+c^2+2\times 0=0$$

$$a^2+b^2+c^2=0$$

ព្រោះ $ab+bc+ac=0$

យើងបាន : $K=\frac{a^2+b^2+c^2}{2011}=\frac{0}{2011}=0$

ដូចនេះ **តម្លៃគណនាបានគឺ $K=0$** ។

## ១៩១ បង្ហាញថា $A$ ជាចំនួនគត់

យើងមាន :

$$A=2011\sqrt{\sqrt{5}-\sqrt{3-\sqrt{29-12\sqrt{5}}}}$$

$$=2011\sqrt{\sqrt{5}-\sqrt{3-\sqrt{\sqrt{20}^2-12\sqrt{5}+3^2}}}$$

$$=2011\sqrt{\sqrt{5}-\sqrt{3-\sqrt{(2\sqrt{5}-3)^2}}}$$

$$=2011\sqrt{\sqrt{5}-\sqrt{3-2\sqrt{5}+3}}$$

$$=2011\sqrt{\sqrt{5}-\sqrt{\sqrt{5}^2-2\sqrt{5}+1^2}}$$

$$=2011\sqrt{\sqrt{5}-\sqrt{(\sqrt{5}-1)^2}}$$

$$=2011\sqrt{\sqrt{5}-\sqrt{5}+1}=2011\sqrt{1}=2011$$

ដូចនេះ **ឃើញថា $A=2011$ ជាចំនួនគត់** ។

## ១៩២ ដោះស្រាយសមីការ

យើងមាន : $\sqrt{x^2+4x+4}=\sqrt{x^2+2x+1}$

លើកអង្គទាំងពីរជាការេ នោះយើងបាន :

$$x^2+4x+4=x^2+2x+1$$

$$2x=-3$$

$$x=-\frac{3}{2}$$

ផ្ទៀងផ្ទាត់

$$\sqrt{\left(-\frac{3}{2}\right)^2+4\left(-\frac{3}{2}\right)+4}=\sqrt{\left(-\frac{3}{2}\right)^2+2\left(-\frac{3}{2}\right)+1}$$

$$\sqrt{\frac{9}{4}-6+4}=\sqrt{\frac{9}{4}-3+1}$$

$$\sqrt{\frac{9}{4}-2}=\sqrt{\frac{9}{4}-2}$$

$$\sqrt{\frac{1}{4}}=\sqrt{\frac{1}{4}}$$

$$\frac{1}{2}=\frac{1}{2}$$

ដូនេះ **សមីការមានឫស $x=-\frac{3}{2}$** ។

(បើមិនឱ្យលក្ខខណ្ឌ ត្រូវផ្ទៀងផ្ទាត់ឱ្យគេ)



www.facebook.com/7khmer
fb : Entertainment And Knowledge

## ១៩៣ គណនាបីចំនួនគត់តគ្នា

តាង $n$ ជាចំនួនទី2 នោះចំនួនទី1គឺ $(n-1)$ និងទី3គឺ$(n+1)$

ដែល $n$ ជាចំនួនគត់វិជ្ជមាន

-តាមបម្រាប់ប្រធានយើងសរសេរបាន :

$$\frac{(n-1)n(n+1)}{\left(\frac{(n-1)+n+(n+1)}{2}\right)^2}=\frac{130}{21}$$

$$\frac{(n-1)n(n+1)}{\left(\frac{3n}{2}\right)^2}=\frac{130}{21}$$

$$n(n-1)(n+1)=\frac{130}{21}\times\left(\frac{9n^2}{4}\right)$$

$$n(n^2-1)=\frac{195}{14}n^2$$

$$14(n^2-1)=195n$$

$$14n^2-195n-14=0$$

មាន $\Delta=195^2-4\cdot14\cdot(-14)$

$$=38025+784=38809=197^2$$

នាំឱ្យ $\bullet\, n_1=\frac{-(-195)-197}{2\cdot14}=-\frac{1}{14}$ មិនយក

$\bullet\, n_2=\frac{-(-195)+197}{2\cdot14}=14$

-ចំពោះ $n=14$

យើងបាន ចំនួនទី1គឺ $n-1=14-1=13$

ចំនួនទី3គឺ $n+1=14+1=15$

ដូចនេះ **ចំនួនគត់ទាំងបីតគ្នាគឺ 13 , 14 , 15** ។

## ១៩៤ គណនាតម្លៃលេខនៃ $xyz$

សម្មតិកម្ម : $x^2yz^3=7^3$ $(i)$ និង $xy^2=7^9$ $(ii)$

ដោយយក $(1)\times(2)$ យើងបាន :

$$\times\begin{cases}x^2yz^3=7^3\\ xy^2=7^9\end{cases}$$

$$x^3y^3z^3=7^{12}\quad\Rightarrow xyz=\sqrt[3]{7^{12}}=7^{\frac{12}{3}}=7^4$$

ដូចនេះ **តម្លៃនៃ $xyz=7^4$** ។

## ១៩៥ រកតម្លៃលេខនៃ $\frac{2^{2012}-2^{2011}}{2^{2012}+2^{2011}}$

យើងមាន $\frac{2^{2012}-2^{2011}}{2^{2012}+2^{2011}}=\frac{2^{2011}(2-1)}{2^{2011}(2+1)}=\frac{1}{3}$

ដូចនេះ **តម្លៃនៃ $\frac{2^{2012}-2^{2011}}{2^{2012}+2^{2011}}=\frac{1}{3}$** ។

## ១៩៦ គណនាកន្សោម $H$ :

យើងមាន $H=\frac{a^2}{(a-b)(a-c)}+\frac{b^2}{(b-c)(b-a)}+\frac{c^2}{(c-a)(c-b)}$

កន្សោមនេះមានភាគបែងរួម $(a-b)(a-c)(b-c)$ នោះ

$$H=\frac{a^2}{(a-b)(a-c)}+\frac{b^2}{(b-c)(b-a)}+\frac{c^2}{(c-a)(c-b)}$$

$$=\frac{a^2}{(a-b)(a-c)}-\frac{b^2}{(b-c)(a-b)}+\frac{c^2}{(a-c)(b-c)}$$

$$=\frac{a^2(b-c)-b^2(a-c)+c^2(a-b)}{(a-b)(a-c)(b-c)}$$

$$=\frac{a^2b-a^2c-ab^2+b^2c+ac^2-bc^2}{(a^2-ac-ab+bc)(b-c)}$$

$$=\frac{a^2b-a^2c-ab^2+b^2c+ac^2-bc^2}{a^2b-a^2c-\cancel{abc}+ac^2-ab^2+\cancel{abc}+b^2c-bc^2}$$

$$=\frac{a^2b-a^2c-ab^2+b^2c+ac^2-bc^2}{a^2b-a^2c-ab^2+b^2c+ac^2-bc^2}=1$$

ដូចនេះ **ក្រោយពីគណនា តម្លៃ $H=1$** ។

## ១៩៧ រកក្រឡាផ្ទៃធំបំផុតនៃចម្ការ

តាង $a$ ជាប្រវែងទទឹង និង $b$ ជាប្រវែងបណ្តោយ

បម្រាប់ : កូនឈើមាន 40 ដើម

គម្លាតនៃកូនឈើ $2m$




នាំឱ្យ ចម្ការមានបរិមាត្រ $P=2\times40m$

តែ $P=2(a+b)$

យើងបាន $2(a+b)=2\times40m \Leftrightarrow a+b=40m$

-ចំពោះចតុកោណកែងដែលមានបរិមាត្រដូចគ្នា គឺចតុកោណកែងមានទទឹងស្មើបណ្តោយមានផ្ទៃធំបំផុត ។

នោះ $a=b \Rightarrow a+a=40 \Rightarrow a=20m$



www.facebook.com/7khmer
fb : Entertainment And Knowledge

នាំឱ្យ ក្រឡាផ្ទៃធំបំផុតគឺ :

$$S_{Max} = ab = aa = a^2 = (20m)^2 = 400\ m^2$$

ដូចនេះ ក្រឡាផ្ទៃធំបំផុតនៃចម្ការគឺ $S_{Max} = 400\ m^2$ ។

## ១៥៨ បង្ហាញថាចំនួន $\sqrt{3}$ ពុំមែនជាចំនួនសនិទាន

( ចំនួនសនិទានជាចំនួនមានទម្រង់ជាប្រភាគ $\frac{a}{b}$ ហើយ $a$ និង $b$ ជាចំនួនបឋមរវាងគ្នា ( បឋមរវាងគ្នាគឺតួចែករួមធំបំផុតនៃ $a$ និង $b$ ស្មើ1) )

-ឧបមាថា $\sqrt{3}$ ជាចំនួនសនិទាន

នាំឱ្យ $\sqrt{3}$ មានទម្រង់ជាប្រភាគសម្រួលមិនបាន

-តាង $\sqrt{3} = \frac{a}{b} \Leftrightarrow 3 = \frac{a^2}{b^2} \Rightarrow a^2 = 3b^2$

-ឃើញថា $a^2$ ជាពហុគុណនៃ 3 នោះ $a$ ក៏ជាពហុគុណនៃ 3 ដែរ មានន័យថា $a = 3k$ , $k$ ជាចំនួនគត់

-នាំឱ្យ $a^2 = 3b^2 \Leftrightarrow (3k)^2 = 3b^2 \Leftrightarrow b^2 = 3k^2$

-ឃើញថា $b^2$ ជាពហុគុណនៃ 3 នោះ $b$ ក៏ជាពហុគុណនៃ 3 ដែរ មានន័យថា $b = 3p$ , $p$ ជាចំនួនគត់

-នាំឱ្យ $\sqrt{3} = \frac{a}{b} = \frac{3k}{3p} = \frac{k}{p}$ អាចសម្រួលបាន មានន័យថាវាពុំបានគោរពតាមលក្ខខណ្ឌចំនួនសនិទាន នោះវាពុំមែនជាចំនួនសនិទានទេ ( អញ្ចឹងមានតែ ជាចំនួនអសនិទាន)

ដូចនេះ ចំនួន $\sqrt{3}$ ពុំមែនជាចំនួនសនិទាន ។

( ខាងលើនេះបកស្រាយតាមសំណើផ្ទុយ តក្កវិទ្យា )

## ១៥៩ ដោះស្រាយសមីការ $x^2 + y^2 = 0$

សម្មតិកម្ម: $x$ និង $y$ ជាចំនួនពិត នោះ $x^2 \ge 0$ និង $y^2 \ge 0$

មានតែមួយករណីគត់ដែលផ្ទៀងផ្ទាត់សមីការ $x^2 + y^2 = 0$ គឺ $x = 0$ & $y = 0$

ដូចនេះ សមីការមានឫស $x = 0$ & $y = 0$ ។

( លំហាត់ខាងលើត្រូវការចំណេះដឹង ពុំមែនបច្ចេកទេសទេ)

## ១៦០ គណនា $A$ , $B$ , $C$ , $D$ និង $E$ :

$$A = 2\frac{3}{4} = \frac{(2\times4)+3}{4} = \frac{8+3}{4} = \boxed{\frac{11}{4}}$$

$$B = 2\cdot\frac{3}{4} = \frac{2\times3}{4} = \frac{6}{4} = \boxed{\frac{3}{2}}$$

$$C = 2\times\frac{3}{4} = \frac{2}{1}\times\frac{3}{4} = \frac{2\times3}{1\times4} = \frac{6}{4} = \boxed{\frac{3}{2}}$$

$$D = 2\left(\frac{3}{4}\right) = (2)\frac{(3)}{(2)(2)} = \frac{(3)}{(2)} = \boxed{\frac{3}{2}}$$

$$E = 2+\frac{3}{4} = \frac{2\times4}{4}+\frac{3}{4} = \frac{8}{4}+\frac{3}{4} = \frac{8+3}{4} = \boxed{\frac{11}{4}}$$

## ១៦១ គណនា $A$ , $B$ , $C$ , $D$ និង $E$ :

$$A = 2^{2^2} = 2^4 = 2\cdot2\cdot2\cdot2 = \boxed{16}$$

$$B = (2^2)^2 = (4)^2 = 4\cdot4 = \boxed{16}$$

$$C = 2^{2\cdot2} = 2^4 = \boxed{16}$$

$$D = 2^{2+2} = 2^4 = \boxed{16}$$

$$E = 2\cdot2^2 = 2\cdot4 = \boxed{8}$$

## ១៦២ សរសេរជាទម្រង់ប្រភាគនៃ $A$ , $B$ , $C$ :

$A = 1.\overline{2}$ មានន័យថា $A = 1.2222222222222...$

នាំឱ្យ $10A = 12.2222222222222...$

សិក្សាផលដក

$$-\begin{cases}10A = 12.2222222222...\\ A = 1.22222222222...\end{cases}$$
$$9A = 11 \Rightarrow \boxed{A = \frac{11}{9}}$$

$B = 0.\overline{12}$ មានន័យថា $B = 0.121212121212...$

នាំឱ្យ $100B = 12.121212121212...$

សិក្សាផលដក

$$-\begin{cases}100B = 12.1212121212...\\ B = 0.121212121212...\end{cases}$$
$$99B = 12 \Rightarrow \boxed{B = \frac{12}{99} = \frac{4}{33}}$$



www.facebook.com/7khmer
fb : Entertainment And Knowledge

$C=0.1\overline{2}$ មានន័យថា $C=0.1222222222222...$

នាំឱ្យ $10C=0.1222222222222...$

សិក្សាផលដក

$$-\begin{cases}10C=1.2222222222222...\\ C=0.12222222222222...\end{cases}$$
$$9C=1.1 \quad \Rightarrow \quad \boxed{C=\frac{1.1}{9}=\frac{11}{90}}$$

$D=1.2\overline{0}$ មានន័យថា

$D=1.2000000...=1.2=\frac{12}{10}=\boxed{\frac{6}{5}}$ ។

## ១៦៣ គណនាអង្កត់ទ្រូង និងចម្ងាយខ្លីបំផុតពីចំណុចប្រសព្វរវាងអង្កត់ទ្រូងទៅជ្រុងការេ




-បើ $d$ ជាប្រវែងអង្កត់ទ្រូងការេដែលមានជ្រុង $a$ :

តាមទ្រឹស្តីបទពីតាគ័រ : $d^2=a^2+a^2=2a^2$

នាំឱ្យ $d=\sqrt{2a^2} \quad \Rightarrow \quad d=a\sqrt{2}$ ព្រោះ $d>0$

ដូចនេះ $\boxed{\text{អង្កត់ទ្រូងការេ } d=a\sqrt{2} \text{ ឯកតាប្រវែង}}$ ។

-ចម្ងាយខ្លីបំផុតពីចំណុចប្រសព្វរវាងអង្កត់ទ្រូងទៅជ្រុងការេ គឺជាប្រវែងអង្កត់ដែលភ្ជាប់ពីចំណុចប្រសព្វនោះទៅចំណុចកណ្តាលនៃជ្រុងការេនោះ ។

បើ $x$ ជាប្រវែងខ្លីបំផុតនោះ ( តាមទ្រឹស្តីបទពីតាគ័រ)

យើងបាន : $x^2+\left(\frac{a}{2}\right)^2=\left(\frac{d}{2}\right)^2$

ឬ $x=\sqrt{\left(\frac{d}{2}\right)^2-\left(\frac{a}{2}\right)^2}=\sqrt{\left(\frac{a\sqrt{2}}{2}\right)^2-\left(\frac{a}{2}\right)^2}$

$=\sqrt{\frac{a^2}{2}-\frac{a^2}{4}}=\sqrt{\frac{a^2}{4}}=\frac{a}{2}$

ដូចនេះ $\boxed{\text{ចម្ងាយខ្លីបំផុតគឺ } x=\frac{a}{2} \text{ ឯកតាប្រវែង}}$ ។

## ១៦៤ គណនា $AC$

$ABC$ និង $ABD$ ជាត្រីកោណកែង




តាមទ្រឹស្តីបទពីតាគ័រ :

-ចំពោះត្រីកោណកែង $ABD$

$$AD^2=AB^2+BD^2$$
$$\Rightarrow BD^2=AD^2-AB^2$$
$$\Rightarrow BD=\sqrt{AD^2-AB^2}$$
$$\Rightarrow BD=\sqrt{2^2-1^2}=\sqrt{3}$$

-ចំពោះត្រីកោណកែង $ABC$

$$AC^2=AB^2+BC^2$$
$$AC=\sqrt{AB^2+BC^2}$$
$$=\sqrt{AB^2+(BD+DC)^2}$$
$$=\sqrt{1^2+\left(\sqrt{3}+2\right)^2}=\sqrt{1+3+4\sqrt{3}+4}$$
$$=\sqrt{8+4\sqrt{3}}=2\sqrt{2+\sqrt{3}}$$

ដូចនេះ $\boxed{\text{ប្រវែង } AC=2\sqrt{2+\sqrt{3}}}$ ។

## ១៦៥ ដោះស្រាយសមីការ

យើងមានសមីការ :

$$\left(\sqrt{2+\sqrt{3}}\cdot\sqrt{2+\sqrt{2+\sqrt{3}}}\cdot\sqrt{2-\sqrt{2+\sqrt{3}}}\right)x-2011=0$$
$$\left(\sqrt{2+\sqrt{3}}\cdot\sqrt{\left(2+\sqrt{2+\sqrt{3}}\right)\left(2-\sqrt{2+\sqrt{3}}\right)}\right)x-2011=0$$
$$\left(\sqrt{2+\sqrt{3}}\cdot\sqrt{2^2-\left(\sqrt{2+\sqrt{3}}\right)^2}\right)x-2011=0$$
$$\left(\sqrt{2+\sqrt{3}}\cdot\sqrt{2^2-\left(\sqrt{2+\sqrt{3}}\right)^2}\right)x-2011=0$$
$$\left(\sqrt{2+\sqrt{3}}\cdot\sqrt{4-2-\sqrt{3}}\right)x-2011=0$$
$$\left(\sqrt{2+\sqrt{3}}\cdot\sqrt{2-\sqrt{3}}\right)x-2011=0$$
$$\left(\sqrt{\left(2+\sqrt{3}\right)\left(2-\sqrt{3}\right)}\right)x=2011$$
$$\left(\sqrt{4-\sqrt{3}^2}\right)x=2011$$
$$x=2011$$

ដូចនេះ $\boxed{\text{ឫសនៃសមីការ } x=2011}$ ។



www.facebook.com/7khmer
fb : Entertainment And Knowledge

## ១៦៦ ដោះស្រាយសមីការ

យើងមានសមីការ :

$$(x^2+2x+4)(x^2+2x+3)=x^2+2x+7$$
$$(x^2+2x+4)(x^2+2x+3)=(x^2+2x+3)+4$$
$$(x^2+2x+4)-(x^2+2x+4)=4$$
$$(x^2+2x+3)[(x^2+2x+4)-1]=4$$
$$(x^2+2x+3)^2=2^2$$
$$(x^2+2x+3)=\pm 2$$

-ចំពោះ $x^2+2x+3=2$

$$x^2+2x+1=0 \Leftrightarrow (x+1)^2=0$$
$$\Leftrightarrow x+1=0$$
$$\Rightarrow x=-1$$

-ចំពោះ $x^2+2x+3=-2$

$$x^2+2x+1=-4 \Leftrightarrow (x+1)^2=-2$$

ដោយ $(x+1)^2 \geq 0$

នាំឱ្យ $(x+1)^2=-2$ ជាសមីការគ្មានឫស

ដូចនេះ | សមីការមានឫស $x=-1$ | ។

## ១៦៧ ស្រាយបញ្ជាក់ថា $aS_{n+1}+bS_n+cS_{n-1}=0$

ដោយ $x_1$ និង $x_2$ ជាឫសនៃសមីការ $ax^2+bx+c=0$

នោះវាផ្ទៀងផ្ទាត់ : $\begin{cases} ax_1^2+bx_1+c=0 \\ ax_2^2+bx_2+c=0 \end{cases}$

យើងអាចគុណថែម $\begin{cases} ax_1^2+bx_1+c=0 & \big| x_1^{n-1} \\ ax_2^2+bx_2+c=0 & \big| x_2^{n-1} \end{cases}$

យើងបាន $\begin{cases} ax_1^{2+n-1}+bx_1^{1+n-1}+cx_1^{n-1}=0 \\ ax_2^{2+n-1}+bx_2^{1+n-1}+cx_2^{n-1}=0 \end{cases}$

$$+\begin{cases} ax_1^{n+1}+bx_1^n+cx_1^{n-1}=0 \\ ax_1^{n+1}+bx_2^n+cx_2^{n-1}=0 \end{cases}$$
$$a(x_1^{n+1}+x_2^{n+1})+b(x_1^n+x_2^n)+c(x_1^{n-1}+x_2^{n-1})=0$$

ដោយ $S_n=x_1^n+x_2^n$ នោះ $S_{n-1}=x_1^{n-1}+x_2^{n-1}$

ហើយ $S_{n+1}=x_1^{n+1}+x_2^{n+1}$

ដូចនេះ | យើងបាន $aS_{n+1}+bS_n+cS_{n-1}=0$ | ។

## ១៦៨ គណនា $\frac{x^2}{y^2}$

គេឱ្យ $\frac{x^2+2y^2}{306}=\frac{x^2-2y^2}{294}$

$$294(x^2+2y^2)=306(x^2-2y^2)$$
$$6\times 49(x^2+2y^2)=6\times 51(x^2-2y^2)$$
$$49x^2+92y^2=51x^2-102y^2$$
$$49x^2-51x^2=-92y^2-102y^2$$
$$-2x^2=-200y^2$$
$$\frac{x^2}{y^2}=\frac{-200}{-2}$$
$$\frac{x^2}{y^2}=100$$

ដូចនេះ | គណនាបាន $\frac{x^2}{y^2}=100$ | ។

## ១៦៩ គណនា $A$ :

គេឱ្យ $A=(x+2)^2-2(x+2)(x-8)+(x-8)^2$

តាមរូបមន្ត $(a-b)^2=a^2-2ab+b^2$

យើងបាន $A=[(x+2)-(x-8)]^2$

$$=[(x+2)-(x-8)]^2$$
$$=[x+2-x+8]^2$$
$$=10^2=100$$

ចំពោះ $x=2011^{2012}$ គ្មានទាក់ទងនឹងតម្លៃរបស់ $A$

ដូចនេះ | យើងគណនាបាន $A=100$ | ។

## ១៧០ ស្រាយបំភ្លឺថា $a^2+b^2+c^2=1$

គេឱ្យ $a+b+c=1$

នាំឱ្យ $(a+b+c)^2=1^2$

$$a^2+b^2+c^2+2ab+2ac+2bc=1$$
$$a^2+b^2+c^2+2(ab+ac+bc)=1 \qquad (1)$$

សម្មតិកម្មបន្ថែម $\frac{1}{a}+\frac{1}{b}+\frac{1}{c}=0$

$$\frac{bc+ac+ab}{abc}=0$$
$$\Rightarrow bc+ac+ab=0 \quad , abc\neq 0$$

នាំឱ្យសមីការ $(1)$ ទៅជា :



www.facebook.com/7khmer
fb : Entertainment And Knowledge

$$a^2+b^2+c^2+2\times 0=1$$
$$a^2+b^2+c^2=1$$

ដូចនេះ | យើងឃើញថា $a^2+b^2+c^2=1$ ពិតមែន | ។

## ១៧១ រកពីរចំនួនពិត

តាង $a$ និង $b$ ជាពីរចំនួនពិតដែលត្រូវរកនោះ

តាមបម្រាប់ : $a+b=13 \quad (1)$

ហើយផលបូកច្រាសគឺ $\frac{1}{a}+\frac{1}{b}=\frac{13}{40} \quad (2)$

តាម $(2)$: $\frac{1}{a}+\frac{1}{b}=\frac{13}{40} \Leftrightarrow \frac{a+b}{ab}=\frac{13}{40}$

ទាញបានផលគុណ $ab=40 \quad (3)$

តាម $(1)\,\&\,(3)$ យើងបានប្រព័ន្ធសមីការ: $\begin{cases}a+b=13\\ ab=40\end{cases}$

ដោយស្គាល់ផលបូក និងផលគុណយើងបានសមីការដឺក្រេទី2

ដែលមាន $a$ និង $b$ ជាឬស គឺសមីការ : $x^2-13x+40=0$

មាន $\Delta=(-13)^2-4\cdot1\cdot40=169-160=9=3^3$

នាំឱ្យ $\begin{cases}a=\dfrac{-(-13)-3}{2\cdot1}=\dfrac{10}{2}=5\\ b=\dfrac{-(-13)+3}{2\cdot1}=\dfrac{16}{2}=8\end{cases}$

ឬ $\begin{cases}b=\dfrac{-(-13)-3}{2\cdot1}=\dfrac{10}{2}=5\\ a=\dfrac{-(-13)+3}{2\cdot1}=\dfrac{16}{2}=8\end{cases}$

ដូចនេះ | ពីរចំនួនពិតរកបាន $\begin{cases}a=5\\ b=8\end{cases}$ ឬ $\begin{cases}a=8\\ b=5\end{cases}$ | ។

## ១៧២ ក. ដោះស្រាយសមីការ ចំពោះ $k=3$

គេឱ្យ
$$(x+1)(x+2)(x+3)(x+4)=k$$
$$[(x+1)(x+4)][(x+2)(x+3)]=3$$
$$(x^2+5x+4)(x^2+5x+6)=3$$
$$[(x^2+5x+5)-1][(x^2+5x+5)+1]=3$$
$$(x^2+5x+5)^2-1^2=3$$
$$(x^2+5x+5)^2-2^2=0$$
$$(x^2+5x+5-2)(x^2+5x+5+2)=0$$
$$(x^2+5x+3)(x^2+5x+7)=0$$

នាំឱ្យកត្តានីមួយៗស្មើសូន្យ យើងបាន :

- $x^2+5x+3=0$

មាន $\Delta=25-12=13$

នាំឱ្យ $x=\dfrac{-b\pm\sqrt{\Delta}}{2a}=\dfrac{-5\pm\sqrt{13}}{2}$

- $x^2+5x+7=0$

មាន $\begin{cases}a>0\\ \Delta=25-28=-3<0\end{cases}$

នាំឱ្យ សមីការគ្មានឬស

ដូចនេះ | ចំពោះ $k=3$ សមីការមានឬស $x=\dfrac{-5\pm\sqrt{13}}{2}$ | ។

## ខ. កំណត់តម្លៃ $k$ ដើម្បីឱ្យសមីការមានឬស

ពីសម្រាយខាងលើពិនិត្យត្រង់កន្សោម :
$$(x^2+5x+5)^2-1^2=k$$
$$(x^2+5x+5)^2=k+1$$

ដោយ $(x^2+5x+5)^2\geq 0$

នាំឱ្យ $k+1\geq 0 \Leftrightarrow k\geq -1$

ដូចនេះ | តម្លៃកំណត់បានគឺ $k\geq -1$ | ។

## ១៧៣ ប្រៀបធៀបពីរចំនួន $200^{300}$ និង $300^{200}$

ពិនិត្យ : $200^{300}=(200^3)^{100}=(8000000)^{100}$

ហើយ $300^{200}=(300^2)^{100}=(90000)^{100}$

តាមរយៈលទ្ធផលបង្ហាញថា $(8000000)^{100}>(90000)^{100}$

ដូចនេះ | ទាញបានថា $200^{300}>300^{200}$ | ។

## ១៧៤ ប្រៀបធៀបពីរចំនួន $31^{11}$ និង $17^{14}$

ពិនិត្យ : $31^{11}<32^{11}=2^{5\cdot11}=2^{55}$ នោះ $31^{11}<2^{55}$

ហើយ $17^{14}>16^{14}=2^{4\cdot14}=2^{56}$ នោះ $17^{14}>2^{56}$

ដោយ $31^{11}<2^{55}<2^{56}<17^{14}$

ដូចនេះ | ប្រៀបធៀបបាន $31^{11}<17^{14}$ | ។



www.facebook.com/7khmer
fb : Entertainment And Knowledge

**១៧៥** **គណនា** $1+a+a^2+a^3+\ldots+a^{2010}$

បម្រាប់ : $a$ ជាឫសនៃសមីការ $x^{2011}=1$

មានន័យថា វាផ្ទៀងផ្ទាត់ $a^{2011}=1$

យើងបាន : $a^{2011}-1=0$

$$(a-1)(a^{2011}+a^{2011}+a^{2011}+\ldots+a+1)=0$$

ឬអាចសរសេរ : $(a-1)(1+a+a^2+a^3+\ldots+a^{2010})=0$

សម្មតិកម្ម : $a\neq 1$ នោះ $a-1\neq 0$

ដូច្នេះមានតែកត្តា $(1+a+a^2+a^3+\ldots+a^{2010})=0$

ដែលនាំឱ្យផលគុណ $(a-1)(1+a+a^2+a^3+\ldots+a^{2010})=0$

ដូចនេះ | គណនាបាន $1+a+a^2+a^3+\ldots+a^{2010}=0$ | ។

**១៧៦** **គណនា** $S=3+3^2+3^3+\ldots+3^n$

យើងមាន : $S=3+3^2+3^3+\ldots+3^n \quad (1)$

យក $(1)\times 3$ : $3S=3^2+3^3+\ldots+3^{n+1} \quad (2)$

ដោយយក $(2)-(1)$ យើងបាន :

$$-\begin{cases}3S=3^2+3^3+3^4+\ldots+3^{n+1}\\ S=3+3^2+3^3+\ldots+3^n\end{cases}$$

$$2S=3^{n+1}-3 \quad \Rightarrow S=\frac{3^{n+1}-3}{2}$$

ដូចនេះ | គណនាបាន $S=\dfrac{3^{n+1}-3}{2}$ | ។

**១៧៧** **គណនា** $A$ :

ពិនិត្យតួនីមួយៗមានរាង

$$\left(1-\frac{1}{n^2}\right)=\frac{n^2-1}{n^2}=\frac{(n-1)(n+1)}{n^2}=\frac{n-1}{n}\times\frac{n+1}{n}$$

យើងមាន :

$$A=\left(1-\frac{1}{2^2}\right)\left(1-\frac{1}{3^2}\right)\left(1-\frac{1}{4^2}\right)\times\ldots\times\left(1-\frac{1}{n^2}\right)$$

ដោយបំបែកកត្តានីមួយៗយើងបាន :

$$A=\left(1-\frac{1}{2^2}\right)\left(1-\frac{1}{3^2}\right)\left(1-\frac{1}{4^2}\right)\times\ldots\times\left(1-\frac{1}{n^2}\right)$$

$$=\left(\frac{2-1}{2}\cdot\frac{2+1}{2}\right)\left(\frac{3-1}{3}\cdot\frac{3+1}{3}\right)\left(\frac{4-1}{4}\cdot\frac{4+1}{4}\right)\times$$

$$\times\ldots\times\left(\frac{n-1}{n}\cdot\frac{n+1}{n}\right)$$

$$=\left(\frac{1}{2}\cdot\underbrace{\frac{3}{2}\right)\left(\frac{2}{3}}_{1}\cdot\underbrace{\frac{4}{3}\right)\left(\frac{3}{4}}_{1}\cdot\underbrace{\frac{5}{4}\right)\times\ldots\times\left(\frac{n-1}{n}}_{1}\cdot\frac{n+1}{n}\right)$$

$$=\frac{1}{2}\cdot 1\cdot 1\cdot 1\cdot\times\ldots\times\frac{n+1}{n}=\frac{n+1}{2n}$$

ដូចនេះ | ក្រោយពីគណនា $A=\dfrac{n+1}{2n}$ | ។

**១៧៨** **កំណត់តម្លៃ** $m$ :

យើងមាន : $\begin{cases}2x-4y=7\\ 3x+y=m\end{cases}$

ដោយដោះស្រាយតាមដេទែមីណង់ យើងបាន :

$$D=ab'-a'b=2+12=14$$
$$D_x=cb'-c'b=7+4m$$
$$\Rightarrow x=\frac{D_x}{D}=\frac{7+4m}{14}$$
$$D_y=ac'-a'c=2m-21$$
$$\Rightarrow x=\frac{D_y}{D}=\frac{2m-21}{14}$$

ដើម្បីឱ្យវាមានឫស $x>0$ និង $y<0$ លុះត្រាតែ :

$$\begin{cases}\dfrac{7+4m}{14}>0\\ \dfrac{2m-21}{14}<0\end{cases}\Leftrightarrow\begin{cases}7+4m>0\\ 2m-21<0\end{cases}\Rightarrow\begin{cases}m>-\dfrac{7}{4}\\ m<\dfrac{21}{2}\end{cases}$$

ឬ អាចសរសេរសរុបយ៉ាងខ្លីគឺ $-\dfrac{7}{4}<m<\dfrac{21}{2}$

ដូចនេះ | តម្លៃដែលកំណត់បានគឺ $-\dfrac{7}{4}<m<\dfrac{21}{2}$ | ។



www.facebook.com/7khmer
fb : Entertainment And Knowledge

## ១៧៩ គណនា $E$ :

យើងមាន

$E=\sqrt{1+2+3+...+2009+2010+2011+2010+2009+...+3+2+1}$

តាង $S=1+2+3+...+2010$

យើងបាន $E=\sqrt{S+2011+S}=\sqrt{2S+2011}$

ដោយ

$$+\begin{cases} S= & 1 + 2 + 3 + ...+2010 \\ S= & 2010 + 2009 + 2008+...+1 \end{cases}$$
$$2S=\underbrace{2011+2011+2011+...+2011}_{\text{មាន 2011 ចំនួន 2010 ដង}}$$

នាំឱ្យ $2S=2011\times 2010$

យើងបាន $E=\sqrt{2S+2011}$

$=\sqrt{2011\times 2010+2011}$

$=\sqrt{2011(2010+1)}$

$=\sqrt{2011\times 2011}=\sqrt{2011^2}=2011$

ដូចនេះ | ក្រោយពីគណនា $E=2011$ | ។

## ១៨០ ដោះស្រាយប្រព័ន្ធសមីការ :

ដោយបូកសមីការទាំងបួនបញ្ចូលគ្នា យើងបាន :

$$+\begin{cases} a+b+c=3 & (1) \\ b+a+d=4 & (2) \\ a+c+d=5 & (3) \\ b+c+d=6 & (4) \end{cases}$$
$$3a+3b+3c+3d=18 \quad \Rightarrow a+b+c+d=6 \ (*)$$

ដោយយកសមីការ $(*)$ ដកសមីការនីមួយៗបន្តបន្ទាប់

$$\begin{matrix}(*)\\(1)\end{matrix} -\begin{cases} a+b+c+d=6 \\ a+b+c=3 \end{cases} \qquad d=3$$

$$\begin{matrix}(*)\\(2)\end{matrix} -\begin{cases} a+b+c+d=6 \\ b+a+d=4 \end{cases} \qquad c=2$$

$$\begin{matrix}(*)\\(3)\end{matrix} -\begin{cases} a+b+c+d=6 \\ a+c+d=5 \end{cases} \qquad b=1$$

$$\begin{matrix}(*)\\(4)\end{matrix} -\begin{cases} a+b+c+d=6 \\ b+c+d=6 \end{cases} \qquad a=0$$

ដូចនេះ | ប្រព័ន្ធសមីការមានចម្លើយគឺ $(a,b,c,d)=(0,1,2,3)$ | ។

## ១៨១ បង្ហាញថា : $\sqrt{7}+\sqrt[3]{7}+\sqrt[4]{7}<7$

យើងដឹងហើយថា : $\sqrt{7}<\sqrt{9}=3$ នោះ $\sqrt{7}<3 \quad (1)$

$\sqrt[3]{7}<\sqrt[3]{8}=2$ នោះ $\sqrt[3]{7}<2 \quad (2)$

$\sqrt[4]{7}<\sqrt[4]{16}=2$ នោះ $\sqrt[4]{7}<2 \quad (3)$

ដោយយក : (1)+(2)+(3) : យើងបាន :

$$+\begin{cases} \sqrt{7}<3 \\ \sqrt[3]{7}<2 \\ \sqrt[4]{7}<2 \end{cases}$$
$$\sqrt{7}+\sqrt[3]{7}+\sqrt[4]{7}<7$$

ដូចនេះ | ឃើញថា $\sqrt{7}+\sqrt[3]{7}+\sqrt[4]{7}<7$ | ។

### ចំណែកឯ ការបង្ហាញថា $\sqrt{4}+\sqrt[3]{4}+\sqrt[4]{4}>4$

យើងមាន : $\sqrt{4}=2 \quad (1)$

$\sqrt[3]{4}>\sqrt[3]{1}=1$ នោះ $\sqrt[3]{4}>1 \quad (2)$

$\sqrt[4]{4}>\sqrt[4]{1}=1$ នោះ $\sqrt[4]{4}>1 \quad (3)$

ដោយយក : (1)+(2)+(3) : យើងបាន :

$$+\begin{cases} \sqrt{4}=2 \\ \sqrt[3]{4}>1 \\ \sqrt[4]{4}>1 \end{cases}$$
$$\sqrt{4}+\sqrt[3]{4}+\sqrt[4]{4}>4$$

ដូចនេះ | ឃើញថា $\sqrt{4}+\sqrt[3]{4}+\sqrt[4]{4}>4$ | ។

## ១៨២ កំណត់តម្លៃ $n$ :

តាង $g(x)$ ជាផលចែកនៃ $f(x)=x^n-4x^2+1$ ជាមួយ $(x-3)$ ដែលមានសំណល់ស្មើ 46

យើងបាន : $(x^n-4x^2+1)=(x-3)\times g(x)+46$

បើយើងឱ្យតម្លៃ $x=3$ នោះសមីការទៅជា :

$(3^n-4\cdot 3^2+1)=(3-3)\times g(3)+46$

$3^n-35=0+46$

$3^n=46+35$

$3^n=81 \quad \Leftrightarrow 3^n=3^4 \quad \Rightarrow n=4$

ដូចនេះ | តម្លៃកំណត់បានគឺ $n=4$ | ។



www.facebook.com/7khmer
fb : Entertainment And Knowledge

## ១៨៣ ដោះស្រាយសមីការ :

យើងមានសមីការ : $\dfrac{x}{2+\dfrac{x}{2+\dfrac{x}{2+\dfrac{x}{2+\dfrac{x}{1+\sqrt{1+x}}}}}}=1$

សមីការមានន័យលុះត្រាតែ $1+x\geq 0\Rightarrow x\geq -1$

ពិនិត្យ ទ្រង់ទ្រាយកន្ទុយចុងក្រោយគេ :

$$2+\frac{x}{1+\sqrt{1+x}}=\frac{2\left(1+\sqrt{1+x}\right)+x}{1+\sqrt{1+x}}$$
$$=\frac{2+2\sqrt{1+x}+x}{1+\sqrt{1+x}}$$
$$=\frac{1+2\sqrt{1+x}+x+1}{1+\sqrt{1+x}}$$
$$=\frac{1^2+2\cdot 1\cdot\sqrt{1+x}+\sqrt{(1+x)^2}}{1+\sqrt{1+x}}$$
$$=\frac{\left(1+\sqrt{1+x}\right)^2}{1+\sqrt{1+x}}$$
$$=1+\sqrt{1+x}$$

បើយើងយកលទ្ធផលនេះទៅជំនួស វានឹងក្លាយទៅជាទម្រង់ដដែលៗវិញ។ បើជំនួសបន្តបន្ទាប់ ចុងក្រោយយើងបាន :

$$\frac{x}{1+\sqrt{1+x}}=1$$
$$x=1+\sqrt{1+x}$$
$$x-1=\sqrt{1+x}$$
$$(x-1)^2=\sqrt{(1+x)^2}$$
$$x^2-2x+1=1+x$$
$$x^2-3x=0$$
$$x(x-3)=0$$
$$\Rightarrow\begin{cases}x=0\\x=3\end{cases}$$

-ចំពោះ $x=0$ មិនយក ព្រោះពេលផ្ទៀងផ្ទាត់ $0\neq 1$

-ចំពោះ $x=3$ យក ព្រោះពេលផ្ទៀងផ្ទាត់ $1=1$

ដូចនេះ | សមីការមានឬស $x=3$ | ។

## ១៨៤ កំណត់គ្រប់ចំនួនគត់ $n$

$B=4^{27}+4^{1016}+4^n$ ជាការេប្រាកដនៃចំនួនគត់

-ករណី : $4^n$ ជាតួចុង យើងបាន :

$$B=4^{27}+4^{1016}+4^n$$
$$=4^{27}\left(1+4^{989}+4^{n-27}\right)$$
$$=\left(2^{27}\right)^2\left[1^2+2^{1978}+\left(2^{n-27}\right)^2\right]$$
$$=\left(2^{27}\right)^2\left[1^2+2\cdot 1\cdot 2^{1977}+\left(2^{n-27}\right)^2\right]$$

ដើម្បីឱ្យបំពេញរាង $(a+b)^2=a^2+2ab+b^2$ លុះត្រាតែ

$$2^{n-27}=2^{1977}$$
$$\Rightarrow n-27=1977$$
$$n=2004$$

-ករណី : $4^n$ ជាតួកណ្ដាល យើងបាន :

$$B=4^{27}+4^n+4^{1016}$$
$$=4^{27}\left(1+4^{n-27}+4^{989}\right)$$
$$=\left(2^{27}\right)^2\left[1^2+2^{2n-54}+\left(2^{989}\right)^2\right]$$
$$=\left(2^{27}\right)^2\left[1^2+2\cdot 1\cdot 2^{2n-55}+\left(2^{989}\right)^2\right]$$

ដើម្បីឱ្យបំពេញរាង $(a+b)^2=a^2+2ab+b^2$ លុះត្រាតែ

$$2^{2n-55}=2^{989}$$
$$\Rightarrow 2n-55=989$$
$$n=\frac{1044}{2}$$
$$n=522$$

ដូនេះ | តម្លៃដែលកំណត់បានគឺ $n=2004$ , $n=522$ | ។

## ១៨៥ ដោះស្រាយសមីការ :

យើងមាន : $\dfrac{x^4+x^2+1}{x^2}=\dfrac{x^2+x+1}{x}$ , $x\neq 0$

$$x^2+1+\frac{1}{x^2}=x+1+\frac{1}{x}$$
$$x^2+\frac{1}{x^2}=x+\frac{1}{x}$$
$$x^2+2+\frac{1}{x^2}-2=x+\frac{1}{x}$$
$$\left(x+\frac{1}{x}\right)^2-2=\left(x+\frac{1}{x}\right)$$



www.facebook.com/7khmer
fb : Entertainment And Knowledge

បើតាង $t = x + \frac{1}{x}$ យើងបានសមីការដឺក្រេទី2 :

$$t^2 - 2 = t$$
$$t^2 - t - 2 = 0$$

មាន $a - b + c = 1 - (-1) - 2 = 0$ ជាករណីពិសេស

នាំឱ្យ $t_1 = -1$ , $t_2 = -\frac{c}{a} = -\frac{(-2)}{1} = 2$

-ចំពោះ $t_1 = -1$ យើងបាន :

$$x + \frac{1}{x} = -1$$
$$x^2 + x + 1 = 0$$
$$x^2 + 2 \cdot x \cdot \frac{1}{2} + \frac{1}{4} + \frac{3}{4} = 0$$
$$\left(x + \frac{1}{2}\right)^2 + \frac{3}{4} = 0$$

ដោយ $\left(x + \frac{1}{2}\right)^2 \geq 0$ , $\frac{3}{4} > 0$

នោះ $\left(x + \frac{1}{2}\right)^2 + \frac{3}{4} > 0$ នាំឱ្យសមីការគ្មានឫស

-ចំពោះ $t_2 = 2$ យើងបាន :

$$x + \frac{1}{x} = 2$$
$$x^2 - 2x + 1 = 0$$
$$(x-1)^2 = 0$$
$$\Rightarrow \quad x - 1 = 0$$
$$x = 1$$

ដូចនេះ **ក្រោយពីដោះស្រាយ សមីការមានឫស $x = 1$** ។

## ១៨៦ ដោះស្រាយប្រព័ន្ធសមីការ :

ក. $\begin{cases} x + y + z = 6 & (1) \\ xy + yz + zx = 12 & (2) \\ \frac{2}{x} + \frac{2}{y} + \frac{2}{z} = 3 & (3) \end{cases}$

សមីការមានន័យលុះត្រាតែ : $x \neq 0$ , $y \neq 0$ , $z \neq 0$

តាម $(1)$ : $x + y + z = 6$

$$(x + y + z)^2 = 6^2$$
$$x^2 + y^2 + z^2 + 2(xy + yz + zx) = 36$$

ដោយ $(2)$: $xy + yz + zx = 12$

នាំឱ្យ $x^2 + y^2 + z^2 + 2 \times 12 = 36$

$$x^2 + y^2 + z^2 = 12$$
$$2x^2 + 2y^2 + 2z^2 = 24 \quad (*)$$

ហើយ $(2)$: $2xy + 2yz + 2zx = 24 \quad (**)$

យើងយក (*)-(**) នោះយើងបាន :

$$-\begin{cases} 2x^2 + 2y^2 + 2z^2 = 24 \\ 2xy + 2yz + 2zx = 24 \end{cases}$$
$$x^2 - 2xy + y^2 + y^2 - 2yz + z^2 + z^2 - 2zx + x^2 = 0$$
$$(x-y)^2 + (y-z)^2 + (z-x)^2 = 0$$

ដោយ $(x-y)^2 \geq 0$ , $(y-z)^2 \geq 0$ , $(z-x)^2 \geq 0$

ដើម្បីឱ្យសមីការផ្ទៀតផ្ទាត់មានតែមួយករណីគត់ គឺកន្ត្រានីមួយៗស្មើសូន្យ មានន័យថា :

$$\begin{cases} x - y = 0 \\ y - z = 0 \\ z - x = 0 \end{cases} \Rightarrow x = y = z$$

តាម $(3)$: $\frac{2}{x} + \frac{2}{y} + \frac{2}{z} = 3$ ដោយ $x = y = z$

យើងបាន $\frac{2}{x} + \frac{2}{x} + \frac{2}{x} = 3$

$$\frac{2+2+2}{x} = 3 \Leftrightarrow x = \frac{6}{3} \Rightarrow x = 2$$

ដូចនេះ **ប្រព័ន្ធសមីការមានឫស $x = y = z = 2$** ។

ខ. $\begin{cases} \frac{1}{x} + \frac{1}{y} + \frac{1}{z} = 3 & (1) \\ \frac{1}{xy} + \frac{1}{yz} + \frac{1}{zx} = 3 & (2) \\ \frac{1}{xyz} = 1 & (3) \end{cases}$

សមីការមានន័យលុះត្រាតែ : $x \neq 0$ , $y \neq 0$ , $z \neq 0$

-តាម $(1)$: $\frac{1}{x} + \frac{1}{y} + \frac{1}{z} = 3$ សមមូល $\frac{xy + yz + zx}{xyz} = 3$

នាំឱ្យ $xy + yz + zx = 3$ ព្រោះ $(3)$: $\frac{1}{xyz} = 1$

-តាម $(2)$: $\frac{1}{xy} + \frac{1}{yz} + \frac{1}{zx} = 3$



www.facebook.com/7khmer
fb : Entertainment And Knowledge

$$\frac{x+y+z}{xyz}=3 \Rightarrow x+y+z=3 \qquad (1)$$

នាំឱ្យ $(x+y+z)^2=3^2$

$$x^2+y^2+z^2+2(xy+yz+zx)=9$$
$$x^2+y^2+z^2+2\times3=9$$
$$x^2+y^2+z^2=3 \qquad (2)$$

ដោយយក (2)-2×(1) យើងបាន :

$$-\begin{cases}x^2+y^2+z^2=3\\2x+2y+2z=6\end{cases}$$
$$x^2-2x+y^2-2y+z^2-2z=-3$$
$$(x^2-2x+1)+(y^2-2y+1)+(z^2-2z+1)=0$$
$$(x-1)^2+(y-1)^2+(z-1)^2=0$$

ដោយ $(x-1)^2\ge0$ , $(y-1)^2\ge0$ , $(z-1)^2\ge0$

ដើម្បីឱ្យសមីការផ្ទៀតផ្ទាត់មានតែមួយករណីគត់ គឺកត្តានីមួយៗស្មើសូន្យ មានន័យថា :

$$\begin{cases}x-1=0\\y-1=0\\z-1=0\end{cases} \Rightarrow \begin{cases}x=1\\y=1\\z=1\end{cases}$$

ដូចនេះ ប្រព័ន្ធសមីការមានឫស $x=y=z=1$ ។

## ១៨៧ គណនា $2^a+2^{-a}$ :

យើងមាន $4^a+4^{-a}=23$

$$(2^a)^2+2+(2^{-a})^2=23+2$$
$$(2^a+2^{-a})^2=25$$
$$2^a+2^{-a}=\sqrt{25}$$
$$2^a+2^{-a}=5$$

សម្គាល់ : ខណៈបំពាក់រ៉ាឌីកាល់ពុំមែន $\pm\sqrt{25}$ ទេ ព្រោះ

$2^a+2^{-a}>0$ ជានិច្ច (ជាអនុគមន៍អិចស្ប៉ូណង់ស្យែល)

ដូចនេះ ក្រោយពីគណនា $2^a+2^{-a}=5$ ។

## ១៨៨ រកចំនួនលទ្ធភាពទាំងអស់នៃការបង្កើតលេខទូរស័ព្ទ

យើងបានដឹងហើយថា នៅប្រទេសកម្ពុជាយើងមានប្រព័ន្ធ ទូរស័ព្ទជាច្រើន ។ ប្រព័ន្ធខ្លះមានលេខ ៦ខ្ទង់ ខ្លះទៀតមាន លេខ ៧ខ្ទង់ ហើយភ្ជាប់ជាមួយក្បាលប្រព័ន្ធ ។ តើចំនួននៃ ការបង្កើតលេខទូរស័ព្ទ យ៉ាងណាដែរ ?

ក. 011

ដោយប្រព័ន្ធ 011 មានលេខ 6ខ្ទង់ភ្ជាប់ជាមួយក្បាលប្រព័ន្ធ ហើយមានទម្រង់ជា : 011 $xxx$ $xxx$

-ជម្រើសនៅតាមខ្ទង់នីមួយៗមាន 10លេខដូចគ្នាគឺ :

$\{0,1,2,3,4,5,6,7,8,9\}$

(តាមគោលការណ៍រាប់)

នាំឱ្យ ចំនួនលេខទាំងអស់គឺ :

$$10\times10\times10\times10\times10\times10=10^6=1\,000\,000$$

ដូចនេះ ចំនួនលទ្ធភាពនៃការបង្កើតលេខទូរស័ព្ទរបស់ប្រព័ន្ធ 011 គឺ 1 000 000 លេខ ។

ខ. 097

ដូចគ្នានឹងប្រព័ន្ធ 011 ដែរគ្រាន់តែប្រព័ន្ធ097 មាន៧ខ្ទង់ មានទម្រង់ 097 $xxx$ $xxxx$

នាំឱ្យ ចំនួនលេខទាំអស់គឺ :

$$10\times10\times10\times10\times10\times10\times10=10^7=10\,000\,000$$

ដូចនេះ ចំនួនលទ្ធភាពនៃការបង្កើតលេខទូរស័ព្ទរបស់ប្រព័ន្ធ 097 គឺ 10 000 000 លេខ ។

## ១៨៩ រកចំនួនរបៀបនៃការបង្កើតលេខ៤ខ្ទង់

យើងមានលេខទាំងបួនគឺ 1 , 2 , 4 និង 9

យើងនឹងបង្កើលេខ៤ខ្ទង់ដែលមាន៤លេខខាងលើ ដោយគិតតាមវិធីដូចខាងក្រោម :

-ខ្ទង់ដំបូងមាន៤ជម្រើស ខ្ទង់ទីពីរមាន៣ជម្រើស ខ្ទង់ទីបីមានពីរជម្រើស និងខ្ទង់ចុងក្រោយមាន១ជម្រើស

-តាមគោលការណ៍រាប់ ចំនួនរបៀប$=4\times3\times2\times1=4!=12$

ដូចនេះ ចំនួនរបៀបក្នុងការបង្កើតលេខ៤ខ្ទង់ខុសគ្នាមាន 12 របៀប ។



www.facebook.com/7khmer
fb : Entertainment And Knowledge

## ១៨០ ស្រាយបញ្ជាក់ថា : $(b-a)(b-c)=pq-6$

-សម្មតិកម្ម : $a\,,b$ ជាឫសនៃសមីការ $x^2+px+1=0$

នាំឱ្យ $\begin{cases} a+b=-p & (1) \\ ab=1 & (2) \end{cases}$

-សម្មតិកម្ម : $b\,,c$ ជាឫសនៃសមីការ $x^2+qx+2=0$

នាំឱ្យ $\begin{cases} b+c=-q & (3) \\ bc=2 & (4) \end{cases}$

-ទាញបាន $(a+b)(b+c)=(-p)(-q)=pq$

ហើយ $ab+bc=1+2=3$

ឬ $2(ab+bc)=6$

-ពិនិត្យ
$$\begin{aligned} pq-6 &= (a+b)(b+c)-6 \\ &= (a+b)(b+c)-2(ab+bc) \\ &= ab+ac+b^2+bc-2ba-2bc \\ &= b^2-ba-bc+ac \\ &= b(b-a)-c(b-a) \\ &= (b-a)(b-c) \end{aligned}$$

ដូចនេះ **ឃើញថា $(b-a)(b-c)=pq-6$** ។

## ១៨១ ស្រាយបំភ្លឺថាយើងបាន $\frac{1}{a^2}+\frac{1}{b^2}+\frac{1}{c^2}=2$

សម្មតិកម្ម : $a+b+c=abc$ នាំឱ្យ $\frac{a+b+c}{abc}=1$

យើងមាន $\frac{1}{a}+\frac{1}{b}+\frac{1}{c}=2$

តាមរូបមន្ត $(a+b+c)^2=a^2+b^2+b^2+2(ab+bc+ac)$

នាំឱ្យ
$$\left(\frac{1}{a}+\frac{1}{b}+\frac{1}{c}\right)^2=4$$
$$\left(\frac{1}{a}\right)^2+\left(\frac{1}{b}\right)^2+\left(\frac{1}{b}\right)^2+2\left(\frac{1}{ab}+\frac{1}{bc}+\frac{1}{ac}\right)=4$$
$$\frac{1}{a^2}+\frac{1}{b^2}+\frac{1}{c^2}+2\left(\frac{c+a+b}{abc}\right)=4$$
$$\frac{1}{a^2}+\frac{1}{b^2}+\frac{1}{c^2}+2\cdot 1=4$$
$$\frac{1}{a^2}+\frac{1}{b^2}+\frac{1}{c^2}=2$$

ដូចនេះ **ឃើញថា $\frac{1}{a^2}+\frac{1}{b^2}+\frac{1}{c^2}=2$** ។

## ១៨២ រកពីរចំនួននោះ :

តាង $x\,,y$ ជាពីរចំនួនដែលត្រូវរកនោះ

តាមបម្រាប់ប្រធាន : ផលបូក=ផលគុណ=ផលចែក

យើងបាន : $x+y=xy=\frac{x}{y}$

-ពិនិត្យសមភាព : $xy=\frac{x}{y} \Leftrightarrow y=\frac{1}{y}$

នាំឱ្យ $y^2=1 \Leftrightarrow y=\pm\sqrt{1} \Rightarrow y=\pm 1$

-ពិនិត្យសមភាព : $x+y=xy$

ចំពោះ $y=1$ នោះ $x+1=x$ គ្មានតម្លៃ $x$ ផ្ទៀងផ្ទាត់

ចំពោះ $y=-1$ នោះ $x-1=-x \Leftrightarrow 2x=1 \Rightarrow x=\frac{1}{2}$

ដូចនេះ **ពីរចំនួននោះគឺ $\frac{1}{2}$ និង $-1$** ។

## ១៨៣ គណនាផលគុណ $P$ :

យើងមាន : $P=(1+x)(1+x^2)(1+x^4)\times\ldots\times(1+x^{2^n})$

-ពិនិត្យ : $a^2-b^2=(a-b)(a+b)$

នាំឱ្យ $(a+b)=\frac{a^2-b^2}{(a-b)}$

តាមរូបមន្តខាងលើយើងបាន :

$$\begin{aligned} P &= (1+x)(1+x^2)(1+x^4)\times\ldots\times(1+x^{2^n}) \\ &= \left(\frac{1-x^2}{1-x}\right)\left(\frac{1-x^4}{1-x^2}\right)\left(\frac{1-x^8}{1-x^4}\right)\times\ldots\times\left(\frac{1-x^{2^{n+1}}}{1-x^{2^n}}\right) \\ &= \frac{1-x^{2^{n+1}}}{1-x} \end{aligned}$$
ដែល $x\neq 1$

ដូចនេះ **ផលគុណគណនាបានគឺ $P=\frac{1-x^{2^{n+1}}}{1-x}$** ។

## ១៨៤ គណនាផលបូក $S$ :

យើងមាន :

$$S=\frac{1}{1+2}+\frac{1}{1+2+3}+\frac{1}{1+2+3+4}+\ldots+\frac{1}{1+2+3+\ldots+2011}$$

ពិនិត្យ : $S_k=1+2+3+\ldots+k$



www.facebook.com/7khmer
fb : Entertainment And Knowledge

នាំឱ្យ

$$+\begin{cases} S_k = 1 + 2 + 3 + \dots + k \\ S_k = k + (k-1) + \dots + 2 + 1 \end{cases}$$
$$2S_k = \underbrace{(k+1)+(k+1)+(k+1)+\dots+(k+1)}_{\text{មាន } k \text{ ដងនៃ } (k+1)}$$

ទាញបាន : $2S_k = k(k+1) \Leftrightarrow S_k = \dfrac{k(k+1)}{2}$

យើងបាន : $S = \dfrac{1}{S_2} + \dfrac{1}{S_3} + \dfrac{1}{S_4} + \dots + \dfrac{1}{S_{2011}}$

ដោយ $S_k = \dfrac{k(k+1)}{2}$

$$S = \frac{1}{\frac{2(2+1)}{2}} + \frac{1}{\frac{3(3+1)}{2}} + \frac{1}{\frac{4(4+1)}{2}} + \dots + \frac{1}{\frac{2011(2011+1)}{2}}$$

$$S = \frac{2}{2(2+1)} + \frac{2}{3(3+1)} + \frac{2}{4(4+1)} + \dots + \frac{2}{2011(2011+1)}$$

$$S = 2\left(\frac{1}{2\cdot 3} + \frac{1}{3\cdot 4} + \frac{1}{4\cdot 5} + \dots + \frac{1}{2011\cdot 2012}\right)$$

ហើយពិនិត្យតួនីមួយៗនៃ $S$ មានទម្រង់ :

$$\frac{1}{n(n+1)} = \frac{n+1-n}{n(n+1)} = \frac{n+1}{n(n+1)} - \frac{n}{n(n+1)} = \frac{1}{n} - \frac{1}{n+1}$$

នាំឱ្យ

$$S = 2\left(\frac{1}{2} - \frac{1}{3} + \frac{1}{3} - \frac{1}{4} + \frac{1}{4} - \frac{1}{5} + \dots + \frac{1}{2011} - \frac{1}{2012}\right)$$
$$= 2\left(\frac{1}{2} - \frac{1}{2012}\right) = 1 - \frac{1}{1006} = \frac{1005}{1006}$$

ដូចនេះ ផលបូកគណនាបានគឺ $S = \dfrac{1005}{1006}$ ។

## ១៩៥ គណនាផលបូក $S$ ចំពោះ $x = 95$ :

យើងមាន $S = \dfrac{1}{x^2 + x} + \dfrac{1}{x^2 + 3x + 2} + \dfrac{1}{x^2 + 5x + 6} + \dfrac{1}{x^2 + 7x + 12} + \dfrac{1}{x^2 + 9x + 20}$

ដោយ $x^2 + x = x(x+1)$

$x^2 + 3x + 2 = (x+1)(x+2)$

$x^2 + 5x + 6 = (x+2)(x+3)$

$x^2 + 7x + 12 = (x+3)(x+4)$

$x^2 + 9x + 20 = (x+4)(x+5)$

នោះ $S = \left(\dfrac{1}{x(x+1)} + \dfrac{1}{(x+1)(x+2)}\right) + \dfrac{1}{(x+2)(x+3)} + \left(\dfrac{1}{(x+3)(x+4)} + \dfrac{1}{(x+4)(x+5)}\right)$

$$S = \frac{x+2+x}{x(x+1)(x+2)} + \frac{1}{(x+2)(x+3)} + \frac{x+5+x+3}{(x+3)(x+4)(x+5)}$$

$$S = \frac{2}{x(x+2)} + \frac{1}{(x+2)(x+3)} + \frac{2}{(x+3)(x+5)}$$
$$= \frac{2x+6+x}{x(x+2)(x+3)} + \frac{2}{(x+3)(x+5)}$$
$$= \frac{3}{x(x+3)} + \frac{2}{(x+3)(x+5)}$$
$$= \frac{3x+15+2x}{x(x+3)(x+5)} = \frac{5}{x(x+5)}$$

ចំពោះ $x = 95$ យើងបាន :

$$S = \frac{5}{x(x+5)} = \frac{5}{95(95+5)} = \frac{5}{5\cdot 19\cdot 100} = \frac{1}{1900}$$

ដូចនេះ ផលបូកគណនាបានគឺ $S = \dfrac{1}{1900}$ ។

## ១៩៦ បង្ហាញឱ្យឃើញពីសមភាព

$$\frac{a}{ab+a+1} + \frac{b}{bc+b+1} + \frac{c}{ca+c+1} = \frac{1}{1+a+ab} + \frac{1}{1+b+bc} + \frac{1}{1+c+ca}$$

-ចំពោះ $abc = 1$ ពិនិត្យ :

$$\frac{1}{1+a+ab} + \frac{1}{1+b+bc} + \frac{1}{1+c+ca}$$
$$= \left(\frac{1}{1+a+ab}\cdot\frac{c}{c}\right) + \left(\frac{1}{1+b+bc}\cdot\frac{a}{a}\right) + \left(\frac{1}{1+c+ca}\cdot\frac{b}{b}\right)$$
$$= \frac{c}{c+ac+abc} + \frac{a}{a+ab+abc} + \frac{b}{b+bc+cab}$$
$$= \frac{c}{c+ac+1} + \frac{a}{a+ab+1} + \frac{b}{b+bc+1}$$
$$= \frac{a}{ab+a+1} + \frac{b}{bc+b+1} + \frac{c}{ca+c+1}$$

ដូចនេះ យើងបានសមភាពប្រាកដមែន ។



www.facebook.com/7khmer
fb : Entertainment And Knowledge

## ១៩៧ រកតម្លៃ $x$ :

យើងមាន $\overline{xxx(x-1)}=(x-1)^{x-2}$

លេខនៃខ្ទង់នីមួយៗ ជាចំនួនគត់ត្រូវតែធំជាង0 និងតូចជាង១០

យើងបាន $\begin{cases}0<x<10\\0<x-1<10\end{cases} \Leftrightarrow 1<x<10$

លេខ $x-2$ ជាស្វ័យគុណត្រូវមានតម្លៃធំជាង0

នោះ $x-2>0 \Rightarrow x>2$

សរុបលក្ខខណ្ឌគឺ $3\le x\le 9$

មានន័យថា $x$ អាចមានតម្លៃស្មើ $3,4,5,6,7,8,9$

ប៉ុន្តែ $\overline{xxx(x-1)}$ ជាលេខបួនខ្ទង់ ហើយមានតែ $6^5$ តែមួយ

គត់ដែលមានលេខបួនខ្ទង់ នាំឱ្យយើងទាញបាន :

$$\begin{cases}x-1=6\\x-2=5\end{cases} \Leftrightarrow x=7$$

នោះណយើងបាន : $\overline{xxx(x-1)}=(x-1)^{x-2}$

$$\overline{777(7-1)}=(7-1)^{7-2}$$

$$7776=6^5$$

$$7776=7776$$

ដូចនេះ **តម្លៃដែលរកបានគឺ $x=7$** ។

## ១៩៨ សម្រួលកន្សោម $A$ :

( រំលឹករូបមន្តលោការីត $\log_a b\cdot\log_b c=\log_a c$

$\log_{a^n} b=\frac{1}{n}\log_a b$ , $\log_a a=1$ ... )

យើងមាន :

$$A=\log_3 2\cdot\log_4 3\cdot\log_5 4\cdot\log_6 5\cdot\log_7 6\cdot\log_8 7$$

$$=\log_3 2\cdot(\log_4 3\cdot\log_5 4)\cdot\log_6 5\cdot(\log_7 6\cdot\log_8 7)$$

$$=\log_3 2\cdot\log_5 3\cdot\log_6 5\cdot\log_8 6$$

$$=(\log_3 2\cdot\log_5 3)\cdot(\log_6 5\cdot\log_8 6)$$

$$=\log_5 2\cdot\log_8 5$$

$$=\log_8 2=\log_{2^3} 2=\frac{1}{3}\log_2 2=\frac{1}{3}\cdot 1=\frac{1}{3}$$

ដូចនេះ **ក្រោយពីសម្រួលឃើញថា $A=\frac{1}{3}$** ។

## ១៩៩ គណនាផលបូក $S$ :

( រំលឹករូបមន្ត $\log_{a^n} b=\frac{1}{n}\log_a b$ , $1+2+3+...+n=\frac{n(n+1)}{2}$

យើងមាន :

$$S=\frac{1}{\log_a x}+\frac{1}{\log_{a^2} x}+\frac{1}{\log_{a^3} x}+...+\frac{1}{\log_{a^k} x}$$

$$=\frac{1}{\log_a x}+\frac{1}{\frac{1}{2}\log_a x}+\frac{1}{\frac{1}{3}\log_a x}+...+\frac{1}{\frac{1}{k}\log_a x}$$

$$=\frac{1}{\log_a x}+\frac{2}{\log_a x}+\frac{3}{\log_a x}+...+\frac{k}{\log_a x}$$

$$=\frac{1}{\log_a x}(1+2+3+...+k)$$

$$=\frac{1}{\log_a x}\cdot\frac{k(k+1)}{2}=\frac{k(k+1)}{2\log_a x}$$

ដូចនេះ **ផលបូកគណនាបានគឺ $S=\frac{k(k+1)}{2\log_a x}$** ។

## ២០០ ដោះស្រាយប្រព័ន្ធសមីការ

យើងមានប្រព័ន្ធសមីការ :

$$\begin{cases}x_1+x_2+x_3+...+x_{2011}=0 & (1)\\x_1^2+x_2^2+x_3^2+...+x_{2011}^2=0 & (2)\\x_1^3+x_2^3+x_3^3+...+x_{2011}^3=0 & (3)\\ \dots\dots\dots\dots\dots\dots\dots\dots\dots\dots\dots\dots & \\x_1^{2011}+x_2^{2011}+x_3^{2011}+...+x_{2011}^{2011}=0 & (2011)\end{cases}$$

តាមសមីការ (2) : $x_1^2+x_2^2+x_3^2+...+x_{2011}^2=0$

ដោយ $x_1^2\ge 0, x_2^2\ge 0, x_3^2\ge 0$ , ..., $x_{2011}^2\ge 0$

នាំឱ្យសមីការ (2) ផ្ទៀងផ្ទាត់លុះត្រាតែ :

$x_1^2=x_2^2=x_3^2=...=x_{2011}^2=0$

ចំពោះសមីការផ្សេងទៀត ក៏ផ្ទៀងផ្ទាត់ដែរសម្រាប់តម្លៃនេះ

ដូចនេះ **ប្រព័ន្ធសមីការមានតម្លៃឬសស្មើៗគ្នាគឺ :**

**$x_1^2=x_2^2=x_3^2=...=x_{2011}^2=0$** ។

## ២០១ ដោះស្រាយប្រព័ន្ធសមីការតាមដេទែមីណង់

យើងមានសមីការ : $\begin{cases}3^\pi x+3^{-\pi}y=2\\2\cdot 3^\pi x-3^{-\pi}y=1\end{cases}$



www.facebook.com/7khmer
fb : Entertainment And Knowledge

ដោះស្រាយតាមដេទែមីណង់ យើងបាន :

$$D=ab'-a'b$$
$$=3^{\pi}\left(-3^{-\pi}\right)-\left(2\cdot 3^{\pi}\right)\cdot 3^{-\pi}$$
$$=-3^{\pi-\pi}-2\cdot 3^{\pi-\pi}$$
$$=-1-2=-3$$

$$D_x=cb'-c'b$$
$$=(2)\left(-3^{-\pi}\right)-1\cdot\left(3^{-\pi}\right)$$
$$=-2\cdot 3^{-\pi}-3^{-\pi}$$
$$=-3\cdot 3^{-\pi}$$

$$D_y=cb'-c'b$$
$$=3^{\pi}(1)-2\cdot 3^{\pi}\cdot(2)$$
$$=3^{\pi}-4\cdot 3^{\pi}$$
$$=-3\cdot 3^{\pi}$$

នាំឱ្យ $x=\dfrac{D_x}{D}=\dfrac{-3\cdot 3^{-\pi}}{-3}=3^{-\pi}$

$y=\dfrac{D_y}{D}=\dfrac{-3\cdot 3^{\pi}}{-3}=3^{\pi}$

ដូចនេះ ប្រព័ន្ធសមីការមានគូចម្លើយ $x=3^{-\pi}$ , $y=3^{\pi}$ ។

**២០២** **បង្ហាញថា ក.** $x^2+y^2\geq 2xy$

ដោយ $x$ និង $y$ ជាចំនួនពិតនោះយើងបាន :

$$(x-y)^2\geq 0$$
$$x^2-2xy+y^2\geq 0$$
$$x^2+y^2\geq 2xy$$

ដូចនេះ ឃើញថា $x^2+y^2\geq 2xy$ ។

**បង្ហាញថា ខ.** $\dfrac{x}{y}+\dfrac{y}{x}\geq 2$

នៅក្នុងសំណួរ ក. ឃើញថា $x^2+y^2\geq 2xy$

សម្មតិកម្ម $x$ និង $y$ មានសញ្ញាដូចគ្នា នោះមានន័យថា

$xy>0$ ជានិច្ច ពេលចែកនឹង $xy$ វិសមីការ មិនប្តូរទិសដៅ

យើងបាន $\dfrac{x^2}{xy}+\dfrac{y^2}{xy}\geq\dfrac{2xy}{xy}\iff\dfrac{x}{y}+\dfrac{y}{x}\geq 2$

ដូចនេះ ឃើញថា $\dfrac{x}{y}+\dfrac{y}{x}\geq 2$ ។

**២០៣** **សម្រួលកន្សោម** $E$ & $F$ :

យើងមាន $E=\dfrac{\left(\sqrt{a}+\sqrt{b}\right)^2-4\sqrt{ab}}{\sqrt{a}-\sqrt{b}}$

$$=\frac{\left(\sqrt{a}+\sqrt{b}\right)^2-4\sqrt{ab}}{\sqrt{a}-\sqrt{b}}$$
$$=\frac{\sqrt{a}^2+2\sqrt{ab}+\sqrt{b}^2-4\sqrt{ab}}{\sqrt{a}-\sqrt{b}}$$
$$=\frac{\sqrt{a}^2-2\sqrt{ab}+\sqrt{b}^2}{\sqrt{a}-\sqrt{b}}=\frac{\left(\sqrt{a}-\sqrt{b}\right)^2}{\sqrt{a}-\sqrt{b}}$$
$$=\sqrt{a}-\sqrt{b}$$

ហើយ $F=\dfrac{a\sqrt{b}+b\sqrt{a}}{\sqrt{ab}}$

$$=\frac{\sqrt{ab}\left(\sqrt{a}+\sqrt{b}\right)}{\sqrt{ab}}=\sqrt{a}+\sqrt{b}$$

ដូចនេះ $E=\sqrt{a}-\sqrt{b}$ , $F=\sqrt{a}+\sqrt{b}$ ។

**គណនា** $E+F$ និង $E\cdot F$

$$E+F=\left(\sqrt{a}-\sqrt{b}\right)+\left(\sqrt{a}+\sqrt{b}\right)$$
$$=\sqrt{a}-\sqrt{b}+\sqrt{a}+\sqrt{b}=2\sqrt{a}$$
$$E\cdot F=\left(\sqrt{a}-\sqrt{b}\right)\times\left(\sqrt{a}+\sqrt{b}\right)$$
$$=\sqrt{a}^2-\sqrt{b}^2=a-b$$

ដូចនេះ $E+F=2\sqrt{a}$ & $E\cdot F=a-b$ ។

**២០៤** **គណនាតម្លៃនៃកន្សោម** $A$ :

យើងមាន :

$$A=x^n-100x^{n-1}+x^{n-2}-100x^{n-3}+x^{n-4}-100x^{n-5}$$
$$=\left(x^n-100x^{n-1}\right)+\left(x^{n-2}-100x^{n-3}\right)+\left(x^{n-4}-100x^{n-5}\right)$$
$$=x^n-100x^{n-1}+x^{n-2}-100x^{n-3}+x^{n-4}-100x^{n-5}$$
$$=x^{n-1}(x-100)+x^{n-3}(x-100)+x^{n-5}(x-100)$$
$$=(x-100)\left(x^{n-1}+x^{n-3}+x^{n-5}\right)$$

ចំពោះ $x=100$

នាំឱ្យ $A=(100-100)\left(100^{n-1}+100^{n-3}+100^{n-5}\right)=0$

ដូចនេះ តម្លៃគណនាបានគឺ $A=0$ ។



www.facebook.com/7khmer
fb : Entertainment And Knowledge

## ២០៥ គណនាតម្លៃនៃកន្សោម $A$ :

យើងមាន $A=\sqrt[3]{22+\sqrt{30-\sqrt{20+\sqrt{27-\sqrt[3]{8}}}}}$

$=\sqrt[3]{22+\sqrt{30-\sqrt{20+\sqrt{27-\sqrt[3]{8}}}}}$

$=\sqrt[3]{22+\sqrt{30-\sqrt{20+\sqrt{27-2}}}}$

$=\sqrt[3]{22+\sqrt{30-\sqrt{20+5}}}$

$=\sqrt[3]{22+\sqrt{30-5}}$

$=\sqrt[3]{22+5}$

$=3$

ដូចនេះ **គណនាបាន $A=3$** ។

## ២០៦ គណនាតម្លៃនៃ $a$ និង $b$

បម្រាប់ $a$ និង $b$ ជាចំនួនគត់

ដោយ $a^2-b^2=321>0$ មានន័យថា $a$ ជាចំនួនធំជាង $b$ ហើយសន្និដ្ឋានថា $b=a-1$ ព្រោះ វាជាចំនួនគត់តគ្នា

យើងបាន : $a^2-(a-1)^2=321$

$$a^2-(a-1)^2=321$$
$$a^2-(a^2-2a+1)=321$$
$$a^2-a^2+2a-1=321$$
$$a=\frac{322}{2}=161$$

នាំឱ្យ $b=a-1=161-1=160$

ដូចនេះ **តម្លៃគណនាបានគឺ $a=161\,,\ b=160$** ។

## ២០៧ មុំទល់កំពូលជាអ្វី?

មុំទល់កំពូល ជាមុំមានកំពូលរួមគ្នា ហើយជ្រុងនៃមុំនីមួយៗ ផ្គុំគ្នាបង្កើតបានបន្ទាត់ពីរកាត់គ្នា និងរង្វាស់មុំទាំងពីរប៉ុនគ្នា ។




យើងនឹងស្រាយថា មុំទល់កំពូល $\alpha$ និង $\beta$ ជាមុំប៉ុនគ្នា

ដោយ $\alpha+\theta=180^o$ និង $\beta+\theta=180^o$ ព្រោះជាមុំរាប

សិក្សាផលដក :

$$-\begin{cases}\alpha+\theta=180^o\\ \beta+\theta=180^o\end{cases}$$
$$\alpha-\beta=0 \quad\Rightarrow\quad \alpha=\beta$$

ដូចនេះ **មុំទល់កំពូល $\alpha=\beta$** ។

## ២០៨ រកចំនួនគត់វិជ្ជមាន $n$ :

យើងមាន : $x^2+x+6=n^2$

គុណនឹង4 : $4x^2+4x+24=4n^2$

$$(4x^2+4x+1)+23=4n^2$$
$$(2n)^2-(2x+1)^2=23$$
$$(2n-2x-1)(2n+2x+1)=1\times 23$$

បម្រាប់ : $x$ និង $n$ ជាចំនួនគត់

ហើយ $n>x$ នោះយើងបាន :

$$+\begin{cases}2n-2x-1=1\\ 2n+2x+1=23\end{cases}$$
$$4n=24 \quad\Rightarrow\quad n=6$$

-ចំពោះ $n=6$ យើងបានសមីការ :

$$x^2+x+6=6^2$$
$$x^2+x-30=0$$

ដោយ $5+(-6)=-1$ & $5(-6)=-30$

តាមទ្រឹស្តីបទវៀត នោះ $5$ & $-6$ ជាឫសគត់នៃសមីការ

ដូចនេះ **តម្លៃដែលកំណត់បានគឺ $n=6$** ។

## ២០៩ ប្រៀបធៀបកន្សោម $\frac{(a+b)^2}{a^2-b^2}$ និង $\frac{a^2+b^2}{(a-b)^2}$

ពិនិត្យ : $\frac{(a+b)^2}{a^2-b^2}=\frac{(a+b)^2}{(a-b)(a+b)}$

$$=\frac{(a+b)}{(a-b)}$$
$$=\frac{(a+b)}{(a-b)}+\frac{(a-b)}{(a-b)}=\frac{a^2-b^2}{(a-b)^2}$$

ចំពោះ គ្រប់ចំនួនពិត $a$ និង $b$ ដែល $a\neq b$ នោះ :

$\frac{a^2+b^2}{(a-b)^2}>\frac{a^2-b^2}{(a-b)^2} \Leftrightarrow a^2+b^2>a^2-b^2 \Rightarrow 2b^2>0$ ពិត



www.facebook.com/7khmer

fb : Entertainment And Knowledge

ដោយ $\frac{(a+b)^2}{(a-b)} = \frac{a^2-b^2}{(a-b)^2} < \frac{a^2+b^2}{(a-b)^2}$

ដូចនេះ **ប្រៀបធៀបបាន $\frac{(a+b)^2}{(a-b)} < \frac{a^2+b^2}{(a-b)^2}$** ។

**២១០ ក. កំណត់តម្លៃ $m$ ដើម្បីឱ្យ $x=1$ ជាឫស**

យើងមាន : $(m+1)x^2-(m+3)x+3-m=0$ (*)

បើ $x=1$ ជាឫសនៃសមីការយើងបាន :

$$(m+1)1^2-(m+3)1+3-m=0$$
$$m+1-m-3+3-m=0$$
$$1-m=0$$
$$m=1$$

ចំពោះ $m=1$ សមីការ (*) ទៅជា :

$$(1+1)x^2-(1+3)x+3-1=0$$
$$2x^2-4x+2=0$$
$$x^2-2x+1=0$$

មាន $a+b+c=1+(-2)+1=0$ (ជាករណីពិសេស)

នាំឱ្យ $x_1=1$ , $x_2=\frac{c}{a}=\frac{1}{1}=1$

ដូចនេះ **តម្លៃ $m=1$ និងឫសមួយទៀតគឺ $x=1$** ។

**ខ. កំណត់តម្លៃ $m$ ដើម្បីឱ្យសមីការមានឫសឌុប**

សមីការ $(m+1)x^2-(m+3)x+3-m=0$ (*)

មាន $\Delta=b^2-4ac$

$$=[-(m+3)]^2-4(m+1)(3-m)$$
$$=m^2+6m+9-12m+4m^2-12+4m$$
$$=5m^2-2m-3$$

ដើម្បីឱ្យសមីការមានឫសឌុប លុះត្រាតែ $\begin{cases} a>0 \\ \Delta=0 \end{cases}$

នាំឱ្យ $\begin{cases} m+1>0 \\ 5m^2-2m-3=0 \end{cases} \Leftrightarrow \begin{cases} m>-1 \\ 5m^2-2m-3=0 \end{cases}$

សម្រាប់ : $5m^2-2m-3=0$ មាន $a+b+c=0$

នាំឱ្យសមីការមានឫស : $m_1=1$ , $m_2=\frac{c}{a}=\frac{-3}{5}$

យើងនឹងរក ឫសឌុបចំពោះតម្លៃ $m$ នីមួយៗដែលរកបាន

-ចំពោះ $m_1=1$: ដូចមាននៅសំណួរ ក. បង្ហាញរួច

នោះសមីការមានឫសឌុបគឺ $x_1=x_2=1$

-ចំពោះ $m_2=\frac{-3}{5}$ សមីការ (*) ទៅជា :

$$\left(-\frac{3}{5}+1\right)x^2-\left(-\frac{3}{5}+3\right)x+3-\left(-\frac{3}{5}\right)=0$$
$$\frac{2}{5}x^2-\frac{12}{5}x+\frac{18}{5}=0$$
$$\frac{2}{5}(x^2-6x+9)=0$$
$$(x^2-6x+9)=0$$
$$(x-3)^2=0$$

នាំឱ្យ សមីការមានឫសឌុបគឺ $x_1=x_2=3$

ដូចនេះ **តម្លៃកំណត់បាន $m_1=1$ , $m_2=\frac{c}{a}=\frac{-3}{5}$ និងឫសឌុប $x_1=x_2=1$ ឬ $x_1=x_2=3$** ។

**២១១ រកពីរចំនួន $x$ និង $y$**

យើងស្គាល់ : $\begin{cases} x^2+y^2=25 \\ xy=12 \end{cases}$ យើងបាន

$$-\begin{cases} x^2+y^2=25 \\ 2xy=24 \end{cases}$$
$$x^2-2xy+y^2=1$$
$$(x-y)^2=1$$
$$x-y=\pm1$$

-ចំពោះ $x-y=1 \Rightarrow x=y+1$

នាំឱ្យ $(y+1)y=12 \Leftrightarrow y^2+y-12=0$

មាន $y_1=\frac{-1-\sqrt{1^2-4(-14)}}{2}=\frac{-1-\sqrt{49}}{2}=\frac{-8}{2}=-4$

$y_2=\frac{-1+\sqrt{1^2-4(-14)}}{2}=\frac{-1+\sqrt{49}}{2}=\frac{6}{2}=3$

បើ $y_1=-4: x=\frac{12}{-4}=-3$ ហើយ $y_2=3$: $x=\frac{12}{3}=4$

-ចំពោះ $x-y=-1 \Rightarrow x=y-1$

នាំឱ្យ $(y-1)y=12 \Leftrightarrow y^2-y-12=0$

មាន $y_3=\frac{-(-1)-\sqrt{1^2-4(-14)}}{2}=\frac{1-7}{2}=-3$



www.facebook.com/7khmer
fb : Entertainment And Knowledge

$$y_2=\frac{-(-1)+\sqrt{1^2-4(-14)}}{2}=\frac{1+7}{2}=4$$

បើ $y_3=-3: x=\frac{12}{-3}=-4$ ហើយ $y_4=4: x=\frac{12}{4}=3$

ដូចនេះ ពីរចំនួនដែលកំណត់បានគឺ : $\begin{cases} x=3, y=4 \\ x=-3, y=-4 \end{cases}$ ឬ $\begin{cases} x=4, y=3 \\ x=-4, y=-3 \end{cases}$ ។

## ២១២ ដោះស្រាយប្រព័ន្ធសមីការ

យើងមាន $\begin{cases} x^2+y^2+x+y=8 & (1) \\ x^2+y^2+xy=7 & (2) \end{cases}$

តាង $S=x+y$ និង $P=xy$

តាម $(1)$ : $x^2+2xy+y^2-2xy+x+y=8$

$$(x+y)^2-2xy+(x+y)=8$$

$$S^2-2P+S=8 \quad (3)$$

តាម $(2)$ : $x^2+y^2+xy=7$

$$x^2+2xy+y^2-2xy+xy=7$$

$$(x+y)^2-xy=7$$

$$S^2-P=7$$

$$P=S^2-7 \quad (4)$$

យក $(4)$ ជំនួសក្នុង $(3)$ យើងបាន :

$$S^2-2P+S=8$$

$$S^2-2(S^2-7)+S=8$$

$$S^2-2S^2+14+S=8$$

$$-S^2+S+6=0$$

$$S^2-S-6=0$$

នាំឱ្យ $S_1=\frac{-(-1)\pm\sqrt{1+24}}{2}=\begin{cases}-2\\3\end{cases}$

តាម $(4)$ បើ $\begin{cases} S=-2 \ : \ P=(-2)^2-7=-3 \\ S=3 \ : \ P=(3)^2-7=2 \end{cases}$

-ចំពោះ $S=-2$ & $P=-3$ យើងបាន $\begin{cases} x+y=-2 \\ xy=-3 \end{cases}$

$x$ & $y$ ជាឬសនៃសមីការ $X^2+2X-3=0$

មាន $a+b+c=0$ នោះសមីការមានឬស :

$x=1, y=-3$ ឬ $x=-3, y=1$

-ចំពោះ $S=3$ & $P=2$ យើងបាន $\begin{cases} x+y=3 \\ xy=2 \end{cases}$

$x$ & $y$ ជាឬសនៃសមីការ $X^2-3X+2=0$

មាន $a+b+c=0$ នោះសមីការមានឬស :

$x=1, y=2$ ឬ $x=2, y=1$

ដូចនេះ ប្រព័ន្ធសមីការមានគូចម្លើយបួនគូ :

$x=1, y=-3$ ឬ $x=-3, y=1$

$x=1, y=2$ ឬ $x=2, y=1$ ។

## ២១៣ បាតមធ្យមនៃត្រីកោណគឺជាអ្វី?

បាតមធ្យមនៃត្រីកោណ គឺជាអង្កត់ដែលគូសភ្ជាប់ពីចំណុចកណ្ដាលនៃជ្រុងពីររបស់ត្រីកោណ ហើយវាស្របនឹងជ្រុងទី3 នៃត្រីកោណនេះ និងមានតម្លៃស្មើពាក់កណ្ដាលជ្រុងទី3 ។

យើងនឹងបង្ហាញថា $MN=\frac{BC}{2}$




តាមនិយមន័យ

$AM=\frac{AB}{2}$ , $AN=\frac{AC}{2}$ និងមាន $MN$ ស្របនឹង $BC$

-ត្រីកោណ : $\Delta ABC$ & $\Delta AMN$ មាន :

មុំ $AMN=ABC$ , មុំ $ANM=ACB$ (មុំត្រូវគ្នា)

នាំឱ្យ $\left.\begin{matrix}\Delta AMN\\ \Delta ABC\end{matrix}\right| \Rightarrow \frac{MN}{BC}=\frac{AM}{AB}$

នាំឱ្យ $MN=\frac{BC\cdot AM}{AB}=\frac{BC\cdot AM}{2AM}=\frac{BC}{2}$

ដូចនេះ បាតមធ្យមនៃត្រីកោណកោណស្មើពាក់កណ្ដាលនៃបាតទី3 ដែលស្របនឹងវា ។

## ២១៤ រកចំនួនគត់ $n$ ដែលផ្ទៀងផ្ទាត់ $\frac{2}{7}<\frac{n}{12}<\frac{4}{5}$

យើងមាន $\frac{2}{7}<\frac{n}{12}<\frac{4}{5}$ ឬអាចសរសេរ $\frac{24}{7}<n<\frac{48}{5}$

សមមូល $3+\frac{3}{7}<n<9+\frac{3}{5}$

នាំឱ្យ ចំនួនគត់ផ្ទៀងផ្ទាត់គឺ $n=4,5,6,7,8,9$



www.facebook.com/7khmer
fb : Entertainment And Knowledge

ដូចនេះ | ចំនួនគត់ដែលផ្ទៀងផ្ទាត់គឺ $n=4,5,6,7,8,9$ | ។

## ២១៥ រកភាគដែលនៅសល់




-ត្រីកោណកែង $AEB$ :

$$S_{AEB}=\frac{1}{2}\cdot 12\cdot 24=144$$

- ត្រីកោណកែង $BDC$ :

$$S_{BDC}=\frac{1}{2}\cdot 10\cdot 12=60$$

ភាគនៅសល់ $=S_{AEB}+S_{BDC}=144+60=204$ ភាគ

ដូចនេះ | ភាគដែលនៅសល់គឺ 204 ភាគ | ។

## ២១៦ ទាញរក $\frac{1}{x+2012}=?$

យើងមាន : $\frac{1}{x+2011}=2011$

សមមូល $x+2011=\frac{1}{2011}$ ឬ $x=\frac{1}{2011}-2011$

នាំឱ្យ $$\frac{1}{x+2012}=\frac{1}{\frac{1}{2011}-2011+2012}$$

$$=\frac{1}{\frac{1}{2011}+1}=\frac{1}{\frac{1+2011}{2011}}=\frac{2011}{2012}$$

ដូចនេះ | ទាញបាន $\frac{1}{x+2012}=\frac{2011}{2012}$ | ។

## ២១៧ រកប្រវែងដែលចុងរបាធ្លាក់ចុះ




ប្រវែងចុងរបាធ្លាក់ចុះគឺ $AC=AO-CO$

តាមទ្រឹស្តីបទពីតាគ័រ

-ចំពោះត្រីកោណកែង $AOB$ មាន :

$$AO^2=AB^2-OB^2$$

$$\Rightarrow \quad AO=\sqrt{AB^2-OB^2}$$

$$=\sqrt{25^2-20^2}=\sqrt{625-400}=\sqrt{225}$$

$$=15\ m$$

-ចំពោះត្រីកោណកែង $COD$ មាន :

$$CO^2=CD^2-OD^2$$

$$\Rightarrow \quad CO=\sqrt{CD^2-OD^2}$$

$$=\sqrt{25^2-24^2}=\sqrt{625-576}=\sqrt{49}$$

$$=7m$$

យើងបាន $AC=AO-CO=15m-7m=8m$

ដូចនេះ | ប្រវែងចុងរបាធ្លាក់ចុះគឺ $AC=8m$ | ។

## ២១៨ គណនារង្វាស់ជ្រុងនីមួយៗនៃត្រីកោណ

តាងរូបត្រីកោណនោះដូចរូបខាងក្រោម :




តាមបម្រាប់ប្រធាន

-បរិមាត្រ $a+b+c=60\ cm$

-ក្រឡាផ្ទៃ $\frac{1}{2}bc=120 \Leftrightarrow bc=240cm^2$

-តាមពីតាគ័រ $a^2=b^2+c^2$

សរុបមកយើងបានប្រព័ន្ធសមីការ $\begin{cases} a+b+c=60 & (1) \\ bc=240 & (2) \\ a^2=b^2+c^2 & (3) \end{cases}$

តាម $(1)$: $a+b=60-c$

$$(b+c)^2=(60-a)^2$$

$$b^2+c^2+2bc=3600-120a+a^2$$

$$b^2+c^2=3600-120a+a^2-2bc \quad (4)$$

ដោយយក (2) និង (3) ជំនួសក្នុង (4)

$$a^2=3600-120a+a^2-2\cdot 240$$

$$120a=3600-480$$

$$a=\frac{3120}{120}=26$$

នាំឱ្យ $\begin{cases} b+c=60-26=34 \\ bc=240 \end{cases}$

តាមវ្យែត $b$ និង $c$ ជាឫសនៃសមីការ :



www.facebook.com/7khmer
fb : Entertainment And Knowledge

$x^2-34x+240=0$

មាន $\Delta'=b'^2-ac=(-17)^2-240=289-240=7^2$

នាំឱ្យ $b=\dfrac{-(-17)-7}{1}=10$ , $c=\dfrac{-(-17)+7}{1}=24$

ឬអាច $c=\dfrac{-(-17)-7}{1}=10$ , $b=\dfrac{-(-17)+7}{1}=24$

ដូចនេះ

| រង្វាស់ជ្រុងនីមួយៗរបស់ត្រីកោណគឺ |
|---|
| $10cm$ , $24cm$ , $26cm$ |

។

## ២១៩ បង្ហាញថាត្រីកោណមានមុំទាំងបីជាត្រីកោណកែង

បម្រាប់មុំទាំងបីគឺ $\alpha$ , $2\alpha$ និង $3\alpha$

ដោយយើងដឹងថាផលបូកមុំក្នុងនៃត្រីកោណស្មើ $180^o$

យើងបាន $\alpha+2\alpha+3\alpha=180^o$

$$6\alpha=180^o \quad\Rightarrow\quad \alpha=30^o$$

មុំទាំងបីនៃត្រីកោណនេះគឺ

$\alpha=30^o$ , $2\alpha=60^o$ , $3\alpha=90^o$

ត្រីកោណនេះមានមុំមួយមានរង្វាស់ $90^o$ វាជាត្រីកោណកែង

ដូចនេះ

| ត្រីកោណមានមុំទាំងបីជាត្រីកោណកែង |
|---|

។

## ២២០ រក $f(9)$

យើងមាន $f(x)\cdot f(x+1)=9$ និង $f(3)=81$ នាំឱ្យ

$$f(3)\cdot f(4)=9 \quad\Rightarrow\quad f(4)=\frac{9}{f(3)}=\frac{9}{81}=\frac{1}{9}$$

$$f(4)\cdot f(5)=9 \quad\Rightarrow\quad f(5)=\frac{9}{f(4)}=\frac{9}{1/9}=81$$

$$f(5)\cdot f(6)=9 \quad\Rightarrow\quad f(6)=\frac{9}{f(5)}=\frac{9}{81}=\frac{1}{9}$$

$$f(6)\cdot f(7)=9 \quad\Rightarrow\quad f(7)=\frac{9}{f(6)}=\frac{9}{1/9}=81$$

$$f(7)\cdot f(8)=9 \quad\Rightarrow\quad f(8)=\frac{9}{f(7)}=\frac{9}{81}=\frac{1}{9}$$

$$f(8)\cdot f(9)=9 \quad\Rightarrow\quad f(9)=\frac{9}{f(8)}=\frac{9}{1/9}=81$$

ដូចនេះ

| រកបាន $f(9)=81$ |
|---|

។

## ២២១ ក. រកប្រភាគតាងចម្ងាយផ្លូវដែលសុខត្រូវដើរ

-បម្រាប់ : សុខធ្វើដំណើរដោយរថយន្តបាន $\dfrac{3}{8}=\dfrac{15}{40}$

សុខធ្វើដំណើរដោយម៉ូតូបាន $\dfrac{3}{5}=\dfrac{24}{40}$

នាំឱ្យ ការធ្វើដំណើរតាមរថយន្ត និងម៉ូតូគឺៈ $\dfrac{15}{40}+\dfrac{24}{40}=\dfrac{39}{40}$

នោះ ការធ្វើដំណើរដោយថ្មើរជើងគឺ $\dfrac{40}{40}-\dfrac{39}{40}=\dfrac{1}{40}$

ដូចនេះ

| ប្រភាគតាងការធ្វើដំណើរដោយថ្មើរជើងគឺ $\dfrac{1}{40}$ |
|---|

។

### ខ. រកចម្ងាយផ្លូវទាំងអស់បើសុខដើរបាន $2\ km$

សុខដើរបាន $2\ km$ ត្រូវនឹងប្រភាគ $\dfrac{1}{40}$

មានន័យថា $\dfrac{1}{40}=2\ km$ ចម្ងាយផ្លូវទាំងអស់គឺ

$\dfrac{40}{40}=40\times 2\ km=80\ km$

ដូចនេះ

| ចម្ងាយផ្លូវទាំងអស់គឺ $80\ km$ |
|---|

។

## ២២២ ក. សរសេរ $45m$ ជាភាគរយនៃ $1km$

ដោយ $1\ km=1000\,m$

យើងបាន $45\times\dfrac{1}{1000}=\dfrac{45}{1000}=\dfrac{4.5}{100}=4.5\%$

ដូចនេះ

| យើងសរសេរបាន $4.5\%$ |
|---|

។

### ខ. សរសេរ $1kg$ ជាភាគរយនៃ $800\,g$

ដោយ $1kg=1000g$

យើងបាន $1000\times\dfrac{1}{800}=\dfrac{1000}{8}\times\dfrac{1}{100}=\dfrac{125}{100}=125\%$

ដូចនេះ

| យើងសរសេរបាន $125\%$ |
|---|

។

## ២២៣ គណនាប្រវែង $AB$ :

បម្រាប់ : $MN=18cm$




យើងបាន : $AB=AI+BI$



www.facebook.com/7khmer
fb : Entertainment And Knowledge

ដោយ $A$ និង $B$ ជាចំណុចកណ្ដាល រៀងគ្នានៃ $MI$ និង $NI$

នាំឱ្យ $AI=\dfrac{MI}{2}$ និង $BI=\dfrac{NI}{2}$

នោះ $AB=\dfrac{MI}{2}+\dfrac{NI}{2}$

$$=\frac{MI+NI}{2}=\frac{MN}{2}=\frac{18\,cm}{2}=9\,cm$$

ដូចនេះ ប្រវែងគណនាបានគឺ $AB=9cm$ ។

## ២២៤ ស្រាយបញ្ជាក់ថាផលបូកមុំក្នុងពីរស្មើមុំក្រៅមួយ

ឧបមាថា យើងមានត្រីកោណ និង មុំ ដូចរូបខាងស្ដាំ ☞




យើងនឹងបង្ហាញថា $\alpha+\beta=\theta$

-ផលបូកមុំក្នុងនៃត្រីកោណស្មើ $180^o$

នោះ $\alpha+\beta+x=180^o$

-ហើយមុំ $x+\theta=180^o$ ព្រោះវាជាមុំរាប

សិក្សាផលដក :

$$-\begin{cases}\alpha+\beta+x=180^o\\ \quad\quad x+\theta=180^o\end{cases}$$

$$\alpha+\beta-\theta=0 \quad\Rightarrow\quad \alpha+\beta=\theta$$

ដូចនេះ ផលបូកមុំក្នុងពីរនៃត្រីកោណស្មើមុំក្រៅមួយ ដែលមិនជាប់នឹងវា ។

## ២២៥ គណនាតម្លៃនៃកន្សោម $A$ :

យើងមាន :

$$A=\left[\sqrt{4+\sqrt{5\sqrt3+5\sqrt{48-10\sqrt{7+4\sqrt3}}}}-4\right]^{2011^{2012}}$$

ពិនិត្យ : $\sqrt{4+\sqrt{5\sqrt3+5\sqrt{48-10\sqrt{7+4\sqrt3}}}}-4$

$$=\sqrt{4+\sqrt{5\sqrt3+5\sqrt{48-10\sqrt{2^2+4\sqrt3+\sqrt3^2}}}}-4$$

$$=\sqrt{4+\sqrt{5\sqrt3+5\sqrt{48-10\sqrt{(2+\sqrt3)^2}}}}-4$$

$$=\sqrt{4+\sqrt{5\sqrt3+5\sqrt{48-10(2+\sqrt3)}}}-4$$

$$=\sqrt{4+\sqrt{5\sqrt3+5\sqrt{28-10\sqrt3}}}-4$$

$$=\sqrt{4+\sqrt{5\sqrt3+5\sqrt{5^2-10\sqrt3+(\sqrt3)^2}}}-4$$

$$=\sqrt{4+\sqrt{5\sqrt3+5\sqrt{(5-\sqrt3)^2}}}-4$$

$$=\sqrt{4+\sqrt{5\sqrt3+5(5-\sqrt3)}}-4$$

$$=\sqrt{4+\sqrt{5\sqrt3+25-5\sqrt3}}-4$$

$$=\sqrt{4+\sqrt{25}}-4$$

$$=\sqrt{4+5}-4$$

$$=-1$$

នាំឱ្យ $A=[-1]^{2011^{2012}}$

ដោយ ស្វ័យគុណនៃ $2011$ ជាចំនួនមានលេខ $1$ ចុងជានិច្ច

នាំឱ្យ $A=2011^{2012}=\dots1$ ជាចំនួនសេស

យើងបាន $A=[-1]^{2011^{2012}}=-1$

ដូចនេះ តម្លៃគណនាបានគឺ $A=-1$ ។

## ២២៦ ដោះស្រាយប្រព័ន្ធសមីការ

រំលឹករាងសមីការដឺក្រេទី៣ : តាមទ្រឹស្ដីបទវ្យែត សមីការ មានរាង

$X^3-SX^2+RX-P=0$ ដែល $a,b,c$ ជាឫស :

$$\begin{cases}S=a+b+c\\ R=ab+ac+bc\\ P=abc\end{cases}$$ ។ អ្នកអាចផ្ទៀងផ្ទាត់រាងខាងលើ

ដោយការពន្លាតកន្សោម $(x-a)(x-b)(x-c)=0$ ។

យើងមាន $\begin{cases}2^x+2^y+2^z=7\\ 2^{-x}+2^{-y}+2^{-z}=\dfrac{7}{4}\\ x+y+z=3\end{cases}$

$$\begin{cases}2^x+2^y+2^z=7\\ \dfrac{1}{2^x}+\dfrac{1}{2^y}+\dfrac{1}{2^z}=\dfrac{7}{4}\\ 2^{x+y+z}=2^3\end{cases}\Leftrightarrow\begin{cases}2^x+2^y+2^z=7\\ \dfrac{2^y2^z+2^x2^z+2^x2^y}{2^x2^y2^z}=\dfrac{7}{4}\\ 2^x2^y2^z=8\end{cases}$$



www.facebook.com/7khmer
fb : Entertainment And Knowledge

$$\begin{cases} 2^x+2^y+2^z=7 \\ 2^y2^z+2^x2^z+2^x2^y=\frac{7}{4}\times 8 \\ 2^x2^y2^z=8 \end{cases} \Leftrightarrow \begin{cases} 2^x+2^y+2^z=7 \\ 2^y2^z+2^x2^z+2^x2^y=14 \\ 2^x2^y2^z=8 \end{cases}$$

ដើម្បីងាយស្រួល យើងតាង $a=2^x$ , $b=2^y$ , $c=2^z$

យើងបានប្រព័ន្ធថ្មី $\begin{cases} a+b+c=7 \\ bc+ac+ab=14 \\ abc=8 \end{cases}$ តាមទ្រឹស្តីបទវ្យែត

$a,b,c$ ជាឬសនៃសមីការ $X^3-7X^2+14X-8=0$

( មានវិធីដោះស្រាយសមីការដឺក្រេទីពាតាម Cadan ប៉ុន្តែពុំមានក្នុងកម្មវិធីសិក្សារបស់ក្រសួងអប់រំ ដូចនេះយើងនៅតែដោះស្រាយដោយរបៀបទាញឬសងាយ ។ សូមចងចាំថា វាពុំមែនហួសសមត្ថភាពរបស់យើងទេ ព្រោះគេរៀបចំលំហាត់បានល្អណាស់ )

សមីការខាងលើមានឬសងាយ : $X=1$

ក្រោយពីចែកពហុធា $X^3-7X^2+14X-8=0$ និង $X=1$

យើងបាន : $(X-1)(X^2-6X+8)=0$

$$(X-1)(X-2)(X-4)=0$$

នាំឱ្យ $\begin{cases} X-1=0 \\ X-2=0 \\ X-4=0 \end{cases} \Leftrightarrow \begin{cases} X=a=1 \\ X=b=2 \\ X=c=4 \end{cases}$

យើងបាន $\begin{cases} a=1 \\ b=2 \\ c=4 \end{cases} \Leftrightarrow \begin{cases} 2^x=2^0 \\ 2^y=2^1 \\ 2^z=2^2 \end{cases} \Rightarrow \begin{cases} x=0 \\ y=1 \\ z=2 \end{cases}$

ដូចនេះ ប្រព័ន្ធសមីការមានឬស $\{x,y,z\}=\{0,1,2\}$ ។

## ២២៧ គណនា $\left(\frac{2a}{b}\right)^{2011}$

គេឱ្យ $a+\sqrt{b}=\sqrt{15+\sqrt{216}}$

$$a+\sqrt{b}=\sqrt{9+\sqrt{36\cdot 6}+6}$$
$$=\sqrt{3^2+6\sqrt{6}+\sqrt{6}^2}$$
$$=\sqrt{\left(3+\sqrt{6}\right)^2}$$
$$=3+\sqrt{6}$$

កន្សោមនៃអង្គទាំងពីរមានទម្រង់ដូចគ្នា និង $a$ និង $b$ ជាពីរចំនួនគត់វិជ្ជមាន នាំឱ្យយើងទាញបានករណីតែមួយគត់គឺ :

$$a=3 \ \& \ b=6$$

ចំពោះ $a=3 \ \& \ b=6$ យើងបាន :

$$\left(\frac{2a}{b}\right)^{2011}=\left(\frac{2\cdot 3}{6}\right)^{2011}=\left(\frac{6}{6}\right)^{2011}=1^{2011}=1$$

ដូចនេះ គណនាបាន $\left(\frac{2a}{b}\right)^{2011}=1$ ។

## ២២៨ រកចំនួនខ្ទង់នៃផ្នែកគត់នៃចំនួន $A=2^{2011}$

យើងមាន : $A=2^{2011}$ ដោយបំពាក់លោការីតគោល10

យើងបាន : $\log A=\log 2^{2011}$

$$\log A=2011\cdot\log 2$$

បម្រាប់ : $\log 2\approx 0.301$

នាំឱ្យ $\log A=2011\cdot 0.301$

$$\log A=605.311$$

ដោយចំនួន $605<605.311<606$

នាំឱ្យ $605<\log A<606$

$$10^{605}<A<10^{606}$$

ដោយ $10^{605}$ ជាចំនួនមានលេខ 606ខ្ទង់ ហើយចំនួន $10^{606}$ ជាចំនួនមានលេខ 607ខ្ទង់

ទាញបាន $A$ ជាចំនួនដែលមានលេខ 606ខ្ទង់

ដូចនេះ $A=2^{2011}$ ជាចំនួនដែលមានផ្នែកគត់ 606ខ្ទង់ ។

## ២២៩ ដោះស្រាយសមីការ $\frac{3\sqrt{x}-5}{2}-\frac{2\sqrt{x}-7}{3}=\sqrt{x}-1$

យើងមាន $\frac{3\sqrt{x}-5}{2}-\frac{2\sqrt{x}-7}{3}=\sqrt{x}-1$ , $x\geq 0$

$$\frac{3\left(3\sqrt{x}-5\right)}{6}-\frac{2\left(2\sqrt{x}-7\right)}{6}=\frac{6\left(\sqrt{x}-1\right)}{6}$$
$$3\left(3\sqrt{x}-5\right)-2\left(2\sqrt{x}-7\right)=6\left(\sqrt{x}-1\right)$$
$$9\sqrt{x}-15-4\sqrt{x}+14=6\sqrt{x}-6$$
$$5\sqrt{x}-1=6\sqrt{x}-6$$
$$\sqrt{x}=5$$
$$x=25$$

ចំពោះ $x=25$ ក្រោយពីផ្ទៀងផ្ទាត់ 4=4 ពិត

ដូចនេះ សមីការមានឬស $x=25$ ។



www.facebook.com/7khmer
fb : Entertainment And Knowledge

## ២៣០ ប្រៀបធៀប $ab$ និង $PGCD(a,b)\times PPCM(a,b)$

យើងមាន $a=90$ , $b=280$ ដោយបំបែកជាកត្តាបឋម :

| | | | | |
|---|---|---|---|---|
| $a=90$ | 2 | | $b=280$ | 2 |
| 45 | 3 | | 140 | 2 |
| 15 | 3 | | 70 | 2 |
| 5 | 5 | | 35 | 5 |
| 1 | | | 7 | 7 |
| | | | 1 | |

នាំឱ្យ $a=90=2\cdot 3^2\cdot 5$ និង $b=280=2^3\cdot 5\cdot 7$

យើងបាន : • $ab=90\times 280=25200$

• $PGCD(a,b)=2\times 5=10$

• $PPCM(a,b)=2^3\times 3^2\times 5\times 7=2520$

នោះ $PGCD(a,b)\times PPCM(a,b)=10\times 2520=25200$

ឃើញថា $ab=PGCD(a,b)\times PPCM(a,b)=25200$

ដូចនេះ យើងប្រៀបធៀបបាន $ab=PGCD(a,b)\times PPCM(a,b)$ ។

## ២៣១ ផ្ទៀងផ្ទាត់ឯកលក្ខណៈភាព

$(1+\sin x+\cos x)^2=2(1+\sin x)(1+\cos x)$

ពិនិត្យ : $(1+\sin x+\cos x)^2$

តាមរូបមន្ត $(a+b+c)^2=a^2+b^2+c^2+2ab+2bc+2ac$

ដោយពន្លាតតាមរូបមន្តខាងលើ យើងបាន :

$$\begin{aligned}
&(1+\sin x+\cos x)^2\\
&=1^2+\sin^2 x+\cos^2 x+2\sin x+2\cos x+2\sin x\cos x\\
&=1^2+1+2\sin x+2\cos x+2\sin x\cos x\\
&=2(1+\sin x+\cos x+\sin x\cos x)\\
&=2[(1+\sin x)+(\cos x+\sin x\cos x)]\\
&=2[(1+\sin x)+\cos x(1+\sin x)]\\
&=2(1+\sin x)(1+\cos x)
\end{aligned}$$

ព្រោះ ដោយសារ $\sin^2 x+\cos^2 x=1$

នាំឱ្យ $(1+\sin x+\cos x)^2=2(1+\sin x)(1+\cos x)$

ដូចនេះ $(1+\sin x+\cos x)^2=2(1+\sin x)(1+\cos x)$ ។

## ២៣២ ដោះស្រាយប្រព័ន្ធសមីការ

យើងមាន $\begin{cases}x+y=4\\ xy-z^2+6z=13\end{cases}\Leftrightarrow\begin{cases}x+y=4\\ xy=z^2-6z+13\end{cases}$

ដោយស្គាល់ផលបូក និងផលគុណ យើងបង្កើតបានសមីការ

$X^2-4X+(z^2-6z+13)=0$ ដែលមាន $x\,\&\,y$ ជាឬស

មាន $\Delta'=b'^2-ac$

$$\begin{aligned}
&=(-2)^2-(z^2-6z+13)\\
&=4-z^2+6z-13\\
&=-z^2+6z-9\\
&=-(z^2-6z+9)\\
&=-(z-3)^2
\end{aligned}$$

ដោយ $-(z-3)^2\le 0$ មានតែមួយករណីគត់ ដែលនាំឱ្យ

សមីការមានឬសគឺ $-(z-3)^2=0$ នោះ $z=3$

-ចំពោះ $z=3$ យើងបានសមីការថ្មី :

$$\begin{aligned}
X^2-4X+(3^2-6\cdot 3+13)&=0\\
X^2-4X+4&=0\\
(X-2)^2&=0
\end{aligned}$$

សមីការមានឬសឌុប $X_1=X_2=2$

យើងបានឬសនៃសមីការគឺ : $\begin{cases}X_1=x=2\\ X_2=y=2\end{cases}$

ដូចនេះ ប្រព័ន្ធសមីការមានចម្លើយ $x=2\,,y=2\,,z=3$ ។

## ២៣៣ បែងចែកនិមិត្តសញ្ញាលោការីត

យើងមាននិមិត្តសញ្ញាលោការីតដូចខាងក្រោម :

$Logx$ , $\log x$ , $\lg x$ , $\ln x$ , $\log_{10} x$ , $\log_e x$

តាមការប្រើប្រាស់ របស់អ្នកគណិតវិទ្យានិមិត្តសញ្ញា :

- លោការីតទស្សភាគ ឬ លោការីតគោល ១០រួមមាន :

$\log x$ , $\lg x$ , $\log_{10} x$

- លោការីតនេពែ ឬ លោការីតគោល $e$ រួមមាន :

$Logx$ , $\ln x$ , $\log_e x$ ។

(លំហាត់ខាងលើ គ្រាន់តែចង់បង្ហាញពីនិមិត្តសញ្ញាលោការីត)



www.facebook.com/7khmer
fb : Entertainment And Knowledge

## ២៣៨ រកក្រឡាផ្ទៃរង្វង់ចារឹកក្នុងត្រីកោណនេះ




-តាមរូបមន្តហេរុង ផ្ទៃនៃត្រីកោណគឺ

$S_\Delta=\sqrt{p(p-a)(p-b)(p-c)}$

ដែលមាន $a,b,c$ ជារង្វាស់ជ្រុង

ហើយ $p=\dfrac{a+b+c}{2}$ ជាកន្លះបរិមាត្រ

-សម្មតិកម្ម : ត្រីកោណមានរង្វាស់ជ្រុង $7$ , $8$ និង $11$

នោះ $p=\dfrac{7+8+11}{2}=13$

យើងបាន : $S_\Delta=\sqrt{13(13-7)(13-8)(13-11)}$

$=\sqrt{13\times6\times5\times2}$

$=2\sqrt{13\times15}$

-ផ្ទៃត្រីកោណធំ បានពីផលបូកផ្ទៃត្រីកោណតូចៗបីដែលមានរង្វាស់ជ្រុងនីមួយៗជាបាត និងកាំរង្វង់ $r$ នៃរង្វង់ចារឹកក្នុងត្រីកោណ ជាកម្ពស់ យើងបាន :

$$S_\Delta=\left(\frac{1}{2}\times7\times r\right)+\left(\frac{1}{2}\times8\times r\right)+\left(\frac{1}{2}\times11\times r\right)$$

$$=\frac{7r}{2}+\frac{8r}{2}+\frac{11r}{2}=13r$$

នាំឱ្យ $13r=2\sqrt{13\times15}\quad\Rightarrow\quad r=\dfrac{2\sqrt{13\times15}}{13}$

-ផ្ទៃរង្វង់ចារឹកក្នុងត្រីកោណគឺ $S_O=\pi r^2$

$$S_O=\pi\left(\frac{2\sqrt{13\times15}}{13}\right)^2$$

$$=\pi\cdot\frac{4\times13\times15}{13^2}=\frac{60\pi}{13}$$

ដូចនេះ ផ្ទៃក្រឡារង្វង់ចារឹកក្នុងត្រីកោណគឺ $S_O=\dfrac{60\pi}{13}$ ។

## ២៣៩ គណនាតម្លៃនៃកន្សោម $P=a^{2010}+b^{2011}+c^{2012}$

តាមរូបមន្តឯកលក្ខណ:ភាព

$$(a+b+c)^3=a^3+b^3+c^3+3(a+b)(b+c)(a+c)$$

សម្មតិកម្ម : $a+b+c=1$ និង $a^3+b^3+c^3=1$

នាំឱ្យ $1^3=1+3(a+b)(b+c)(a+c)$

$$3(a+b)(b+c)(a+c)=0$$

$$(a+b)(b+c)(a+c)=0$$

ទាញបាន $\begin{cases}a+b=0\\ b+c=0\\ a+c=0\end{cases}$

-ចំពោះ $a+b=0$ តាមបម្រាប់ $a+b+c=1$ នោះ $c=1$

ហើយ $a^2+b^2+c^2=1$ នោះ $a^2+b^2=0$ ទាញបាន

$a=0$ , $b=0$ យើងគណនាតម្លៃនៃកន្សោម :

$$P=a^{2010}+b^{2011}+c^{2012}=0^{2010}+0^{2011}+1^{2012}=1$$

-ចំពោះ $b+c=0$ តាមបម្រាប់ $a+b+c=1$ នោះ $a=1$

ហើយ $a^2+b^2+c^2=1$ នោះ $b^2+c^2=0$ ទាញបាន

$b=0$ , $c=0$ យើងគណនាតម្លៃនៃកន្សោម :

$$P=a^{2010}+b^{2011}+c^{2012}=1^{2010}+0^{2011}+0^{2012}=1$$

-ចំពោះ $a+c=0$ តាមបម្រាប់ $a+b+c=1$ នោះ $b=1$

ហើយ $a^2+b^2+c^2=1$ នោះ $a^2+c^2=0$ ទាញបាន

$a=0$ , $c=0$ យើងគណនាតម្លៃនៃកន្សោម :

$$P=a^{2010}+b^{2011}+c^{2012}=0^{2010}+1^{2011}+0^{2012}=1$$

សរុបមក ទោះជាករណីណាក៏ដោយ $P=1$ ជានិច្ច

ដូចនេះ តម្លៃគណនាបានគឺ $P=1$ ។

## ២៤០ បង្ហាញថា $a^2+b^2+c^2+d^2+1\geq a+b+c+d$

យើងមាន $a^2+b^2+c^2+d^2+1\geq a+b+c+d$

$$a^2-a+b^2-b+c^2-c+d^2-d+1\geq0$$

$$\left(a^2-a+\frac{1}{4}\right)+\left(b^2-b+\frac{1}{4}\right)+\left(c^2-c+\frac{1}{4}\right)+\left(d^2-d+\frac{1}{4}\right)\geq0$$

$$\left(a-\frac{1}{2}\right)^2+\left(b-\frac{1}{2}\right)^2+\left(c-\frac{1}{2}\right)^2+\left(d-\frac{1}{2}\right)^2\geq0$$

ដោយ $\left(a-\frac{1}{2}\right)^2\geq0$ , $\left(b-\frac{1}{2}\right)^2\geq0$ , $\left(c-\frac{1}{2}\right)^2\geq0$ , $\left(d-\frac{1}{2}\right)^2\geq0$

នាំឱ្យ $\left(a-\frac{1}{2}\right)^2+\left(b-\frac{1}{2}\right)^2+\left(c-\frac{1}{2}\right)^2+\left(d-\frac{1}{2}\right)^2\geq0$ ពិតជានិច្ច

ដូចនេះ $a^2+b^2+c^2+d^2+1\geq a+b+c+d$ ។



www.facebook.com/7khmer
fb : Entertainment And Knowledge

## ២៣៧ រកអាយុម្នាក់ៗ

តាង $a$ ជាអាយុឪពុក និង $b,c,d$ ជាអាយុកូនទាំងបី

បម្រាប់ : អាយុអ្នកទាំងបួនមានសមាមាត្រ $15\,,7\,,5\,,4$

បើតាង $x$ ជាផលធៀបសមាមាត្រអាយុអ្នកទាំងបួន

យើងបាន : $\frac{a}{15}=\frac{b}{7}=\frac{c}{5}=\frac{d}{4}=x$

ទាញបាន : $\frac{a}{15}=x \Rightarrow a=15x$ $\qquad \frac{b}{7}=x \Rightarrow b=7x$

$\frac{c}{5}=x \Rightarrow c=5x$ $\qquad \frac{d}{4}=x \Rightarrow d=4x$

សម្មតិកម្មៈ អាយុឪពុកតិចជាងផលបូកអាយុកូនទាំងបី 3ឆ្នាំ

យើងបាន $a+3=b+c+d$

$$15x+3=7x+5x+4x$$

$$x=3$$

នាំឱ្យ : $\frac{a}{15}=3 \Rightarrow a=45$ $\qquad \frac{b}{7}=3 \Rightarrow b=21$

$\frac{c}{5}=3 \Rightarrow c=15$ $\qquad \frac{d}{4}=3 \Rightarrow d=12$

ផ្ទៀងផ្ទាត់ : $45+3=21+15+12 \Leftrightarrow 48=48$ ពិត

ដូចនេះ | ឪពុកមានអាយុ45ឆ្នាំ និងកូនទាំងបីមានអាយុរៀងគ្នាគឺ : 21ឆ្នាំ , 15ឆ្នាំ , 12ឆ្នាំ | ។

## ២៣៨ ប្រៀបធៀបពីរចំនួន $\left(\frac{9}{25}\right)^{60}$ និង $\left(\frac{225}{625}\right)^{50}$

ពិនិត្យ : $\left(\frac{9}{25}\right)^{60}=\left(\left(\frac{3}{5}\right)^{2}\right)^{60}=\left(\frac{3}{5}\right)^{2\times 60}=\left(\frac{3}{5}\right)^{120}$

ហើយ $\left(\frac{225}{625}\right)^{50}=\left(\left(\frac{15}{25}\right)^{2}\right)^{50}=\left(\frac{3}{5}\right)^{2\times 50}=\left(\frac{3}{5}\right)^{100}$

ដោយ $\left(\frac{3}{5}\right)^{120}<\left(\frac{3}{5}\right)^{100}$ ព្រោះវាមានគោល $\frac{3}{5}<1$

នាំឱ្យ $\left(\frac{9}{25}\right)^{60}=\left(\frac{3}{5}\right)^{120}<\left(\frac{3}{5}\right)^{100}=\left(\frac{225}{625}\right)^{50}$

ដូចនេះ | ក្រោយពីប្រៀបធៀប $\left(\frac{9}{25}\right)^{60}<\left(\frac{225}{625}\right)^{50}$ | ។

( លំហាត់ខាងលើមានច្រើននាក់ណាស់ ដែលច្រលំភ្លេចគិតថា គោលតូចជាង1)

## ២៣៩ ស្រាយបំភ្លឺថាគេបាន $\frac{ab}{cd}=\frac{(a+b)^2}{(c+d)^2}$

យើងមានសមាមាត្រ : $\frac{a}{b}=\frac{c}{d}$ សមមូល $\frac{a}{c}=\frac{b}{d}$ (1)

-គុណ (1) នឹង $\frac{b}{d}$ យើងបាន : $\frac{ab}{cd}=\frac{b^2}{d^2}$ (2)

-គុណ (1) នឹង $\frac{a}{c}$ យើងបាន : $\frac{a^2}{c^2}=\frac{ab}{cd}$ (3)

តាម (2) និង (3) យើងបានផលធៀបស្មើគ្នាគឺ :

$\frac{a^2}{c^2}=\frac{ab}{cd}=\frac{b^2}{d^2}$ ឬអាចសរសេរ $\frac{a^2}{c^2}=\frac{2ab}{2cd}=\frac{b^2}{d^2}$

យើងបាន $\frac{a^2}{c^2}=\frac{2ab}{2cd}=\frac{b^2}{d^2}=\frac{a^2+2ab+b^2}{c^2+2cd+d^2}$

$$=\frac{(a+b)^2}{(c+d)^2}$$

នាំឱ្យ $\frac{2ab}{2cd}=\frac{(a+b)^2}{(c+d)^2} \Leftrightarrow \frac{ab}{cd}=\frac{(a+b)^2}{(c+d)^2}$

ដូចនេះ | បង្ហាញបានថា $\frac{ab}{cd}=\frac{(a+b)^2}{(c+d)^2}$ | ។

## ២៤០ រកពីរចំនួនគត់វិជ្ជមានតគ្នា

តាង $x$ ជាចំនួនទី1 នោះចំនួនទី2 បន្ទាប់គឺ $x+1$

តាមបម្រាប់ប្រធានយើងបាន :

$$(x+1)^2-x^2=321$$

$$x^2+2x+1-x^2=321$$

$$2x=321-1$$

$$x=\frac{320}{2}=160$$

ដោយ $x=160$ ជាចំនួនទី1 នោះចំនួនទី2 គឺ $x+1=161$

ដូចនេះ | ចំនួនគត់វិជ្ជមានតគ្នានោះគឺ 160 និង 161 | ។

## ២៤១ តើក្មេងណាឈ្នះ ហើយក្មេងណាចាញ់

តាង $N$ ជាចំនួនឃ្លីសរុប មានន័យថា $A+B+C=N$

-មុនពេលលេង យើងមានសមាមាត្រ :

$\frac{A}{3}=\frac{B}{4}=\frac{C}{5}$



www.facebook.com/7khmer
fb : Entertainment And Knowledge

តាមលក្ខណៈសមាមាត្រយើងអាចសរសេរបាន :

$$\frac{A}{3}=\frac{B}{4}=\frac{C}{5}=\frac{A+B+C}{3+4+5}=\frac{N}{12}$$

ទាញបាន :

- $\frac{A}{3}=\frac{N}{12} \Rightarrow A=\frac{3N}{12}=\frac{12N}{48}$
- $\frac{B}{4}=\frac{N}{12} \Rightarrow B=\frac{4N}{12}=\frac{16N}{48}$
- $\frac{C}{5}=\frac{N}{12} \Rightarrow C=\frac{5N}{12}=\frac{20N}{48}$

-ក្រោយពេលលេង យើងមានសមាមាត្រ :

$$\frac{A}{15}=\frac{B}{16}=\frac{C}{17}$$

តាមលក្ខណៈសមាមាត្រយើងអាចសរសេរបាន :

$$\frac{A}{15}=\frac{B}{16}=\frac{C}{17}=\frac{A+B+C}{15+16+17}=\frac{N}{48}$$

ទាញបាន :

- $\frac{A}{15}=\frac{N}{48} \Rightarrow A=\frac{15N}{48}$
- $\frac{B}{16}=\frac{N}{48} \Rightarrow B=\frac{16N}{48}$
- $\frac{C}{17}=\frac{N}{48} \Rightarrow C=\frac{17N}{48}$

-ប្រៀបធៀបមុនពេលលេង និងក្រោយពេលលេង :

ក្មេង $A$ : $\frac{12N}{48}<\frac{15N}{48}$ មានន័យថា $A$ ឈ្នះ

ក្មេង $B$ : $\frac{16N}{48}=\frac{16N}{48}$ មានន័យថា $B$ រួចខ្លួន

ក្មេង $C$ : $\frac{20N}{48}>\frac{17N}{48}$ មានន័យថា $C$ ចាញ់

ដូចនេះ ក្មេង : $A$ ឈ្នះ , $B$ រួចខ្លួន និង $C$ ចាញ់ ។

## ២៤២ ដោះស្រាយសមីការ

$$\frac{x}{3}-\frac{x}{6}+\frac{x}{9}-\frac{x}{12}=-1+\frac{1}{2}-\frac{1}{3}+\frac{1}{4}$$

$$-\frac{x}{3}\left(-1+\frac{1}{2}-\frac{1}{3}+\frac{1}{4}\right)=\left(-1+\frac{1}{2}-\frac{1}{3}+\frac{1}{4}\right)$$

$$-\frac{x}{3}=1 \quad \Rightarrow x=-3$$

ដូចនេះ សមីការមានឫស $x=-3$ ។

## ២៤៣ ដោះស្រាយប្រព័ន្ធសមីការ :

យើងមាន : $\begin{cases} x+xy+y=1 \\ y+yz+z=4 \\ z+zx+x=9 \end{cases}$ យើងបាន

$$\begin{cases} x+xy+y=1 \\ y+yz+z=4 \\ z+zx+x=9 \end{cases} \Leftrightarrow \begin{cases} x+xy+y+1=1+1 \\ y+yz+z+1=4+1 \\ z+zx+x+1=9+1 \end{cases}$$

$$\begin{cases} x(y+1)+(y+1)=2 \\ y(z+1)+(z+1)=5 \\ z(x+1)+(x+1)=10 \end{cases} \Leftrightarrow \begin{cases} (y+1)(x+1)=2 & (i) \\ (z+1)(y+1)=5 & (ii) \\ (x+1)(z+1)=10 & (iii) \end{cases}$$

ដោយគុណសមីការ : $(i)\times(ii)\times(iii)$ បញ្ចូលគ្នា យើងបាន

$$(x+1)^2(y+1)^2(z+1)^2=100$$
$$(x+1)(y+1)(z+1)=\pm 10$$

-ចំពោះ $(x+1)(y+1)(z+1)=10 \quad (*)$

ចែកសមីការ $(*)$ និងសមីការ $(i),(ii),(iii)$ យើងបាន :

$$\begin{cases} \frac{(x+1)(y+1)(z+1)}{(y+1)(x+1)}=\frac{10}{2} \\ \frac{(x+1)(y+1)(z+1)}{(z+1)(y+1)}=\frac{10}{5} \\ \frac{(x+1)(y+1)(z+1)}{(x+1)(z+1)}=\frac{10}{10} \end{cases} \Leftrightarrow \begin{cases} z+1=5 \\ x+1=2 \\ y+1=1 \end{cases} \Rightarrow \begin{cases} z=4 \\ x=1 \\ y=0 \end{cases}$$

-ចំពោះ $(x+1)(y+1)(z+1)=-10 \quad (**)$

ចែកសមីការ $(**)$ និងសមីការ $(i),(ii),(iii)$ យើងបាន :

$$\begin{cases} \frac{(x+1)(y+1)(z+1)}{(y+1)(x+1)}=\frac{-10}{2} \\ \frac{(x+1)(y+1)(z+1)}{(z+1)(y+1)}=\frac{-10}{5} \\ \frac{(x+1)(y+1)(z+1)}{(x+1)(z+1)}=\frac{-10}{10} \end{cases} \Leftrightarrow \begin{cases} z+1=-5 \\ x+1=-2 \\ y+1=-1 \end{cases} \Rightarrow \begin{cases} z=-6 \\ x=-3 \\ y=-2 \end{cases}$$

ដូចនេះ ប្រព័ន្ធសមីការមានចម្លើយពីរគឺ :

$(x,y,z)=(1,0,4)$ ឬ $(x,y,z)=(-3,-2,-6)$ ។

## ២៤៤ ប្រៀបធៀបចំនួន :

យើងមាន $2^{2^{2^{\cdot^{\cdot^{2}}}}}$ មានលេខ 2 ចំនួន 1001 ដង

ហើយ $3^{3^{3^{\cdot^{\cdot^{3}}}}}$ មានលេខ 3 ចំនួន 1000 ដង

ពិនិត្យ : $2^{2^2}=2^4=16$ ហើយ $3^3=27$



www.facebook.com/7khmer
fb : Entertainment And Knowledge

ឃើញថា $16<27 \quad \Rightarrow \quad 2^{2^2}<3^3$

យើងដឹងថា $2^{2^{2^{\cdot^{\cdot^{2}}}}}$ តូចជាង $3^{3^{3^{\cdot^{\cdot^{3}}}}}$ ដែលមាន 998 ដង

ជាស្វ័យគុណបន្តបន្ទាប់ដូចគ្នា

នោះយើងបាន $16^{2^{2^{\cdot^{\cdot^{2}}}}}<27^{3^{3^{\cdot^{\cdot^{3}}}}}$ ដែលមានលេខ2 និងលេខ3

ចំនួន 998 ដងជាស្វ័យគុណបន្តបន្ទាប់ដូចគ្នា

ដោយ $16^{2^{2^{\cdot^{\cdot^{2}}}}}$ ( មាន 998 ដងលេខ 2 ) $=2^{2^{2^{\cdot^{\cdot^{2}}}}}$ ( មាន 1001 ដងលេខ 2 )

$27^{3^{3^{\cdot^{\cdot^{3}}}}}$ ( មាន 998 ដងលេខ 3 ) $=3^{3^{3^{\cdot^{\cdot^{3}}}}}$ ( មាន 1000 ដងលេខ 3 )

ដូចនេះ $2^{2^{2^{\cdot^{\cdot^{2}}}}}$ ( មាន 1001 ដងលេខ 2 ) $<3^{3^{3^{\cdot^{\cdot^{3}}}}}$ ( មាន 1000 ដងលេខ 3 )

## ២៨៥ ដោះស្រាយសមីការ

$x=\sqrt{3-x}\cdot\sqrt{4-x}+\sqrt{4-x}\cdot\sqrt{5-x}+\sqrt{5-x}\cdot\sqrt{3-x}$

( វាជាសមីការអសនិទាន ចាំបាច់ត្រូវយកចម្លើយដែលរកឃើញមកផ្ទៀងផ្ទាត់ )

សមីការមានន័យកាលណា :

$$\begin{cases}3-x\ge 0\\4-x\ge 0\\5-x\ge 0\end{cases}\Leftrightarrow\begin{cases}x\le 3\\x\le 4\\x\le 5\end{cases}\Rightarrow x\le 3$$

-ដើម្បីកុំឱ្យវែងពេក និងពិបាកក្នុងការសរសេរ :

យើងតាង $4-x=t \Rightarrow \begin{cases}x=4-t\\3-x=t-1\\5-x=t+1\end{cases}$ យើងបាន :

$4-t=\sqrt{t-1}\cdot\sqrt{t}+\sqrt{t}\cdot\sqrt{t+1}+\sqrt{t+1}\cdot\sqrt{t-1}$

$4-t=\sqrt{(t-1)t}+\sqrt{t(t+1)}+\sqrt{(t+1)(t-1)}$

$4-t=\sqrt{t^2-t}+\sqrt{t^2+t}+\sqrt{t^2-1}$

$(4-t)-\sqrt{t^2-1}=\sqrt{t^2-t}+\sqrt{t^2+t}$

លើកអង្គទាំងពីជាការេ យើងបាន :

$$(4-t)-\sqrt{t^2-1}=\sqrt{t^2-t}+\sqrt{t^2+t}$$

$(4-t)^2-2(4-t)\sqrt{t^2-1}+t^2-1=2t^2+2t\sqrt{t^2-1}$

$(4-t)^2+t^2-1-2t^2=2t\sqrt{t^2-1}+2(4-t)\sqrt{t^2-1}$

$$15-8t=8\sqrt{t^2-1}$$

លើកអង្គទាំងពីរជាការេម្តងទៀតយើងបាន :

$$225-240t+64t^2=64t^2-64$$

$$240t=289$$

$$t=\frac{289}{240}$$

នាំឱ្យ $x=4-t=4-\frac{289}{240}=\frac{960-289}{240}=\frac{671}{240}<3$

ផ្ទៀងផ្ទាត់ ចំពោះ $x=\frac{671}{240}$

$\sqrt{3-x}\cdot\sqrt{4-x}+\sqrt{4-x}\cdot\sqrt{5-x}+\sqrt{5-x}\cdot\sqrt{3-x}$

$=\sqrt{\frac{49}{240}}\cdot\sqrt{\frac{289}{240}}+\sqrt{\frac{289}{240}}\cdot\sqrt{\frac{529}{240}}+\sqrt{\frac{529}{240}}\cdot\sqrt{\frac{49}{240}}$

$=\sqrt{\frac{7^2\cdot17^2}{240^2}}+\sqrt{\frac{17^2\cdot23^2}{240^2}}+\sqrt{\frac{23^2\cdot7^2}{240^2}}$

$=\frac{7\cdot17}{240}+\frac{17\cdot23}{240}+\frac{23\cdot7}{240}$

$=\frac{119+391+161}{240}=\frac{671}{240}$

ដោយ $x=\frac{671}{240}$ នោះ $\frac{671}{240}=\frac{671}{240}$ ពិត

ដូចនេះ សមីការមានឫស $x=\frac{671}{240}$ ។

## ២៨៦ រកចម្ងាយពីស្វាយជ្រៃទៅស្វាយរៀង

-សម្មតិកម្ម : បង្គោលចម្ងាយទី១ដាក់ថា "ស្វាយជ្រៃ 17$km$"

មានន័យថាធ្វើដំណើរ 17$km$ ទៀត ដល់ស្វាយជ្រៃ

ហើយ បង្គោលចម្ងាយទី២បន្ទាប់ដាក់ថា "ស្វាយរៀង25$km$ "

មានន័យថាធ្វើដំណើរ 25$km$ ទៀត ដល់ស្វាយរៀង ។

យើងអាចគូសរូបងាយមើល




តាមរូបយើងអាចបកស្រាយបានយ៉ាងងាយថា

ចម្ងាយពីស្វាយជ្រៃ ទៅស្វាយរៀងគឺ :

$(25+1)-17=26-17=9km$

ដូចនេះ ចម្ងាយពីស្វាយជ្រៃទៅស្វាយរៀងគឺ 9$km$ ។



www.facebook.com/7khmer
fb : Entertainment And Knowledge

## ២៤៧ រកចំនួនចាប និងចំនួនផ្កាឈូក

តាង $x$ ជាចំនួនចាប និង $y$ ជាចំនួនផ្កាឈូក

-តាមសម្មតិកម្ម : ចាបមួយទំផ្កាឈូកមួយ នោះសល់ចាបមួយគ្មានផ្កាឈូកទំ យើងបានសមីការ :

$$x-1=y \quad (i)$$

-ហើយ បើចាបពីរទំផ្កាឈូកមួយ នោះនៅសល់ផ្កាឈូកមួយគ្មានចាបទំ យើងបានសមីការ :

$$\frac{x}{2}=y-1 \quad (ii)$$

-តាមសមីការ $(i)\,\&\,(ii)$ យើងចងជាប្រព័ន្ធសមីការគឺ :

$$\begin{cases} x-1=y \\ \frac{x}{2}=y-1 \end{cases} \Leftrightarrow \begin{cases} x-y=1 \\ x=2y-2 \end{cases} \Leftrightarrow \begin{cases} x-y=1 \\ -x+2y=2 \end{cases}$$

ដោយបូកអង្គ និងអង្គនៃសមីការទាំងពីរ យើងបាន :

$$+\begin{cases} x-y=1 \\ -x+2y=2 \end{cases}$$

$$y=3 \quad \Rightarrow \quad x=y+1=3+1=4$$

ដូចនេះ | ចាបមានចំនួន4 ក្បាល , ផ្កាឈូកមានចំនួន3 ទង | ។

## ២៤៨ រកចំនួនសត្វខ្វែកដែលងាប់ និង រស់

-យើងគួតប្បិគិតថា ក្រៅពីសត្វខ្វែកងាប់ និងរស់វាគ្មានអ្វីទៀតទេ ហើយសម្មតិកម្មនិយាយថា ងាប់បីរស់ពីរ នោះយើងអាចសន្និដ្ឋានបានថា សត្វទាំងអស់មានចំនួន 5ក្បាល ។

( ក្រៅពីងាប់ និងរស់គ្មានអ្វីទៀតឡើយ )

-ពិចារណាថា : បើសត្វ5 ងាប់3 នោះសត្វ120ងាប់ប៉ុន្មាន?

នាំឱ្យ ចំនួនសត្វងាប់ $=\frac{120\times 3}{5}=72$ ក្បាល

បើសត្វ5 រស់2 នោះសត្វ120រស់ប៉ុន្មាន?

នាំឱ្យ ចំនួនសត្វរស់ $=\frac{120\times 2}{5}=48$ ក្បាល

ដូចនេះ | ចំនួនសត្វខ្វែកដែលងាប់មាន 72 ក្បាល<br>ហើយចំនួនសត្វខ្វែកដែលរស់មាន 48 ក្បាល | ។

## ២៤៩ រកអាយុរបស់ដារីស្រីសព្វថ្ងៃ

-សម្មតិកម្ម : អាយុរបស់ដារីតាងដោយ $x$ ហើយ $x$ ជាពហុគុណនៃ មានន័យថា $x$ អាចមានតម្លៃ ជាច្រើនដូចជា :

$0 , 8 , 16 , 24 , 32 , 40 , 48 , ...$

ក្នុងចំណោមលេខទាំងអស់ខាងលើ មានតែលេខ 16 ទេដែលគោរពតាមលក្ខខ័ណ្ឌ ធំជាង10 និងតូចជាង 20

នាំឱ្យតម្លៃ $x$ មានតែមួយគត់គឺ 16

ដូចនេះ | សព្វថ្ងៃដារីស្រីមានអាយុ 16 ឆ្នាំ | ។

## ២៥០ រកចំនួនថ្ងៃដែលគាត់ផ្គត់ផ្គង់ចំណីដែលឱ្យគោ

-យើងសង្កេតឃើញថា កាលណាចំនួនគោកាន់តែច្រើន នោះរយៈពេលស៊ីកាន់តែថយចុះ វាជាសមាមាត្រច្រាស

នាំឱ្យ ចំនួនថ្ងៃដែលត្រូវផ្គត់ផ្គង់គឺ :

$$\frac{40}{(40+10)}\times 35=\frac{35\times 40}{(40+10)}=\frac{1400}{50}=28 \text{ ថ្ងៃ}$$

( ពុំមែន $\frac{(40+10)\times 35}{40}=43.75$ ថ្ងៃនោះទេ )

ដូចនេះ | ចំនួនថ្ងៃដែលត្រូវផ្គត់ផ្គង់គឺ 28 ថ្ងៃ | ។

## ២៥១ បង្ហាញថា $a_1^2+a_2^2+a_3^2=1$

យើងមាន :

$$a_1=\sin a_1 \quad \Rightarrow \quad a_1^2=\sin^2 a_1$$
$$a_2=\cos a_1\cdot\sin a_2 \quad \Rightarrow \quad a_2^2=\cos^2 a_1\cdot\sin^2 a_2$$
$$a_3=\cos a_1\cdot\cos a_2 \quad \Rightarrow \quad a_3^2=\cos^2 a_1\cdot\cos^2 a_2$$

នាំឱ្យ $a_1^2+a_2^2+a_3^2$

$$=\sin^2 a_1+\cos^2 a_1\cdot\sin^2 a_2+\cos^2 a_1\cdot\cos^2 a_2$$
$$=\sin^2 a_1+\cos^2 a_1\left(\sin^2 a_2+\cos^2 a_2\right)$$
$$=\sin^2 a_1+\cos^2 a_1=1$$

ព្រោះ $\sin^2\alpha+\cos^2\alpha=1$

ដូចនេះ | ឃើញថា $a_1^2+a_2^2+a_3^2=1$ ប្រាកដមែន | ។



www.facebook.com/7khmer
fb : Entertainment And Knowledge

**២៩២ គណនាផលគុណ** $P_n$

ពិនិត្យ : $1+a^2+a^4=(1+2a^2+a^4)-a^2$

$$=(1+2a^2+a^4)-a^2$$
$$=(1+a^2)^2-a^2$$
$$=(1+a^2-a)(1+a^2+a)$$
$$=(1-a+a^2)(1+a+a^2)$$

នាំឱ្យ $(1-a+a^2)=\dfrac{1+a^2+a^4}{1+a+a^2}$

បើប្តូ $a$ ជា $x^{2^k}$ យើងបាន :

$$\left(1-x^{2^k}+x^{2^{k+1}}\right)=\frac{1+x^{2^{k+1}}+x^{2^{k+2}}}{1+x^{2^k}+x^{2^{k+1}}}$$

យើងឱ្យតម្លៃ $k=0,1,2,3,\dots,n$

$$\times\begin{cases}
\text{បើ } k=0: & (1-x+x^2)=\dfrac{1+x^2+x^4}{1+x+x^2}\\
\text{បើ } k=1: & (1-x^2+x^4)=\dfrac{1+x^4+x^8}{1+x^2+x^4}\\
\text{បើ } k=2: & (1-x^4+x^8)=\dfrac{1+x^8+x^{16}}{1+x^4+x^8}\\
\dots\dots & \dots\dots\dots\dots\\
\text{បើ } k=n: & \left(1-x^{2^n}+x^{2^{n+1}}\right)=\dfrac{1+x^{2^{n+1}}+x^{2^{n+2}}}{1+x^{2^n}+x^{2^{n+1}}}
\end{cases}$$

$$(1-x+x^2)(1-x^2+x^4)(1-x^4+x^8)\times\dots\times\left(1-x^{2^n}+x^{2^{n+1}}\right)=\frac{1+x^{2^{n+1}}+x^{2^{n+2}}}{1+x+x^2}$$

ឬអាចសរសេរ $P_n=\dfrac{1+x^{2^{n+1}}+x^{2^{n+2}}}{1+x+x^2}$

ដូចនេះ **គណនាបាន $P_n=\dfrac{1+x^{2^{n+1}}+x^{2^{n+2}}}{1+x+x^2}$** ។

**២៩៣ បង្ហាញថា** $\dfrac{3}{a+b+c}<\dfrac{1}{a+b}+\dfrac{1}{b+c}+\dfrac{1}{c+a}$

តាមបម្រាប់ $a>0\,,b>0$ និង $c>0$

នាំឱ្យ

$a+b+c>a+b \Rightarrow \dfrac{1}{a+b+c}<\dfrac{1}{a+b}$ (1)

$a+b+c>b+c \Rightarrow \dfrac{1}{a+b+c}<\dfrac{1}{b+c}$ (2)

$a+b+c>c+a \Rightarrow \dfrac{1}{a+b+c}<\dfrac{1}{c+a}$ (3)

ដោយបូកអង្គនិងអង្គនៃវិសមភាព : (1)+(2)+(3)

យើងបាន :

$$+\begin{cases}
\dfrac{1}{a+b+c}<\dfrac{1}{a+b}\\
\dfrac{1}{a+b+c}<\dfrac{1}{b+c}\\
\dfrac{1}{a+b+c}<\dfrac{1}{c+a}
\end{cases}$$
$$\frac{3}{a+b+c}<\frac{1}{a+b}+\frac{1}{b+c}+\frac{1}{c+a}$$

ដូចនេះ **ឃើញថា $\dfrac{3}{a+b+c}<\dfrac{1}{a+b}+\dfrac{1}{b+c}+\dfrac{1}{c+a}$** ។

**២៩៤ គណនាផលបូក** $S_n=1\cdot1!+2\cdot2!+3\cdot3!+\dots+n\cdot n!$

ពិនិត្យ : $(k+1)!=(k+1)\cdot k!$

$(k+1)!=k\cdot k!+k!$

នាំឱ្យ $k\cdot k!=(k+1)!-k!$

បើឱ្យតម្លៃ $k=1,2,3,4,\dots,n$ យើងបាន :

$$+\begin{cases}
1\cdot1!=2!-1!\\
2\cdot2!=3!-2!\\
3\cdot3!=4!-3!\\
4\cdot4!=5!-4!\\
\dots\dots\dots\\
n\cdot n!=(n+1)!-n!
\end{cases}$$
$$1\cdot1!+2\cdot2!+3\cdot3!+\dots+n\cdot n!=(n+1)!-1!$$

ដូចនេះ **ក្រោយពីគណនាឃើញថា $S_n=(n+1)!-1$** ។

**២៩៥ គណនាផលបូក** $\displaystyle\sum_{n=1}^{9999}\left(\frac{1}{(\sqrt{n}+\sqrt{n+1})(\sqrt[4]{n}+\sqrt[4]{n+1})}\right)$

ពិនិត្យ : $(\sqrt[4]{n+1}+\sqrt[4]{n})(\sqrt[4]{n+1}-\sqrt[4]{n})=(\sqrt{n+1}-\sqrt{n})$

តែ $(\sqrt{n+1}-\sqrt{n})(\sqrt{n+1}+\sqrt{n})=1$

នាំឱ្យ $(\sqrt{n+1}-\sqrt{n})=\dfrac{1}{(\sqrt{n+1}+\sqrt{n})}$

យើងបាន $(\sqrt[4]{n+1}+\sqrt[4]{n})(\sqrt[4]{n+1}-\sqrt[4]{n})=\dfrac{1}{(\sqrt{n+1}+\sqrt{n})}$



www.facebook.com/7khmer
fb : Entertainment And Knowledge

ទាញបាន $\left(\sqrt[4]{n+1}-\sqrt[4]{n}\right)=\dfrac{1}{\left(\sqrt{n+1}+\sqrt{n}\right)\left(\sqrt[4]{n+1}+\sqrt[4]{n}\right)}$

យើងបាន :

$$\sum_{n=1}^{9999}\left(\frac{1}{\left(\sqrt{n}+\sqrt{n+1}\right)\left(\sqrt[4]{n}+\sqrt[4]{n+1}\right)}\right)=\sum_{n=1}^{9999}\left(\sqrt[4]{n+1}-\sqrt[4]{n}\right)$$

បើឱ្យតម្លៃ $n=1,2,3,\dots,9999$ យើងបាន :

$$+\begin{cases}\sqrt[4]{2}-\sqrt[4]{1}\\ \sqrt[4]{3}-\sqrt[4]{2}\\ \sqrt[4]{4}-\sqrt[4]{3}\\ \dots\dots\dots\dots\\ \sqrt[4]{10000}-\sqrt[4]{9999}\end{cases}$$

$$\sum_{n=1}^{9999}\left(\sqrt[4]{n+1}-\sqrt[4]{n}\right)=\sqrt[4]{10000}-\sqrt[4]{1}$$

$$\sum_{n=1}^{9999}\left(\sqrt[4]{n+1}-\sqrt[4]{n}\right)=10-1=9$$

ដូចនេះ $\boxed{\displaystyle\sum_{n=1}^{9999}\left(\frac{1}{\left(\sqrt{n}+\sqrt{n+1}\right)\left(\sqrt[4]{n}+\sqrt[4]{n+1}\right)}\right)=9}$ ។

## ២៩៦ សម្រួលកន្សោម $A=\dfrac{a^3+b^3+c^3-3abc}{a^2+b^2+c^2-ab-bc-ca}$

ដោយ $a^3+b^3+c^3-3abc$

$$=a^3+3a^2b+3ab^2+b^3+c^3-3a^2b-3ab^2-3abc$$
$$=(a+b)^3+c^3-3ab(a+b+c)$$
$$=(a+b+c)\left[(a+b)^2-(a+b)c+c^2\right]-3ab(a+b+c)$$
$$=(a+b+c)\left[a^2+2ab+b^2-ac-bc+c^2-3ab\right]$$
$$=(a+b+c)\left(a^2+b^2-ac-bc+c^2-ab\right)$$
$$=(a+b+c)\left(a^2+b^2+c^2-ab-bc-ac\right)$$

នាំឱ្យ

$$A=\frac{a^3+b^3+c^3-3abc}{a^2+b^2+c^2-ab-bc-ca}$$
$$=\frac{(a+b+c)\left(a^2+b^2+c^2-ab-bc-ca\right)}{\left(a^2+b^2+c^2-ab-bc-ca\right)}$$
$$=a+b+c$$

ដែល $\left(a^2+b^2+c^2-ab-bc-ca\right)\neq 0$

ដូចនេះ $\boxed{\text{ក្រោយពីសម្រួល } A=a+b+c}$ ។

## ២៩៧ ស្រាយបញ្ជាក់ថាគេបាន $\left(\dfrac{a-b}{c-d}\right)^4=\dfrac{a^4+b^4}{c^4+d^4}$

យើងមាន

$$\frac{a}{b}=\frac{c}{d}\Leftrightarrow\frac{a}{c}=\frac{b}{d}\Leftrightarrow\frac{a^4}{c^4}=\frac{b^4}{d^4}=\frac{a^4+b^4}{c^4+d^4}\qquad(1)$$

ម្យ៉ាងទៀត $\dfrac{a}{c}=\dfrac{b}{d}=\dfrac{a-b}{c-d}$

សមមូល $\left(\dfrac{a}{c}\right)^4=\left(\dfrac{b}{d}\right)^4=\left(\dfrac{a-b}{c-d}\right)^4\qquad(2)$

តាម $(1)\&(2)$ $\dfrac{a^4}{c^4}=\dfrac{b^4}{d^4}=\left(\dfrac{a}{c}\right)^4=\left(\dfrac{b}{d}\right)^4$

នាំឱ្យ $\dfrac{a^4+b^4}{c^4+d^4}=\left(\dfrac{a-b}{c-d}\right)^4$

ដូចនេះ $\boxed{\text{ស្រាយបានថា } \left(\dfrac{a-b}{c-d}\right)^4=\dfrac{a^4+b^4}{c^4+d^4}}$ ។

## ២៩៨ រករូបមន្តទូទៅ

យើងមានឧទាហរណ៍ :

$6^2-5^2=11$

$56^2-45^2=1111$

$556^2-445^2=111111$

$5556^2-4445^2=11111111$

..................................................

យើងឃើញថា លេខ1 កើនឡើងទ្វេដងជានិច្ច

ដូចនេះ តាមលំនាំគំរូខាងលើនេះយើងទាញបានរូបមន្តទូទៅ

$$\underbrace{555\dots56^2}_{\text{មាន } n \text{ ខ្ទង់}}-\underbrace{444\dots45^2}_{\text{មាន } n \text{ ខ្ទង់}}=\underbrace{111\dots111}_{\text{មាន } 2n \text{ ខ្ទង់}}$$

### ស្រាយបញ្ជាក់រូបមន្តខាងលើ

តាង $A_n=555\dots56^2-444\dots45^2$

$$=(555\dots55+1)^2-(444\dots44+1)^2$$
$$=\left(\frac{5}{9}\cdot111\dots11+1\right)^2-\left(\frac{4}{9}\cdot111\dots11+1\right)^2$$
$$=\left[\frac{5}{9}\left(10^n-1\right)+1\right]^2-\left[\frac{4}{9}\left(10^n-1\right)+1\right]^2$$



www.facebook.com/7khmer
fb : Entertainment And Knowledge

$$A_n=\left[\frac{5}{9}(10^n-1)+1\right]^2-\left[\frac{4}{9}(10^n-1)+1\right]^2$$

$$=\left[\frac{5}{9}(10^n-1)+1-\frac{4}{9}(10^n-1)-1\right]\times$$

$$\times\left[\frac{5}{9}(10^n-1)+1+\frac{4}{9}(10^n-1)+1\right]$$

$$=\left[\frac{1}{9}(10^n-1)\right]\left[10^n-1+2\right]$$

$$=\frac{1}{9}(10^n-1)(10^n+1)$$

$$=\frac{1}{9}(10^{2n}-1)$$

$=\frac{1}{9}(999...999)$ ដែលមានលេខ 9 ចំនួន 2n

$=111...11$ ដែលមានលេខ 1 ចំនួន 2n

ដូចនេះ ជាការពិត រូបមន្តនេះពិតជាត្រឹមត្រូវគឺ $\underbrace{555...56}_{\text{មាន } n \text{ ខ្ទង់}}{}^2-\underbrace{444...45}_{\text{មាន } n \text{ ខ្ទង់}}{}^2=\underbrace{111...111}_{\text{មាន } 2n \text{ ខ្ទង់}}$

**២៥៩ គណនា** $S=\cos^2 1^o+\cos^2 2^o+\cos^2 3^o+\ldots+\cos^2 89^o$

តាមរូបមន្ត $\cos\left(\frac{\pi}{2}-\alpha\right)=\sin\alpha$

ឬ $\cos(90^o-\alpha)=\sin\alpha$

នាំឱ្យ $\cos 1^o=\cos(90^o-89^o)=\sin 89^o$

$\cos 2^o=\cos(90^o-88^o)=\sin 88^o$

..................................................

$\cos 44^o=\cos(90^o-46^o)=\sin 46^o$

នោះយើងបាន :

$\cos^2 1^o=\sin^2 89^o$ ,

$\cos^2 2^o=\sin^2 88^o$

.............................

$\cos^2 44^o=\sin^2 46^o$

នោះយើងបាន :

$$+\begin{cases}\cos^2 1^o+\cos^2 89^o\\ \cos^2 2^o+\cos^2 88^o\\ \cos^2 3^o+\cos^2 87^o\\ \ldots\ldots\ldots\ldots\\ \cos^2 44^o+\cos^2 46^o\\ \cos^2 45^o\end{cases} \quad + \begin{cases}\cos^2 1^o+\sin^2 1^o=1\\ \cos^2 2^o+\sin^2 2^o=1\\ \cos^2 3^o+\sin^2 3^o=1\\ \ldots\ldots\ldots\ldots\\ \cos^2 44^o+\sin^2 44^o=1\\ \cos^2 45^o=\left(\frac{\sqrt{2}}{2}\right)^2\end{cases}$$

$$S = 44+\frac{1}{2}$$

នោះ $S=44+\frac{1}{2}=\frac{88+1}{2}=\frac{89}{2}$

ដូចនេះ គណនាបាន $S=\frac{89}{2}$ ។

**២៦០ គណនា**

$S=\sin^2 0^o+\sin^2 1^o+\sin^2 2^o+\ldots+\sin^2 90^o$

( ស្រដៀងលំហាត់ទី២៥៩ )

តាមរូបមន្ត $\sin\left(\frac{\pi}{2}-\alpha\right)=\cos\alpha$

យើងបាន :

$$+\begin{cases}\sin^2 0^o+\sin^2 90^o\\ \sin^2 1^o+\sin^2 89^o\\ \sin^2 2^o+\sin^2 88^o\\ \ldots\ldots\ldots\ldots\\ \sin^2 44^o+\sin^2 46^o\\ \sin^2 45^o\end{cases} \quad + \begin{cases}\sin^2 0^o+\cos^2 0^o=1\\ \sin^2 1^o+\cos^2 1^o=1\\ \sin^2 2^o+\cos^2 2^o=1\\ \ldots\ldots\ldots\ldots\\ \sin^2 44^o+\cos^2 46^o=1\\ \sin^2 45^o=\left(\frac{\sqrt{2}}{2}\right)^2\end{cases}$$

$$S = 45+\frac{1}{2}$$

នោះ $S=45+\frac{1}{2}=\frac{90+1}{2}=\frac{91}{2}$

ដូចនេះ គណនាបាន $S=\frac{91}{2}$ ។



www.facebook.com/7khmer
fb : Entertainment And Knowledge

**២៦១ កំណត់តម្លៃ** $a$ & $b$

យើងមានចំនួន $\overline{abba}$ ដែល $1\le a\le 9$ , $0\le b\le 9$

យើងបាន $\overline{abba}=1000a+100b+10b+a$

$=1001a+110b$

$=11(91a+10b)$

សម្មតិកម្ម $\overline{abba}$ ជាគូបប្រាកដនៃចំនួនគត់ នោះយើងបាន

$$\overline{abba}=k^3$$

$$11(91a+10b)=k^3$$

$$91a+10b=\frac{k^3}{11}$$

ដោយ $a$ & $b$ ជាចំនួនគត់ នោះ $91a+10b$ ជាចំនួនគត់ដែរ

នាំឱ្យ $k^3$ ចែកដាច់នឹង 11 នោះ $k=11n$ , $n$ គត់វិជ្ជមាន

យើងបាន $k^3=(11n)^3$ ដែល $n=1,2,3,\ldots$

តែបើ $n=2$ នោះ $k^3=(22)^3=10648>\overline{abba}$

នាំឱ្យ ចំនួនគត់វិជ្ជមាន $n$ មានតម្លៃតែមួយគត់គឺ $n=1$

យើងបាន $\overline{abba}=k^3=(11\times 1)^3=11^3=1331$

ទាញបាន តម្លៃ $a=1$ , $b=3$

ដូចនេះ | តម្លៃកំណត់បានគឺ $a=1$ , $b=3$ | ។

**២៦២ ក. កំណត់តម្លៃលេខនៃអញ្ញាត** $a,b,c$ **និង** $d$

យើងមានចំនួន $\overline{abcd}$ និង $\overline{dcba}$ តាមខ្ទង់នីមួយៗនោះ

$1\le a\le 9$ , $0\le b\le 9$ , $0\le c\le 9$ , $1\le d\le 9$

គេឱ្យ $\overline{abcd}\times 9=\overline{dcba}$ (1)

តាមទំនាក់ទំនង(1) នាំឱ្យកំណត់បានតម្លៃ $a=1$ តែមួយគត់

( ព្រោះបើ $a>1$ នោះលទ្ធផលជាលេខ ប្រាំខ្ទង់ )

-ចំពោះ $a=1$ យើងបាន $\overline{1bcd}\times 9=\overline{dcb1}$ (2)

តាមទំនាក់ទំនង(2) នាំឱ្យកំណត់បានតម្លៃ $d=9$ តែមួយគត់

( ព្រោះមានតែករណីនេះទើប $9\times 9=81$ មានលេខ1ចុង)

-ចំពោះ $d=9$ យើងបាន $\overline{1bc9}\times 9=\overline{9cb1}$ (3)

តាមទំនាក់ទំនង (3) ទាញបាន $b=0$

( ព្រោះ $b\times 9$ មិនត្រូវមានត្រាទុកទេ )

-ចំពោះ $b=0$ យើងបាន $\overline{10c9}\times 9=\overline{9c01}$ (4)

តាមទំនាក់ទំនង(4) ទាញបាន $c=8$ ព្រោះ $8\times 9=72$

ហើយថែមត្រាទុក 8 គឺ $72+8=80$ មានលេខ0នៅចុង

-ចំពោះ $c=8$ យើងបាន $1089\times 8=9801$

ដូចនេះ | តម្លៃកំណត់បានគឺ $a=1,b=0,c=8,d=9$ |

**ខ. បញ្ជាក់ថា** $\overline{abcd}$ **និង** $\overline{dcba}$ **សុទ្ធតែជាការេប្រាកដ**

ដោយ $\overline{abcd}=1089=33^2$

ហើយ $\overline{dcba}=9801=99^2$

ដូចនេះ | ចំនួន $\overline{abcd}$ និង $\overline{dcba}$ សុទ្ធតែជាការេប្រាកដ | ។

**២៦៣ រកពីរចំនួនជាការេប្រាកដ**

តាង $a=k^2$ ជាចំនួនទី 1 និង $b=n^2$ ជាចំនួនទី 2 ដែល

$k$ & $n$ ជាចំនួនគត់ ហើយ $k>n$ ឬ $k<n$

តាមបម្រាប់ប្រធាន $ab-(a+b)=4844$

យើងបាន : $ab-a-b=4844$

$ab-a-b+1=4844+1$

$a(b-1)-(b-1)=4845$

$(a-1)(b-1)=4845$

ដោយ $a=k^2$ និង $b=n^2$ នោះយើងបាន :

$(a-1)(b-1)=4845$

$(k^2-1)(n^2-1)=4845$

$(k+1)(k-1)(n+1)(n-1)=4845$

| | |
|---|---|
| 4845 | 3 |
| 1615 | 5 |
| 323 | 17 |
| 19 | 19 |
| 1 | |

តែ $4845=3\times 5\times 17\times 19$ ជាផលគុណនៃបួនចំនួនគត់

ដែលមានតែមួយបែបគត់

ដោយ $3\times 5=(4-1)(4+1)$ និង $17\times 19=(18-1)(18+1)$

នោះ$(k+1)(k-1)(n+1)(n-1)=(4+1)(4-1)(18+1)(18-1)$

-ចំពោះ $k>n$ ទាញបាន $k=18$ , $n=4$

-ចំពោះ $k<n$ ទាញបាន $k=4$ , $n=18$



www.facebook.com/7khmer
fb : Entertainment And Knowledge

នាំឱ្យ $\begin{cases} a=k^2=18^2=324 \\ b=n^2=4^2=16 \end{cases}$

ឬ $\begin{cases} a=k^2=4^2=16 \\ b=n^2=18^2=324 \end{cases}$

ផ្ទៀងផ្ទាត់ : $324\times16-(324+16)=4844$ ពិត

ហើយ $16\times324-(16+324)=4844$ ពិត

ដូចនេះ | ពីរចំនួនដែលជាការេប្រាកដគឺ 324 & 16 | ។

## ២៦៤ គណនារង្វាស់ជ្រុងនីមួយៗរបស់ត្រីកោណ




តាង $a , b , c$ ជារង្វាស់ជ្រុងនៃត្រីកោណកែង ដែល $c$ ជាអ៊ីប៉ូតេនុស

-តាមពីតាគ័រ : $a^2+b^2=c^2$ (1)

-បម្រាប់ក្រឡាផ្ទៃស្មើ $24cm^2$ នាំឱ្យ $\frac{1}{2}ab=24$ (2)

-បម្រាប់បរិមាត្រស្មើ $24cm$ នាំឱ្យ $a+b+c=24$ (3)

តាម (3) : $a+b=24-c$ លើកជាការេ

$$a^2+2ab+b^2=24^2-48c+c^2$$

$$(a^2+b^2)+2ab=576-48c+c^2 \quad (4)$$

ដោយយក (1) & (2) ជំនួសក្នុង (4) យើងបាន :

$$c^2+2\cdot48=576-48c+c^2$$

$$96=576-48c$$

$$48c=576-96 \quad \Rightarrow c=\frac{480}{48}=10cm$$

ចំពោះ $c=10$ នោះ $a+b=14$ និង $ab=48$

តាមវ្យែតយើងបានសមីការ : $x^2-14x+48=0$ ដែល មាន $a$ និង $b$ ជាឬសនៃសមីការ

$\Delta'=b'^2-ac=49-48=1$

នោះ $a=\frac{7-1}{1}=6$ , $b=\frac{7+1}{1}=8$ ឬ $a=8 , b=6$

ដូចនេះ | រង្វាស់ជ្រុងនីមួយៗនៃត្រីកោណកែងគឺ : $6cm$ , $8cm$ , $10cm$ | ។

## ២៦៥ រកចំនួនទាំងពីរនោះ

តាង $x$ ជាចំនួនទី 1 ដែល $x$ ជាចំនួនបឋម នោះចំនួនទី2គឺ $x+1$ ហើយ $x+1$ ជាការេប្រាកដ នោះ $x+1=n^2$

យើងបាន $n^2-1=x$ សមមូល $(n-1)(n+1)=x$

តែ $x$ ជាចំនួនបឋម នាំឱ្យផលគុណរបស់ $x$ គឺ $x=x\cdot1$

យើងបាន $(n-1)(n+1)=1\cdot x$

ទាញបាន : $\begin{cases} n-1=1 \\ n+1=x \end{cases} \Leftrightarrow \begin{cases} n=2 \\ n+1=x \end{cases} \Leftrightarrow \begin{cases} n=2 \\ 3=x \end{cases}$

ដូចនេះ | ចំនួនទី1គឺ 3 និងចំនួនទី2គឺ 4 | ។

## ២៦៦ រកកាំរង្វង់




តាង $r$ ជាកាំរង្វង់ដែលត្រូវរក ដោយភ្ជាប់ផ្ចិតរង្វង់ទាំងបីដូចរូប

នោះយើងបានត្រីកោណកែង ដែលមានទំនាក់ទំនងជាមួយ $r$

តាមពីតាគ័រយើងបាន :

$$(2-2r)^2+(2r)^2=(4r)^2$$

$$4-8r+4r^2+4r^2=16r^2$$

$$8r^2+8r-4=0$$

$$2r^2+2r-1=0$$

តាម $\Delta'=b'^2-ac=1+2=3$

នាំឱ្យ $r_1=\frac{-1-\sqrt{3}}{2}<0$ មិនយក

$r_1=\frac{-1+\sqrt{3}}{2}$ ឯកតាប្រវែង

ដូចនេះ | កាំរង្វង់ដែលត្រូវរកគឺ : $r=\frac{-1+\sqrt{3}}{2}$ | ។

## ២៦៧ ស្រាយថាត្រីកោណចារឹកកន្លះរង្វង់ជាត្រីកោណកែង




( មុនបកស្រាយ អ្នកត្រូវស្គាល់ មុំចារឹក និង មុំផ្ចិតជាមុនសិន : មុំចារឹក ជាមុំមានកំពូលលើរង្វង់ និងជ្រុងទាំងពីរកាត់រង្វង់ ឯមុំផ្ចិតជាមុំដែលមានកំពូលលើផ្ចិតរង្វង់ ។



www.facebook.com/7khmer
fb : Entertainment  And Knowledge

-ទំនាក់ទំនងរវាងមុំផ្ចិត និងមុំចារឹកគឺ

បើ $\theta$ ជាមុំផ្ចិត និង $\alpha$ ជាមុំចារឹកដែលមានធ្នូស្កាត់រួម នោះយើងបានទំនាក់ទំនង : $\alpha = \frac{\theta}{2}$ ។

-ត្រីកោណចារឹកកន្លះរង្វង់ ជាត្រីកោណដែលមានជ្រុងមួយជាអង្កត់ផ្ចិតនៃរង្វង់ ចែករង្វង់ជាពីរផ្នែកប៉ុនគ្នា

-(មើលរូប) មុំ $\theta$ និង $\angle A$ មានធ្នូស្កាត់រួម $BC$

នាំឱ្យ $\angle A = \frac{\theta}{2}$ ដោយ $\theta$ ជាមុំរាប នោះ $\theta = 180^o$

យើងបាន : $\angle A = \frac{180^o}{2} = 90^o$ ជាមុំកែង ។

នាំឱ្យ ត្រីកោណចារឹកកន្លះរង្វង់មានមុំកែងជានិច្ច

ដូចនេះ | ត្រីកោណចារឹកកន្លះរង្វង់ជាត្រីកោណកែងជានិច្ច | ។

## ២៦៨ រកចំនួនជ្រុងច្រើនបំផុតនៃពហុកោណ

-ទំនាក់ទំនងរវាងចំនួនជ្រុង និងមុំនៃពហុកោណគឺ :

បើពហុកោណមួយមាន $n$ ជ្រុងនោះផលបូកមុំក្នុងទាំងអស់នៃពហុកោណគឺ : $180^o(n-2)$

តាមបម្រាប់យើងបាន :

$$180^o(n-2) < 2011^o$$
$$n-2 < \frac{2011^o}{180^o}$$
$$n < \frac{2011}{180} + 2$$
$$n < \frac{1980+31}{180} + 2$$
$$n < 11 + \frac{31}{180} + 2$$
$$n < 13 + \frac{31}{180}$$

តែ $n$ ជាចំនួនជ្រុង ដែលជាចំនួនគត់ នោះ $n = 13$

ផ្ទៀងផ្ទាត់ $180^o(13-2) < 2011^o \Leftrightarrow 1980^o < 2011^o$ ពិត

ដូចនេះ | ពហុកោណនេះអាចមានជ្រុងច្រើនបំផុតចំនួន 13 | ។

## ២៦៩ ស្រាយថាជ្រុងនីមួយៗនៃត្រីកោណតូចជាងកន្លះបរិមាត្ររបស់វាជានិច្ច




ឧបមាថាយើងមានត្រីកោណ ដែលមានរង្វាស់ជ្រុង $a, b, c$ និងមានកន្លះបរិមាត្រ $\frac{a+b+c}{2}$

-តាមវិសមភាពនៃត្រីកោណ យើងបាន :

- $a < b+c \Leftrightarrow 2a < a+b+c \Rightarrow a < \frac{a+b+c}{2}$
- $b < a+c \Leftrightarrow 2b < a+b+c \Rightarrow b < \frac{a+b+c}{2}$
- $c < a+b \Leftrightarrow 2c < a+b+c \Rightarrow c < \frac{a+b+c}{2}$

ដូចនេះ | រង្វាស់ជ្រុងនីមួយៗនៃត្រីកោណតូចជាងកន្លះបរិមាត្ររបស់វាជានិច្ច | ។

## ២៧០ រកចំនួនដងនៃការជក់បារីរបស់បុរសនោះ

-បារី 10 ដើម $\rightarrow$ ជក់បាន 10 ដង

នៅសល់កន្ទុយបារីចំនួន 10 កន្ទុយ $=3$ ដើម និង 1 កន្ទុយ

-បារី 3 ដើម និង 1 កន្ទុយ $\rightarrow$ ជក់បាន 3 ដង

នៅសល់កន្ទុយបារីចំនួន 4 កន្ទុយ $=1$ ដើម និង 1 កន្ទុយ

-បារី 1 ដើម និង 1 កន្ទុយ $\rightarrow$ ជក់បាន 1 ដង

នៅសល់ កន្ទុយបារីចំនួន 2 កន្ទុយ ខ្ចីកន្ទុយបារីគេ 1

នាំឱ្យបាន 3 កន្ទុយ $=1$ ដើម $\rightarrow$ ជក់បាន 1 ដង

នៅសល់កន្ទុយបារី 1 យកសងគេវិញ នោះបារីអស់គ្មានសល់

នាំឱ្យចំនួនដងនៃការជក់បារីគឺ $=10+3+1+1=15$ ដង

ដូចនេះ | បុរសនោះត្រូវជក់ចំនួន 15 ដងទើបអស់បារីគាត់ | ។

## ២៧១ ដោះស្រាយសមីការ : ក. $3^x + 4^x = 5^x$

យើងសង្កេតឃើញថា $x = 2$ ជាឬសនៃសមីការ

